# វគ្គសិក្សាមូលដ្ឋាន ICT សំរាប់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល

## ម៉ូឌុល ៨

# និន្នាការសំរាប់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល

**Richard Labelle**

មជ្ឈមណ្ឌលបណ្តុះបណ្តាល អាស៊ី និងប៉ាស៊ីហ្វិច សំរាប់វិស័យ
បច្ចេកវិទ្យា គមនាគមន៍ និងពត៌មាន សំរាប់ការអភិវឌ្ឍន៍

ស៊េរីម៉ូឌុលកម្មវិធីសិក្សាអំពីសារសំខាន់នៃបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (ICT) សម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាល

**ម៉ូឌុល ៨ ៖ ជម្រើសមូលនិធិ ICT សំរាប់ការអភិវឌ្ឍន៍**

អត្ថបទបោះពុម្ពផ្សាយនេះ ត្រូវបានចេញផ្សាយក្រោមអាជ្ញាប័ណ្ណរក្សាកម្មសិទ្ធិបញ្ញាផ្អែកគំនិតច្នៃប្រឌិតលេខ ៣.0 (Creative Commons Attribution 3.0 License) ។ ដើម្បីមើលច្បាប់ចម្លងនៃអាជ្ញាប័ណ្ណនេះ សូមចូលទៅកាន់វែបសាយត៍ http://creativecommons.org/licenses/by/3.0/ ។

ទស្សនៈ រូបភាព និងសេចក្តីប៉ាន់ស្មាននានាដែលបានរៀបរៀងនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ គឺជាទំនួលខុសត្រូវរបស់អ្នកនិពន្ធ និងមិនត្រូវបានចាត់ទុកថា ជាការឆ្លុះបញ្ចាំងអំពីទស្សនៈ ឬបង្ហាញអំពីការអនុម័តទទួលស្គាល់របស់អង្គការសហប្រជាជាតិឡើយ ។

នាមកត្តាដែលប្រើ និងការបង្ហាញឯកសារផ្សេងៗនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ មិនមែនមានន័យថាការសម្តែងទស្សនៈណាមួយពីសំណាក់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ អំពីស្ថានភាពស្របច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ ណាមួយ ឬអាជ្ញាធរនានារបស់ប្រទេស តំបន់ ឬដែនដីទាំងនេះ ឬអំពីការកំណត់ព្រំដែន ឬដែនកំណត់នៃប្រទេស តំបន់ ឬដែនដីទាំងនេះឡើយ ។

ការលើកឡើងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្មផ្សេងៗ មិនមែនបង្កប់អត្ថន័យថាជាការអនុម័តទទួលស្គាល់របស់អង្គការសហប្រជាជាតិឡើយ ។

អាសយដ្ឋានទំនាក់ទំនង ៖
មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា
សម្រាប់ការអភិវឌ្ឍតំបន់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ
Bonbudong, 3rd Floor Songdo Techno Park
7-50 Songdo-dong, Yeonsu-gu, ទីក្រុង Incheon
សាធារណៈរដ្ឋកូរ៉េ
ទូរស័ព្ទលេខ ៖ +82 32 245 1700-02
ទូរសារលេខ ៖ +82 32 245 7712
អ៊ីមែល ៖ info@unapcict.org
http://www.unapcict.org

រក្សាសិទ្ធិដោយ © UN-APCICT 2009
ISBN: 978-89-955886-3-5 [94560]

រចនា និងកាត់តរូបភាពដោយ ៖ ក្រុមហ៊ុនបោះពុម្ព Scandinavian Publishing Co., Ltd.

## អារម្ភកថា

ដំណើរការនៅក្នុងការវិវត្តនៃ *កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី ពិសេសសំរាប់ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាលសម្រាប់វគ្គ បន្ត* នេះ ពិតជាបានបង្ហាញនៅការផុសឡើងនៅបទពិសោធន៍ថ្មីៗ ។ The Academy មិនត្រឹមតែបំពេញបន្ថែមទៅ ក្នុងការកសាងសមត្ថភាពនៃការយល់ដឹងអំពី អាយស៊ីធី ប៉ុន្តែថែមទាំងបានត្រួសត្រាផ្លូវថ្មីមួយសំរាប់ការអភិវឌ្ឍន៍នៅកម្មវិធីសិក្សា (តាមរយៈការចូលរួមរបស់អ្នកសិក្សា និងភាពជាម្ចាស់នៃការអនុវត្ត) ។

The Academy គឺជាកម្មវិធីដល់ល្អបំផុតរបស់ អេភីស៊ីអាយស៊ីធី, ដែលបានធ្វើការអភិវឌ្ឍន៍ពឹងផ្អែកលើៈ លទ្ធផល នៃការស្ទង់មតិដ៏ចាំបាច់ជាច្រើនប្រកបដោយភាពទូលំទូលាយ ដែលធ្វើឡើងជាមួយចំនួនប្រទេសច្រើនជាង ២០ នៅក្នុងតំបន់ រួមទាំងទទួលការប្រឹក្សាយោបល់ពីមន្ត្រីរដ្ឋាភិបាលជាច្រើនរូប, សមាជិកជាច្រើននៃសហគមន៍អភិវឌ្ឍន៍អន្តរជាតិ, កម្មវិធីសិក្សានិងអ្នកអប់រំជាច្រើនរូប, ធ្វើការស្រាវជ្រាវនិងវិភាគយ៉ាងស៊ីជំរៅអំពីភាពខ្លាំង និង ភាពខ្សោយ ចំពោះឧបករណ៍សម្រាប់ការហ្វឹកហ្វឺនដែលមាន ស្រាប់, ប្រតិកម្មតបរបស់អ្នកចូលរួមសិក្ខាសាលារបស់ អេភីស៊ីអាយស៊ីធី ដែលបានរៀបចំឡើងជាបន្តបន្ទាប់សម្រាប់ថ្នាក់តំបន់ និងអនុតំបន់ទៅលើអត្ថប្រយោជន៍និងភាពជាប់ទាក់ទងគ្នា ពីវគ្គមួយទៅវគ្គមួយរួមទាំងយុទ្ធសាស្រ្តហ្វឹកហ្វឺនយ៉ាងសមរម្យមួយ, និងមានភាពប្រាកដនិយមនៅក្នុងការរំលឹក ឡើងវិញអំពីវគ្គទាំងនោះ ដោយមានការដឹកនាំពីអ្នកជំនាញជាច្រើនរូបនៅក្នុងវគ្គសិក្សា សម្រាប់ការអភិវឌ្ឍវិស័យអាយស៊ីធី ។ សិក្ខាសាលារបស់ The Academy ត្រូវបានធ្វើឡើង តាមតំបន់ដែលបានផ្តល់ឱកាសដែលមិនអាចកាត់ថ្លៃ បានក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងក្នុងចំណោមអ្នកចូលរួមពីប្រទេសផ្សេងៗ សិក្ខាសាលានេះដែលបានបង្កើតនៅ Academy Alumni នឹងដើរតួយ៉ាងសំខាន់ក្នុងការធ្វើឲ្យលេចចេញជារូបរាងនៅមេរៀនជាបន្តបន្ទាប់ ។

ការដាក់បង្ហាញចេញដំបូងនៅវគ្គសិក្សាទាំងប្រាំបី សម្គាល់ឃើញថាជាការចាប់ផ្តើមសម្រាប់ដំណើរការដ៏ជោគជ័យ ដែលជាភាពខ្លាំងនៃដៃគូដែលមានស្រាប់ និងការកសាងភាពថ្មីផ្សេងមួយទៀតដើម្បីអភិវឌ្ឍនៅក្នុងការធ្វើឲ្យសម្រេច នៅគោលនយោបាយរបស់ អាយស៊ីធីឌី កាត់តាមតំបន់ ។ អេភីស៊ីអាយស៊ីធី គឺបានប្តេជ្ញាចិត្តជាអ្នកផ្តល់ ក្នុងការផ្គត់ផ្គង់ផ្នែកបច្ចេកទេសនៅក្នុងការផ្សព្វផ្សាយពី National Academies ពីព្រោះថាការឆ្ពោះទៅមុខយ៉ាង សំខាន់របស់វា គឺការធានាថា The Academy គឺចាប់បានរាល់ការសម្រេចនៅគោលនយោបាយរបស់ខ្លួន ។ អេភីស៊ីអាយស៊ីធី ផងដែរបាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធ

ជាមួយវិទ្យាស្ថានហ្វឹកហ្វឺនរបស់ជាតិនិងតំបន់មួយចំនួន ដែលមានទំនាក់ទំនងជាមួយការគ្រប់គ្រងថ្នាក់កណ្តាល, ការគ្រប់គ្រងរបស់រដ្ឋ និងការគ្រប់គ្រង់តាមលំដាប់ថ្នាក់ ប្រចាំតំបន់ ដើម្បីធ្វើឲ្យប្រសើរឡើងនៅសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបនៅតំរូវការ ការបកប្រែ និង ការប្រគល់ ឲ្យនៅមេរៀននីមួយៗរបស់ Academy ព្រមទាំងធ្វើវាទៅជាសេចក្តីត្រូវការ និងជាអទិភាពដំបូងសម្រាប់រដ្ឋ ។
ច្រើនជាងនេះទៅទៀត អេភីស៊ីអាយស៊ីធី កំពុងតែជួលនៅប៉ុស្តិ៍ជាច្រើនសម្រាប់ការខិតទៅរកការជានាមួយថា ខ្លឹមសារមេរៀនរបស់ Academy បានទៅដល់អ្នកមើលក្នុងលក្ខណៈយ៉ាង ទូលំទូលាយនៅក្នុងតំបន់មួយ ។ ក្រៅពីការផ្តល់ឲ្យជាលក្ខណៈផ្ទាល់របស់ Academy តាមរយៈកម្មវិធីសិក្សាជាច្រើនរបស់ជាតិនិងតំបន់ Academy ផងដែលផ្តល់ឲ្យជា លក្ខណៈ the APCICT Virtual Academy (អេវីអា(AVA)), គឺជាទម្រង់នៃការសិក្សាពីចម្ងាយ តាមប្រព័ន្ធ Online របស់ Academy, ដែលត្រូវបង្កើតឡើងដើម្បីឲ្យអ្នកសិក្សាទទួល បានចំណេះដឹងពីកន្លែង របស់ខ្លួនគេផ្ទាល់ ។ AVA ជានាថាវគ្គនីមួយៗរបស់ Academy រួមទាំងឧបករណ៍ដទៃទៀត ដូចជា ផ្ទាំងបញ្ចាំងអំពី បទបង្ហាញនៃមេរៀន និង ករណីសិក្សាដទៃទៀត គឺមានភាពងាយស្រួលក្នុងការទាញយកមកពីប្រព័ន្ធ អ៊ីនធើរណិត, ការយកមកប្រើម្តងទៀត, ឆ្លើយតបតាមតំរូវការនិងឋានបរិច្ឆេទ រួមទាំងការប្រើប្រាស់នៅលើមុខងារផ្សេងៗទៀត រួមមាន ការបង្រៀនជា មូលដ្ឋានគ្រឹះ, ការសិក្សាស្វែងយល់ទៅលើការគ្រប់គ្រងឧបករណ៍ផ្សេងៗ, ខ្លឹមសារមេរៀនស្តីអំពីការអភិវឌ្ឍន៍ទៅលើ ឧបករណ៍មួយចំនួន ព្រមទាំង វិញ្ញាបណ្ណប័ត្រ។

ជាអាទិ៍ការបង្កើតនៅវគ្គទាំងប្រាំបីរបស់ Academy និងការផ្តល់ឲ្យពួកគេតាមរយៈសិក្ខាសាលាស្តីពី Academy របស់ថ្នាក់ជាតិ, ថ្នាក់តំបន់និងអនុតំបន់ និងមិនអាចប្រព្រឹត្តទៅបានប្រសិនបើគ្មានការប្តេជ្ញាចិត្តការចង្អុលបង្ហាញនិង ពីអ្នកចូលរួមយ៉ាងសកម្មរបស់ បុគ្គលៗម្នាក់ ឬពីអង្គការជាច្រើននោះទេ ។ ខ្ញុំសូមយកឱកាសនេះ សំដែងនៅសមានចិត្ត សម្រាប់ការប្រឹងប្រែង ព្រមទាំងការសម្រេចនូវស្នាដៃនៃ Academy Alumni ដោយមានការសហការពីក្រសួង រដ្ឋាភិបាល, វិទ្យាស្ថានហ្វឹកហ្វឺន, ព្រមទាំងអង្គការជាតិនិងអង្គការ ប្រចាំតំបន់ជាច្រើនដែលបានចូលរួមក្នុងសិក្ខាសាលា Academy ។ ពួកគេមិន ត្រឹមតែផ្តល់នៅទស្សនៈដ៏មានតំលៃជាច្រើន ដើម្បីដាក់បញ្ចូលទៅក្នុងវគ្គនីមួយៗ ប៉ុន្តែថែមទាំងដើរតួយ៉ាងសំខាន់ជាច្រើនទៀត ដោយពួកគេបានក្លាយជាអ្នកជួយគាំទ្រ Academy នៅក្នុងប្រទេសពួកគេដែលឲ្យជា លទ្ធផលសម្រាប់ការឃោគយល់គ្នាជាលក្ខណៈផ្លូវការ រវាង អេភីស៊ីអាយស៊ីធី ជាមួយវិទ្យាស្ថានរបស់ជាតិ និងតំបន់មួយចំនួន ក្នុងការផ្តល់នៅការឆ្លើយតបតាមតំរូវការ និងការប្រគល់ឲ្យនៅមុខវិជ្ជារបស់ Academy សម្រាប់ប្រទេសទាំងនោះ យ៉ាងទៀងទាត់ ។

ខ្ញុំសូមសម្តែងនៅសមានចិត្តជាការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត សម្រាប់ការខិតខំប្រឹងប្រែងក្នុងការចូលរួមពីបុគ្គលដែលប្រកបដោយគតិបណ្ឌិតជាច្រើនរូប ក្នុងការបង្កើតនៅដំណើរការប្រតិបត្តិដ៏អស្ចារ្យមួយនេះឲ្យប្រព្រឹត្តទៅ បាន ដែលមានដូចជា លោក Shahid Akhtar, ទីប្រឹក្សាគម្រោងនៃ *The Academy*, Patricia Arinto, Christine Apikul, Publications Manager, និងរាល់អ្នកនិពន្ធ *Academy*, និងក្រុម អេភីស៊ីអាយស៊ីធី ។

ខ្ញុំសង្ឃឹមយ៉ាងស្មោះស្ម័គ្រថា *Academy* មួយនេះនឹងជួយប្រទេសជាច្រើនឲ្យរួចផុតពីចន្លោះប្រហោងក្នុង ការបណ្តុះបណ្តាលធនធានមនុស្សផ្នែក អាយស៊ីធី, ដកចេញនៅភាពរាំងស្ទះក្នុងការទទួលយក អាយស៊ីធី មកប្រើប្រាស់ ដោយផ្ទាល់ខ្លួន ព្រមទាំងជួយជំរុញឲ្យមានការអនុវត្តន៍នៃវិស័យ អាយស៊ីធី ដើម្បីពន្លឿនការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម រួមទាំង ការសម្រេចបានស្នាដៃក្នុងគោលដៅ រាប់លានផ្សេងទៀត។

Hyeun-Suk Rhee
ប្រធាន
UN-APCICT

# អំពីសេរីម៉ូឌុលនេះ

នៅក្នុង “សម័យព័ត៌មានវិទ្យា” បច្ចុប្បន្ននេះ ភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន កំពុងធ្វើការផ្លាស់ប្តូររបៀបនៃការរស់នៅ ជីវិតការងារ ក៏ដូចជាការកំសាន្តរបស់យើងគ្រប់ៗគ្នា ។ “សេដ្ឋកិច្ចឌីជីថល” ដែលត្រូវបានស្គាល់ថាជា “សេដ្ឋកិច្ចនៃចំណេះដឹង” “សេដ្ឋកិច្ចជាបណ្តាញ” ឬ “សេដ្ឋកិច្ចថ្មី” នោះត្រូវបានកំណត់លក្ខណៈតាមរយៈការផ្លាស់ប្តូរ ពីផលិតកម្មទំនិញទៅរកការបង្កើតជាគំនិតថ្មីៗ ។ នេះចង្អុលបង្ហាញអំពីភាពរីកចម្រើន ដែលត្រូវបានដើរតួយ៉ាងសំខាន់ ដោយបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (ICTs) នៅក្នុងប្រព័ន្ធសេដ្ឋកិច្ច និងសង្គមទាំងមូលថែមទៀតផង ។

ជាលទ្ធផល រដ្ឋាភិបាលទូទាំងសកលលោកបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា គមនាគន៍ព័ត៌មានវិទ្យា (ICTD) ។ សម្រាប់រដ្ឋាភិបាលទាំងនេះ ICTD មិនមែនមានន័យត្រឹមតែជាការអភិវឌ្ឍឧស្សាហកម្ម បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ឬវិស័យសេដ្ឋកិច្ចប៉ុណ្ណោះទេ ការអភិវឌ្ឍនេះថែមទាំងមានវិសាលភាពទៅលើការ ប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាដើម្បីជំរុញអោយមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច ក៏ដូចជាការរីកចម្រើន ផ្នែកសង្គម និងនយោបាយផងដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងចំណោមផលលំបាកនានាដែលរដ្ឋាភិបាលកំពុងជួបប្រទះក្នុងការបង្កើតគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យានោះ គឺអ្នកបង្កើតគោលនយោបាយទាំងនោះជាញឹកញាប់មិនទាន់ទម្លាប់នឹងបច្ចេកវិទ្យា ដែលខ្លួនកំពុងប្រើប្រាស់សម្រាប់ការអភិវឌ្ឍជាតិតែម្តង ។ ដោយហេតុថាបុគ្គលម្នាក់មិនអាចគោរពតាមបញ្ញត្តិដែលខ្លួនមិនយល់នោះ អ្នកបង្កើតគោលនយោបាយបានគេចចេញពីការបង្កើតគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ។ ប៉ុន្តែការទំលាក់បញ្ហារៀបចំគោលនយោបាយបច្ចេកវិទ្យាទូរគមនាគមន៍ព័ត៌មានវិទ្យានេះទៅអោយជំនាញការផ្នែកបច្ចេកវិទ្យាទទួលខុសត្រូវនោះ ក៏ជារឿងមួយមិនត្រឹមត្រូវដែរ ពីព្រោះជាធម្មតាជំនាញការបច្ចេកវិទ្យាទាំងនេះមិនបានដឹងអំពីទំនាក់ទំនងនៃគោលនយោបាយនេះចំពោះបច្ចេកវិទ្យាដែលខ្លួនកំពុងបង្កើត និងប្រើប្រាស់នោះទេ ។

ស៊េរីម៉ូឌុលកម្មវិធីសិក្សាអំពីសារសំខាន់នៃបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាល នេះ ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ការអភិវឌ្ឍតំបន់អាស៊ី និងប៉ាស៊ីហ្វិក របស់អង្គការសហប្រជាជាតិ (UN-APCICT) សម្រាប់ ៖

១. អ្នកបង្កើតគោលនយោបាយថ្នាក់ជាតិ និងរដ្ឋាភិបាលមូលដ្ឋានដែលទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយ ICT
២. មន្ត្រីរដ្ឋាបាលដែលទទួលខុសត្រូវការងារអភិវឌ្ឍន៍ និងការអនុវត្តកម្មវិធីផ្អែកតាម ICT និង
៣. អ្នកគ្រប់គ្រងនានានៅក្នុងវិស័យសាធារណៈ ដែលកំពុងស្វែងរកការប្រើប្រាស់ឧបករណ៍ ICT សម្រាប់ការងារគ្រប់គ្រងគម្រោងរបស់ខ្លួន ។

ស៊េរីម៉ូឌុលនេះ មានគោលបំណងអភិវឌ្ឍភាពទម្លាប់ជាមួយនឹងបញ្ហាសំខាន់ៗដែលជាប់ពាក់ព័ន្ធនឹង ICTD ដែលកើតចេញពីទស្សនវិស័យផ្អែកគោលនយោបាយ និងបច្ចេកវិទ្យា ។ គោលបំណងនៃម៉ូឌុលនេះ មិនមែនត្រឹមតែសម្រាប់ការអភិវឌ្ឍសៀវភៅណែនាំបច្ចេកទេស ICT តែប៉ុណ្ណោះនោះទេ ប៉ុន្តែជាងនេះទៅទៀតគឺដើម្បីផ្តល់នូវការយល់ដឹងដ៏ល្អអំពីអ្វីដែលបច្ចេកវិទ្យាឌីជីថលសព្វថ្ងៃអាចមាន ឬកន្លែងដែលបច្ចេកវិទ្យានេះ ត្រូវបានដឹកនាំទៅរក និងអ្វីដែលបច្ចេកវិទ្យានេះ ការបង្កើតគោលនយោបាយនានា ។ ប្រធានបទផ្សេងៗដែលមាននៅក្នុងម៉ូឌុលនេះ ត្រូវបានធ្វើការកំណត់ឡើងតាមរយៈការវិភាគទៅលើតម្រូវការនៃការបណ្តុះបណ្តាល ព្រមទាំងការស្ទាបស្ទង់ទៅលើសម្ភារៈដែលចាំបាច់សម្រាប់វគ្គបណ្តុះបណ្តាលដទៃទៀតនៅលើសកលលោក ។

ម៉ូឌុលនេះ ត្រូវបានរចនាឡើងនៅក្នុងរបៀបមួយដែលអាចអោយអ្នកអានគ្រប់រូបអាចធ្វើការស្វ័យសិក្សា បាន ឬដើម្បីប្រើប្រាស់ជាធនធានសិក្សាសម្រាប់វគ្គបណ្តុះបណ្តាល ឬកម្មវិធីបណ្តុះបណ្តាលនានា ។ ម៉ូឌុលនេះ អាចប្រើប្រាស់ជាឯកសារឯករាជ្យ និងឯកសារយោងជាមួយឯកសារផ្សេងៗទៀត ហើយកិច្ចប្រឹងប្រែងផ្សេងៗត្រូវបានធ្វើឡើងនៅក្នុងម៉ូឌុលនីមួយៗដើម្បី ផ្សារភ្ជាប់ម៉ូឌុលនេះទៅនឹងនិក្ខេបបទ និងកិច្ចពិភាក្សានានានៅក្នុងម៉ូឌុលដទៃទៀតដែលស្ថិតនៅក្នុងស៊េរីជាមួយគ្នានោះ ។ គោលបំណងរយៈពេលវែងគឺធ្វើយ៉ាងណាអោយម៉ូឌុលនេះត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាដែលមានការទទួលស្គាល់ ។

ម៉ូឌុលនីមួយៗចាប់ផ្តើមជាមួយនឹងសេចក្តីថ្លែងអំពីកម្មវត្ថុសិក្សា និងលទ្ធផលគោលដៅដែលនឹងទទួលបានក្រោយពេលសិក្សា ដែលអ្នកអានគ្រប់រូបអាចធ្វើការវាយតម្លៃអំពីភាពរីកចម្រើនរបស់ខ្លួនធៀបនឹងលទ្ធផលគោលដៅដែលផ្តល់អោយបាន ។ ខ្លឹមសារនៃម៉ូឌុលនេះ ចែកចេញជាផ្នែកៗដែលក្នុងនោះ

រួមមានករណីសិក្សានិងលំហាត់អនុវត្តផ្សេងៗដើម្បីជួយអោយអ្នកអានយល់កាន់តែស៊ីជម្រៅអំពីទស្សនទាន ជាគន្លឹះនានា ។ លំហាត់ទាំងនេះអាចនឹងអនុវត្តដោយបុគ្គលអ្នកអានម្នាក់ៗ ឬក្រុមសិក្ខាកាមដែលចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល ។ ម៉ូឌុលនេះផ្តល់នូវរូបភាព និងតារាងផ្សេងៗ ដើម្បីធ្វើការចង្អុលបង្ហាញអំពីតថភាពជាក់លាក់នានានៅក្នុងការពិភាក្សា ។ ឯកសារយោង និងធនធានឯកសារនៅលើបណ្តាញអ៊ីនធឺណិតទាំងឡាយ មានរាយនៅក្នុងសៀវភៅណែនាំនេះ សម្រាប់អ្នកអានក្នុងការការសិក្សាស្រាវជ្រាវដើម្បីបង្កើនទស្សនវិស័យអំពីបច្ចេកវិទ្យានេះបន្ថែមទៀត ។

ការប្រើប្រាស់ ICTD មានលក្ខណៈទូលំទូលាយណាស់រហូតដល់ពេលខ្លះករណីសិក្សា និងឧទាហរណ៍ នៅក្នុង និងទូទាំងម៉ូឌុលទាំងមូលអាចមានលក្ខណៈផ្ទុយគ្នា ។ យើងរំពឹងថាករណីនេះ នឹងអាចកើតមាន ឡើង ។ នេះគឺជារឿងមួយដែលគួរអោយភ្ញាក់ផ្អើល ព្រមទាំងបញ្ហាប្រឈមនៃមុខវិជ្ជាសិក្សាដែលទើបនឹងលេចឡើងថ្មីៗ និងសញ្ញានៃមុខវិជ្ជាទាំងនោះខណៈពេលដែល ប្រទេសនីមួយៗចាប់ផ្តើមរុករកសក្តានុពល នៃ ICTs ដើម្បីប្រើប្រាស់ធ្វើជាឧបករណ៍សម្រាប់ការអភិវឌ្ឍរបស់ខ្លួន ។

ការគាំទ្រកម្មវិធីសិក្សាសម្រាប់ស៊េរីម៉ូឌុលកម្មវិធីសិក្សានៅក្នុងទម្រង់ជាឯកសារបោះពុម្ពនេះ គឺជាបែបផែននៃការសិក្សាពីចម្ងាយតាមបណ្តាញអ៊ីនធឺណិត ពោលគឺកម្មវិធីសិក្សាជាក់ស្តែង APCICT (AVA – http://www.unapcict.org/academy ) ដោយមានថ្នាក់រៀនដែលផ្តល់នូវបទបង្ហាញពីគ្រូបណ្តុះបណ្តាលក្នុងទម្រង់ជាវីដេអូ និងបទបង្ហាញក្នុងទម្រង់ជាកម្មវិធី PowerPoint នៃម៉ូឌុលនានា ។

លើសពីនេះទៀត APCICT បានបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិតមួយសម្រាប់ ICTD (e-Co Hub – http://www.unapcict.org/ecohub ) ដែលជាវេទិការបម្រើដល់គោលបំណងជាក់លាក់មួយតាមបណ្តាញអ៊ីនធឺណិតសម្រាប់អ្នកអនុវត្ត និងអ្នកបង្កើតគោលនយោបាយ ICTD ដើម្បីលើកកម្ពស់បទពិសោធន៍នៃការសិក្សា និងការបណ្តុះបណ្តាលរបស់ខ្លួន ។ មជ្ឈមណ្ឌលសហប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិត ផ្តល់អោយអ្នកនូវការទទួលបានធនធាន ចំណេះដឹងនៅក្នុងតថភាពផ្សេងៗពីគ្នានៃ ICTD ព្រមទាំងផ្តល់នូវលំហអន្តរកម្មមួយសម្រាប់ចែករំលែកចំណេះដឹង និងបទពិសោធន៍ ព្រមទាំងសហប្រតិបត្តិការក្នុងគោលបំណងជួយអោយ ICTD កាន់តែមានលក្ខណៈទំនើប ។

# ម៉ូឌុល ៨

នៅពេលដែលការសាយភាយ នៃ អាយ ស៊ី ធី កាន់តែ កើនឡើង រាជរដ្ឋាភិបាលនៅជុំវិញពិភពលោកកំពង់តែជំរុញ នូវផែនការ និង គំរោង រដ្ឋាភិបាល-អេឡិចត្រូនិច ដើម្បីបង្កើនការផ្តល់សេវាសាធារណៈ តាមរយៈការប្រើប្រាស់ អាយ ស៊ី ធី ។ នៅក្នុងយុត្តាធិកាជាច្រើនមធ្យោបាយបច្ចេកទេស និងហិរញ្ញវត្ថុដែលរដ្ឋាភិបាលមានគឺតែងតែមានកំណត់បញ្ហានេះរារាំងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់នៅផលប្រយោជន៍របស់រដ្ឋាភិបាល-អេឡិចត្រូនិច ទៅដល់មនុស្សទាំងអស់គ្នា។ ទោះបីជាយ៉ាណាក៏ដោយ ក៏មាននូវ មូលនិធិនិងជំនាញការជាច្រើន ដែលវិស័យឯកជនអាចប្រើប្រាស ដើម្បីផ្តល់កាតួពកិច្ចរបស់ខ្លួនក្នុងការ ផ្តល់សេវាដែលមានកំរិតខ្ពស់បំផុតនៅក្នុងតម្លៃដ៏សមរម្យមួយ។ មេរៀននេះពិភាក្សាអំពីជំរើស មូលនិធិផ្សេងជាច្រើនសំរាប់ គំរោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៍ (ICTD) និង គំរោង រដ្ឋាភិបាល-អេឡិចត្រូនិច។ ភាពជាដៃគូអភិវឌ្ឍន៍ ឯកជន-សាធារណៈ (PPPs) ត្រូវបានគេលើកឡើង យ៉ាងសំខាន់ថាជាជំរើសមូលនិធិដ៏មានសារប្រយោជន៍ដ៏ជាក់លាក់មួយ សំរាប់ការផ្តល់សេវា គ្រឹះ អាយ ស៊ី ធី និង ការផ្តួចផ្តើម រដ្ឋាភិបាល-អេឡិចត្រូនិច នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍។

## កម្មវត្ថុនៃមេរៀន

មេរៀននេះមានគោលបំណង ដើម្បី :

១-ពិភាក្សាអំពីបញ្ហាដែលអាចប៉ះពាល់ដល់ ការវិនិយោគក្នុងការប្រើប្រាស់ អាយ ស៊ី ធី ជាមួយនិង ការផ្តោតយ៉ាងសំខាន់ទៅលើ រដ្ឋាភិបាល-អេឡិចត្រូនិច

២-ពិពណ៌នាអំពី យន្តការហិរញ្ញវត្ថុផ្សេងៗ សំរាប់ គំរោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៍ (ICTD)

៣-ពិពណ៌នាភាពជាដៃគូអភិវឌ្ឍន៍ ឯកជន-សាធារណៈ (PPPs) ថាជាជំរើស សំរាប់ផ្តល់មូលនិធិ ដល់គំរោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៍ (ICTD) និង គំរោង រដ្ឋាភិបាល-អេឡិចត្រូនិច និង

៤-គ្រោងនូវបញ្ហាដើម្បីពិចារណា នៅពេលសំរេចចិត្តទៅលើជំរើសមូលនិធិណាមួយ ដើម្បីបន្ត គំរោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៍ (ICTD) និង គំរោង រដ្ឋាភិបាល-អេឡិចត្រូនិច លទ្ធផលនៃការសិក្សា

## បន្ទាប់ពីសិក្សាមេរៀននេះ អ្នកសិក្សានិងអាច

១-ពិពណ៌នាអំពី យន្តការហិរញ្ញវត្ថុផ្សេងៗ សំរាប់ គំពោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD)

២-ពិពណ៌នាភាពជាដៃគូអភិវឌ្ឍន៏ ឯកជន-សាធារណៈ (PPPs) ថាជាជំរើស សំរាប់ផ្តល់មូលនិធិ ដល់ គំរោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD) និង គំរោង រដ្ឋាភិបាល-អេឡិចត្រូនិច និង

៣-រៀបចំនូវ យុទ្ធសាស្រ្តប្រើប្រាស់ធនធាន និង

៤-អភិវឌ្ឍន៏នូវពង្រាងសំណើរមូលនិធិសំរាប់ គំរោង អាយ ស៊ី ធី ដោយគិតអំពីផលលំបាក ដែល អ្នកបរិច្ចាក អាចមានចំពោះ ការផ្តល់មូនិធិ សំរាប់ សកម្មភាព អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD) និង គំរោង រដ្ឋាភិបាល-អេឡិចត្រូនិច

## មាតិកា


កថាមុខ

អារម្ភកថា

អំពីសេរីម៉ូឌុល

ម៉ូឌុល ៨

    កម្មវត្ថុម៉ូឌុល
    លទ្ធផលនៃការសិក្សា
    បញ្ជីប្រអប់
    បញ្ជីរូបភាព
    បញ្ជីតារាង
    ន័យដូច
    បញ្ជីនិមិត្តសញ្ញា

១- ការសាយភាយ អាយ ស៊ី ធី និង ការកើនឡើងសេដ្ឋកិច្ចពិភពលោក

    ១,១ ហេតុអ្វីវិនិយោគជាមួយ អាយ ស៊ី ធី ?
    ១.២ បញ្ហាប៉ះពាលការវិនិយោគលើគម្រោង ICT
    ១.៣ ឱកាសសំរាប់បញ្ហាប៉ះពាលការវិនិយោគលើគម្រោង ICT

២. បែបបទមូលនិធិផ្សេងៗគ្នា

    ២.១ ការវិនិយោគលើ
    ២.២ សេវាកម្មមូលនិធិមូលដ្ឋាន ICT
    ២.៣ បែបបទសំរាប់គម្រោងមូលនិធិ ICT
    ២.៥ ទទួលវស័យឯកជននិងរដ្ឋធ្វើការងារទាំងអស់គ្នា

៣. ដៃគូឯកជននិងរដ្ឋ

    ៣.១ ប្រវត្ត
    ៣.២ និយយន័យនិងប្រភេទ
    ៣.៣ គុណសម្បត្តិនិងគុណវិបត្តិនៃ PPPs
    ៣.៤ គោលការណអភិវឌ្ឍន៍

៤. PPP និងគម្រោងអេឡិចត្រូនិចរាជរដ្ឋាភិបាល
៤.១ និន្នាការអេឡិចត្រូនិចរាជរដ្ឋាភិបាល
៤.២ មូលហេតុសំរាប់ PPPs ក្នុងរាជរដ្ឋាភិបាល
៤.៣ តើគម្រោងអេឡិចត្រូនិចរាជរដ្ឋាភិបាលគឺសាកសមសំរាប់ PPPs?
៤.៤ លក្ខខណ្ឌសំរាប់ភាពជោគជ័យ
៤.៥ ឧទាហរណ៍អន្តរជាតិនៃ PPPs

៥. ហានិភ័យក្នុងគម្រោង PPPs សំរាប់អេឡិចត្រូនិចរាជរដ្ឋាភិបាល
៥.១ ហានិភ័យជាប់ទាក់ទងនឹងគម្រោង ICTs
៥.២ ការគ្រប់គ្រងនិងសម្រាលហានិភ័យក្នុង PPPs សំរាប់អេឡិចត្រូនិចរាជរដ្ឋាភិបាល

៦. ជម្រើសមូលនិធិដ៏ទៃទៀត
៦. ១ ការវិនិយោគទិសដៅបរទេស
៦.២ ធនធានប្រថុយប្រថាន
៦.៣ សហប្រត្តិបត្តិការកិច្ចការជំនួញ
៦.៤ វិទ្យាស្ថានហិរញ្ញវត្ថុ(វិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ)
៦.៥ មូលនិធិរដ្ឋាភិបាលទៅរដ្ឋាភិបាល

៧. ការរៀបចំយុទ្ធិសាស្ត្រកែប្រែធនធាន
៧.១ សង្ខេបកែប្រែធនធាន
២.២ ការរៀបចំសំណើរគម្រោងហិរញ្ញវត្ថុ

ឯកសារបន្ថែម
ការអានបន្ថែម
ពាក្យកាត់
កំណត់សំគាល់អ្នកបណ្តុះបណ្តាល
អំពីអ្នកនិពន្ធ
ថ្លែងអំណរគុណ

## បញ្ជីនៃការសិក្សា


១. PPP មួយក្នុងការផ្តល់ឲ្យជាអេឡិចត្រូនិចក្នុងប្រទេសកាណាដា និងហ្វីលីពីន
២. Intel ក្នុង Costa Rica: ការទាក់ទាញការវិនិយោគខ្ពស់


## បញ្ជីប្រអប់


ប្រអប់ ១ សមាសភាពសំណើគម្រោងហិរញ្ញវត្ថុ


## បញ្ជីរូបភាព


រូបភាព ១. ការបែកចាយ ICT ទៅកាន់ការលូតលាស់សេដ្ឋកិច្ច
រូបភាព ២. ការពង្រីកទីផ្សារ ICT 2000-2008
រូបភាព ៣. ការចូលទៅកាន់ទូរស័ព្ទដៃ
រូបភាព ៤. ការកាត់បន្ថយក្នុងការផ្សាយ GHG ក្នុងសហរដ្ឋអាមេរិកសំរាប់ការជ្រើសរើសសកម្មភាព
រូបភាព ៥. ការដឹកនាំដ៏រឹងមាំទៅការធ្វើជំនួញ
រូបភាព ៦. ការផ្តល់ផ្នែកឯកជនបន្តបន្ទាប់ក្នុង PPPs
រូបភាព ៧. ការមានហានិភ័យក្នុងគម្រោង PPPs
រូបភាព ៨. ការបង្ហាញជាឧទាហរណ៍នូវ Gantt chart នៃការសំរេចចិត្តគាំទ្រពីការគ្រប់គ្រងគម្រោង ICT
រូបភាព ៩. ការលំហូរ FDI, សកលនិងដោយក្រុមសេដ្ឋកិច្ច, ១៩៨០-២០០៦


## បញ្ជីតារាង


តារាង ១. បញ្ជីមូលនិធិ Sovereign Wealth
តារាង ២. ប្រភេទនៃ PPPsដោយយោងតាមបំណងដំបូង
តារាង ៣. លក្ខខណ្ឌមុនមួយចំនួនសំរាប់ការជោគជ័យ PPPs
តារាង ៤. សង្ខេបនៃ PPPs ដោយផ្នែកឯកជនក្នុងសហព័ន្ធអ៊ឺរ៉ុប
តារាង ៥. សង្ខេបនៃ PPPs ដោយផ្នែកឯកជនដែលមិនមែនក្នុងសហព័ន្ធអ៊ឺរ៉ុប
តារាង ៦. ឧទាហរណ៏ការរៀបចំគម្រោងហានិភ័យនិងយុទ្ធការបន្ធូបន្ថយ
តារាង ៧. ឧទាហរណ៏គម្រោងហានុភ័យកើតឡើងនិងយុទ្ធការបន្ធូបន្ថយ
តារាង ៨. ឧទាហរណ៏គម្រោងហានុភ័យដំណើរការនិងយុទ្ធការបន្ធូបន្ថយ

## ពាក្យសរសេរកាត់

ABT កិច្ចព្រមព្រាងលើទូរគមនាគមន៍

AMS ប្រព័ន្ធគ្រប់គ្រងសហរដ្ឋអាមិរិក

APCICT មជ្ឈមណ្ឌលបណ្ដុះបណ្ដាលអាស៊ី និងប៉ាស៊ីហ្វិកសំរាប់ ICT សំរាប់ការអភិវឌ្ឍន៍

ATP រោងចក្រផ្គុំ និងសាកល្បង

AVA កម្មវិធីសិក្សាជាក់លាក់នៃ APCICT

BOO បង្កើត-ផ្ទាល់ខ្លួន-ដំណើការ

BOOT បង្កើត-ផ្ទាល់ខ្លួន-ដំណើការ-បញ្ជូន

BOT បង្កើត-ផ្ទាល់ខ្លួន-បញ្ជូន

BRICS ប្រេស៊ីល, រុស្សី, ឥណ្ឌា, ចិន, និងអាព្រិកខាងត្បូង

CIO ប្រធានមន្ត្រីពត៌មាន

CMS ប្រព័ន្ធគ្រប់គ្រងមាតិកា

CRM ការគ្រប់គ្រង់ទំនាក់ទំនងអតិថិជន

DAC គណៈគម្មាធិការជំនួយការអភិវឌ្ឍន៍

DB ការបង្កើតរចនា

DFID នាយកដ្ឋានសំរាប់ការអភិវឌ្ឍនអន្តរជាតិ, ចក្រភពអង់គ្លេស

ECM ការគ្រប់គ្រង់មាតិការសហគ្រាស

EMF ពង្រឹងការគ្រប់គ្រងគ្រោង

ERP គម្រោងធនធាន់សហគ្រាស

ESCAP គណៈគម្មាធិការសេដ្ឋកិច្ចសង្គមសម្រាប់អាស៊ីប៉ាស៊ីហ្វិក

FDI ការវិនិយោគផ្ទាល់បរទេស

GATS កិច្ចព្រមព្រាងទូទៅលើពានិជ្ជកម្មក្នុងសេវាកម្ម

GHG ឧស្ម័ន្ធផ្ទះបៃតង

GoC រាជរដ្ឋាភិបាលកាណាដា

HP Hewlett Packard

ICT បច្ចេកវិទ្យា គមនាគមន៍ ពត៌មាន

ICTD បច្ចេកវិទ្យា គមនាគមន៍ ពត៌មានសម្រាប់ការអភិវឌ្ឍន៍

IDRC មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍអន្តរជាតិ

| | |
|---|---|
| IFI | វិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ |
| IPP | រោងចក្រឥទ្ធិពលឯករាជ |
| IPR | សិទ្ធកម្មសិទ្ធបញ្ញា |
| IT | បច្ចេកវិទ្យាពត៌មាន |
| ITU | សហព័ន្ធបច្ចេកវិទ្យាពត៌មាន |
| MDG | គោលបំណងអភិវឌ្ឍសហស្សវត្ត |
| NASCIO | ប្រធានមន្រ្តីពត៌មានសហគមន៏ជាតិ |
| NGO | អង្គការមិនមែនរាជដ្ឋាភិបាល |
| ODA | មន្រ្តីជំនួយការអភិវឌ្ឍ |
| OECD | អង្គការអភិវឌ្ឍសហរប្រត្តិបត្តិការសេដ្ឋកិច្ច |
| OPEC | សមាគមន៏បណ្តាប្រទេសនាំចេញសាំង |
| PFI | ការបង្កើតហិរញ្ញវត្ថុឯកជន, ចក្រភពអង់គ្លេស |
| PPD | អធ្លាធិប្បាយផ្នែកឯកជន និងរដ្ឋ |
| PPP | ដៃគូផ្នែកឯកជន និងរដ្ឋ |
| PRSP | ឯកសារយុត្តិសាស្រ្តកាត់បន្ថយភាពក្រីក្រ |
| RBM | ការគ្រប់គ្រងប្រព័ន្ធលទ្ធផល |
| SDNP | កម្មវិធីបណ្តាញអភិវឌ្ឍនិរន្តភាព |
| SME | សហគ្រាសខ្នាតតូចនិងកណ្តាល |
| SWF | មូលនិធិសុខភាព Sovereign |
| TNC | ការផ្លាស់ប្តូរសហប្រត្តិបត្តិការ |
| UAF | មូលនិធិប្រើប្រាស់សកល |
| UK | ចក្រភពអង់គ្លេស |
| UN | អង្គការសហប្រជាជាតិ |
| UNCTAD | សិក្ខាសាលាស្តីពីពានិជ្ជកម្មនិងការអភិវឌ្ឍន៏ |
| UNDP | កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ |
| UNIDO | អង្គការអភិវឌ្ឍឧស្សាហកម្មអង្គការសហប្រជាជាតិ |
| US | សហរដ្ឋអាមេរិក |
| USA | សហរដ្ឋអាមេរិក |
| WDM | ការបែងចែកប្រវែងរលកច្រើន |

| | |
|---|---|
| WSIS | កិច្ចប្រជុំពិភពលោកស្តីពីសង្គមពត៌មាន |
| WTO | អង្គការពានិជកម្មពិភពលោក |

## បញ្ជីនិមិត្តសញ្ញា



សញ្ញាសម្រាប់ផ្នែកសិក្សា


សំនួរត្រិះរិះ


អ្វីដែលត្រូវអនុវត្ត/ការងារដែលត្រូវធ្វើ



សាកល្បងខ្លួនអ្នក

### អ្វីដែលត្រូវធ្វើ

កំនត់វិការដ្ឋាន : សារៈសំខាន់នៃ អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD) នៅក្នុងយុត្តាធិការរបស់អ្នក

<u>ទិសដៅ </u>: វាយតំលៃ សារៈសំខាន់នៃ អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD) នៅក្នុងយុត្តាធិកា របស់អ្នកដោយប្រើសំនួរខាងក្រោមជាមគ្គុទេសក៏

១-តើអ្វីជាប្រភពចំបងនៃការផ្តល់មូនិធិសំរាប់សកម្មភាព អាយ ស៊ី ធី នៅក្នុងប្រទេសរបស់អ្នក ?

២-តើមានធនធានគ្រប់គ្រាន់សំរាប់អនុវត្តន៏ គំរោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD) ទេ ?

៣-តើមាន យុទ្ធសាស្រ្តប្រើប្រាស់ធនធានសំរាប់ គំរោង អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD) ទេ ?អ្វីខ្លះ? តើវាដំណើរការ ទេ?

៤-តើមានគណៈរៀបផែនការ អាយ ស៊ី ធី ថ្នាក់ជាតិ រឺក៏គណៈដែលមានតំលៃស្មើគ្នា ទេ ?

៥-តើផែនការ រឺ យុទ្ធសាស្រ្ត អាយ ស៊ី ធី ថ្នាក់ជាតិ រឺក៏ រដ្ឋាភិបាល-អេឡិចត្រូនិច ត្រូវបានគេអនុវត្តន៏ រឺនៅ ?
ជ្រើសរើស ចំលើយដែលអាចប្រើការច្រើនបំផុត និង ពន្យល់ពីជំរើសនេះ

ក- គ្មាន យុទ្ធសាស្រ្ត
ខ- មិនត្រូវបានចាប់ផ្តើមនៅឡើយទេ
គ- ទើបតែបានចាប់ផ្តើម
ឃ- កំពុងតែបន្ត
ង- បានផ្អាក

ចំណាំ : នៅពេលដែលរៀបចំធ្វើ វគ្គបណ្ដុះបណ្ដាល សកម្មភាពទាំងអស់នេះ និងអាចអោយសិក្ខាកាម ផ្ដល់ពត៌មានដល់អ្នកបណ្ដុះបណ្ដាល អំពីខ្លួនរបស់ពួកគេ និងការយល់អំពី អាយ ស៊ី ធី សំរាប់ ការអភិវឌ្ឍន៍ (ICTD) ។ ផងដែរ វានិងអាចអោយ សិក្ខាកាមសិក្សាពីគ្នាទៅវិញទៅមក និងធ្វើអោយ វគ្គសិក្សាមានភាពរីករាយ។

## ១- ការសាយភាយ អាយ ស៊ី ធី និង ការកើនឡើងសេដ្ឋកិច្ចពិភពលោក

ផ្នែកនេះមានគោលបំណងដើម្បី :

- ផ្តល់នូវទស្សនៈវិស័យនៃបញ្ហាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានឥទ្ធិពលទៅលើការសំរេចចិត្ត វិនិយោគ យោងទៅលើ គំរោង អាយ ស៊ី ធី និង
- រៀបគំរោង ឱកាសវិនិយោគ ក្នុងការរៀបចំផែនការ គំរោង អាយ ស៊ី ធី

បញ្ហាជាច្រើនមានឥទ្ធិពល ទៅលើ ការវិនិយោគជាមួយ គំរោង អាយ ស៊ី ធី ហើយ ថ្នាក់ដឹកនាំរដ្ឋាភិបាល ត្រូវការយល់ដឹងពីបញ្ហាទាំងអស់នេះ ដើម្បីអាចសំរេច ទៅលើដំណើរការដ៏ល្អប្រសើរ នៃគំរោងអភិវឌ្ឍន៍ អាយ ស៊ី ធី និង ការធ្វើហរិញ្ញប្បទាន។

និន្នាការពាណិជ្ជកម្ម និង ហរិញ្ញវត្ថុបច្ចុប្បន្ន, សេដ្ឋកិច្ចពិភពលោក, និង និន្នាការក្នុងលំហូរមូលធន រួមទាំង និន្នាការ ក្នុងការបញ្ជោញនិងប្រើប្រាស់ អាយ ស៊ី ធី, ត្រូវតែបានពិចារណានៅ ពេលជ្រើសរើស យុទ្ធសាស្ត្រ ផ្តល់មូលនិធិដល់ គំរោង ដ៏សមរម្យ។ ជាមួយនិង Internet ពត៌មានទាំងនេះអាចរកបានយ៉ាង ទូលំទូលាយ តាមរយៈ ទូរលេខទូទៅ ជំនួញ និង ហរិញ្ញវត្ថុ រឺ សេវាពត៌មាន ដូចជា Reuters, Bloomberg, Associated Press and Agence France-Presse សេវាពត៌មានជាតិ Xinhua សេវាផ្សព្វផ្សាយអន្តរជាតិ ដូចជា BBC, CNN and Al-Jazeera ហើយនិង ផ្នែកហរិញ្ញវត្ថុនិងជំនួញ របស់កាសែតជាតិនិងអន្តរជាតិ ។ពត៌មានវិនិយោគអាចរកបានផងដែរ ដោយមិនគិតថ្លៃ តាមរយៈ ការផ្តល់សេវា របស់ប្រភពដែលបានរៀបរាប់ខាងលើ និង ក្រុមហ៊ុនវិនិយោគ Standard and Poors ។

ចំណេះដឹងនៃនិន្នាការហិរញ្ញវត្ថុ គឺមិនមែនជាការយល់ដឹងដល់កម្រិតតែមួយ របស់អ្នកសេដ្ឋកិច្ច រឺ អ្នករៀបចំផែន ការថ្នាក់ខ្ពស់ ដែលធ្វើការនៅក្នុងក្រសួងហិរញ្ញវត្ថុ រឺ ក្រសួងផែនការ រឺក៏ក្រសួងដែលអាចមាន កម្រិតស្មើរ និង អង្គភាពដែលទាក់ទង (ឧទាហរណ៍ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ) ។ អ្នករៀបចំផែនការ និង អ្នកគ្រប់គ្រងរដ្ឋាភិបាល ទាំងអស់ គួរតែមានការចាប់អារម្មណ៍ជាមួយនិង ការវិភាគនិងពត៌មាន ហិរញ្ញវត្ថុ ដើម្បីអាចស្វែងរក វិការដ្ឋានផ្តល់ មូលនិធិផ្សេងៗ សំរាប់ការវិនិយោគ អាយ ស៊ី ធី នៅក្នុងផ្នែកសាធារណៈ

## ១,១ ហេតុអ្វីវិនិយោគជាមួយ អាយ ស៊ី ធី ?

មានមូលហេតុជាច្រើនដែលប្រទេសមួយ រឺ អជ្ញាធរដែលត្រូវបានផ្តល់អោយមួយ អាចចង់វិនិយោគជាមួយនិង អាយ ស៊ី ធី។ ទាំងនេះ រួមបញ្ចូលទាំង បំណង ដើម្បីរក្សា រឺក៏ បង្កើន អត្ថប្រយោជន៏ នៃការប្រៀបធៀប និងប្រកួតប្រជែងតាមរយះការផ្សព្វផ្សាយការអភិវឌ្ឍន៏សេដ្ឋកិច្ច, ដើម្បីផ្តល់ការអប់រំសំរាប់ទាំងអស់គ្នា និង ពង្រីកការឈាន ចូលទៅកាន់សេវាសង្គម។ ការបញ្ចោញនូវសេដ្ឋកិច្ចបន្តជាគោលបំណងគន្លឹះរបស់រដ្ឋាភិបាលជាច្រើន។ សំរាប់ សហគមន៏ផ្តល់ជំនួយ, ការកាត់បន្ថយភាពក្រីក្រ និងការសំរេចគោលដៅអភិវឌ្ឍន៏សហសវត្សគឺជាគោលបំណង ចំបងរបស់ជំនួយអភិវឌ្ឍន៏ ដោយរួមទាំងការផ្តល់មូលនិធិសំរាប់សកម្មភាព អាយ ស៊ី ធី សំរាប់ការអភិវឌ្ឍន៏ (ICTD)

នៅក្នុងសេដ្ឋកិច្ចពត៌មានពិភពលោក, ពត៌មាននិងចំណេះដឹង គឺជាកត្តាសំខាន់នៃផលិតផល។ ដោយយោង ទៅលើ របាយការណ៏បច្ចុប្បន្នរបស់ International Telecommunication Union (ITU), ភស្តុតាងគឺបង្ហាញច្បាស់ថា តំបន់ជុំវិញពិភពលោកកំពង់តែទទួលផលប្រយោជន៏ ពីឥទ្ធិពលរបស់ អាយ ស៊ី ធី ទៅលើសេដ្ឋកិច្ច[១] (សូមមើល រូបភាពទី១ )

**រូបភាព ១ : ការរួមចំណែករបស់ អាយ ស៊ី ធី ទៅលើកំនើនសេដ្ឋកិច្ច**

(Source: ITU, *World Telecommunication/ICT Development Report 2006: Measuring ICT for Social and Economic Development* (Geneva: ITU, 2006), 44, http://foss.org.my/projects/us-my-free-trade-agreement-issues/ resources /wtdr2006-e.pdf)




១ ITU, *World Telecommunication/ICT Development Report 2006: Measuring ICT for Social and Economic Development (Geneva: ITU, 2006), http://foss.org.my/projects/us-my-free-trade-agreement-issues/resources/wtdr2006-e.pdf.*

នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៏ ការសាយភាយនៃ អាយ ស៊ី ធី “បានផ្តល់នូវឱកាសថ្មីៗច្រើន សំរាប់បញ្ចូលទៅក្នុង ចង្វាក់តម្លៃពិភពលោក និង ការធ្វើអោយ សកម្មភាពផលិតផល និងការនាំចេញ មានភាពប្លែកៗពីគ្នា” ហេដ្ឋារចនាសម្ពន្ធ័របស់ អាយ ស៊ី ធី ត្រូវបានគេចាត់ទុកជាចាំបាច់ ចំពោះអត្ថប្រយោជន៏ប្រកួតប្រជែងរបស់ជាតិ ជាច្រើន។ សូម្បីតែតំបន់អភិវឌ្ឍន៏ជាច្រើននៅលើពិភពលោក ក៏មានការជំរុញឆ្ពោះទៅការសាយភាយដ៏ធំធេងនៃ អាយ ស៊ី ធី, ជាមួយនិងការផ្តោតដ៏ជាក់លាក់មួយ ទៅលើការបញ្ជូនទិន្នន័យ (Broadband) ជាពិសេសជាមួយខ្សែ (Fibre) និង ការបញ្ជូនទិន្នន័យគ្មានខ្សែ (Wireless Broadband) នៅគ្រប់ប្រភេទទំរង់ផ្សេងៗគ្នាទាំងអស់របស់វា។

អង្គការអភិវឌ្ឍន៏និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) រាយការណ៏ថា នៅក្នុងប្រទេស ប្រេស៊ីល រុស្សី ឥណ្ឌា ចិន និង អាហ្រិកខាងត្បូង អត្រានៃការចំណាយលើ អាយ ស៊ី ធី បានបង្ហាញនូវការកើនឡើងយ៉ាងខ្លាំងលើការចំណាយស្រដៀងគ្នាដែលធ្វើឡើងនៅក្នុង OECD ( សូមមើល រូបភាពទី២ ) ។

**រូបភាពទី២ : ការចំណាយទីផ្សា អាយ ស៊ី ធី ២០០០-២០០៨** (USD current prices, indexed 2000 = 100)




*Note:* 2006 to 2008 forecast.
*Source:* WITSA, OECD analysis.

StatLink http://dx.doi.org/10.1787/003431437710

សមត្ថភាពអ៊ីនធរណេតអន្តរជាតិ កំពង់តែរីកដុះដាល នៅអត្រាកំនើនប្រចាំឆ្នាំ ៤៥ ភាគរយ។ ដោយយោងទៅលើ *Broadband Properties Magazine*។ ទីផ្សា broadband ដែលរីកដុះដាលលឿនបំផុត ១០ គឺ ក្រិក ហ្វីលីពីន ឥណ្ឌូនេស៊ី អៀរឡង់ ឥណ្ឌា អ៊ុយក្រែន ថៃ វៀតណាម រុស្សី និង ទួរគី វាគួរអោយកត់សំគាល់ថាមានប្រទេស ៥ ស្ថិតនៅក្នុងទ្វីបអាស៊ី។

សរុបសេចក្តីមក មានការកើនឡើងដ៏ច្រើននៃ អាយ ស៊ី ធី គ្រប់ទីកន្លែង។ ការជ្រៀបចូលនៃ អាយ ស៊ី ធី នេះ គឺកំពង់តែឆ្ពោះទៅកាន់អ្វីមួយដែលអ្នកស្រាវជ្រាវមួយចំនួនដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកបានហៅថា "ការងារដោយកុំព្យូទ័រគ្រប់កន្លែង" ( ubiquitous computing )។ ឥឡូវនេះ អាយ ស៊ី ធី គឺមានសំរាប់មនុស្សរាល់គ្នា និងសំរាប់ធ្វើការងារផ្សេងៗគ្នាជាច្រើន។ ការប្រើប្រាស់យ៉ាងទូលំទូលាយនៃ អាយ ស៊ី ធី គឺកំពង់តែផ្លាស់ប្តូរនូវរបៀបដែលមនុស្សកំពង់ធ្វើការងារ។ សកម្មភាពផ្សេងៗគ្នាជាច្រើន ដែល ធ្វើដោយដៃ និង បញ្ចោញថាមពលខ្លាំងក្លា ត្រូវបានជំនួសដោយម៉ាស៊ីន ដើម្បីការកើនឡើងល្បឿននៃប្រតិបត្តិការ និងការកាត់បន្ថយសកម្មភាពដដែលៗរបស់ខ្លួន។ បច្ចេកវិទ្យាពីរ បង្ហាញសមត្ថភាពលេចធ្លោ ដើម្បីបង្កើន ការសាយភាយ អាយ ស៊ី ធី និង ការប្រើប្រាស់នៃ ឧបករណ៍និងកម្មវិធីដែលមានឥទ្ធិពលខ្លាំងក្លា និងយ៉ាងធំទូលំទូលាយ។ បច្ចេកទេសទាំងនោះ គឺ បច្ចេកទេសបញ្ជូនពត៌មានគ្មានខ្សែ ដែលអាចអោយការងារដោយកុំព្យូទ័រចល័ត ធ្វើទៅបាន ហើយនិងបច្ចេកទេសបញ្ជូនពត៌មាន broadband ដែលអនុញ្ញាតិការចូលទៅយ៉ាងរហ័សទៅដល់ប្រពន្ធ័ប្រតិបត្តការ របស់ កុំព្យូទ័រ ឧបករណ៍ និង កម្មវិធីផ្សេងៗដែលទាក់ទង។

ទោះបីជាយ៉ាងណាក៏ដោយ មនុស្សរាល់គ្នាមិនមែនកំពង់តែទទួលបានផលប្រយោជន៍ពីការភាយសាយនៃសេវាគ្មានខ្សែទាំងអស់ទេ។ ថ្វីបើ ៥៨ ភាគរយ នៃអ្នកជាវចល័ត គឺស្ថិតនៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ ហើយចំនួនរបស់ពួក គេបានកើនឡើងមួយជាបី នៅក្នុង៥ឆ្នាំចុងក្រោយ, នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ ប្រហែល ៤០ ការជ្រៀបចូល នៃសេវាគ្មានខ្សែ បានឈានដល់ប្រហែលត្រឹមតែ ១០ ភាគរយនៃ ចំនួនប្រជាជន, យោងទៅលើ សន្និសិទ្ធអង្គការ សហប្រជាជាតិទៅលើ ពាណិជ្ជកម្មនិងការអភិវឌ្ឍន៍ (UNCTAD) របាយការណ៍សេដ្ឋកិច្ចពត៌មាន ២០០៧-២០០៨។

ទោះបីជា ៤០ភាគរយ នៃអ្នកជាវសេវាគ្មានខ្សែទូទាំងពិភពលោក ស្ថិតនៅទ្វីបអាស៊ី អត្រាការជ្រៀបចូលជាភាគរយនៃចំនួនប្រជាជន គឺមានកំរិតទាបនៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍តិចតួចនៃតំបន់ ដូចជា ភូមា និង នេប៉ាល់។ មានការកើនឡើងយ៉ាងខ្លាំងក្លានៅកន្លែងដែលច្បាប់បញ្ញាត្តិលើកទឹកចិត្ត ការប្រកួតប្រជែង ដូចជានៅក្នុងប្រទេស ម៉ុងហ្គោលី រឺ នៅបណ្តាប្រទេសដែលផ្សព្វផ្សាយការវិនិយោគជាមួយហេដ្ឋារចនាសម្ពន្ធ័ អាយ ស៊ី ធី ដូចប្រទេស ចិន។ នៅក្នុងអាស៊ីកណ្តាល អត្រាជ្រៀបចូលមានកំរិតទាបណាស់ នៅតិចជាង ៥ភាគរយ (សូមមើល រូបភាពទី៣)។

## រូបភាពទី៣ : ការជ្រៀបចូលនៃទូរសព្ទ័ចល័ត

(ប្រភព: UNCTAD, *Information Economy Report 2007-2008 - Science and technology for development: The new paradigm of ICT* (New York and Geneva: United Nations, 2007), 23, http://unctad.org/en/docs/ sdteecb 200 71 _en.pdf)




ជាមួយនិងកំណើននៃការលក់ អាយ ស៊ី ធី មានការកើនឡើងយ៉ាងខ្លាំងក្លា នូវ ពាណិជ្ជកម្ម-អេឡិចត្រូនិច និង រដ្ឋាភិបាល-អេឡិចត្រូនិច។ មនុស្សជាច្រើនកំពង់ធ្វើការទិញទំនិញតាមរយៈប្រពន្ធ័អ៊ីនធណែត ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៏។ គ្រប់ទម្រង់ទាំងអស់នៃ ពាណិជ្ជកម្ម-អេឡិចត្រូនិចកំពង់តែរីកលូតលាស់ ទោះបីជាយ៉ាងណាក៏ដោយ ដែនកំណត់មួយក្នុងចំណោមដែនកំណត់សំខាន់ៗចំពោះអត្រានៃការកើនឡើងពាណិជ្ជកម្ម-អេឡិចត្រូនិចនៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ គឺអត្រានៃការយល់ដឹពី អាយ ស៊ី ធី ដោយសហគ្រាសធុនតូច និងមធ្យម(SMEs)។

សហគ្រាសធុនតូច និង មធ្យម(SMEs) គឺមានសារៈសំខាន់ណាស់ ពីព្រោះពួកគេជាចលករនៃការផ្តល់ការងារ និងការរីកលូតលាស់។ មានកិច្ចប្រឹងប្រែងដែលកំពង់ធ្វើឡើង នៅក្នុងប្រទេសផ្សេងៗគ្នា ជាច្រើនដើម្បីបង្កើនសមត្ថភាព របស់សហគ្រាសធុនតូច និង មធ្យម(SMEs) ចំពោះការប្រើប្រាស់ អាយ ស៊ី ធី។ ទាំងនេះរួមបញ្ចូលទាំងការប្រើប្រាស់ទូរសព្ទ័ចល័តដើម្បីកិច្ចការជំនួញ ពីព្រោះនៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍

មួយចំនួន អាយ សី ធី ដែលមាន ប្រជាប្រិយភាពជាងគេបំផុត គឺ ឧបករណ៍ចល័ត។ ការប្រើប្រាស់ទូរសព្ទ័ចល័ត នៅក្នុងជំនួញបានគេបកស្រាយថាជាការកើនឡើងនូវភាពងាយ ស្រួលក្នុងការធ្វើជំនួញសំរាប់គ្រប់គ្រឹស្ថានទាំងអស់។ ការប្រាស្រ័យទាក់ទងរវាង អ្នក ផ្គត់ផ្គង់ និងអតិថិជន គឺបានកើនឡើង ហើយនិងប្រសិទ្ធភាពអាចទុកចិត្តបាន ដែលបណ្តាលអោយមានការសន្សំ សំចៃបាននូវចំណាយ និងការឈានចូលទៅទីផ្សាធំៗ។ យន្តការផ្តល់មូលនិធិខុសគ្នាផ្សេងៗទៀត អាចដើរតួនាទី សំខាន់ៗ ក្នុងការលើកទឹកចិត្តការអភិវឌ្ឍន៏របស់សហគ្រាសធុនតូច និង មធ្យម(SMEs) នៅក្នុងឧស្សាហាកម្ម អាយ ស៊ី ធី ក្នុងប្រទេសមួយ។ ប្រភពនៃមូលនិធិទាំងអស់នេះ ត្រូវបានគេយកមកប្រើប្រាស់សំរាប់ផ្តល់មូលនិធិដល់ ការបង្កើតមុខជំនួញដែលផ្តល់ផងដែលនូវការបណ្តុះបណ្តាលដ៏ត្រឹមត្រូវក្នុងផ្នែក ជំនួញ-អេឡិចត្រូនិច ទៅដល់ សហគ្រិនដែលទើបតែកំពង់និងចាប់ផ្តើម។

ក៏ដូចជាពាណិជ្ជកម្ម-អេឡិចត្រូនិច, រដ្ឋាភិបាល-អេឡិចត្រូនិច បន្តលូតលាស់គួរអោយកត់សំគាល់ជុំវិញពិភពលោក[៦] ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកំពង់អភិវឌ្ឍន៏ជាច្រើន បន្តដើម្បីធ្វើអោយអស់ពីសមត្ថភាពនៅក្នុង ការផ្តល់សេវា រដ្ឋាភិបាល-អេឡិចត្រូនិច ដោយការខ្វះខាតនូវធនធាននិងមូលនិធិ។ ប្រទេសជាច្រើនបានអភិវឌ្ឍន៏ យុទ្ធសាស្រ្តនិងផែនការ រដ្ឋាភិបាល-អេឡិចត្រូនិច ជាច្រើន ប៉ន្តែខ្វះខាតនូវធនធានដើម្បីអនុវត្តន៏ផែនការទាំងនោះបញ្ហានេះគឺកំពង់តែកម្រិត ការជំរុញនូវសេវា រដ្ឋាភិបាល-អេឡិចត្រូនិច ដែលស្របជាមួយអត្ថប្រយោជន៏ដែល បញ្ហានេះតម្រូវ។

## ១.២ បញ្ហាដែលប៉ះពាល់ការវិនិយោគជាមួយគំរោង អាយ ស៊ី ធី

សំរាប់សេដ្ឋកិច្ចពត៌មាននៅក្នុងប្រទេសកំពង់អភិវឌ្ឍន៏ដើម្បីបន្តលូតលាស់ គឺត្រូវតែមានការទាមទារជានិរន្តរ៏ និង ការផ្គត់ផ្គង់ នៃសេវាកម្មនិងទំនិញដែលផ្អែកលើ អាយ ស៊ី ធី។ នៅក្នុងពេលតែមួយរដ្ឋាភិបាលទាំងអស់ត្រូវការធានាថា រាល់សមាជិកសាធារណះទាំងអស់ អាចទទួលបានផលប្រយោជន៏របស់សង្គមផ្អែកលើចំណេះដឹង។

វិស័យឯកជនអាចបន្តផ្តល់សេវានិងទំនិញដែលសារធារណះជនត្រូវបានគេរៀបចំអោយបង់ប្រាក់សំរាប់អោយរដ្ឋាភិបាល បន្តធានា បរិយាកាសនិយតកម្មគាំទ្រមួយ។ គោលនយោបាយប្រកួតប្រជែងដ៏ត្រឹមត្រូវមួយ;

៧ United Nations, *UN e-Government Survey 2008: From e-Government to Connected Governance* (New York: United Nations,2008), http://unpan1.un.org/intradoc/groups/public/documents/un/unpan028607.pdf.

ទីផ្សារបើកចំហប្រកួតប្រជែង និងដែលអាចឈានចូលបាន សំរាប់គ្រប់លក្ខណៈនៃសេវានិងទំនិញ ជាពិសេស សំរាប់អាយ ស៊ី ធី; របបនិយតកម្មដែលបានអភិវឌ្ឍន៏ល្អ; ភាពអាចព្យាករណ៍ បាននូវរបៀបដែលរដ្ឋាភិបាល ធ្វើការ; ការគោរពច្បាប់; ការលើកទឹកចិត្តរបស់រដ្ឋាភិបាលគឺត្រូវបានគេតម្រូវដើម្បីអោយមានការកើតឡើង រឿងនេះ; ភាគច្រើននៃគោលការណ៍ត្រូវបានគេដាក់ដំកល់នៅក្នុងកិច្ចព្រមព្រៀង អង្គការពាណិជ្ជកម្មពិភព លោក (WTO) ទៅលើ ពាណិជ្ជកម្មអន្តរជាតិ ដែលប្រទេសជាច្រើនក្នុងពេលបច្ចុប្បន្ន ជាហត្ថលេខី។ កិច្ចព្រម ព្រៀងទូទៅលើពាណិជ្ជកម្មក្នុងការផ្តល់សេវា (GATS) និង កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (WTO) 1997 ទៅលើទូរគមនាគមន៏មូលដ្ឋាន (ABT) បានលើកទឹកចិត្ត យ៉ាងជាក់លាក់ លើសេរីភាព ពាណិជ្ជកម្មលើទីផ្សារសកល[៧]។

ក្នុងការងើបឡើងវិញនៃសេដ្ឋកិច្ចជាច្រើននៅអាស៊ី ជាពិសេសការកើនឡើងនៃថ្នាក់កណ្តាល គឺកំពង់តែធានា ថាការទាមទារផ្នែក អាយ ស៊ី ធី បន្តលូតលាស់ នៅពេលដែលប្រាក់ចំណូល កើនឡើង។ ប៉ុន្តែដើម្បីធានាថា សាធារណៈជន អាចទទួលបានផលប្រយោជន៏ពីសេដ្ឋកិច្ចពត៌មាន,ការបន្តការវិនិយោគជាមួយហេដ្ឋារចនា សម្ពន្ធ័ អាយ ស៊ី ធី និង រដ្ឋាភិបាល-អេឡិចត្រូនិច នឹងត្រូវបានគេតម្រូវជាចាំបាច់។ ការនិយាយវាស្រួលជាងធ្វើ នៅពេលដែលមានបញ្ហានៃកង្វល់ជាបន្ទាន់ចំពោះរដ្ឋាភិបាលគ្រប់ទីកន្លែង។ ទោះបីជាមួយកំនើន អាជីវកម្ម និងប្រាក់ចំណូលពន្ធដារពីសេដ្ឋកិច្ចជាតិដែលកើនឡើង និងថ្នាក់កណ្តាលមានទ្រព្យធនធូរធារដែលមានច្រើន តម្លៃនៃការផ្តល់សេវាសាធារណៈ និង រដ្ឋាភិបាល-អេឡិចត្រូនិច គឺសំខាន់គួរអោយកត់សំគាល់។

ការងារលំបាកផ្សេងៗទៀតលេចឡើងផងដែរមានបញ្ហាសកលផ្សេងៗគ្នាដែលកំពង់ប៉ះពាល់ប្រទេសជា ច្រើន គ្រប់ ទីកន្លែង។ ទាំងអស់នេះនឹងមានឥទ្ធិពលទៅលើសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីធានាមូលនិធិដែល គេត្រូវការដើម្បីដំណើរការ រដ្ឋាភិបាល-អេឡិចត្រូនិច, រួមទាំងសមត្ថភាពរបស់ប្រទេសដើម្បីបង្កើនមូលនិធិ ជាទូទៅ។ បញ្ហាខ្លះក្នុងចំណោមបញ្ហាទាំងអស់នេះមានដូចខាងក្រោម :

- វិបិត្តសំខាន់រងនៅសហរដ្ឋ បានមានឥទ្ធិពលលើទីផ្សារហេរិញ្ញវត្ថុទូទាំងពិភពលោក និងបានកាត់បន្ថយ ការរំពឹងគិតនៃកំនើន នៅក្នុងប្រទេសជាច្រើនក្នុងប្រទេសអភិវឌ្ឍន៏ ហើយនិងលើសពីនេះទៅទៀតដោយ កាត់បន្ថយតម្រូវការ និងការកើនឡើងតម្រូវការអោយខ្ចីរបស់វិទ្យាស្ថានហិរិញ្ញវត្ថុនានា។ ជាលទ្ធផល ពិភពលោកបច្ចុប្បន្នស្ថិតនៅក្នុងកណ្តាប់ដៃរបស់ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក។ នៅក្រោមលក្ខណ្ឌ័នេះ អ្នកផ្តល់កម្ចីគឺ ស្ទាក់ស្ទើរជាង មុន ក្នុងការអោយលុយកម្ចី ហើយនិង ពាណិជ្ជកម្មកំពង់តែរងការឈឺចាប់ ជាមួយនិង ផលិតភាព របស់ប្រទេស នាំចេញនៅអាស៊ី និងជុំវិញពិភពលោក។

- តម្លៃនៃថាមពលដែលតែងតែកើនឡើងយ៉ាងខ្ពស់បានបង្កើនការចំណាយនៃការធ្វើជំនួញសំរាប់រដ្ឋាភិបាល និងវិស័យឯកជនរួមបញ្ចូលទាំងចំណាយក្នុងការរស់នៅរបស់អ្នកប្រើប្រាស់។ នៅពេលដែលតម្លៃនៃថាមពល បាន ធ្លាក់ចុះដោយសារការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក, អ្នកវិភាគបានព្យាករណ៍ថាតម្រូវការថាមពលពិភពលោក នឹង “កើនឡើង ដោយ ៥០ភាគរយ ពីឆ្នាំ ២០០៥ ដល់ ២០៣០” ដែលអាចនាំទៅដល់ការកើនឡើង នូវតម្លៃ “ការកើនឡើង........ធំបំផុត...........គឺសំរាប់ សេដ្ឋកិច្ច non-OECD ”[៨]

- ការកើនឡើងតំម្លៃនៃម្ហូបអាហារមានផលប៉ះពាល់ធ្ងន់ធ្ងរសំរាប់ប្រទេសទាំងអស់ ជាពិសេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការកើនឡើងជាបន្តនៃតម្លៃថាមពលនិងអាហារដែលគេបានរំពឹងទុកអាចនឹងបង្វែរធនធាន ពីការផ្តល់សេវា និង អាយ ស៊ី ធី។

- កង្វះខាតនៃហេដ្ឋារចនាសម្ពន្ធ័ម៉ាស៊ីនថាមពលនៅក្នុងប្រទេសជាច្រើនដូចជា ចិន និងអាហ្វ្រិកខាងត្បូង មានន័យថា មូលនិធិនឹងត្រូវតែបានគេរៃអង្គាសដើម្បីប្រឈមនិងបញ្ហានេះ។ ដោយគ្មានថាមពលដែលមានតម្លៃថោក និងគ្រប់គ្រាន់ ប្រទេសទាំងនេះ នឹងមិនអាច ធ្វើអោយមានអំណាចសេដ្ឋកិច្ចរបស់គេនិងធ្វើតាមតម្រូវការ នៃចំនួនប្រជាជនដែលកើនឡើងដ៏ច្រើនទេ។

- ការកើនឡើងនូវតម្រូវការសំរាប់ថាមពលបានបណ្តាលអោយមានការកើនឡើងប្រជាជន និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់គ្រប់ទីកន្លែង។ បំរែបំរួលបរិយាកាស បង្ហាញនូវការលំបាកធ្ងន់ធ្ងរ ទៅលើ ចំហេះហ្វូសីលបច្ចុប្បន្ន ដោយផ្អែកទៅលើគំរូនៃការអភិវឌ្ឍន៏សេដ្ឋកិច្ច។ ប្រជាជនជុំវិញពិភពលោកកំពង់តែត៌វាចង់បានបរិស្ថាន ដ៏ស្រស់ស្អាត សំរាប់រស់នៅនិងចញ្ចឹមគ្រួសាររបស់ពួកគេ។

- ជាមួយបំរែបំរួលបរិយាកាស, គ្រោះមហន្តរាយធម្មជាតិគឺសមញ្ញណាស់ និងតម្លៃនៃការគ្រប់គ្រងគ្រោះមហន្តរាយខ្ពស់ខ្លាំងណាស់។ ប្រជាជនដែលក្រីក្រជាងគេគឺរងវេទនាយ៉ាងខ្លាំងនៅពេលដែលពួកគេរស់នៅដោយមិនអាចផ្លាស់ប្តូរបាននៅក្នុងផ្នែកមួយចំនួននៃពិភពលោកដែលរងគ្រោះច្រើនបំផុតពីគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ។ ការបង្កើនយុទ្ធាសាស្រ្តដោះស្រាយ និង ត្រៀមរៀបចំគ្រោះមហន្តរាយ រួមនិងការគ្រប់គ្រង ការធ្វើអោយធូរស្រាលគ្រោះមហន្តរាយ នឹងបង្ហាញ ការកើនឡើងនូវបន្ទុកនៃសារពើពន្ធនិងពស្តុភា លើរដ្ឋាភិបាល ជុំវិញពិភពលោក។

៨ US Department of Energy, *International Energy Outlook 2008* (Washington D.C.: Energy Information Administration, US Department of Energy, 2008), 7, http://www.eia.doe.gov/oiaf/ieo/index.html.

## ១.៣ ឱកាសសំរាប់ទាក់ទាញការវិនិយោគជាមួយនិងគម្រោង អាយ ស៊ី ធី

ម្យ៉ាងវិញទៀត មានការអភិវឌ្ឍន៏វិជ្ជមានខ្លះៗ ដែលគួរអោយកត់សំគាល់។

ការកើនឡើងទ្រព្យធនរបស់ ប្រទេសកំពង់អភិវឌ្ឍន៏ខ្លះ: ប្រទេសខ្លះកំពង់តែកើនឡើងប្រាក់បំរុងបរទេសរបស់ពួកគេដែលជាលទ្ធផលពី សកម្មភាពសេដ្ឋកិច្ចដែលបានកើនឡើង។ឧទាហរណ៏ប្រាក់បំរុងរូបិយបណ្ណ័បរទេសរបស់ចិន ឈរនៅកម្រិត លើមួយសែនកោដិកន្លះ ដុល្លារអាមេរិក (USD 1.5 trillion) នៅចុងឆ្នាំ ២០០៧ ។

ការកើនឡើងតួនាទីមូលនិធិភោគទ្រព្យអធិបតេយ្យ (SWFs): ជាមួយការកើនឡើងប្រាក់ចំណូលសាធារណៈដែលបានទទួលពីការបង់ប្រាក់ ជួល ពន្ធដារ និង កំរៃលើការរុករកនិងនាំចេញ រ៉ែនិងប្រេង (ឧទា, រដ្ឋឈូងសមុទ្រ និង រុស្ស៊ី ) រឺមកពី ភាពខុសគ្នានៅក្នុងតម្លៃរវាងការនាំចេញនិងនាំចូលដែលល្អហើយច្រើន (ឧទា, ចិន និង សាំងហ្គាពួរ ) ប្រទេសជាច្រើនបានទទួលចំនួនដ៏ធំពី រូបិយបណ្ណ័បរទេស និងកំពង់តែស្វែងរកមើលយ៉ាងខ្លាំងនូវ ឱកាសដើម្បីវិនិយោគនូវភោគទ្រព្យដែលបានរកឃើញថ្មី។ រដ្ឋបាលពត៌មានថាមពលសហរដ្ឋអាមេរិកបានវាយតម្លៃ “ថាសមាជិករបស់ អង្គការនៃប្រទេសនាំចេញប្រេង (OPEC) បានរកប្រាក់បាន ៦៧១កោដិ ដុល្លារអាមេរិក ($671 billion) នៅក្នុងប្រាក់ចំណូលសុទ្ធពីការនាំចេញប្រេងក្នុងឆ្នាំ ២០០៧, ១០ ភាគរយកើនលើសឆ្នាំ ២០០៦”[១០]។ រដ្ឋឈូងសមុទ្រ ៤ រាប់គិតថាបានច្រើនជាងពាក់កណ្តាលនៃប្រាក់ចំណូល នោះ។ អង្គការនៃប្រទេស នាំចេញប្រេង (OPEC) រាប់គិតថាបានច្រើនជាងមួយភាគបីនៃផលិតផលប្រេង ទូទាំងពិភពលោក។

មូលនិធិភោគទ្រព្យអធិបតេយ្យ SWFs ជាយានយន្តនៃហិរញ្ញវត្ថុដែលគេបានរៀបចំឡើងដើម្បីជួយប្រទេសជាច្រើន អោយគ្រប់គ្រងនិង វិនិយោគ ប្រាក់ ចំណូលដែលច្រើនលើសលប់របស់ពួកគេ។ ដែលបានធ្វើរួចរាល់ហើយ មួយចំនួននៃមូលនិធិទាំងអស់នេះបានទៅដល់ការជួយសង្គ្រោះ ធានាគារសហរដ្ឋអាមេរិកដែលធំជាងគេមួយចំនួននៅក្នុងទំរង់នៃការបញ្ចូលសាច់ប្រាក់ដ៏ច្រើនកោដិដុល្លារ ក្នុងរូបិយបណ្ណ័ភាគហ៊ុន រឺជាប្រាក់ទុនក្នុងក្រុមហ៊ុនមួយ។ពត៌មានពី *The Globe and Mail* បានរាយការណ៏ថា ប្រទេស OPEC គឺ :

> ការស្ថាបនាមូលនិធិវិនិយោគក្រៅប្រទេសដ៏ធំសម្បើមដែលកំពង់តែប្រើឡើងវិញនូវទឹកប្រាក់ប្រេងទៅក្នុងសេដ្ឋកិច្ចលោកខាងលិច ដែលអាចកត់សំគាល់បាន ការបោះនូវប្រាក់ទុន

៩ chinability, “China’s foreign exchange reserves, 1977-2008,” http://www.china bility.com/Reserves.htm.

១០ US Energy Information Administration, “OPEC Revenues Fact Sheet,” http://www.eia.doe .gov/emeu/cabs/OPEC_Revenues/Factsheet.html.

> ៣កោដិដុល្លារអាមេរិច ក្នុងសារជីវកម្ម Citigroup Inc. របស់អជ្ញាធរវិនិយោគប្រទេសគុយវ៉ែត និង ភាគហ៊ុន ២កោដិដុល្លារ អាមេរិច នៅក្នុងសារជីវកម្ម Merrill Lynch & Co.Inc. ហើយនិង អជ្ញាធរវិនិយោគ Abu Dhabi) បានវិនិយោគទឹកប្រាក់ ៧,៥ កោដិដុល្លារអាមេរិច ក្នុងសារជីវកម្ម Citigroup Inc. ។ ការប្រើឡើងវិញនូវដុល្លារ-ប្រេង ត្រូវបានគេឃើញ យ៉ាងទូលំទូលាយថាជាផលប្រយោជន៍សំរាប់សេដ្ឋកិច្ចពិភពលោក ការផ្លាស់ប្តូរក្នុងអំណាច ហិរញ្ញវត្ថុ ចំពោះប្រទេសដែលសំបូររបស់ប្រើប្រាស់ និង ឆ្ងាយពីប្រទេសអ្នកប្រើប្រាស់។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេស OPEC ប្រឈមមុខនិងសម្ពាធដែលកើនឡើង ដើម្បី ធានាថា មូលនិធិគ្រប់គ្រងរដ្ឋ របស់ពួកគេ ដែលទទួលយកច្បាប់លោកខាងលិច សំរាប់អភិបាលកិច្ចនិង តម្លាភាព។ ពួកយើងចូលទៅក្នុងដែនដីដែលគ្មានផែនទីច្បាស់លាស់ ជាមួយប្រភេទនៃលំហូរហិរញ្ញវត្ថុដែលកំពង់ចូលទៅក្នុងសំណុំតូចមួយរបស់ប្រទេសទាំងអស់ នោះ និយាយដោយលោក David Pumphrey,សមាជិកជាន់ខ្ពស់នៅមជ្ឈមណ្ឌលសំរាប់ ការសិក្សាអន្តរជាតិនិងយុទ្ធសាស្រ្ត នៅទីក្រុងវ៉ាស៊ីនតោន។ ពួកយើងកំពង់តែមើលការធ្វើ អោយស្មើគ្នាឡើងវិញនៃតួអង្គរបស់ពិភពលោកនិង ពួកគេនឹងកំពង់ដើរតួនាទី ផ្សេងៗគ្នានៅ ពេលអនាគត ដូចច្នេះតួអង្គដែលត្រូវបានបង្កើតឡើងនឹងត្រូវតែបង្កើតកន្លែងទំនេរសំរាប់ពួក គេចូលរួម។[១១]

និន្នាការនេះទំនងជាបន្ត និងបង្កបង្កើតឱកាសមួយ សំរាប់រដ្ឋាភិបាលដែលស្វែងរកដើមីពង្រីក ការប្រថុយ ប្រថាន និងការវិនិយោគ អាយ ស៊ី ធីរបស់ពួកគេ។ ធានាគារពិភពលោកបានលើកទឹកចិត្ត មូលនិធិភោគ ទ្រព្យអធិបតេយ្យ SWFs ដើម្បីវិនិយោគជាមួយប្រទេសក្រីក្រជាច្រើន។[១២] តារាងទី១ បង្ហាញបញ្ជីថ្មីបំផុត (កុម្ភៈ ២០០៩ ) របស់ មូលនិធិភោគទ្រព្យអធិបតេយ្យ SWFs ពីវេបសាយ Wikipedia ។

---

១១ Shawn McCarthy, "Barrelling Ahead: Cartel members are using record crude prices to finance their global ambitions," *The Globe and Mail*, 8 May 2008, http://www.theglobeandmail.com/servlet/story/LAC.20080508.ROIL08/TPStory/?query=barreling+ahead.

១២ Christopher Swann, "World Bank Urges Sovereign Wealth Funds to Invest in Africa," *Bloomberg*, 12 April 2008, http://www.bloomberg.com/apps/news?pid=20601116&sid=a3O5_Nx5hf0k&refer=africa.

## តារាងទី១, បញ្ជី របស់ មូលនិធិភោគទ្រព្យអធិបតេយ្យ

| Country | Abbreviation | Fund | Assets $Billion | Inception | Origin | Approx wealth per citizen ($) |
|---|---|---|---|---|---|---|
| Abu Dhabi (United Arab Emirates) | ADIA | Abu Dhabi Investment Authority | 875 [9] | 1976 | Oil | 100,000 |
| Norway | GPF | Government Pension Fund of Norway | 391 [10] | 1990 | Oil | 81,500 |
| Singapore | GIC | Government of Singapore Investment Corporation | 330 [9] | 1981 | Non-commodity | 100,000 |
| Kuwait | KIA | Kuwait Investment Authority | 264.4 [11] | 1953 | Oil | 80,000 |
| China | CIC | China Investment Corporation | 200 [12] | 2007.09.28 | Non-commodity | 151 |
| Singapore | | Temasek Holdings[1] | 159.2 [9] | 1974 | Non-commodity | 35,400 |
| Australia | FFMA | Australian Government Future Fund | 81.3 [13] | 2004 | Non-commodity | 3,900 |
| Qatar | QIA | Qatar Investment Authority | 60 [14] | 2005 | Oil | 250,000 |
| Alaska (United States) | APFC | Alaska Permanent Fund | 40.1 | 1976 | Oil | 61,000 |
| Libya | | Libyan Investment Authority | 50 | 2007 | Oil | 7,200 |
| Russia | RNWF | Russian National Wealth Fund | 87,97 [15] | 2008 | Oil | n/a |
| Brunei | BIA | Brunei Investment Agency | 30 | 1983 | Oil | 90,100 |
| South Korea | KIC | Korea Investment Corporation | 30 | 2005 | Non-commodity | 417 |
| Malaysia | KN | Khazanah Nasional | 18.3 | 1993 | Non-commodity | 658 |
| Kazakhstan | KNF | Kazakhstan National Fund | 23.0 | 2000 | Oil | 1,170 |
| China | SAFE | State Administration of Foreign Exchange | n/a | n/a | Non-commodity | n/a |
| Taiwan | NSF | National Stabilisation Fund | 15 | 2000 | Non-commodity | 652 |
| Alberta (Canada) | AHF | Alberta Heritage Fund | 16.6 | 1976 | Oil & Gas | 5,000 |
| Iran | OSF | Oil Stabilisation Fund | 12.9 | 1999 | Oil | 174 |
| Dubai (United Arab Emirates) | DB | Dubai World | 100 | 2006 | Oil | n/a |
| Saudi Arabia | | Sanabil al-Saudia | 5.3 | 2008 | Oil | n/a |

ដោយយោងទៅលើ *The Economist*, មានមូលនិធិភោគទ្រព្យអធិបតេយ្យ SWFs ជាអន្តរជាតិ ប្រហែល ២៩ ដែលត្រូវបានត្រួតពិនិត្យដោយ Morgan Stanley, ធានាគារវិនិយោគដុល្លារសហរដ្ឋអាមេរិក, ហើយពួកគេមាន តំលៃ ប្រហែល ២,៩ សែនកោដិដុល្លារអាមេរិក (USD 2.9 trillion)។[១៣] វាត្រូវបានគេព្យាករណ៍ថា ចំនួនទាំងនេះ នឹងកើនឡើងយ៉ាងខ្លាំង នៅក្នុងឆ្នាំថ្មីៗ ខាងមុខនេះ។ គម្រោងជាច្រើន ដែលឧបត្ថម្ភដោយរដ្ឋាភិបាល អាចត្រូវបានគេចាត់ទុកជា ការ វិនិយោគ ដែលមានសុវត្ថិភាព សំរាប់មូលនិធិភោគទ្រព្យអធិបតេយ្យ SWFs ទាំងនេះ ប្រសិនបើ កាលៈទេសៈ ត្រឹមត្រូវ។

១៣ *The Economist*, "Sovereign-wealth funds: Asset-backed insecurity," 17 January 2008, http://www.economist.com/finance/displaystory.cfm?story_id=10533428.

ការប្រើប្រាស់ អាយ ស៊ី ធី និង ការកើនឡើងកាបូនកម្រិតទាបរីសូន្យៈ តួនាទីនៃ អាយ ស៊ី ធី នៅក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន GHG និងការរួមចំណែក ក្នុងបំរែបំរួលអាកាសធាតុ គឺជាប្រធានបទមួយនៃ ការកើនឡើងនៃ ការស្រាវជ្រាវ និង ការពិភាក្សា។ យោងទៅលើមតិខ្លះៗ អាយ ស៊ី ធី អាចចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់ បន្ថយ ការបញ្ចេញ GHG និង ការប្រយុទ្ធប្រឆាំងជាមួយបំរែបំរួលអាកាសធាតុ។ ការប្រើប្រាស់ អាយ ស៊ី ធី អាច ជួយបន្ថយ ការប្រើប្រាស់សម្ភារះខ្លះៗ ( ឧទា, កិច្ចការជំនួញដែលគ្មានក្រដាស ) និងដូចច្នេះហើយ កម្រិតនូវផលប៉ះ ពាល់លើ បរិស្ថាននៃកំនើនសកម្មភាព និង ការប្រើប្រាស់របស់មនុស្ស។

ដោយយោងទៅលើ ការសិក្សាថ្មីមួយដែលរៀបចំដោយ វិទ្យាស្ថានអ្នកប្រើប្រាស់អាមេរិក និងនាយកដ្ឋានថាមពលសហរដ្ឋអាមេរិក,[១៤] ការកាត់បន្ថយការបញ្ចេញឧស្ម័ន GHG ដែល អាយ ស៊ី ធី អាចនាំយកមកបាននៅក្នុងសហរដ្ឋអាមេរិកគឺមានសារៈសំខាន់។រូបភាពទី៤ សង្ខេបនូវការរកឃើញពីការសិក្សានេះ។

### រូបភាពទី៤, ការកាត់បន្ថយការបញ្ចេញឧស្ម័ន GHG នៅក្នុង សហរដ្ឋអាមេរិក សំរាប់សកម្មភាពជម្រើស

(ប្រភព: Joseph P. Fuhr Jr. and Stephen B. Pociask, *Broadband Services: Economic and Environmental Benefits* (The American Consumer Institute, 2007), http://www.internetinnovation.org/Portals/0/Documents/Final_Green_Benefits.pdf)

The ITU - ផ្នែកការអភិវឌ្ឍន៏បំរែបំរួលបរិយាសកាស គឺប្រភពមួយទៀតនៃពត៍មានលើតួនាទីរបស់ អាយ ស៊ី ធី ក្នុងការសម្រាល និង ជួយសម្របសម្រួលទៅនិងបំរែបំរួលបរិយាសកាស។[១៥] The ITU ទទួលខុសត្រូវសំរាប់ ការអនុវត្តន៍ អនុសាសន៏ដែលទាក់ទងទៅនិង រដ្ឋាភិបាល-អេឡិចត្រូនិច ហើយនិងបញ្ហាផ្សេងៗទៀត ដែលបានធ្វើ ឡើងកិច្ចប្រជុំកំពូលពិភពលោក អំពីសង្គមពត៌មាន (WSIS)។

១៥ See ITU, “ICTs and e-Environment,” http://www.itu.int/ITU-D/cyb/app/e-env.html; and Green IT/Broadband and Cyber-infrastructure, http://green-broadband.blogspot.com.

តម្លៃដែលកើនឡើងនៃការធ្វើជំនួញក្នុងប្រទេសចិន និង ឥណ្ឌា : ប្រាក់ឈ្នួល និង តម្លៃផ្សេងៗនៃការធ្វើជំនួញក្នុង ប្រទេសចិន និង ឥណ្ឌា កំពង់តែកើនឡើង។ នេះ ជាសញ្ញាអោយឱកាសវិនិយោគ និង ជំនួញ សំរាប់ប្រទេស ជាច្រើន ក្នុងអាស៊ីដែលមានតម្លៃពលកម្មទាបជាង ( ឧទា, កម្ពុជា ឡាវ វៀតណាម និង ថៃ ) ។

## ២- បែបបទមូលនិធិផ្សេងៗគ្នា

ផ្នែកនេះមានគោលបំណងដើម្បី :

- ផ្តល់នូវទស្សនៈវិស័យនៃបែបបទមូលនិធិផ្សេងៗគ្នា សំរាប់ហេដ្ឋារចនាសម្ពន្ធ័ អាយ ស៊ី ធី និង គម្រោង ពាណិជ្ជកម្ម-អេឡិចត្រូនិច និង រដ្ឋាភិបាល-អេឡិចត្រូនិច
- គ្រោង នូវកត្តាផ្សេងៗដើម្បីពិចារណាក្នុងការជ្រើសរើសបែបបទមូលនិធិ និង
- ពិភាក្សា ថាកិច្ចសហការផ្នែកឯកជន និង ផ្នែកសារធារណៈ អាចត្រូវបានគេបង្កឡើងយ៉ាងដូចម្តេច ជាពិសេស តាមរយៈកិច្ចសន្ធនា ឯកជន-សារធារណៈ ។

### ២.១ ការវិនិយោគជាមួយ ចលនា អាយ ស៊ី ធី

តើរដ្ឋាភិបាលដូចម្តេចដែរ ចំពោះការទាក់ទាញការវិនិយោគ ដែលតម្រូវសំរាប់ការស្ថាបនាហេដ្ឋារចនាសម្ពន្ធ័ និង កិច្ចអនុវត្តន៏ ដែលនឹងពង្រឹងអត្ថប្រយោជន៍ប្រកួតប្រជែង នៅក្នុងសេដ្ឋកិច្ចពត៌មានសកល ?

ប្រសិនបើទីផ្សារ កំពង់តែដំណើរការ នៅក្នុងបែបផែន តម្លាភាព យុត្តិធម៌ និងបើកទូលាយ, មូលនិធិសំរាប់ ចលនា ហេដ្ឋារចនាសម្ពន្ធ័ អាយ ស៊ី ធី គឺទំនងជាអាចរកបាន។ ប្រសិនបើទីផ្សារធំល្មម ហើយមានការ ប្រកួតប្រជែងក្នុង ការផ្តល់ ហេដ្ឋារចនាសម្ពន្ធ័ និង សេវា, ការរួមបញ្ចូលការផ្តល់ ហេដ្ឋារចនាសម្ពន្ធ័គ្រឹះ អ៊ីនធរណែត ហើយនិងសេវា ពាណិជ្ជកម្ម-អេឡិចត្រូនិច និង រដ្ឋាភិបាល-អេឡិចត្រូនិច នឹងដើរតាមក្រោយ។

បញ្ហាគឺថា ប្រទេសដែលមានការអភិវឌ្ឍន៍ច្រើនបំផុត មិនមានមធ្យោបាយរីទីផ្សារដើម្បីធានាការប្រកួតប្រជែង នៅក្នុងការផ្តល់សេវា និង ហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៏ ដ៏ថ្លៃ។ នៅក្រោមកាលៈទេសៈនេះ រដ្ឋាភិបាលនឹង ត្រូវការ មានចំណែកក្នុងផ្តល់មូលនិធិដល់ហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៍ដែលនៅលើនោះសេដ្ឋកិច្ចពត៌មាន នឹងត្រូវបានគេស្ថាបនា។ រដ្ឋាភិបាលត្រូវការធានាផងដែរថា វិនិយោគសាធារណៈ ផ្តល់ប្រយោជន៍ដល់អ្នកប្រើ ប្រាស់ក្នុងចំនួនដ៏ធំសម្បើម និងដូចច្នេះហើយ មានភាពដែលអាចធ្វើបានដ៏ច្រើនបំផុត នៃការផ្សព្វផ្សាយ គោលដៅអភិវឌ្ឍន៍ជាតិ។ ប្រទេសជាច្រើនជាមួយនិង ហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៍កម្រិតខ្ពស់ និងអាច ឈានចូលបាន គឺជាកន្លែងដែលល្អជាងគេ សំរាប់ទាក់ទាញវិនិយោគ និង បំពេញសេដ្ឋកិច្ចពត៌មានសកល។ ទស្សនៈនៃបណ្តាញដែលបើកចំហ គឺផ្អែកទៅលើគំនិតមួយដែលថា ដើម្បីធ្វើអោយមានសុវត្ថិភាពការប្រើ ប្រាស់ដ៏មាន សក្តានុពលធំបំផុត នៃការវិនិយោគសារធារណៈជាមួយ ហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៏រដ្ឋាភិ បាលប្រគល់អាណត្តិ ការបែងចែករវាង ភាពជាម្ចាស់ និង ប្រតិបត្តិការណ៏នៃហេដ្ឋារចនាសម្ពន្ធ័ដឹកជញ្ជូន

ដូចជា ខ្សែកាបអុបទិកលើទស្សនះតែមួយ និងការផ្តល់សេវា Network លើទស្សនះផ្សេងទៀត។ នេះលើកទឹកចិត្តដល់ការប្រកួតប្រជែង ក្នុងការផ្តល់សេវា និងសំខាន់ជាងនេះទៅទៀត ធានាថា តម្លៃសំរាប់ការឈានចូល និងការប្រើប្រាស់ ហេដ្ឋារចនាសម្ពន្ធ័ គឺប្រកួតប្រជែង និងឆ្លុះបញ្ចាំងទុនប្រាកដ និងតម្លៃប្រតិបត្តិរបស់ហេដ្ឋារចនាសម្ពន្ធ័។

បណ្តាញដែលបើកចំហ អនុវត្តន៏ច្រើនបំផុតក្នុងយុត្តាធិការដែលគ្មាន រឺមានការប្រកួតប្រជែងតិចតួច ក្នុងការផ្តល់សេវាហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៏ ដូចជានៅក្នុងប្រទេសតូចនិងក្រីក្រ ប្រទេសដែលមិនជាប់សមុទ្រ និងរដ្ឋលើកោះតូចៗដែលកំពង់អភិវឌ្ឍន៏។ ប្រទេសទាំងនេះ ត្រូវបានកំណត់ចរិកលក្ខណះដោយការឈានចូល ដោយកំណត់ ទៅកាន់ ហេដ្ឋារចនាសម្ពន្ធ័គ្រឹះ (fibre) ដែលបណ្តាលអោយមាន តម្លៃខ្ពស់សំរាប់អ្នកប្រើប្រាស់ទាំង អស់ ដែលរួមបញ្ចូលអ្នកផ្តល់សេវាអ៊ីនធរណែតថ្នាក់ទី២។

នៅក្នុងបណ្តាញដែលបើកចំហ តម្លៃសំរាប់ការចូលទៅកាន់ហេដ្ឋារចនាសម្ពន្ធ័ ត្រូវបានកំណត់អោយទាបដូចដែល អាចធ្វើបាន ហើយអ្នកគ្រប់គ្នាបង់នូវតម្លៃដូចគ្នាសំរាប់ការចូលទៅកាន់ហេដ្ឋារចនាសម្ពន្ធ័ Network ។ នេះ ផ្តល់ សេរីភាពដល់អ្នកវិនិយោគ និង សហការីសេវាអេឡិចត្រូនិក ផ្តោតតែមួយគត់ទៅលើការផ្តល់សេវាទាំងអស់នេះ និងលើការប្រកួតប្រជែងជាមួយអ្នកផ្តល់សេវាផ្សេងៗទៀត នៅក្នុងទីលំហអ៊ីនធរណែតជាតិ។

បែបផែនអភិបាលកិច្ចដែលគេប្រើសំរាប់គ្រប់គ្រង បណ្តាញដែលបើកចំហ គឺមានសំខាន់។ ការរៀបចំអភិបាលកិច្ច និងការគ្រប់គ្រង ដែលមានតម្លាភាពនិងចំហ លើកទឹកចិត្ត ការវិនិយោគ និងការប្រកួតប្រជែង ដែលនឹងពង្រឹង យ៉ាងជោគជ័យ នូវបរិមាណនិងគុណភាពនៃសេវាដែលអាចរកបានចំពោះសារធារណះជន និងលើកទឹកចិត្តការប្រកួតប្រជែងតម្លៃ និងជាចុងក្រោយធ្វើអោយមានតំម្លៃទាប និងកែប្រែសេវា។ បែបផែនអភិបាលកិច្ចអាចរួមបញ្ចូលរដ្ឋាភិបាលដែលធ្វើជាធិបតេយ្យដោយគណៈកម្មការដឹកនាំ ឆ្អឹងខ្នងជាតិ រឺគណៈកម្មការដែលមានតំលៃស្មើរ ដែលបង្កើតឡើងដោយ អ្នកតំណាងអោយ វិស័យឯកជន និង សារធារណះរួមទាំងសហការី និង សមាជិករបស់ សង្គមស៊ីវិល និង សារធារណះជន។

បរិស្ថាននិយ័តកម្មទូរគមនាគមន៍ដ៏ខ្លាំងមួយ និងនិយតករដ៏ខ្លាំងម្នាក់គឺជាធាតុផ្សំយ៉ាងសំខាន់របស់ល្បាយនេះ។រដ្ឋាភិបាលត្រូវការរក្សា ហើយនិងពង្រឹង រឺដាក់វិធានការ នូវគោលនយោបាយសមរម្យជាច្រើន ដែលនឹងផ្តល់កម្លាំងដល់ យន្តការទីផ្សារ និង ការប្រកួតប្រជែងក្នុងការផ្តល់សេវាបញ្ជូនពត៌មានគ្មានខ្សែនិងថេរ។ រដ្ឋាភិបាលត្រូវធានាថាហេដ្ឋារចនាសម្ពន្ធ័គឺអាចរកបាននៅតំលៃទីផ្សារត្រឹមត្រូវយុត្តិធម៌ និងធានាថាសហការី

រឺ អ្នកដ៏ទៃទៀត ដែលកំពង់កាន់តំណែង ត្រូវបានទប់ស្កាត់ពីការបង្កើត ភាពផ្តាច់មុខដែលនឹងកម្រិត ជំរើស បង្កើនតម្លៃ និងរារាំងការបញ្ចោញ និងភាពដែលអាចរកបាននៃហេដ្ឋារចនាសម្ពន្ធ័ និង សេវា។

ជាសង្ខេប វាត្រូវបានគេយល់ព្រមជាទូទៅថា ដោយការអនុញ្ញាតិ និង ការលើកទឹកចិត្ត យន្តការទីផ្សារ និង ការប្រកួតប្រជែង តាមរយះការបង្កើតនៃ បរិស្ថានដែលអាចអោយធ្វើបានមួយ, រដ្ឋាភិបាល អាចផ្តល់កំលាំងវិនិយោគជាមួយការបញ្ចោញនៃហេដ្ឋារចនាសម្ពន្ធ័ អាយ ស៊ី ធី, ហេដ្ឋារចនាសម្ពន្ធ័ broadband និងគ្មានខ្សែយ៉ាងជាក់លាក់, និងសេវាផ្អែកលើ អាយ ស៊ី ធី ដែលរួមបញ្ចូល សេវាពាណិជ្ជកម្ម-អេឡិចត្រូនិក និងរដ្ឋាភិបាល-អេឡិចត្រូនិក។

ហេដ្ឋារចនាសម្ពន្ធ័ broadband ដែលនៅក្នុងទំរង់ បណ្តាញគ្រឹះខ្សែអុបទិក, ឧទាហរណ៏ បណ្តាញ broadband ល្បឿន លឿនគ្មានខ្សែ រួមទាំងបច្ចេកវិទ្យាផ្សេងៗទៀត ដូចជា DSL និង មានខ្សែ, គឺល្អបំផុត សំរាប់អោយផ្នែកឯកជន, លើកលែងតែក្នុងកាលៈទេសៈខ្លះ នៅពេលដែលវាមិនត្រូវបានគេចាត់ទុកថាមាននិរន្តន៏ភាពពាណិជ្ជកម្មសំរាប់ផ្នែកឯកជនដើម្បីស្ថាបនា ហេដ្ឋារចនាសម្ពន្ធ័ដូចនោះ (ឧទា, នៅក្នុងសហគមន៏ដាច់ស្រយាល ក្រីក្រ រឺ មានចំនួនប្រជាជនតិច ) ។ មូលនិធិ និង គោលនយោបាយចូលជាសកល ដ៏សមរម្យមួយ អាចត្រូវបានដាក់អនុវត្តន៍ ដើម្បីធានាថា ការឧបត្ថម្ភទុនជាសារធារណៈ អាចត្រូវបានប្រើដើម្បី លើកទឹកចិត្ត ដល់សហការីពាណិជ្ជកម្ម ដើម្បី ផ្តល់សេវានៅ ក្នុងទីតាំងដែលមិនត្រូវបានគេចាត់ទុកថាអាចបិតថេរ ផ្នែកពាណិជ្ជកម្ម។ មូលនិធិ និង គោល នយោបាយចូលជាសកល គឺមានប្រយោជន៍នៅក្នុងការពង្រីក ការឈានទៅដល់បណ្តាញទូរសព្ទ័ចល័ត និង ភាពអាច រកបាននៃសេវាអ៊ីនធរណែត។

## ២.២ ការផ្តល់មូលនិធិដល់សេវាផ្អែកលើ អាយ ស៊ី ធី

សេវា ទីផ្សារពាណិជ្ជកម្ម-អេឡិចត្រូនិក គឺជាឱកាសយ៉ាងសំខាន់ ដើម្បីទិញ និង លក់ទំនិញ ហើយនិង សេវា ដែល ត្រូវបានគេ ធ្វើអោយងាយស្រួល រឺ អនុញ្ញាតិតាមរយះការប្រើប្រាស់នៃ អាយ ស៊ី ធី។ នៅពេលដែល សកម្មភាព ពាណិជ្ជកម្ម-អេឡិចត្រូនិក មិនតម្រូវ នូវការវិនិយោគផ្នែកសារធារណៈដ៏រឹងមាំ ជាមួយនិង អាយ ស៊ី ធី នោះ, ពួកគេ តម្រូវថា រដ្ឋាភិបាល គួរតែបង្កើត ច្បាប់ និង បទបញ្ជាច្បាស់លាស់ និង អនុវត្តន៏យន្តការ ដើម្បីបង្កើត ការការពារ និង ការយល់ដឹងរបស់អ្នកប្រើប្រាស់ ហើយនិង បរិយាកាសទំនុកចិត្ត ក្នុងប្រតិបត្តិការណ៏ ពាណិជ្ជកម្ម- អេឡិចត្រូនិក។ ជាការពិត ទាំងនេះគឺជាការលំបាកធំបំផុតដែលប្រឈមមុខនិង ការយល់ដឹង ពាណិជ្ជកម្ម- អេឡិចត្រូនិក នៅក្នុងប្រទេសមួយចំនួន។ អ្នកប្រើប្រាស់ត្រូវតែបានធ្វើអោយជឿថា ពួកគេនឹងត្រូវបានការពារ នៅ ពេលទិញទំនិញតាមអ៊ីនធរណែត បើមិនដូចច្នេះទេ ពួកគេនឹងមិនទិញទេ។

ដើម្បីផ្តល់សេវាសារធារណៈ, រដ្ឋាភិបាល ជាប្រពៃណីបានពឹងផ្អែកទៅលើ ធនធានរដ្ឋាភិបាល ដែលជារឿយៗមាន ន័យថា ការរៃអង្គាសមូលនិធិតាមរយៈប្រភពជាធម្មតា – ពន្ធអាករ, ការដកពន្ធ, ការផ្តល់អជ្ញាបណ្ណ័រួម និងជំនួយអភិវឌ្ឍន៏នៅពេលដែលអាចធ្វើបាន។ ប៉ុន្តែការទាមទារបែបប្រកួតប្រជែង និងធនធានដែលមានកំណត់ដែលអាចរកបានដើម្បីផ្តល់មូលនិធិដល់សកម្មភាព រដ្ឋាភិបាល-អេឡិចត្រូនិក, ឆាកមូលនិធិផ្សេងៗទៀត គួរតែ ត្រូវបានពិចារណា។

ផ្នែកសារធារណៈ អាចទទួលប្រយោជន៏យ៉ាងធំពីដំណោះស្រាយមូលនិធិផ្សេងៗទៀត បើរដ្ឋាភិបាល និងផ្នែកសារធារណៈ បានរៀបចំដេម្បិពីចិរាណារ ការនាំយកដៃគូ ផ្នែកឯកជន ទៅកាន់តុចរចារ ដើម្បីទាញយកធនធាន ហិរញ្ញវត្ថុ, បច្ចេកទេស និង ជំនាញ របស់ពួកគេ។ ដោយផ្អែកទៅលើភាពបន្ទាន់នៃ កិច្ចការសារធារណៈ ដែលតម្រូវ អោយពេញលេញ និង ធនធានហិរញ្ញវត្ថុ និងដ៏ទៃទៀត តាមអំណាចរបស់ពួកគេ, រដ្ឋាភិបាលអាចមាន អារម្មណ តិ៏ច រឺ ច្រើនមានទំនោរ ទៅសហការជាមួយទុនផ្នែកឯកជន ដើម្បីផ្តល់មូលនិធិ និង អនុវត្តន៏ សេវា សារធារណៈ ។

ហិរញ្ញប្បទានផ្នែកឯកជនជាប្រពៃណីបានមកពី ផ្នែកឯកជនដោយផ្ទាល់, ដោយរួមមកពីប្រភព ដូចជាការវិនិយោគផ្ទាល់បរទេស (FDI)។ នៅក្នុងករណីនេះ, តម្រូវការទីផ្សារតម្រូវថាតើវិនិយោគ នឹងកើតឡើងរឺអត់។ផែនការជំនួញត្រូវបានគេធ្វើឡើង ដែលបានដាក់ចេញនូវជំរើសជាច្រើន សំរាប់ការធ្វើអោយល្អប្រសើរឡើងវិញនូវ វិនិយោគ និង បង្កើតប្រាក់ចំណេញ។

ហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៏ និង សេវា រដ្ឋាភិបាល-អេឡិចត្រូនិច គឺត្រូវបានគេចាត់ទុកថាមានសក្តានុពលធំបំផុត សំរាប់ការផ្តល់មូលនិធិផ្នែកឯកជន ពីព្រោះពួកគេមានទំហំធំ និងជាក់ស្តែង ហើយនៅក្នុងប្រទេសតូចមួយចំនួន ពួកគេពេលខ្លះត្រូវបានគេដំណើរការជា ភាពផ្តាច់មុខ។ ដោយសារតែអ្នកប្រតិបត្តិទូរគមនាគមន៏មួយចំនួនធំ បង្កើតប្រាក់ចំណេញ, ការវិនិយោគជាមួយ ហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៏ ត្រូវបានគេចាត់ទុកថាជា ការវិនិយោគដ៏ល្អមួយ ដែលទំនងជាឆាប់រហ័ស។ គម្រោងហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៏ នឹងទាក់ទាញមូលនិធិ ពីប្រភពមូលនិធិធម្មតា និងប្រភពផ្សេងៗដ៏ទៃទៀតជាច្រើន។ គម្រោងរដ្ឋាភិបាល-អេឡិចត្រូនិច ត្រូវបានគេ ដំណើរការលើមូលដ្ឋានផ្តាច់មុខ ផងដែរ ហើយពួកវាអាចទាក់ទាញចំណាប់អារម្មណ៏ពិណិជ្ជកម្មដ៏ខ្លាំងក្លាសំរាប់ បញ្ហានេះ និង ផ្សេងៗទៀត។

ការផ្តួចផ្តើម ពាណិជ្ជកម្ម-អេឡិចត្រូនិច នឹងត្រូវបានអភិវឌ្ឍន៏ដោយគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើន និងអ្នកប្រតិបត្តិ ផ្នែកឯកជន ដែលមានបំណងទាញផលប្រយោជន៏ពី ឱកាសទីផ្សារ និង តម្រូវការ សំរាប់ ទំនិញ និង

សេវា។ វាមិន ទំនងថា ផ្នែកសារធារណៈ នឹងផ្តល់មូលនិធិដល់ ការផ្តួចផ្តើម ពាណិជ្ជកម្ម-អេឡិចត្រូនិច ដោយផ្ទាល់ទេ, ប៉ុន្តែ រដ្ឋាភិបាលអាចអនុវត្តន៏ សេវា និង យន្តការ ផ្សេងៗដែលអាចលើកទឹកចិត្តផ្នែកឯកជន អោយ ចាប់អារម្មណ៍ ពាណិជ្ជកម្ម-អេឡិចត្រូនិច។ ប្រពន្ធ័ទិញទំនិញ-អេឡិចត្រូនិច គឺជាយន្តការបែប ហ្នឹងមួយ។

## ២.៣ បែបបទ សំរាប់ការផ្តល់មូនិធិគម្រោង អាយ ស៊ី ធី

មានប្រភេទផ្សេងៗគ្នា នៃបែបបទផ្តល់មូលនិធិ ដែលផ្អែកទៅលើការអនុវត្តន៏គម្រោង។ បែបបទ និងវិធី សាស្រ្តសំខាន់ៗជាច្រើន ត្រូវបានគេគ្រោងដូចខាងក្រោមនេះ :

### រដ្ឋាភិបាលជាអ្នកផ្តល់មូលនិធិតែមួយគត់

រដ្ឋាភិបាលអភិវឌ្ឍន៏ផែនការផ្សេងៗ, កម្មវិធីនិងគម្រោង ផ្សេងៗ, ថវិកាសំរាប់អនុវត្តន៏ការងារ ហើយនឹង ប្រមូលពន្ធអាករ សំរាប់ហិរញ្ញប្បទានការងារ។ រដ្ឋាភិបាល ជាម្ចាស់ និងអនុវត្តន៏ គម្រោងនេះរួមបញ្ចូលទាំង គម្រោង ដែលផ្តល់មូលនិធិដោយអ្នកបរិច្ចាគអន្តរជាតិ ដែលរកមូលនិធិតាមរយះដៃគូផ្នែកសារធារណៈនៅ ក្នុងប្រទេសកំពង់អភិវឌ្ឍន៏ជាច្រើន។

រដ្ឋាភិបាលមានផែនការអភិវឌ្ឍន៏មួយ និង ថវិការមួយ ហើយអនុវត្តន៏ គម្រោងដោយប្រើ និតិវិធីល្អៗដែលបាន បង្កើតឡើង និងព្រមព្រៀងគ្នា។ ជាឧទាហរណ៏, រដ្ឋាភិបាល រឺ ក្រសួង មាន ផែនការរដ្ឋាភិបាល-អេឡិចត្រូនិចមួយ ដើម្បីបានហរិញ្ញប្បទាន តាមរយះរតនាគារជាតិ។ ក្រុមហ៊ុនឯកជន ត្រូវបានចុះកិច្ចសន្យា ដើម្បីផ្តល់សេវា អោយស្របទៅតាម។ ផ្នែកសារធារណៈ មិនគ្រាន់តែ ពិនិត្យពិច័យការងារដោយផ្ទាល់ទេ ប៉ន្តែមានភាពជាម្ចាស់ ពេញលេញ និង ការត្រួតត្រានូវរាល់ទិដ្ឋភាពទាំងអស់ របស់គម្រោងផងដែរ។ផ្នែក សារធារណៈអាចជ្រើសរើស ផងដែរ ដើម្បីរក្សាទុក អ្នកប្រតិបត្តិផ្នែកឯកជន លើមូលដ្ឋាន ដែលមាន កិច្ចសន្យាមួយ ជាមួយនិងការទទួល ខុសត្រូវសំរាប់ការចែកចាយ សេវា និងទំនិញ ជាកលាក់ដោយយោង ទៅលើកិច្ចសន្យាដែលបានព្រមព្រៀង។ផ្នែកឯកជន មានតួនាទី តិចតួច រឺក៏គ្មាន ក្នុងការអភិវឌ្ឍន៏ និងការរៀបគម្រោង។ ទស្សនៈទាន និង ការរៀបចំ គម្រោង គឺជាការទទួលខុសត្រូវតែមួយគត់របស់អ្នក ប្រតិបត្តិផ្នែកសារធារណៈ ដែលជាម្ចាស់ និង អនុវត្តន៏គម្រោង ជាគោល សំរាប់ប្រយោជន៏សារធារណៈ។ ក្នុងករណីនេះ រដ្ឋាភិបាលសន្មតជាមុន នូវហានិយភ័យទាំងអស់របស់ គម្រោង។

## បែបបទផ្តល់មូលនិធិផ្សំ

ទាំងនេះរួមបញ្ចូល ការរៀបចំដែលមានកិច្ចសន្យាផ្សេងៗ និងចំណាយដែលរួមចំណែក ដែលមួយភាគធំ មូលនិធិបានមកពី ផ្នែកសារធារណៈ ហើយ រដ្ឋាភិបាល ជាម្ចាស់ សេវា រឺ ផលិតផល រឺក៏ហេដ្ឋារចនាសម្ពន្ធ័។ ផ្នែក ឯកជន អាចមានតួនាទីសំខាន់ដើម្បីសំដែង ការអនុវត្តន៍ និង ប្រតិបត្តិការណ៍ក្នុងគម្រោងបែបទាំងនោះ។

នៅក្នុងបែបបទនេះ, មិនមានសម្បទានសេវាសារធារណៈ ដល់អ្នកប្រតិបត្តិភាគីទីបីទេ ទោះបីជាភាគីទីបី អាចផ្តល់ សេវាក៏ដោយ វានៅតែគេចាត់ទុកថាជាកិច្ចប្រតិបត្តិការណ៍របស់រដ្ឋាភិបាល។ កិច្ចប្រតិបត្តិការណ៍ របស់សេវា សារធារណៈ អាចត្រូវគេចុះកិច្ចសន្យា ជាមួយអ្នកប្រតិបត្តិផ្នែកឯកជនលើមូលដ្ឋានកិច្ចសន្យាមួយ ប៉ុន្តែរដ្ឋាភិបាល នៅតែរក្សា ការគ្រប់គ្រងទូទៅ និង ភាពជាម្ចាស់ នៅគ្រប់ដំណាក់កាលទាំងអស់នៃគម្រោង។

## សម្បទានដល់ផ្នែកឯកជន

នៅក្នុងវិធីសាស្ត្រនេះ, អង្គភាពសារធារណៈ ចរចារ សម្បទានទៅដល់អ្នកប្រតិបត្តិផ្នែកឯកជនមួយ រឺ ច្រើន ដើម្បី ស្ថាបនា, ធ្វើជាម្ចាស់ និង ប្រតិបត្តិ, រឺផ្ទេរសេវាសារធារណៈ នៅក្រោមលកខណ្ឌ័ដែលបាន ព្រមព្រៀងដែលអាចរួមទាំងការបញ្ចូលគ្នានៃ ភាពជាម្ចាស់ និង កិច្ចប្រតិបត្តការណ៍។ ផ្នែកសារធារណៈ អាច រឺ មិនអាច លៃលកថវិការ សំរាប់មួយផ្នែកនៃគម្រោង។ ផ្នែកឯកជន សន្មតជាមុន មួយផ្នែកធំបើមិនទាំងអស់ ចំពោះហានិយភ័ហិរញ្ញវត្ថុ, និងប្រតិបត្តិ រឺធ្វើជាម្ចាស់សម្បទានក្រោមកិច្ចសន្យាជាមួយផ្នែកសារធារណៈ សំរាប់កំឡុងពេលដ៏ជាក់លាក់មួយ។ នេះជាធម្មតា អនុវត្តន៏ចំពោះគម្រោង “Greenfield” ដែលជាគម្រោង មិនមានដាក់កំហឹតដោយការងារអទិភាព។

ភាពជាដៃគូរឯកជន-សារធារណៈលើសម្បទាន (PPPs) ត្រូវការ ទំនាក់ទំនងការងារយ៉ាងជិតស្និត រវាងដៃ គូរទាំងអស់រួមទាំងការត្រួតត្រាយ៉ាងខ្លាំងក្លានិងភ្ជាប់ភ្ជួន។ពួកគេអោយទាក់ទាញវិនិយោគផ្ទាល់បរទេស(FDI) ពីព្រោះ ក្នុងករណីជាច្រើន អ្នកផ្តល់សេវាផ្នែកសារធារណៈ (ឧ. រដ្ឋាភិបាល ) ប្រើអំណាចទីផ្សារក្នុងការ ផ្តល់សេវាសារធារណៈ។ ជាធម្មតា គ្មានការប្រកួតប្រជែងសំរាប់សេវាទាំងអស់នេះ និងគ្មានអ្នកផ្តល់សេវា ផ្សេងទៀតទេ ដូច្នេះសារធារណៈជនត្រូវតែប្រើប្រាស់នូវសេវា។ ដូចនេះហើយសំរាប់អ្នកវិនិយោគផ្នែក ឯកជន, ការធានា សេវា បែបនេះ អាចជា ឱកាសដ៏ខ្ពស់ដែលអាចស្របតាមបំណង ដើម្បីប្រាក់ចំណេញ។ សំរាប់សារធារណៈជន, ការរៀបចំ បែបនេះ អាចចាត់ទុកជាគ្រោះថ្នាក់មួយ នៅពេលតម្លៃដ៏ខ្ពស់ មួយត្រូវបានគេគិត សំរាប់សេវានេះ។ ចំណាប់ អារម្មណ៏ទៅលើភាពស្មើរគ្នាដ៏ត្រឹមត្រូវ គឺសំខាន់។

**ពហុម្ចាស់ភាគហ៊ុន ភាពជាដៃគូរឯកជន-សារធារណៈលើសម្បទាន** (PPPs)

ដៃគូរបីបួនផ្សេងៗ គឺបានទាក់ទងក្នុងការរៀបចំទាំងនេះ, ដែលរួមបញ្ចូលផ្នែកឯកជន និងសារធារណៈ, សង្គមស៊ីវិល, ម្ចាស់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាល (NGOs) ។[១៦] គំរូ គឺជាគម្រោងដើម្បីអភិវឌ្ឍន៍ ការសម្រួល ការឈានចូលទៅក្នុងសហគមន៍ រឺទូរមណ្ឌល, រឺគម្រោងការឈានចូលទៅក្នុងសកល។ នៅក្នុងគម្រោងទាំងអស់ នេះ ភាពស្មុគស្មាញនៃការប្រឹក្សា និង ដំណោះស្រាយ ដែលត្រូវបានផ្តល់ ត្រូវការ វិធិសាស្រ្តពហុម្ចាស់ភាគហ៊ុន។

ប្រភពសក្តានុពល នៃមូលនិធិសំរាប់ប្រភេទរបស់ ភាពជាដៃគូរឯកជន-សារធារណៈលើសម្បទាន PPP រួមមាន FDI និង SWF ។មូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបែបបទនេះត្រូវបាន លើកទឹកចិត្តយ៉ាងខ្លាំងពីម្ចាស់ជំនួយ គឺថាវាពឹងផ្អែកទៅលើសមត្ថភាពនៃដៃគូរក្នុងស្រុកទាំងអស់។ ដោយ ផ្តោតទៅលើលទ្ធផលដែលអាចវាស់បានផ្ទុយទៅនិងទិន្នផល, គម្រោងនេះ គឺជាក់ស្តែងជាងរួមទាំងអាច សម្របបានជាង ទៅនិងស្ថានភាព និង លក្ខណ្ឌ ដែលផ្លាស់ប្តូរ ហើយនិងឆ្លើយតបច្រើនជាង ទៅនិងបញ្ហា នៅពេលពួកគេកើតឡើង។

បែបបទមូលនិធិនេះលើកទឹកចិត្តផងដែរ ដល់ការកើនឡើងសំរាប់ភាពក្រីក្រ រឺការអភិវឌ្ឍន៍សេដ្ឋកិច្ចដែល ផ្តោតទៅលើប្រជាជនក្រីក្រ។ ភាពជាដៃគូរឯកជន-សារធារណៈលើសម្បទាន PPPs ជាទូទៅផ្តល់នូវ អត្ថប្រយោជន៏ប្រាកដ សំរាប់ការសំរេចបានរបស់ MDGs ។ ពួកគេអាចនឹងជួយ ប្រទេសក្រីក្រដើម្បីសំរេច :

- គោលដៅអភិវឌ្ឍន៍ ជាច្រើនសន្ទឹកសន្ទាប់
- ប្រាក់ចំណេញហិរញ្ញវត្ថុដែលបិតថេរ
- ការពង្រឹងស្ថាបន័ និង ភាពអាចទ្រទង់ នៃការចំណាយ និង ការអភិវឌ្ឍន៍ លទ្ធផល
- ការផ្តោតយ៉ាងខ្លាំងទៅលើភាពក្រីក្រ
- ការគាំទ្រដ៏ធំជាសាធារណៈ និង នយោបាយ
- ម៉ែត្រសាស្រ្ត និង រចនាសម្ពន្ធ័គ្រប់គ្រងគម្រោងផ្អែកលើការប្រពឹត្ត, រួមទាំងប្រសិទ្ធភាពក្នុងការគ្រប់គ្រង គម្រោង រឺ ការគ្រប់គ្រងផ្អែកលើលទ្ធផល (RBM)

---

១៦ World Economic Forum, *Building on the Monterrey Consensus: The Growing Role of Public-Private Partnerships in Mobilizing Resources for Development* (Geneva: World Economic Forum, 2005), http://www.weforum.org/pdf/un_final_report.pdf.

គម្រោងឈានចូលសកល, ជាឧទាហរណ៍ , ត្រូវបានគេនាំទៅ ចំពោះអ្នកប្រើប្រាស់នៅក្នុង ទីកន្លែងដែលក្រីក្រ និងដាច់ស្រយាលដែលក្រីក្រជាង សហគមន៍ដ៏ទៃទៀតនៅក្នុងប្រទេស រឺក៏យត្តាធិកាដែល ត្រូវយកមកគិត។ សំរាប់មូលហេតុនេះ និងដ៏ទៃទៀត សហគមន៍នេះអាចនឹងមិនត្រូវបានបំរើដោយអ្នកផ្តល់សេវា និងអ្នកប្រតិបត្តិទូរគមនាគមន៍ជាតិ។គោលនយោបាយឈានចូលសកលដែលគាំទ្រដោយមូលនិធិឈានចូលសកល (UAF) ត្រូវបានគេតម្រូវអោយផ្តល់មូលនិធិដល់ ការផ្តល់សេវាអ៊ីនធរណែត និងសំលេងទៅដល់សហគមន៍ទាំងអស់នេះ។ អ្នកផ្តល់សេវាទូរគមនាគមន៍ចល័ត និងផ្សេងៗទៀតត្រូវបានលើកទឹកចិត្តអោយដេញថ្លៃ ដើម្បីទទួលមូលនិធិពី UAF ដើម្បីផ្តល់សេវាដែលចាំបាច់លើមូលដ្ឋានពាណិជ្ជកម្មមួយ នៅក្នុងសហគមន៍ដែលពាក់ព័ន្ធ។ ប្រភេទនៃគម្រោងនេះ ទាក់ទងកិច្ចសហការ រវាងផ្នែកសារធារណៈ និងឯកជនក្នុងការផ្តល់សេវាទូរគមនាគមន៍ជាគោល។

## វិភាគទានជួយជនក្រីក្រ ដោយផ្នែកឯកជន

បែបបទផ្តល់មូលនិធិមួយទៀត គឺផ្អែកលើវិភាគទានជួយជនក្រីក្រ ដោយក្រុមហ៊ុនធំៗ, យ៉ាងជាក់លាក់ សារជីវកម្មដែលទាក់ទងពហុជាតិ (TNCs)។ បែបបទផ្តល់មូលនិធិនេះ ត្រូវបានគេចាត់ទុកផងដែរជាភាពខុសគ្នាលើពហុម្ចាស់ភាគហ៊ុន PPP ។

អង្គការជួយជនក្រីក្រឧបត្ថមដោយ អ្នកជំនួញដ៏ជោគជ័យ រួមមាន :

- Ford Foundation
- Rockefeller Foundation
- The Bill and Melinda Gates Foundation ( 25 កោដិដុល្លាអាមេរិក ក្នុងមូលនិធិសំរាប់ សុខភាព និង ការអប់រំ )
- Private voluntary agencies and foundations in OECD Development Assistance Committee ( DAC ) member countries ( ជំនួយពីប្រភពទាំងនេះ បានកើនឡើងពី 8.8 កោដិដុល្លាអាមេរិក ក្នុងឆ្នាំ ២០០២ រហូតដល់ 14.6 កោដិដុល្លាអាមេរិកក្នុងឆ្នាំ ២០០៦ )[១៧]

វិភាគទានជាប្រាក់សុទ្ធជាក្រុម គឺត្រូវបានចាត់ទុកផងដែរ ថាជាប្រភពសំខាន់នៃមូលនិធិ។ វាត្រូវបានគេប៉ាន់

---

១៧ OECD, *Development Co-operation Report 2007: Summary* (Paris: OECD, 2008), 3, http://www.oecd.org/dataoecd/21/10/40108245.pdf.

ស្មានថា បណ្តាក្រុមហ៊ុន Fortune 500 Global តែឯង ធ្វើការបរិច្ចាគជាប្រាក់សុទ្ធប្រហែល 12 កោដិដុល្លាអាមេរិក និងរវាង 10-15 កោដិដុល្លាអាមេរិក ក្នុងប្រភេទបរិច្ចាគរាល់ឆ្នាំ។[១៨]

ការជួយជនក្រីក្រជាក្រុម ត្រូវបានភ្ជាប់ទៅ ផលិតផល រឺ ប្រតិបត្តិការណ៍ទីផ្សារ។ ដូចន្នេះហើយវិភាគទាននៅក្នុងប្រទេសក្រីក្រទំនងជាតិចតួចជាង ពីព្រោះទីផ្សារតូចជាង រឺ ក្រីក្រជាង។ ទោះបីជាយ៉ាងណាក៏ដោយ មូលនិធិទាំងអស់នេះ គឺជាប្រភពសំខាន់នៃការផ្តល់ហិរញ្ញប្បទាន នៅពេលប្រៀបធៀបជាមួយ FDI រឺជំនួយអភិវឌ្ឍន៏។ វាត្រូវបានគេប៉ាន់ស្មានថា 10 -15 ភាគរយ នៃវិភាគទានសកល សរុប ដោយបណ្តាក្រុមហ៊ុន Fortune 500 Global បានឆ្ពោះទៅកាន់ ប្រទេសដែលមានប្រាក់ចំណូលទាបជាច្រើន។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីដែលបានកើនឡើងយ៉ាងច្រើន អ្នកប្រតិបត្តិផ្នែកឯកជន ដឹងថាពួកគេត្រូវការធ្វើការយ៉ាងជិតស្និទជាមួយនិង ប្រជាជន និងសហគមន៏ក្នុងស្រុក ដើម្បីអោយការវិនិយោគរបស់ពួកគេមានផ្លែផ្កា។ក្នុងករណី ក្រុមហ៊ុនប្រេងជាច្រើន, ជាពិសេស Shell, ដែលដំណើរការនៅក្នុងតំបន់ទន្លេ Niger ប្រទេសនីហ្សេរីយ៉ា គឺជាគំរូចំបង។ ចលាចលសង្គម គឺត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនិង ការធ្វើអាជីវកម្មប្រេងនៅតាមដងទន្លេក្នុង សហគមន៏ជាច្រើនដែលមានអារម្មណ៏ថា ពួកគេត្រូវបានគេបំបិទសិទ្ធ។ សារជីវកម្មទាំងអស់ ត្រូវទទួលស្គាល់ សារៈសំខាន់នៃការទទួលបាន ការគាំទ្រក្នុងស្រុក ដើម្បីជានាការវិនិយោគរបស់ពួកគេ។

ហរិញ្ញប្បទានជាច្រើនមកតាមរយៈ ការបរិច្ចាគដល់គម្រោងសង្គម នៅថ្នាក់សហគមន៏ និង ក្នុងស្រុក។ ខាងក្រោមនេះ គឺគ្រាន់តែជាគំរូដ៏តូចមួយ :

- Tata នៅឥណ្ឌា ផ្តល់ ២,៧ ភាគរយ នៃប្រាក់ចំណោញសរុប និង Pakistan Telecom ផ្តល់ 0,0៧៤ ភាគរយ។

- Cisco ផ្តល់វិភាគទាន ដល់ ការស្ថាបនាសមត្ថភាព អាយ ស៊ី ធី តាមរយៈ Cisco Academy, ដែលបានបណ្តុះបណ្តាលអ្នកជំនាញ អាយ ស៊ី ធី ជាច្រើន នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៏។

---

១៨ World Economic Forum, op. cit., 27.

- នៅក្នុងទសវត្សរ៍ ១៩៩០ Hewlett Packard (HP) ជាដៃគូរជាមួយនិង អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្នុងការបង្កើត អោយមានសម្ភារៈ និងការគាំទ្រក្នុងទំរង់ផ្សេងៗទៀតសំរាប់កម្មវធីបណ្តាញអភិវឌ្ឍន៍ទ្រទ្រង់ (SDNP)។ នៅក្នុងប្រទេសជាច្រើន ដែលជាផ្នែករបស់ SDNP, HP បានផ្តល់សម្ភារៈ និងការបណ្តុះបណ្តាល ជាច្រើន។ វិភាគទានទាំងអស់នេះ ត្រូវបានគេចាត់ទុកថាជាអំណោយ។ UNDP និង HP ត្រូវតែបង្កើតដំបូងនូវមូលដ្ឋាននៃការសហការណ៍ និង បានព្យាយាមចាប់ផ្តើមការពិភាក្សាយ៉ាងស្វិតស្វាញ និងការចរចារដើម្បីជានាអព្យាក្រឹតភាព ដើម្បីប្រាកដថា គម្រោងនឹងមិនត្រូវបានឃើញថាផ្ទុយទៅ និងផលប្រយោជន៏ដ៏ល្អបំផុតរបស់ម្ចាស់ភាគហ៊ុន និងក្រុមអ្នកចូលរួមវិភាគទាន។

- នៅក្នុងប្រទេស Trinidad និង Tobago, ក្រុមហ៊ុន BP បានប្រកាសថា ក្រុមហ៊ុននិងវិនិយោគ ១០ លានដុល្លារអាមេរិក ជាមួយនិង សកលវិទ្យាល័យថ្មីរបស់ Trinidad និង Tobago ដែលផ្តោតលើការអភិវឌ្ឍន៏ ការស្រាវជ្រាវដែលមានគុណភាពខ្ពស់ ក្នុងផ្នែកវិទ្យាសាស្រ្ត និង បច្ចេកវិទ្យា។[១៩] ក្រុមហ៊ុន BP កំពង់មានផែនការដើម្បីវិនិយោគ ប្រហែល ៥០០ លានដុល្លារអាមេរិក នៅក្នុងឆ្នាំថ្មីបន្តបន្ទាប់ជាលទ្ធផលនៃការយល់ដឹងដែលកើនឡើង ពីការប្រកួតប្រជែង និងគោលការណ៍ អភិវឌ្ឍន៍សកលដែលការអភិឌ្ឍន៍ពាណិជ្ជកម្ម គឺជាផ្នែកមួយផងដែរ ក្នុងផ្នែកធំទាំងមូល។

- Barrick Gold អ្នកផលិតមាសដ៏ធំបំផុតមួយនៅលើពិភពលោក បានវិនិយោគ ៣,៤ លានដុល្លារអាមេរិក ជាមួយនិងបំពង់ទីបទឹកដែលមានប្រវែង ៤៧ គ,ម នៅប្រទេស Tanzania ។[២០]

ផ្អែកទៅលើភស្តុតាងដែលមាន វាអាចនិយាយថា ប្រហែល ១០-១៥ ភាគរយនៃវិភាគទានទាំងអស់ បានមកពីបណ្តាក្រុមហ៊ុន Fortune Global 500, រឺ កន្លែងផ្សេងៗទៀតចន្លោះពី ២ កោដិដុល្លារអាមេរិក ទៅ ៤ កោដិដុល្លារអាមេរិក ត្រូវបានគេបរិច្ចាគទៅដល់សកម្មភាពផ្សេងៗនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប។ ប្រសិនបើ ការបរិច្ចាគរបស់ TNCs, ក្រុមហ៊ុន ធំៗ ក្នុងតំបន់ រឺក្នុងប្រទេស និង ការបរិច្ចាគរបស់ឯកជនដោយផ្ទាល់ គឺត្រូវបានគេរាប់បញ្ចូលផងនោះ, ការបរិច្ចាគដោយផ្នែកឯកជន ទំនងជាធំជាង FDI ។[២១]

---

១៩ *bpTT Insider*, “Lord Browne visits Trinidad and Tobago,” Issue 7, July 2004, http://www.bp.com/liveassets/bp_internet/globalbp/STAGING/global_assets/downloads/B/bp_Insider_7.pdf.
២០ World Economic Forum, op. cit., 26.
២១ Ibid., 29.

សំរាប់បណ្តាក្រុមហ៊ុនដែលដំណើរការនៅក្នុងប្រទេសកំពង់អភិវឌ្ឍន៏, វិនិយោគសង្គមនាំមកអានុភាពសំខាន់ជាសក្តានុពល សំរាប់ក្រុមហ៊ុនក្នុងការសំរេចគោលបំណងរបស់គេ នៅក្នុងប្រទេស។

**‘ប្រភពល្អបំផុត’ ផ្អែកទៅលើការសាកល្បងទីផ្សារ**

នៅក្នុងប្រភពល្អបំផុត រដ្ឋាភិបាល ដាក់ស្នើរនូវសំណើរ សំរាប់ការផ្តល់សេវា និង ប្រកួតប្រជែងទីផ្សារ ដើម្បីនឹក ឃើញ ដំណោះស្រាយដែលមានប្រសិទ្ធភាពខ្ពស់បំផុតដែលអាចធ្វើបាន នៅពេលធ្វើអោយច្បាស់ រឺ ធ្វើអោយលើស ភាពជាក់លាក់ដែលតម្រូវ សំរាប់សេវា រឺ ផលិតផលដែលគេស្វែងរក។ នេះគឺជាឆាកប្រកួតប្រជែងខ្លាំងមួយ ដែលការសាកល្បងទីផ្សារ គឺជាឱកាសមួយដើម្បីមើលនូវ អ្វីដែលទីផ្សារ នឹងផ្តល់អោយ ហើយនិងអ្វីដែលគំនិតផ្តួចផ្តើម អាចត្រូវបានគេគិតឡើង ដើម្បីផ្តល់សេវាសារធារណៈដែលគេស្វែងរកក្នុងតម្លៃថោកបំផុតទៅដល់សារធារណៈជន និង អ្នកបង់ពន្ធ។ ក្នុងន័យនេះ អង្គភាពរដ្ឋាភិបាល ធ្វើការតាមរយៈក្រុមប្រឹក្សាដឹកនាំជាតិ រឺក៏ ក្រុមដែលមានតម្លៃ ស្មើរ ដើម្បីពិនិត្យមើលនូវ អ្វីដែលផ្នែកឯកជន នឹងស្នើរសុំ។ ការជ្រើសរើសគឺផ្អែកលើ តំលៃល្អបំផុតរបស់ប្រាក់ ដែលគាំទ្រដោយគុណភាពនៃសំណើរបច្ចេកទេស។

រដ្ឋាភិបាលសាំងហ្គាពួរបានទទួលយកយុទ្ធសាស្រ្តនេះរបស់ប្រភពល្អបំផុតតាមរយះការសាកល្បងទីផ្សារ។ ប្រសិនបើក្រុមហ៊ុនឯកជនអាចចែកចាយសេវាថោកជាង និង មានប្រសិទ្ធភាពជាង ផ្នែកសារធារណៈនោះ វាត្រូវបានជួលអោយធ្វើការងារ។ នាយកដ្ឋានរបស់រដ្ឋាភិបាល នឹងត្រូវតែធ្វើអោយមានយុត្តធម៌ដល់ស្ថេរភាពរបស់ពួកគេ ដោយ ការប្រកួតប្រជែងផងដែរ ជាមួយនិង អ្នកប្រតិបត្តិ និង អ្នកផ្តល់សេវាផ្នែកខាងក្រៅ ដើម្បីសំរេចការងារ។ ផងដែរ វា អាចលើកទឹកចិត្តដល់ ភាពជាដៃគូរជាមួយផ្នែកឯកជន និងធ្វើអោយផ្នែកសារធារណៈមានការប្រកួតប្រជែង និង មានផ្លែផ្កាច្រើនជាងមុន ក្នុងដំណើរការរយះពេលយូរអង្វែង។ ផលប្រយោជន៏ រឺ សុពលភាព រយះពេលវែង របស់វិធីសាស្រ្តនេះ នៅតែរក្សាអោយគេឃើញ ប៉ុន្តែគំនិតវិញគឺពិតជារឿងស្រមើរស្រមៃមួយ។

## ២.៤ ការជ្រើសរើសនូវជម្រើសមូលនិធិមួយ

ជម្រើសមូលនិធិនិមួយៗ ដែលបានបង្ហាញនៅក្នុងផ្នែកផ្សេងៗ មានគុណសម្បត្តិ និងគុណវិបត្តិជាច្រើន។ ការជ្រើសរើសនូវជម្រើសមូលនិធិណាមួយ ដើម្បីបន្ត នឹងត្រូវបានគេធ្វើ ដោយយោងទៅលើការយល់ឃើញជាក់ស្តែង។ទាំងនេះត្រូវបានគេពិភាក្សាដូចខាងក្រោមៈ

### កំរិតនៃតម្រូវការ

តម្រូវការបន្ទាន់មួយ សំរាប់ហេដ្ឋារចនាសម្ពន្ធ័ រឺ សេវា ដែលប្រភពមូលនិធិធម្មតាមិនអាចរកបាន ធ្វើអោយឈុត ឆាកហិរញ្ញប្បទានផ្សេងៗ ក្លាយជាជម្រើសមួយ។ ប្រសិនបើបរិយាកាសជំនួញ នាំអោយមាន លទ្ធផលដល់ការវិនិយោគផ្នែកសារធារណៈ និង ការធ្វើជំនួញ ហើយនិងមានឱកាសពាណិជ្ជកម្មពិតប្រាកដមួយ នោះផ្នែកឯកជន នឹងមានចំណាប់អារម្មណ៍។

### ការបែងចែក ការរាលដាល រឺ ការជៀសវាង ហានិភ័យ

មួយក្នុងចំណោមមូលហេតុសំខាន់ៗ សំរាប់ការពិចារណា PPP គឺត្រូវជៀសវាង រឺធ្វើអោយតិចបំផុតនូវហានិភ័យ។នៅក្នុង PPPs ហានិភ័យហិរញ្ញវត្ថុ អាចក្នុងករណីខ្លះ ត្រូវបានគេប៉ាន់ស្មានបានទាំងស្រុងដោយដៃគូរផ្នែកឯកជន។នៅក្នុងគម្រោងធំដ៏ជាក់លាក់មួយ ចំណាយគម្រោង អាចត្រូវបានបែងចែក។ ប្រាកដណាស់ ដៃគូរផ្នែកឯកជន នឹងត្រូវបានលើកទឹកចិត្តដោយប្រាក់ចំណេញ ហើយនិងអ្នកប្រតិបត្តិសារធារណៈត្រូវតែធានាថាថ្លៃឈ្នួលដែលត្រូវបានគិតដោយ អ្នកប្រតិបត្តិផ្នែកឯកជន មិនធ្វើអោយមានការដើបឡើងនូវទំរង់ផ្សេងៗនៃហានិភ័យ - ឧទាហរណ៍ ហានិភ័យ ដែលសារធារណៈជននឹងមិនទទួលយកសំណើរ និងផ្តលរលំរដ្ឋាភិបាល រឺ បង្កើតចលាចលសារធារណៈ ដើម្បីបង្ហាញភាពមិនពេញចិត្តរបស់ពួកគេ។
វិធីសាស្ត្រមួយដើម្បីធ្វើអោយហានិភ័យមានចំនួនតិចតួចបំផុត សំរាប់អ្នកគាំទ្រ រឺអតិថិជនផ្នែកសារធារណៈ គឺត្រូវ ធ្វើការស្នើសុំនៃគម្រោង ជាសារធារណៈ និង បើកចំហ។ នេះ នឹងដាក់បញ្ចូនការដេញថ្លៃអោយមានភាពហ្មត់ចត់ នៃការប្រកួតប្រជែង និងអនុញ្ញាតិអោយរដ្ឋាភិបាលស្ទាបស្ទង់នូវចំណាប់អារម្មណ៍របស់អ្នកប្រតិបត្តិផ្នែកឯកជន រួម និង ភាពសាកសម្បរបស់ពួកគេសំរាប់ការងារនៅក្បែរដៃ។ ភាពមិនប្រែប្រួលការប្រកួតប្រជែង និង ការដេញថ្លៃ ដោយបើកចំហ បង្កើននូវគុណភាពនៃការដេញថ្លៃដែលបានស្នើរសុំដែលនៅពេលតែមួយកាត់បន្ថយតម្លៃនៃការ ផ្គត់ផ្គង់។ ប្រសិនបើក្រុមហ៊ុនដែលដេញថ្លៃ មិនមានរបាយការណ៍

សមរម្យ រឺមិនអាចបំពេញនូវតម្រូវការគ្រឹះ, រដ្ឋាភិបាលអាចសំរេចលុបចោលនូវគម្រោង រឺ ដាក់សំណើរម្តងទៀត។

មានសំណើរមួយចំនួន ដែលត្រូវបានគេជានា គ្មានហានិភ័យហិរញ្ញវត្ថុភ្លាមៗ ចំពោះដៃគូរផ្នែកសារធារណៈ។ ក្នុងករណីទាំងនេះ វា គឺផ្នែកឯកជនដែលប៉ាន់ស្មាននូវរាល់ហានិភ័យហិរញ្ញវត្ថុទាំងអស់។

**ភាពអាចរកបាននៃជំនាញការ**

នៅក្នុងគម្រោងដ៏ស្មុគស្មាញជាច្រើន អាចមាននូវតម្រូវការមួយសំរាប់ការផ្សំបញ្ចូលនៃ សមត្ថភាព និង ជំនាញផ្សេងៗគាផ្ងាច្រើន។ ផ្នែកឯកជន អាចមានជំនាញការដែលរដ្ឋាភិបាលកំពង់ស្វែងរក។ បទពិសោធន៍របស់ផ្នែកឯកជន អាចផ្តល់នូវជំនៀសប្រឆាំងនិង ភាពមិនច្បាស់លាស់ និង ហានិភ័យរបស់គម្រោងដែលស្មុគសញ្ញា។ការទាញយកជំនាញរបស់ផ្នែកឯកជន អាចជាដំណោះស្រាយតែមួយគត់ដែលអាចមាន, ក្រៅពីនេះជាការសាកល្បង និង កំហុសឆ្គង។ ស្រដៀងគ្នានេះដែរ នៅពេលដែលទាក់ទងជាមួយ ប្រពន្ធ័ និង កម្មវធីអាយ ស៊ី ធី, ផ្នែកឯកជន អាចជាប្រភពនៃជំនាញការតែមួយគត់ដែលអាចរកបាន។

លើសពីនេះទៅទៀត ផ្នែកឯកជន បានកំពង់តែពិសោធន៏ និងចែកចាញ សេវាអ៊ីនធរណែតសំរាប់រយះពេលយូរ និង ជំនាញការ អាចមានប្រយោជន៏ ក្នុងការជួយយុត្តាធិការដែលកំពង់តែស្វែងរក រដ្ឋាភិបាល-អេឡិចត្រូនិច សំរាប់ចែកចាញសេវា។ ស្រដៀងគ្នានេះដែរ ផ្នែកឯកជន តាមរយះភាពប្រថុយប្រថានរួមគ្នារវាងក្រុមហ៊ុន អន្តរជាតិ និងសូម្បីតែជាមួយ TNCs, ប្រហែលជាអាចប្រើជំនាញការពីយុត្តាធិការដ៏ទៃទៀតដែលមាន បទពិសោធន៏ក្នុងការប្រើប្រាស់ រដ្ឋាភិបាល-អេឡិចត្រូនិច ។
ជាការពិត អ្នកប្រតិបត្តិផ្នែកឯកជនជាច្រើន អាចមានជំនាញកង្ការចែកចាញ រដ្ឋាភិបាល-អេឡិចត្រូនិច និងសេវា ដែលទាក់ទងទៅដល់យុត្តាធិកាផ្សេងៗនៅលើពិភពលោក។ ជាឧទាហរណ៏ Atos Consulting បានអភិវឌ្ឍន៏ ជំនាញការ ក្នុងការធ្វើអោយមានរចនាសម្ពន្ធ័ កិច្ចព្រមព្រៀង PPP ។ Accenture មានជំនាញការក្នុងផែក រដ្ឋាភិបាល-អេឡិចត្រូនិច។ ក្រុមហ៊ុនប្រឹក្សាយោបលអនរ្តជាតិធំៗជាច្រើនមានជំនាញការដែលពាក់ពន្ធ័ ក៏ដូចជា ក្រុមហ៊ុនតូចៗ និង អ្នកប្រឹក្សាយោបលឯកជនជ្រាេចីនដែរ។

## ការគាំទ្រជាសារធារណៈ

ការយល់ដឹងជាសារធារណៈ នៃកិច្ចសហការដែលកើនឡើង របស់ផ្នែកសារធារណៈជាមួយនិង ផ្នែកឯកជន ចាំបាច់ត្រូវតែ យកមកពិចារណា។ នៅក្នុងប្រទេសជាច្រើន, សារធារណៈជនប្រហែលជាខ្វាយខល់ អំពីការបង្កើត រឺ ការរឹតបន្តឹង ចំនងរវាងអ្នកមានអំណាច និង អ្នកជំនួញជាន់ខ្ពស់។ ហេតុដូចច្នេះ ការផ្គតផ្គង់របស់ PPPs និង យនក្ការហិរញ្ញប្បទានផ្សេងៗទៀត គួរតែត្រូវបានគេធ្វើឡើង ក្នុងបែបផែនតម្លាភាព និង បើកចំហ, ហេយិនិង គួរតែមានរបាយការណ៍បើកចំហ និង ទៀងទាត់ របស់ដំណើរការគម្រោង ដោយប្រើអ្នកត្រួតពិនិត្យនិងចេញផ្សាយ ឯករាជ្យ បើមិនដូចច្នេះ ការប្រឆាំង និង ចលាចល អាចជាប្រតិកម្មរបស់សារធារណៈជន ជាពិសេសនៅពេលដែល សេវាសារធារណៈសំខាន់ៗ ត្រូវបានពាក់ពន្ធ័ ហើយថ្លៃឈ្នួលនៃការផ្តល់សេវាសារធារណៈត្រូវបានគេដាក់កំហិត។កង្វះខាតការគាំទ្រជាសារធារណៈ សំរាប់គម្រោងជាក់លាក់ណាមួយ ធ្វើអោយរដ្ឋាភិបាល ប្រយ័ត្នប្រយ៉ែង ផងដែរ អំពី គម្រោងទាំងនោះ នៅពេលដែល ពួកគេខ្លួនឯង អាចបាត់បង់នូវ ការគាំទ្រនយោបាយ និង កៅអីនៅក្នុង រដភ្លាបិលារបស់គេ បើសារធារណៈជនគិតថា ពួកគេកំពង់តែគ្រាំទគម្រោងបែបនោះ។

## ការកាត់បន្ថយទំហំនៃសេវាសារធារណៈ

ការប្រើប្រាស់យន្តការហិរញ្ញប្បទានផ្សេងៗ អាចអនុញ្ញាតិអោយរដ្ឋាភិបាល បង្កើនការផ្តល់សេវាសារធារណៈ ដោយមិនចាំបាច់ បង្កើនចំនួននៃមន្ត្រីសារធារណៈដែលបានប្រើប្រាស់។ នេះអាចជាការពិចារណា ដ៏សំខាន់មួយនៅពេលដែល មានតម្រូវការដើម្បីកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល និង ទំហំនៃសេវាសារធារណៈ។

## ភាពអាចរកបាននៃ មូលនិធិ / ហិរញ្ញប្បទាន / ឱកាសវិនិយោគ

រដ្ឋាភិបាល អាចមិនមានមូលនិធិ ដើម្បីវិនិយោគជាមួយ រដ្ឋាភិបាល-អេឡិចត្រូនិច។ ផ្ទុយទៅវិញ អក្នវិនិយោគផ្នែកឯកជនអាចមាន និង ចាប់អារម្មណ៏ជាមួយ ការធ្វើជាដៃគូរ ជាមួយ ផ្នែកសារធារណៈ ក្នុងការចែកចាយសេវាសារធារណៈ ដែលត្រូវតែចរចារសិន។

នៅក្នុង PPPs, ដៃគូរផ្នែកឯកជន ផ្តល់រាល់ហិរញ្ញប្បទាន ដោយទទួលបានមកវិញ ការបង់ប្រាក់, ថៃឈ្នួល្ន, រឺក៏ប្រាក់ចំណេញ ដែលបានដំណើរការលើចំនួនពេលដែលបានចំណាយណាមួយ។ ក្នុងករណីនេះគម្រោងអាចត្រូវបានគេចាត់ទុកថាជា សកម្មភាពនៃថវិកាបុរេ ដែលគ្មានផលប៉ះពាល់ភ្លាមៗ លើរតនាគារជាតិ រឺក៏ឃ្លាំង

ប្រាក់។ប្រាកដណាស់ វាមានផលវិបាករយះពេលវែង ប៉ុន្តែផលលំបាកទាំងនោះ អាចត្រូវបានគេស្វែងរក និង ត្រួតពិនិត្យ កំឡុងពេល ដំណាក់កាល ស្រាវជ្រាវ និង ត្រួតពិនិត្យ របស់ គម្រោង។

## សក្តានុពលពាណិជ្ជកម្មដែលអាចឃើញ របស់សោវាដែលត្រូវផ្តល់

ជាក់សែង្ត បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន ដែលផ្នែកឯកជន អាចចាប់អារម្មណ៏ជាមួយការផ្តល់សេវាសារធារណៈ គឺបង្កើតប្រាក់ចំណេញ។ មិនគ្រប់សេវាសារធារណៈទាំងអស់ទេ ដែលចាត់ទុកថា ទាក់ទាញផ្នែកពាណិជ្ជកម្ម ប៉ុនែស្តេវាសារធារណៈជាច្រើន គឺជាសេវាដែលអាចរកមានតែមួយគត់ និងអ្នកប្រើប្រាស់អាចនឹងមិនមានជំរើស។ នេះ នាំទៅដល់ភាពផ្តាច់មុខពីធម្មជាតិ រឺ អំណាចទីផ្សារសំខាន់ដែល ត្រូវបានរួមផ្សំជាមួយការផ្តល់សេវា ក្នុងភាពងឿងឆ្ងល់។

សេវាខ្លះ គឺមានភាពផ្តាច់មុខពីធម្មជាតិ ដូចជា កំពង់ផែ, ផ្លូវរថភ្លើង, ព្រលានយន្តហោះ, ស្ពាន រឺ ផ្លូវ និងស្ថានីយ៍ យកពន្ធលើផ្លូវថ្នល់ រឺ ស្ពាន។ ផ្នែកឯកជនអាចប្រើប្រាស់ ភាពផ្តាច់មុខពីធម្មជាតិ នេះ ដើម្បីទាក់ទាញភាពពាក់ពន្ធ័ របស់ផ្នែក្នឯកជន ក្នុងពេលតែមួយជាមួយការស្វែងរក ដើម្បីធានាថា ផលប្រយោជន៏សារធារណៈត្រូវបានគេគោរពវាគឺជាផ្លូវដ៏ចងេគ្ៀមួយត្រូវដើរ ប៉ុន្តែអ្វីដែលធ្លាប់មានពីមុន បង្ហាញថាវាអាចធ្វើទៅបាន និង អាចជាផលប្រយោជន៏ ដ៏សម្បើម សំរាប់ភាគីទាំងពីរ និង សំរាប់សាធារណៈជនតាមរយះសេវាច្រើន និងលជ្អាងមុន។

## សមត្ថភាពធ្វើការជាមួយផ្នែកឯកជន

ការដែលអាចធ្វើការយ៉ាងជិតស្និទជាមួយផ្នែកឯកជនអាចដាក់បង្ហាញផ្នែកឯកជនចំពោះរបៀបនៃការធ្វើការងារផ្សេងៗគ្នាជាច្រើន។ នៅក្នុងផ្នែកខ្លះ, ដូចជា ផ្នែកការពារក្នុងប្រទេស ដូចសហរដ្ឋអាមេរិក, ទំនាក់ទំនងការងារយ៉ាងជិតស្និតជាមួយ អ្នកប្រតិបិត្តសារធារណៈ និង ឯកជន បានបងេត្កីទំនាក់ទំនងនៃភាពទុកចិត្តដែលបានផ្តល់ផល ប្រយោជន៏យ៉ាងច្រើន ដល់ផ្នែកនោះទាំងមូល ។ អ្នកប្រតិបិត្តសារធារណៈ ដឹងពីក្រុមហ៊ុនផ្នែកឯកជន និងអ្វីដែល ពួកគេពូកែ និងអ្វីដែលពួកគេអាចផ្តល់ ដែលបណ្តាលអោយមានការងារជាបន្តបន្ទាប់យ៉ាងជិតស្និត លើគម្រោង និង ការទទួលធ្វើ។

### ផលប្រយោជន៍ទៅវិញទៅមក

ផលប្រយោជន៍ទៅវិញទៅមក អាចផ្តល់មូលដ្ឋានសំរាប់ការនាំមុខក្នុងភាពជាដៃគូរ។ ក្នុងករណីខ្លះ, វិធីសាស្រ្ត PPP មួយ អាចជាវិធីតែមួយគត់ ឆ្ពោះទៅមុខ នៅពេលដែលសេវាសារធារណៈមួយ ត្រូវបានគេតម្រូវ ពីព្រោះ មិនមានមូលនិធិ, មិនមានជំនាញការ, និង ឆន្ទះនយោបាយ ដើម្បីផ្សព្វផ្សាយ និង អភិវឌ្ឍន៍ សំណើរ។ ក្នុងករណីទាំងនេះ ផ្នែកឯកជន អាចមើលឃើញ ឱកាសសំខាន់ដែលផ្នែកសារធារណៈ មិនអាចដឹង តាមរយៈតួនាទី របស់ពួកគេ។ នៅពេលដែលចំណង់ប្រាក់ចំណូល ជាកត្តាជំរុញ, ការពិនិត្យពិចារណាថ្មីៗ ើបឡើង ហើយទាំងនេះ អាចជាមូលដ្ឋានសំរាប់ការពិភាក្សា និងដែលអាចសំរាប់ការអនុវត្តន៍។ ចំពោះ ផលប្រយោជន៍ដែលមើលឃើញ, នៃពាណិជ្ជកម្មនិងផ្សេងទៀត, របស់ការប្រថុយប្រថាន ដែលបាន ស្នើឡើង, អ្នកប្រតិបត្តិផ្នែកឯកជន អាចរៀបចំ ប្រើអោយអស់ធនធាន ដើម្បីបង្កើនការយល់ដឹង, ផ្សព្វផ្សាយនូវឱកាស, ផ្តល់ដល់សារធារណៈជន, និងមានឥទ្ធិពល លើក្រុមអ្នកសំរេចចិត្តរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍គម្រោង។ សំរាប់អ្នកប្រតិបត្តិផ្នែកឯកជន, ផលប្រយោជន៍ អាចជាសមត្ថភាព ដើម្បីផ្តល់សេវាមួយ ដែលបើមិនអញ្ចឹងទេ នឹងមិនអាចរកបាន សំរាប់សារធារណៈជននិង ប្រមូលផ្តុំនយោបាយ និងចំនុចផ្សេងៗទៀត ក្នុងដំណើរការ។

## ២.៥ ការនាំ ផ្នែកឯកជន និង សារធារណៈអោយធ្វើការជាមួយគ្នា

បុរេលក្ខណ្ឌ សំរាប់ជម្រើសមូលនិធិខ្លះៗ ដែលត្រូវបានពិចារណាកង្នុមេរៀននេះ គឺជាសមត្ថភាពរបស់ផ្នែកឯកជន និង សារធារណៈ ដើម្បីធ្វើការជាមួយគ្នា។ ទំនាក់ទំនងការងារជជិតស្និតរវាង តួអង្គសំខាន់ៗ ត្រូវបានគេភ្ជាប់ទៅ ភាពប្រកួតប្រជែង, ជាមួយប្រទេសដែលធ្វើការជិតស្និតជាមួយផ្នែកឯកជន ដែលជាទូទៅ គេចាត់ទុកថាមានការ ប្រកួតប្រជែងច្រើនជាង។ ការស្រាវជ្រាវ បានបង្ហាញអោយឃើញថា ប្រទេសដែលមាន បរិយាកាសជំនួញល្អជាង មាននូវចរិកលក្ខណៈ ដូចខាងក្រោមៈ

- អត្រាកំនើនលឿនជាង ដោយវាស់វែងតាមផលិតផលជាតិសរុប
- សមតភ្ថាពទាក់ទាញវិនិយោគច្រើនជាង
- ការកាត់បន្ថយភាពក្រីក្រច្រើនជាង
- កិច្ចសន្ទនាល្អជាង រវាងផ្នែកឯកជន និង សារធារណៈ

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសជាច្រើនមានភាពខុសបែគ្លគ្នាជាច្រើន ដែលញែកផ្នែកសារធារណៈជនពីផ្នែកឯកជន ហើយដែលធ្វើអោយវាពិបាក បើអាចធ្វើបានសំរាប់ពួកេគធ្វើការជាមួយគ្នាលើការ

អនុវត្តន៍ដែល បំរើផលប្រយោជន៍ទៅវិញទៅមក។ មួយក្នុងចំណោមបញ្ហាធំបំផុតគឺកង្វះខាតនៃការប្រាស្រ័យទាក់ទងរវាងផ្នែក និមួយៗ។ នេះ នាំអោយមានកង្វះខាតនៃការយល់ដឹង និង រារាំងកិច្ចសហការ។ កិច្ចសន្ទនា គឺជាគន្លឹះដើម្បីការ អភិវឌ្ឍន៍ទំនាក់ទំនងការងាររឹងប៉ឹង រវាងផ្នែកឯកជន និង សារធារណះ។

**កិច្ចសន្ទនា ឯកជន-សារធារណះ**

ដំណើរការកិច្ចសន្ទនា ឯកជន-សារធារណះ (PPD)បានវិវឌ្ឍន៍ជា របៀបនៃការលើកទឹកចិត្ត ផ្នែកឯកជន និង សារធារណះ ដើម្បីពិភាក្សាបញ្ហាពាក់ពន្ធ័រួម ហើយជាចុងក្រោយធ្វើការរួមគ្នា។ សំខាន់ជាងនេះទៀត កិច្ចសន្ទនា ឯកជន-សារធារណះ (PPD) គឺជាអ្វីដែលត្រូវការជាមុន និង បុរេលក្ខខណ្ឌ័ សំរាប់ពិចារណាយន្តការមូលនិធិ ផ្សេងៗ ដូចជា PPPs ។ បើគន្មាកិច្ចសហការជិតស្និតរវាងដៃគូរផ្នែកឯកជន និង សារធារណះ ក្នុងដំណើរការ PPP, យន្តការមូលនិធិផ្សេងៗទាំងនេះ នឹងមិនកើតឡើងទេ។ អ្នកផ្តល់ជំនួយ លើកទឹកចិត្ត PPDs នៅក្នុង ប្រទេស និង យុត្តាធិការទាំងនោះ ដែលផ្នែកសារធារណះ និង ឯកជន មិនកំពង់តែធ្វើការយ៉ាងជិតស្និតសមល្មម ជាមួយគ្នានៅឡើយទេ,

មានទំនាក់ទំនងយ៉ាងជិតស្និតមួយ រវាងឥរិយាបទជំនួយរបស់រដ្ឋាភិបាល និង សមត្ថភាពរបស់ប្រទេស ដើម្បីធ្វើការ ជាមួយផ្នែកឯកជន។ ប្រទេស និង យុត្តាធិការ ដែលរាក់ទាក់ខាងជំនួញ បានពឹងផ្អែកលើភាពផ្សេងគ្នានៃវិធានការ ដូចជា ប្រទេសទាំងឡាយណាដែលបានចេញផ្សាយជាប្រចាំឆ្នាំ នូវរបាយការណ៍ក្នុង ‘ការធ្វើជំនួញ’ ដែលផលិត ដោយ ធានាគារពិភពលោក គឺទំនងច្រើនជាបេក្ខជន សំរាប់ប្រភេទនៃកិច្ចសហការ ដែលអាចបណ្តាលអោយមាន ដំណោះស្រាយមូលនិធិផ្សេងៗ ដូចជា PPPs និង យានយន្តវិនិយោគផ្សេងៗទៀត។ កត្តាមួយចំនួនដែលរារាំង ជំនួញ នឹងរារាំងឱកាស នៃការធ្វើការក្នុង ភាពជាដៃគូរ ជាមួយផ្នែកឯកជន។ ការរារាំងមួយចំនួន ត្រូវបានសង្ខេប នៅក្នុងរូបភាពទី ៥។

**រូបភាពទី ៥ ការរាំងដែលនាំមុខ ចំពោះការធ្វើជំនួញ**

( ប្រភព: Benjamin Herzberg, “Engaging stakeholders through competitiveness partnerships”
( presentation made at the International Workshop on PPD, Paris, France, 2006 ) )

ដើម្បីកសាងភាពជាដៃគូរ ដែលចង្អុលបង្ហាញ យន្តការមូលនិធិផ្សេងៗ, ត្រូវតែមានការផ្សារភ្ជាប់រវាងភាគី។ PPD ជួយកសាងការផ្សារភ្ជាប់នេះនៅក្នុងរបៀបដែលបានរៀបចំមួយ។ PPD ពាក់ព័ន្ធនិងការអភិវឌ្ឍន៍យន្តការ ដែលនាំយកភាគីមកជាមួយគ្នា។

ជាដំបូង ដៃគូរផែកសារធារណៈត្រូវតែទទួលស្គាល់សារសំខាន់នៃ PPD និង សំខាន់ជាងនេះទៅទៀត ទទួលស្គាល់ អត្ថប្រយោជន៍នៃការធ្វើការយ៉ាងជិតស្និតជាមួយផ្នែកឯកជន។ លេខាធិការដ្ឋានសម្របសម្រួលជំនួញ រឺក៏រចនាសម្ពនផ្ទើលមានតម្លៃស្មើរ របស់ក្រសួងពាណិជ្ជកម្ម រឺក៏ ក្រសួងដែលមានតម្លៃស្មើរ អាចត្រូវបានបង្កើតឡើង ដើម្បីសិក្សាបន្ថែមពីផែក្នងឯកជន, ការព្រួយបារម្ភ និង ការលំបាករបស់ពួកគេដែលពួកគេប្រឈមជាមួយក្នុងការ ធ្វើជំនួញរបស់គេ។

សំរាប់ផ្នែករបស់ពួកគេ, ដៃគូផ្នែកឯកជន អាចរៀចរចនាសម្ពន្ធ័របស់ខ្លួនគេ ដោយយ៉ោងទៅលើក្រុមឧស្សាហកម្ម និង បង្កើតក្រុមការងារតូចៗ ដែលតំណាងអោយការពាក់ពនត្វ័មផ្នែករបស់ពួកគេ (ឧទា, សមាគមន៍និយោជិក, សមាគមន៍ឧស្សាហកម្ម, និង ក្រុមពាណិជ្ជកម្ម) ។ ការបង្កើតក្រុមផ្នែកឯកជន អាចត្រូវបានគេនាំយកមកជាមួយគ្នា នៅក្រោមការគាំទ្រ របស់សភាពាណិជក្ជម្ម និង ឧស្សាហកម្ម រឺក៏ស្ថាប័នដែលមានតម្លៃស្មើរ។

យន្តការមួយចំនួន ត្រូវបានគេប្រើដើម្បីនាំយក ដៃគូរផ្នែកសារធារណៈ និង ឯកជន មកជាមួយគ្នាគឺៈ

- វេទិការជាតិ
- ក្រុមការងារ
- គំនិតផ្តួចផ្តើមក្នុងស្រុក រឺ ក្នុងតំបន់ ដូចជា ការតាំងពិពណ៌, ការពិភាក្សាតុមូល
- សកម្មភាពយល់ព្រមដោយរដ្ឋាភិបាល ដែលពាក់ពន្ធ័ផ្នែកឯកជន
- ក្រុមប្រឹក្សារបស់អ្នកវិនិយោគ ដើម្បីនាំយកមកជាមួយគ្នា នូវអ្នកវិនិយោគ និង រដ្ឋាភិបាលដើម្បីពិភាក្សា យោបល និង ឱកាស។
- កិច្ចព្រមព្រៀងដោយកំណត់ពេល នៅក្នុងទំរង់នៃកិច្ចព្រមព្រៀងចរចារ រវាងផ្នែកសារធារណៈ និង ឯកជន ទៅលើបញ្ហានៃការពាក់ពន្ធ័រួម ដោយរួមបញ្ចូលទាំង កិច្ចព្រមព្រៀង ដើម្បីអនុវត្តន៏កំណែទម្រង់សេដ្ឋកិច្ច ក្នុង ១៥០ ថ្ងៃ។ ឧទាហរណ៏មួយនៃបញ្ហានេះ គឺ 'គំនិតផ្តួចផ្តើម Bulldozer' នៅក្នុងប្រទេស Bosnia ដើម្បីចូលទៅកាន់ 'កំណែទម្រង់សេដ្ឋកិច្ច ៥០ ក្នុង ១៥០ ថ្ងៃ ' ។ ការប្តេជ្ញាខ្ពស់ចំពោះគំនិតផ្តួចផ្តើមនេះ បានបង្កើតនូវអារម្មណ៍ បន្ទាន់ និង ជំរុញ ពីការចាប់ផ្តើម។[២៣]

ការគាំទ្ររបស់ម្ចាស់ជំនួយ, សហគ្រាសជំនួញធំៗ, និង រដ្ឋាភិបាលនិងអ្នកដឹកនាំនយោបាយ គឺសំខាន់ណាស់។ ការគាំទ្រពីសហគមន៏អន្តរជាតិ នឹងមិនពិបាកដើម្បីទទួលបាន, ចំពោះសារសំខាន់នៃការមានផ្នែកឯកជន និង សារធារណៈ ធ្វើការយ៉ាងជិតស្និតជាមួយគ្នា។

---

២៣ Benjamin Herzberg, "Engaging stakeholders through competitiveness partnerships" (presentation made at the International Workshop on PPD, Paris, France, 2006); and Benjamin Herzberg and Andrew Wright, *The PPD Handbook: A Toolkit for Business Environment Reformers* (DFID, World Bank, IFC, OECD Development Centre, 2006), http://siteresources.worldbank.org/INTEXPCOMNET/Resources/PPD_Handbook.pdf.

## ៣. ភាពជាដៃគូរ ផ្នែកសារធារណៈ និង ឯកជន

ផ្នែកនេះមានគោលបំណងដើម្បី :

- កំណត់ ភាពជាដៃគូរ ផ្នែកសារធារណៈ-ឯកជន (PPPs) និង ប្រភេទផ្សេងៗនៃ PPPs :
- ពិភាក្សាអំពី គុណសម្បត្តិ និង គុណវិបត្តិ នៃ PPPs និង
- គូសគ្រោងនូវ គោលការណ៍សំរាប់ការអនុវត្តន៍ នៃ PPPs

### ៣,១ ប្រវត្តិរូប[២៤]

ការស្ថាបនា កិច្ចការសាធារណៈ ដែលប្រើមូលនិធិឯកជន ត្រឡប់ទៅកាន់បូរាណកាល។ ច្បាប់សម្បទានជាផ្លូវការ បានកើតមាននៅដើមគ្រឹស្តរាជ ៥៣០ ។ នៅអឺរ៉ុប នៅក្នុងសតវត្សទី ១៦ និង ១៧, កច្ចិការសារធារណៈ ដូចជា ការសារសង់ប្រឡាយ, ការត្រួសត្រាយផ្លូវ, ការប្រមូលកាកសំណល់, ការរៀបចំភ្លើងសារធារណៈ, ការចែកចាយ សំបុត្រ និង ការដឹកជញ្ជូនសារធារណៈ ត្រូវបានប្រទានរង្វាន់ដោយព្រះមហាក្សត្រ ទៅដល់អ្នកវិនិយោគឯកជន។[២៥]

នៅក្នុងឆ្នាំថ្មីៗនេះ, ការទទួលយកផ្នែកជន ដើម្បីផ្តល់ទំនិញ និង សេវាសារធារណៈត្រូវបានគេដឹងថាបានកើនឡើង ជាវិធីសាស្ត្រមួយនៃការសន្សំសំចៃប្រាក់រដ្ឋាភិបាល ហើយនៅក្នុងពេលតែមួយផ្តល់នូវសេវាដ៏ល្អ។ នៅក្នុងឆ្នាំ ១៩៩២, ចក្រភពអង់គ្លេស (UK) ស្ថិតនៅក្នុងការធ្លាក់ចុះសេដ្ឋកិច្ច ហើយប្រទេសបានកំពង់រងការឈឺចាប់ ពីការ ធ្វើអោយវិនាសហេដ្ឋារចនាសម្ពន្ធ័សារធារណៈ។ មិនមានសាច់ប្រាក់ដែលអាចរកបានពី រតនាគាររបស់រដ្ឋាភិបាល ហើយរដ្ឋាភិបាលសម័យនោះ គឺមិនមានឆន្ទះដើម្បីបង្កើនពន្ធដារ ទេ។ ដើម្បីជំរុញសេដ្ឋកិច្ច, វិនិយោគឯកជនដ៏ធំ មួយនៅក្នុងសេវាសារធារណៈត្រូវបាន គេស្នើរឡើង។ វាត្រូវបានគេគិតថា ដោយការទាក់ទងផ្នែកឯកជន នៅក្នុង ការផ្តល់សេវាសារធារណៈ, ផលប្រយោជន៍ដូចខាងក្រោម នឹងត្រូវបានគេយល់ឃើញ:

---

២៤ This section is drawn from a report entitled “Background Study on Public Private Partnerships (PPPs) in e-Government” that was prepared by Richard Labelle under contract to Atos Consulting of London in the context of work undertaken in Mongolia in 2007. The report was a collective endeavour and reflects the contributions of other team members, especially Rahzeb Chowdury of Atos in London. The author wishes to thank Atos for permission to reproduce portions of the report here.

២៥ H.K. Yong and Windhu Hidranto, “My Say: Private finance in public works,” *The EdgeDaily,* 21 February 2006, http://www.theedgedaily.com.

- សមត្ថភាពដែលចំណាញ របស់រដ្ឋាភិបាល អាចនឹងត្រូវបានកើនឡើង
- ហានិភ័យអាចនឹងត្រូវបានផ្ទេរទៅផ្នែកឯកជន, និង
- តម្លៃលុយដែលកើនឡើង អាចនឹងត្រូវបានសម្រេច[២៦]

ការខិតខំប្រឹងប្រែង បានបង្ហាញនូវជោគជ័យ ហើយចាប់តាំងពីពេលនោះមក, រដ្ឋាភិបាល UK បានកំពង់តែប្រើប្រាស់ PPPs ដើម្បីផ្តល់មូលនិធិដល់ ផ្នែកដ៏សំខាន់មួយនៃគម្រោងសារជារណៈ។ “រដ្ឋាភិបាល លោកBlair បានទទួលយក ការផ្តួចផ្តើមហិរញ្ញវត្ថុឯកជន (PFI) ជាវិធីសាស្ត្រមួយក្នុងការទទួលយក អ្នកម៉ៅការផ្នែកឯកជន អោយចេញប្រាក់សំរាប់ចំណាញសាងសង់ ហើយបន្ទាប់មក អោយជួលគម្រោងដែលបញ្ចប់នោះទៅដល់ ផ្នែក សារជារណៈ។ នេះធ្វើអោយរដ្ឋាភិបាលទទួលបាន មន្ទីរពេទ្យ, សាលារៀន និង គុកថ្មីៗ ដោយគ្មានការបង្កើន ពន្ធដារ។ អ្នកម៉ៅការ, សំរាប់ផ្នែករបស់គាត់, គឺត្រូវបានអនុញ្ញាតិអោយទុកសាច់ប្រាក់ដែលនៅសល់ពីដំណើរការ សាងសង់ នឹង រចនា, ហើយថែមទាំងប្រាក់ឈ្នួល ” ។[២៧] រដ្ឋាភិបាល UK បានផ្តល់មូលនិធិដល់ ៦២០ PPPs ដែល មានតម្លៃ ៦០ កោដិអឺរ៉ូ និង ៤៥០ គម្រោង នៅបន្តដំណើរការ។ ជាការចាប់ផ្តើម, គម្រោងដែលបានមូលនិធិ គឺ ភាគច្រើនដើម្បី សាងសង់ហេដ្ឋារចនាសម្ពន្ធ័។ នេះកំពង់តែផ្លាស់ប្តូរខ្លះៗ នៅពេល សេវា បានកំពង់តែដំណើរការ ដោយដៃគូរផ្នែកឯកជន ក្រោមការស្នើរសុំ PPP និងកិច្ចព្រមព្រៀងដែលមានកិច្ចសន្យា ។

ទិដ្ឋភាពដែលផ្នែកឯកជន អាចនាំយកផលប្រយោជន៏ដ៏សំខាន់ ទៅដល់ការចែកចាញនៃវិនិយោគសារជារណៈបានក្លាយ ជាទូទៅហើយក្នុងប្រទេសជាច្រើន។ ដោយយើងទៅលើ ក្រុមប្រឹក្សាប្រទេសកាណាដាសំរាប់ភាពជា ដៃគូរ ឯកជន-សារជារណៈ, ចំនួននៃ PPP សំរាប់គម្រោងហេដ្ឋារចនាសម្ពន្ធ័ គឺកំពង់តែកើនឡើង យ៉ាងខ្លាំងនៅ អាស៊ី, អូស្ត្រាលី និង អ៊ឺរ៉ុប។ ចក្រភពអង់គ្លេស UK បានប្រើ PPPs យ៉ាងជោគជ័យក្នុងកំឡុងពេល ១៧ឆ្នាំ នៅ ពេលដែលអូស្ត្រាលីបានធ្វើដូចច្នោះដែរ អស់រយះពេលប្រហែល ១០ឆ្នាំហើយ។[២៨]

---

២៦ Abridged from M. Rathbone, “Overview of public private partnerships” (presentation made to the Government of Brunei, 2006).

២៧ *BBC News*, “What are Public Private Partnerships?” 12 February 2003, http://news.bbc.co.uk/1/hi/uk/1518523.stm.

២៨ Canadian Council for Public-Private Partnerships, *Responsible PPP Procurement for British Columbia* (2005), http://www.pppcouncil.ca/pdf/bc_procure.pdf.

PPPs គឺមានប្រយោជន៍ផងដែរសំរាប់ ការចែកចាយសេវា និង ហេដ្ឋារចនាសម្ពន្ធ័ទំហំតូច។ នៅឥណ្ឌា, PPPs បាន បង្ហាញថា ជាយន្តការនៃការចែកចាយដ៏ជោគជ័យមួយ សំរាប់ភាពផ្សេងៗគ្នានៃសេវាសារធារណៈ នៅកម្រិតថ្នាក់សហគមន៍ និង ក្នុងស្រុករួមនិងថ្នាក់ភូមិផងដែរ។ "នៅក្នុងគម្រោងរបស់ឥណ្ឌាមួយ ចំនួន............ការអភិវឌ្ឍន៍កម្មវិធី (Software), ការបណ្តុះបណ្តាល, ការបញ្ចូលទិន្នន័យ និង វិធីថែទាំនិងរក្សាឯកសារ ត្រូវបានគេប្រគល់អោយ ផ្នែកឯកជន " ។ Bhatnagar បានរាយការណ៍ផងដែរថា ក្រុមហ៊ុនឯកជន បានចុះកិច្ចសន្យា ដើម្បី "អភិវឌ្ឍន៍ កម្មវិធី រដ្ឋាភិបាល-អេឡិចត្រូនិច ជាផលិតផលមួយ " ។ នៅក្នុងករណីខ្លះ, សេវាទាំងនេះ អាចបញ្ចូលជាមួយ ការបង្កើត និង ប្រតិបត្តិការណ៍ពាណិជ្ជកម្ម របស់ភាពងាយស្រួលការចូលជាសារធារណៈ រឺផ្អែកលើសហគមន៍មួយ ដែលផ្តល់នូវជម្រើសនៃសេវា ផ្អែកលើទូរគមនាគមន៍សារធារណៈ និង ឯកជនផងដែរ។ នៅក្នុងករណីនេះ, តម្លៃ គឺនៅក្នុងការចែកចាយ រដ្ឋាភិបាល-អេឡិចត្រូនិច ពាសពេញប្រទេស ដោយប្រើ វិធីសាស្រ្ត PPP។

បច្ចុប្បន្ននេះមានច្រើនជាងមុន, រដ្ឋាភិបាលមិនអាចទ្រទ្រង់ ហេដ្ឋារចនាសម្ពន្ធ័ដែលមានស្រាប់ និង មិនអាច លៃលក សាងសង់ ហេដ្ឋារចនាសម្ពន្ធ័ថ្មី ជាមួយដើមទុនសារធារណៈដែលមានកម្រិត។ នៅក្នុងសេដ្ឋកិច សកលឯករាជ្យ ដែលក្នុងនោះ ការបង្កើនការចំណាយពនអ្នាករ មានផលប៉ះពាល់ចំបង លើដំណើរការម៉ាក្រូ សេដ្ឋកិច្ច និង ការប្រកួត ប្រជែង, រដ្ឋាភិបាល ជារឿយៗមិនអាចធ្វើមានការបង្កើនពន្ធអាករ សំរាប់គោល បំណងនេះទេ។ PPPs ត្រូវបានគេ មើលឃើញយ៉ាងច្រើន ថាជាវិធីសាស្រ្តមួយក្នុងការបំពេញតម្រូវការ សំរាប់ហេដ្ឋារចនាសម្ពន្ធ័ដែលត្រូវធ្វើអោយ ប្រសើរឡើង និង សេវា ក្នុងតម្លៃបចប្បុន្នដែលបានកំណត់ចំពោះ ឃ្លាំងប្រាកសារធារណះ។

លើសពីនេះទៅទៀត, រដ្ឋាភិបាលជាច្រើន ដឹងថាវាជារឿយៗសំខាន់ ដើម្បីបង្កើតការគិតប្រាក់ អ្នកប្រើប្រាស់ លើ សេវាសារធារណះ ដើម្បីកំរិតចំនួនប្រើប្រាស់របស់ពួកគេ។ ឧទាហរណ៍មួយក្នុងបញ្ហានេះ គឺការប្រើប្រាស់ ហេដ្ឋារចនាសម្ពន្ធ័ផ្លូវថ្នល់, ជាធម្មតា អ្នកប្រើប្រាស់មានឆន្ទះក្នុងការបង់ប្រាក់ ដើម្បីប្រើប្រាស់ផ្លូវថល្ន់ ដែលកាត់ បន្ថយតម្រូវការ និង ការកកស្ទះ, ដោយគុណធម៌នៃការគិតប្រាក់សំរាប់ការប្រើប្រាស់។ ប្រាក់ចំណូលដែលកើន ឡើង គឺជាផលប្រយោជន៍មួយផងដែរ – ក្នុងន័យ តម្លៃហិរញ្ញវត្ថុ ដែលគេ បញ្ចូលជាមួយ ការចែកចាយសេវា និង ហេដ្ឋារចនាសម្ពន្ធ័ សារធារណះ។

ការអំពាវនាវ ដល់រដ្ឋាភិបាល អំពីការលក់ រឺ ជួលធនធានទាំងនេះ ទៅអោយផ្នែកឯកជន ក្រោមប្រភេទនៃការ រៀបចំ PPP ហេតនេះធ្វើអោយក្លាយ ជាការទាក់ទាញខ្លាំងឡើង។

ការទាក់ទងជាមួយផ្នែកឯកជន មានអត្ថប្រយោជន៍ផ្សេងៗច្រើនទៀត។ ដោយយោងទៅលើ PricewaterhouseCoopers, ក្រុមប្រឹក្សាយោបល់គ្រប់គ្រង, ទាំងនេះគឺ :

- ការចំណាយ ពេញមួយជីវិត – វិធីសាស្ត្រមួយនៃការវាយតម្លៃ រឺប្រៀបធៀប សំភារៈសាង់សង់ និង គ្រឿងផ្សំ ផ្សេងៗ ដោយមើលទៅលើ ចំណាយក្នុងការតំឡើង, អាយុកាល, ចំណាយក្នុងការដំណើរការ និង ការថែទាំ
- ការកែលម្អឡើងវិញ / ជំនាញគ្រប់គ្រងផ្សេងៗគ្នា
- ការផ្ទេរ ហានិភ័យ
- រចនា, កសាង, ដំណើរការ កិចស្វហការដើម្បីបានលទ្ធផលល្អ និង
- ការស្រាយ នូវការប្រើប្រាស់ផ្សេងៗ

## ៣.២ និយមន័យ និង ប្រភេទ

ក្រុមប្រឹក្សាកាណាដា សំរាប់ភាពជាដៃគូរ ឯកជន-សារធារណៈ អោយនិយមន័យ PPP ថា :

> ការប្រថុយប្រថានរួមគ្នា រវាង ផ្នែកឯកជន និង សារធារណៈ ដែលបង្កើតឡើង លើជំនាញការនៃដៃគូរ និមួយៗ ដែលបំពេញឥតខ្ចោះនូវតម្រូវការសារធារណៈដែលបានកំណត់ច្បាស់លាស់ តាមរយះការ បែង ចែកធនធានដ៏សមរម្យ, ហានិភ័យ និង រង្វាន់។

ធានាគារពិភពលោក toolkit អោយនិយមន័យ PPP ថា :

> ភាពជាដៃគូរឯកជន-សារធារណៈ (PPP) បង្ករបង្កើតកិច្ចប្រឹងប្រែងសហការណ៍ជានិរន្តរ៍ រវាងផ្នែក រធារណៈ (ភ្នាក់ងាររដ្ឋាភិបាល) និង សហគ្រាសឯកជន ដើម្បីសំរេចគោលដៅរួម (ឧទា, គម្រោងផ្លូវ) នៅពេល ដែលគេស្វែងរក ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

PPPs បង្ហាញពី វិធីសាស្ត្រប្រលោមលោកមួយចំពោះ ការគ្រប់គ្រង និង អនុវត្តន៍គម្រោង។ ពួកគេត្រូវបានគេ ចាត់ទុកជា វិធីសាស្ត្រប្រលោមលោក និង មានសក្តានុពលសំខាន់ នៃការថ្លែងអំពី តម្រូវការជាច្រើន និង បរាជ័យ នៃជំនួយអភិវឌ្ឍន៏អន្តរជាតិ ដោយគុណធម៌នៃអត្ថប្រយោជន៍របស់ពួកគេ, ដ៏រាបណា តម្រូវការរបស់ពួកគេ និង គ្រោះថ្នាក់ជាសក្តានុពល ត្រូវបានគេដឹង និង និយាយអំពី ផងដែរ។

មានប្រភេទជាច្រើននៃ PPPs និង ហើយទាំងនេះ នឹងត្រូវគេបង្ហាញនៅក្នុង ចំណុចផ្សេងៗគ្នាជាច្រើនក្នុងវដ្តនៃ គម្រោង។ ប្រភេទផ្សេងៗគ្នាមួយចំណួននៃ PPPsត្រូវបានគេចាត់ជាក្រុម នៅក្រោមចំណងជើងខាងក្រោមនេះ :

ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច

- កិចក្ខារប្រព្រឹត្តកម្ម ទឹក និង លូទឹកស្អុយ
- ឡដុត
- ផ្លូវអិក្សប្រេស និង ផ្លូវបង់លុយ
- ប្រពន្ធ័រោងចក្រថាមពល និង ឧស្ម័ន

ហេដ្ឋារចនាសម្ព័ន្ធសង្គម

- គ្រឿងបរិក្ខា អប់រំ, សាលាពហុបច្ចេកទេស
- មន្ទីរពេទ្យ
- កស្រួងការពារជាតិ : កន្លែងស្នាក់នៅ, សម្ភារះ, ឃ្លាំងសត្កុ
- អាគារការិយាល័យរដ្ឋាភិបាល
- គ្រឿងបរិក្ខា កីឡា
- កិច្ចការហេដ្ឋារចនាសម្ពន្ធ័ ពត៌មានវិទ្យា ជាន់ខ្ពស់

មាន PPPs ដែលផ្តល់សេវាផងដែរ។ តារាងទី២ បង្ហាញពីការប្រើប្រាស់ផ្សេងៗរបស់ PPPs

### តារាងទី២ ប្រភេទ នៃ PPPs យ៉ោងទៅលើគោលបំណងចំបង

Source: World Economic Forum, *Building on the Monterrey Consensus: The Growing Role of Public-Private Partnerships in Mobilizing Resources for Development* (Geneva: World Economic Forum, 2005), 24, http://www.weforum.org/pdf/un_final_report.pdf.

### PPPs ជាសម្បទាន

PPPs យ៉ាងទូលំទូលាយផ្អែកទៅលើ កិចស្វនាប្រភេទសម្បទាន, ដែលក្នុងនោះ ឯកសារសម្បទាន បានកំណត់ សិទ្ធិ, ឯកសិទ្ធិ, និង កាតព្វកិច្ចរបស់អ្នកវិនិយោគឯកជន។ អត្ថន័យរបស់ពាក្យ សម្បទាន ក្នុងន័យទូលំទូលាយ ត្រូវបានគេប្រើ ដើម្បីបងញ្ហាពី ប្រភេទណាមួយនៃការរៀបចំ ដែលក្នុងនោះ រដ្ឋាភិបាលផល្ត់ សិទ្ធិទៅអោយ អ្នកវិនិយោគឯកជន ដើម្បីផ្តល់សេវាជាក់លាក់មួយ ក្រោមលក្ខខណ្ឌ័ នៃអំណាចទីផ្សារសំខាន់។ សម្បទាន ត្រូវបាន គេផ្តល់អោយក្នុងការប្តូរ សំរាប់ប៉ាន់ស្មាននូវហានិភ័យ ដែលភប្ជាប់ជាមួយនិងគម្រោង។ សម្បទានត្រូវបានគេស្នើរសុំដោយប្រើប្រាស់ដំណើរ ការស្នើរសុំបើកចំហ ដោយយ៉ោងទៅលើការអនុវត្តន៏ដែលបានទទួលយក នៅការផ្តត់ផង្គ់ សារធារណះ។

ដូចច្នេះហើយ, សម្បទានក្នុងន័យនេះ រួមបញ្ចូលទាំង កិច្ចសន្យា សប្កនា-ជាម្ចាស់-ដំណើរការ, កិច្ចសន្យា សប្កានា-ដំណើរការ-ផ្ទេរ, កិច្ចសន្យា សេវា និង គ្រប់គ្រង, ហើយនិង កច្ចិសន្យាជួល។ ក្នុងន័យ លក្ខខណ្ឌអំណាច ទីផ្សារ, ពាក្យស្នើរសុំនៃបែបផែននេះ គឺនៅក្នុងបរិបទមួយ ដែលទីផ្សារសំរាប់ផត្គ់ផ្គង់ នៃសេវាមួយ គឺផ្តាច់មុខពី ធម្មជាតិ។ គ្រែងឿបរិក្ខាហេដ្ឋារចនាសម្ពន្ធ័ (ឧទា, កំពង់ផែ និង ព្រលានយន្តហោះ) និង ឧស្សាហកម្មដែលភ្ជាប់ បណ្តាញ (ឧទា, អគ្គិសនី និង ហ្គាស) គឺជាឧទាហរណ៏ពិតប្រាកដ របស់វិស័យនានា ដែលបានកំនត់ចរិកលក្ខណះ ដោយការផល្តដោយភាពផ្តាច់មុខពីធម្មជាតិ នៅក្នុងមួយផ្នែក ខ្លះរបស់ពួកគេ ។

**បែបបទ PPP**

PPP អាចត្រូវបានគេចាត់ទុក នៅក្នុងភាពជាបន្តបន្ទាប់ នៃការរៀបចំការផ្តល់សេវា រវាងផែក្នសារធារណះ និង ឯកជន។ រូបភាពទី ៦ បង្ហាញភាពដែលអាចកើតមានខ្លះៗ ចាប់ពី ការចុះកិច្ចសន្យាធម្មតា ទៅដល់ការផេរ្ទអោយ ឯកជនពេញលេញ នូវសេវារបស់រដ្ឋាភិបាល។ នៅក្នុងការបង្ហាញនេះ, វិសាលភាពនៃការចូលរួមផ្នែកឯកជន កើន ឡើងពីធ្វេងទៅស្តាំ ។

**រូបភាពទី ៦ ភាពជាបន្តបន្ទាប់របស់ការផ្តលសេវាផ្នែកឯកជន**

(Source: World Bank, *Toolkit for Public Private Partnerships in Highways:Choosing the right PPP option* (2002), http://rru.worldbank.org/Documents/Toolkits/Highways /1overdiag/ 12/12_.htmand http://rru.worldbank.org/Documents/Toolkits/Highways/start.HTM)

PPPs គឺផ្អែកទៅលើបែបផែនគ្រឹះពីរ : សម្បទានប្រតិបត្តិ និង សម្បទានវិនិយោគ។
នៅក្នុងសម្បទានប្រតិបត្តិ, ផ្នែកសារធារណៈ រក្សានូវភាពជាម្ចាស់របស់ទ្រព្យសម្បត្តិសាធារណៈ ដែលបានប្រើប្រាស់ក្នុងការចែកចាយសេវា។ នៅកង្នុសម្បទានវិនិយោគ, ផ្នែកឯកជនទទួលខុសត្រូវ ដល់ការផ្តល់មូលនិធិ និង ដល់ប្រតិបត្តិការណ៏នៃរបស់ប្រើប្រាស់។

សម្បទាន អាចត្រូវបានគេផ្តល់អោយទាំងពីរ សំរាប់ការវិនិយោគជាមួយ ហេដ្ឋារចនាសម្ពន្ធដែលមានស្រាប់ រឺក៏ ជាមួយគ្រឿងបរិក្ខាថ្មីៗទាំងអស់ (សម្បទាន Greenfield)។ កាតព្វកិច្ចវិនិយោគរបស់សម្បទានិក និងត្រូវបាន គេដាក់ក្នុងកិច្ចព្រមព្រៀងសម្បទាន និងអាចត្រូវបានគេកំណត់ទាំងពីរ ក្នុងចំនួនប្រាក់សុទ្ធ និង ក្នុងលក្ខខណ្ឌ បរិមាណ, ឧទាហរណ៏ កាតព្វកិច្ចដើម្បីផ្តល់សេវា ទៅដល់ចំនួនអ្នកប្រើប្រាស់ថ្មី ដែលបានកំណត់។ កាតព្វកិច្ច ប្រតិបត្តិ ជាបែបផែនរួមបញ្ចូល ស្តង់ដារនៃការប្រព្រឹត្ត ហើយនិង ប្រាក់ចំណូលរបស់សម្បទានិក នឹងផ្អែកទៅលើ ការគិតប្រាក់លើអ្នកប្រើប្រាស់ ដែលទាក់ទងទៅ គុណភាព (ដូចដែលបានកំណត់ក្នុងសម្បទាន), ភាពរហ័ស និង កម្រិតនៃការបំពេញចិត្ត ដែលបានផ្តល់ដល់អ្នកប្រើប្រាស់។ នៅក្នុងក្របខណ្ឌ័នេះ, ហានិភ័យ ប្រតិបត្តិ និង វិនិយោគទាំងពីរត្រូវបានគេផ្ទេរយ៉ាងទូលំទូលាយ ទៅផ្នែកឯកជន។

PPPs ត្រូវបានគេដាក់ជាក្រុម យ៉ោងទៅលើការរៀបចំខាងក្រោមៈ

១. ការងារសំរាប់កិច្ចសន្យាសេវា

នេះ គឺជាការរៀបចំពិតប្រាកដមួយ សំរាប់ផ្តល់សេវា និង ទំនិញ។ មូលនិធិ ត្រូវបានគេបែងចែក ដើម្បីអនុវត្តន៏ការងារដែលកំណត់ទុកជាមុន, កិច្ចសន្យាត្រូវបានគេធ្វើឡើង, និង ការដេញថ្លៃដែលឈ្នះត្រូវបានគេជ្រើសរើស អោយអនុវត្តន៏ការងារដែលគេតម្រូវ។ នៅក្នុងស្ថានភាពនេះ, អង្គភាពផ្នែកសាធារណៈ បង់ប្រាក់ទៅអោយ អ្នកម៉ៅការ ដោយយ៉ោងទៅលើ គុណភាពនៃភាពអាចចែកចាយទៅបាន ផ្អែកលើសេចក្តីបញ្ជាក់លំអិតដែលបាន ព្រមពៀងគ្នា។ អតិថិជនផ្នែកសារធារណៈ រក្សានូវ បែបបទ និង អំណាចសំរេចចិត្ត ទាំងអស់ រួមទាំង ភាពជាម្ចាស់ និង ការត្រួតពិនិត្យប្រតិបត្តិ នៅពេលដែលការងារបានបញ្ចប់។ នេះ មិនត្រូវបានគេចាត់ទុកជា PPP មួយ, នៅ ពេលដែល មានហានិភយ័តិចតួចណាស់ ហើយនេះ គឺជារបៀបធម្មតា នៃការបំពេញតម្រូវការសំរាប់សេវា និង ទំនិញ នៅក្នុងផ្នែកសារធារណៈ។

ទោះបីជាយ៉ាងណាក៏ដោយ ទំនាក់ទំនងការងារជិតស្និតជាមួយ ផ្នែកឯកជន អាចត្រូវបានគេបង្កើត លើមូលដ្ឋាននៃ កិច្ចសន្យាយ៉ាងរឹងមាំ សំរាប់ រឺការទទួលយក ទំនិញ និងសេវាហើយនេះ គឺជាមូលដ្ឋាន លើអ្វីដែល PPP អាច អភិវឌ្ឍន៏។

២.កិច្ចសន្យាគ្រប់គ្រង និង ថែទាំ

នេះ គឺជាសម្បទានប្រតិបត្តិ ដែលក្នុងនោះ ផ្នែកឯកជន មានកិច្ចសន្យាដើម្បីផ្តល់ ការគ្រប់គ្រង និង ថែទាំ នៃគ្រឿង បរិក្ខា និង សេវាសារធារណះ។ ឧទាហរណ៍មួយ គឺ ក្រុមហ៊ុនមួយ ដែលបានចុះកិច្ចសន្យាផ្តល់នូវ មុខងារផ្តល់ ពត៌មានមួយ ដោយយោងទៅលើ ការប្រើប្រាស់ និង ដំណើរការ របស់គ្រឿងឧបករណ៏ និង កម្មវិធី អាយ ស៊ី ធី។

៣.សម្បទានថែទាំ និង ប្រតិបត្តិ

នៅក្នុងករណីនេះ, អង្គភាពផ្នែកឯកជនដែលបានរចនាឡើង បានទទួលសម្បទានមួយ សំរាប់ប្រតិបត្តិ និង ថែទាំ នូវ
សេវាសារធារណះមួយ។ ផ្នែកឯកជន បន្តជាម្ចាស់លើ សេវា និង ប្រគល់ប្រតិបត្តិការណ៍ ទៅអោយអ្នកប្រតិបត្តិ ផ្នែកឯកជន ដែលជាធម្មតាសំរាប់កំឡុងពេលដែលបានកំណត់មួយ។ មានពីរប្រភេទ : កិច្ចសន្យាគ្រប់គ្រង និង ថែទាំ, និង កិច្ចសន្យាប្រតិបត្តិ និង ថែទាំ។ នេះ គឺជាឧទាហរណ៏មួយទៀតនៃ សម្បទានប្រតិបត្តិ។

៤.BOT, BOO, BOOT និងសម្បទានផ្សេងៗដែលទាក់ទង

ស្ថាបនា ប្រតិបត្តិ ផ្ទេរ (BOT), ស្ថាបនា ជាម្ចាស់ ប្រតិបត្តិ (BOO) និង ស្ថាបនា ជាម្ចាស់ ប្រតិបត្តិ ផ្ទេរ (BOOT) គឺជាសម្បទានវិនិយោគផ្សេងៗគ្នា។ សម្បទាន BOT ប្រគល់ទៅអោយផ្នែកសារធារណះវិញ បន្ទាប់ពី ប្រតិបតិការណ៍ ដោយផ្នែកឯកជន លើកំឡុងពេលដែលបានផ្តល់អោយមួយរួចមក។ ក្នុង BOO សម្បទាន, អ្នកប្រតិបត្តិផ្នែកឯកជន ជាម្ចាស់លើរបស់របរទាំងអស់។ សម្បទាន BOOT អនុញ្ញាតិអោយ ប្រតិបត្តិការណ៍ លើរយះពេលវែងមួយ មុនពេល គម្រោងចុងបញ្ចប់ ប្រគល់ទៅអោយផ្នែកសារធារណះវិញ។ បែបផែននេះ អនុញ្ញាតិអោយអ្នកប្រតិបត្តិផែក្នុងឯកជន មានពេលប៉ះប៉ូវ នូវចំណាយនៃការវិនិយោគ និងរកប្រាក់ ចំណេញ។ សម្បទានទាំងនេះត្រូវបានគេពិពណ៍នាបន្ថែមដូចខាងក្រោម។

ស្ថបនា ជាម្ចាស់ ប្រតិបត្តិ (BOO) នេះ គឺការរៀបចំដោយមានកិច្ចសន្យាមួយ ដែលក្នុងនោះ អ្នកវិនិយោគផ្នែកឯកជន ធ្វើហិរញ្ញប្បទានដល់ របស់ប្រើប្រាស់សេវាសារធារណៈ ហើយចុះកិច្ចសន្យាសំរាប់ការស្ថាបនាដែលចាំបាច់ និងប្រតិបត្តិការណ៏ជាបន្តបន្ទាប់នូវរបស់របរប្រើប្រាស់ទាំងនោះ។ អ្នកវិនិយោគឯកជន មានភាពជាម្ចាស់លើ របស់របរប្រើប្រាស់េនាះពេញមួយជីវិតរបស់វា។ អ្នកវិនិយោគត្រូវបានគេអនុញ្ញាតិអោយ ប្រមូលថ្លៃឈ្នួល, គិតប្រាក់ សេវា រឺ ឈល្ន ដើម្បីបានមកវិញនូវ ចំណាយប្រតិបត្តិ និង វិនិយោគ។ ទោះបីជាគេអោយន័យមិនច្បាស់ ភាព ជាម្ចាស់ អាចមាន ព្រំដែនក្នុងការអនុវត្តន៏អាចកត់សំគាល់បាន ពីព្រោះកិច្ចព្រមព្រៀងសម្បទាន តាម បែបផែន មានពេលកំណត់ ច្បាស់លាស់មួយ។ ផងដែរ ដើម្បីអោយកិច្ចសន្យារក្សានូវសុពលភាព, អ្នកវិនិយោគ ត្រូវតែ អនុវត្តន៏ជំនួញ អោយ ស្របជាមួយកម្រិតប្រតិបិត្តិដែលបានចែងនៅក្នុង កិច្ចព្រមព្រៀងសម្បទាន រឺដោយ និយតករ។ ជីវិតនៃរបស់របរ ទាំងនោះ អាចដាក់ផងដែរ នូវកំហិតកិច្ចសន្យា ‘ជាធម្មជាតិ ’។
កិច្ចសន្យា BOO មានការប្រើប្រាស់ទូលំទូលាយ។ ឧទាហរណ៏, វា ជារួមត្រូវបានគេប្រើ សំរាប់ រោងចក្រថាមពល ឯករាជ្យ (IPPs), ដែល IPPs ត្រូវបានចុះកិច្ចសន្យា េដីម្បីផ្គត់ផង្គ់អគ្គិសនី ទៅដល់អ្នកទិញថាមពល ទាំងដុលុ, ជាធម្មតាក្នុងនាមនៃប្រទេស, សំរាប់ការបញ្ជូនឆ្ពោះទៅផ្នែកចែកចាយ។

លក្ខណះសំខាន់ៗរបស់ សម្បទាន BOO គឺមានដូចខាងក្រោម :

- អ្នកវិនិយោគផ្នែកឯកជន ផ្តល់ហិរញ្ញប្បទាន ដល់របស់របរប្រើប្រាស់សេវាសារធារណះ។
- អ្នកវិនិយោគផ្នែកឯកជន ចុះកិចស្ចន្យា សំរាប់ការស្ថាបនា និង ប្រតិបត្តិការណ៏ជាបន្តបន្ទាប់នូវរបស់របរប្រើប្រាស់សេវាសារធារណះទាំងនោះ។
- អ្នកវិនិយោគផ្នែកឯកជន ធ្វើជាម្ចាស់របស់របរប្រើប្រាស់នោះពេញមួយជីវិតរបស់វា។
- អ្នកវិនិយោគផ្នែកឯកជន រកបានឡើងវិញនូវ ចំណាយប្រតិបត្តិ និង វិនិយោគតាមរយះប្រាក់ចំណេញពី ថ្លៃឈ្នួល, ការគិតប្រាក់សេវា រឺ ឈ្នួល។
- មានពេលកំណត់កិច្ចសន្យច្បាសាំលាស់។
- សុពលភាពនៃកិច្ចសន្យាផ្អែកទៅលើការប្រព្រឹត្ត។

ស្ថាបនា ប្រតិបត្តិ ផ្ទេរ (BOT) សម្បទាននេះ គឺស្រដៀងទៅនិងសម្បទាន BOO លើកលែងថា នៅពេលចុងបញ្ចប់ នៃសម្បទាន ភាពជាម្ចាស់នៃរបស់របរប្រើប្រាស់ ត្រូវប្រគល់ទៅអោយរដ្ឋាភិបាលវិញ។ ចំណាយប្រតិបត្តិ និង វិនិយោគ ដែលទទួលរងដោយអ្នកវិនិយោគ ចាំបាច់ត្រូវទទួលបានមកវិញតាមរយះការគិតប្រាក់ពីអ្នកប្រើ ប្រាស់។ ពេលវេលាដែលត្រូវការ ដើម្បីទទួលបានមកវិញនូវចំណាយប្រតិបត្តិ

និង វិនិយោគ តាមបែបផែនគឺជា កត្តាសំខាន់ ក្នុងការកំណត់ចំនុចមួយយូ ពេលដែលរបស់របរប្រើប្រាស់ត្រូវបានផ្ទេរមកវិញ។

ទោះបីជា កិច្ចសន្យា BOO និង BOT ជាធម្មតាត្រូវបានគេប្រើប្រាស់ ដើម្បីសម្បទានវិនិយោគ Greenfield, ក៏មានការផ្លាស់ប្តូរជាច្រើន ដូចជា អាគារសំរាប់, ការធ្វេីអោយល្អឡើងវិញ នូវរបស់របរដែល មានស្រាប់ហើយ តាមរយះ ធ្វើអោយល្អឡើងវិញ ប្រតិបត្តិ ផ្ទេរ, ហើយនិងការបន្ថែម ការវិនិយោគថ្មីក្នុងកំឡុងពេលការជួល។

ការផ្លាស់ប្តូរផ្សេងៗទៀត គឺ :

- រចនា-ស្ថាបនា (DB) – ត្រូវបានគេដឹងផងដែរថាជា សប្តានា-ផ្ទេរ, បែបផែននេះ ទាក់ទងទៅនិងរដ្ឋាភិបាលដែលបានចុះកិច្ចសន្យា អោយដៃគូរឯកជន រៀបចំរចនា និង ស្ថាបនា គ្រឿងបរិកម្មាយូ ដោយស្របជាមួយ តម្រូវការដែលបានកំណត់ដោយរដ្ឋាភិបាល។ រដ្ឋាភិបាល បន្តទទួលខុសត្រូវការប្រតិបត្តិ និង ថែទាំ គ្រឿងបរិក្ខាដែលធ្វើរួចរាល់ហើយ។
- រចនា-ស្ថាបនា-ថែទាំ – ដូចនៅក្នុងបែបផែន DB ដែរ, ផ្នែកឯកជន ថែទាំគ្រឿងបរិក្ខា នៅពេលដែលផ្នែកសារធារណះ រក្សាការទទួលខុសត្រូវចំពោះការប្រតិបត្តិ។
- រចនា-ស្ថាបនា-ប្រតិបត្តិ – ត្រូវបានគេស្គាល់ផងដែរថាជា សប្តានា-ផ្ទេរ-ប្រតិបត្តិ, បែបផែននេះ តម្រូវផ្នែកឯកជន ធ្វើការរចនា និង ស្ថាបនា នូវគ្រឿងបរិក្ខាមួយ ដែលនៅពេលបញ្ចប់ វាប្រតិបត្តិផងដែរក្នុងរយះពេលជាក់លាក់ណាមួយ។
- រចនា-ស្ថាបនា-ប្រតិបត្តិ-ថែទាំ – ផងដែរ សំដៅទៅលើ ថាជា BOT, បែបបទនេះ ផ្សំបញ្ចូលការទទួលខុសត្រូវ នៃការផ្តល់របស់ DB ជាមួយ ការប្រតិបត្តិ និង ថែទាំ នៃគ្រឿងបរិក្ខាសំរាប់ពេលវេលាជាក់លាក់ណាមួយ ដោយដៃគូរផ្នែកឯកជន។ ផ្នែកសារធារណះកាន់កាប់ប្រតិបត្តិការណ៍របស់ គ្រឿងបរិក្ខានោះ នៅចុងបញ្ចប់នៃរយះពេលមួយនោះ។
- BOOT – រដ្ឋាភិបាល ផ្តល់ដៃគូរឯកជន នូវសិទ្ធដើម្បី ផ្តល់ហារិញ្ញប្រទាន, រចនា, ស្ថាបនា និង ប្រតិបត្តិ គ្រឿងបរិក្ខាមួយ សំរាប់ពេលវេលាជាក់លាក់ណាមួយ។ ផែក្នសារធារណះ បន្តភាពជាម្ចាស់នៅចុងបញ្ចប់នៃរយះពេលមួយនោះ។
- BOO – អង្គភាពឯកជន គឺត្រូវបានផ្តល់សិទ្ធដើម្បី ផ្តល់ហរិញ្ញប្បទាន-រចនា-ស្ថាបនា-ប្រតិបត្តិ និង ថែទាំ គម្រោងមួយ។ អង្គភាពឯកជន រក្សាភាពជាម្ចាស់របស់គម្រោង។
- រចនា-ស្ថាបនា-ផ្តល់ហិរញ្ញប្បទាន-ប្រតិបត្តិ/ថែទាំ – ផ្នែកឯកជន រចនា-ស្ថាបនា-ផ្តល់ហិរញ្ញប្បទាន-

ប្រតិបត្តិ /ថែទាំ គ្រឿងបរិក្ខាថ្មីមួយ ក្រោមកិចសន្យាជួលរយៈពេលវែង ហើយនៅចុងបញ្ចប់នៃកុងត្រា នោះ គ្រឿងបរិក្ខា នឹងត្រូវបានផ្ទេរទៅអោយផ្នែកសារធារណៈ។ ក្នុងប្រទេសមួយចំនួន, នេះ រួមបញ្ចូលទាំង BOO និង BOOT។

PPPs អាចត្រូវបានគេប្រើផងដែរ សំរាប់សេវា និង គ្រឿងបរិក្ខា ដែលមានស្រាប់តាមរយៈយន្តការខាងក្រោមៈ

- កិច្ចសន្យាសេវា – អង្គភាពឯកជន ត្រូវបានចុះហត្ថលេខា ដើម្បីផ្តល់សេវា ដែលត្រូវបានធ្វើពីមុន ដោយរដ្ឋាភិបាល។
- កិច្ចសន្យាគ្រប់គ្រង – មិនដូចជាកិច្ចសន្យាសេវា, អង្គភាពឯកជន នៅក្នុងកិច្ចសន្យាគ្រប់គ្រង គឺទទួលខុសត្រូវនូវ រាល់ទិដ្ឋភាពទាំអអស់របស់ ការប្រតិបត្តិ និង ការថែទាំរបស់គ្រឿងបរិក្ខា។
- កិច្ចសន្យាជួល – អង្គភាពឯកជន ត្រូវបានគេផ្តល់នូវ ផលប្រយោជន៍ពីការជួលទ្រព្យសម្បត្តិរដ្ឋ, ដៃគូរឯកជន ប្រតិបត្តិ និង ថែទាំ ទ្រពស្យម្បត្តិនោះ អោយស្របជាមួយនិង លកខណ្ឌក្នុងកិច្ចសន្យាជួល។
- សម្បទាន – អង្គភាពឯកជន ត្រូវបានគេផ្តល់អោយ សិទ្ធផ្តាច់មុខ ដើម្បីផ្តល់, ប្រតិបត្តិ និង ថែទាំ ទ្រព្យសម្បត្តិរដ្ឋ លើរយៈពេលវែងណាមួយ ដោយស្របជាមួយ តម្រូវការនៃការប្រព្រិត្តិ ដែលបានកំណត់ជាមុន ដោយរដ្ឋាភិបាល។ ទ្រព្យសម្បត្តិដើម គឺត្រូវបានកាន់កាប់ដោយផ្នែកសារធារណៈ នៅពេលមានការកែប្រែណាមួយ ត្រូវបានធ្វើឡើង នៅក្នុងកំឡុងពេលសម្បទាន ដែលបានកាន់កាប់ដោយអង្គភាពឯកជន។
- ការលក់ចេញ – ទ្រព្យសម្បត្តិរដ្ឋ គឺត្រូវបានលក់ទៅអោយផ្នែកឯកជន ទាំងអស់ រឺ មួយផ្នែក ហើយជាធម្មតា ទៅលើលកខណ្ឌ ដែលការកែប្រែត្រូវបានធ្វើឡើង និង ពលរដ្ឋ ត្រូវបានគេបន្តបំរើ។ និន្នាការបច្ចុប្បន្ន គឺ ការទទួលបានល្អបំផុត ដែលជាការប្រកួតប្រជែងបើកចំហ សំរាប់ការផ្តល់នូវរាល់សេវារដ្ឋទាំងអស់ ដោយការសាកល្បងទីផ្សារ។ ក្នុងករណីនេះ, ផ្នែកឯកជន បញ្ជាក់ពីលក្ខខណ្ឌនៃភាពជាដៃគូរនៅក្នុង ឯកសារស្នើរសុំ។

## ៣.៣ គុណសម្បត្តិ និង គុណវិបត្តិរបស់ PPPs

PPPs មាននូវ គុណសម្បត្តិ, ហានិភ័យ, និង គុណវិប្បត្តិ ពិតប្រាកដ។ ផ្ទុយមកវិញ, PPPs ពឹងផ្អែកទៅលើទំនាក់ទំនងរវាង អ្នកប្រតិបត្តិ ដែលជាធម្មតា ខ្វះការយល់ដឹងពីគ្នាទៅវិញទៅមក, រឺដែលពេលខ្លះមានការសង្ស័យ លើគ្នាទៅវិញទៅមក។ ប្រសិនបើ គម្លាតដែលញៀក អ្នកប្រតិបត្តិផ្នែកឯកជន ពីផ្នែកសារធារណៈ អាចត្រូវបានគេ យកឈ្នះបាន, ប្រសិនបើដៃគូរទាំងពីរ អាចធ្វើការជាមួយគ្នា, ហើយនិង

ប្រសិនបើ មានកឱកាសប្រាកដមួយដើម្បី កែប្រែ និង ធ្វើអោយរីកចំរើន លទ្ធផលគម្រោង តាមរយៈការប្រើប្រាស់ PPPs, បន្ទាប់មកនោះ មនុស្សរាល់គ្នា មានអត្ថប្រយោជន៍។

**អត្ថប្រយោជន៍ ចំពោះផ្នែកសារធារណៈ**

តើកន្លែងណា ដែលផ្នែកជនមានសប្រសិទ្ធភាពជាង ផ្នែកសារធារណៈ ? ក្នុងករណីទាំងនេះ, ផ្នែកឯកជន អាចផ្តល់ ជំនាញ ដែលមិនអាចរកបានកង្នុផ្នែកសារធារណៈ, ដូចជា ការអភិវឌ្ឍន៍នូវ ដំណោះស្រាយពត៌មានវិទ្យា ដ៏ស្មុគ ស្មាញ រឺ សូម្បីតែ សាមញ្ញ មួយ។ ផ្នែកឯកជន អាចនឹងលជ្អាងផងដែរ ចំពោះការគ្រប់គ្រងគម្រោងទាំងមូល និង នាំយក ល្បាយនៃដៃគូរ ដ៏ត្រឹមត្រូវមួយ ជាមួយគ្នា។ ផ្នែកឯកជន អាចនឹងល្អជាងផងដែរ ក្នុងការគ្រប់គ្រង ការ ផ្គត់ផ្គង់ និងការប្រតិបត្តិ ក្រោមកាលៈទេសៈ ណាមួយ, ជាពិសេសនៅពេលដែល ការងារដែលត្រូវធ្វើ គឺថ្មីកហើយ ចំពោះ អ្នកប្រតិបត្តិផ្នែកឯកជន។ ផ្នែកឯកជន ជាធម្មតា មានវិធានផគ្គ់ផ្គង់បត់បែនច្រើនជាង ផ្នែកសារធារណៈ ដែលអាចធ្វើការអោយមាន អត្ថប្រយោជន៍ ដល់ ផែនការ និង ការអនុវត្តន៍ គម្រោង។

PPPs ដែលពាក់ពន្ធ័ហិរញ្ញប្បទានឯកជន ផងដែរអាចសម្រួល បញ្ហាពន្ធអាករ ដោយការប្តូរ គម្រោងហេដ្ឋារចនា សម្ពន្ធ័ ចេញពីថវិកា ក្នុងកំឡុងឆ្នាំនៃការស្ថាបនា។ ប្រសិនបើលកខណ្ឌ័ត្រឹមត្រូវ, "សក្តានុពលសំរាប់ ការរៃអង្គាសមូលនិធិ លើទីផ្សារទុន ទាំងពីរ ក្នុងស្រុក និង ក្រៅស្រុក អាចត្រូវបានគេពង្រឹង ដោយការធ្វើកំណែទម្រង់ គោល នយោបាយដែលបង្កើតវិធានច្បាស់លាស់, ដែលអនុញ្ញតិអោយ អ្នកវិនិយោគបង្កើត ការរំពឹងគិតម៉ឺងម៉ាត់ និង សម ហេតផល អំពី លំហូរសាច់ប្រាក់ដែលបានបងេក្តីឡើងក្នុងជំនួញហេដ្ឋារចនាសម្ពន្ធ័។ "

អត្ថប្រយោជន៍ដែលរដ្ឋាភិបាលអាចទាញចេញពី PPPs អាចត្រូវបានគេសង្ខេបដូចខាងក្រោមៈ

- ប្រសិទ្ធភាពដែលកើនឡើង ក្នុងការប្រតិបត្តិគម្រោង
- វិនិយោគដែលកើនឡើង ជាមួយទ្រព្យសម្បត្តិសារធារណៈ ដោយគ្មានការបង្កើនបនក្ទុពន្ធអាករ
- ភាពប្រាកដនៃថវិកាដែលបានកែប្រែ
- ការចំណាញពេញមួយជីវិត, វិធីសាស្ត្រមួយនៃការវាយតម្លៃ រឺការប្រៀបធៀប គ្រឿងផ្សំ និង សំភារៈ សាង់សង់ ដោយមើលទៅលើ ចំណាយការតំឡើង, អាយុកាល, ចំណាយក្នុងការដំណើរការ និង ថែទាំ។
- តម្លៃសំរាប់ប្រាក់ ( ប្រសិទ្ធភាពដែលបានកែប្រែ )

- កំនើន និង បំរែបំរួល សេដ្ឋកិច្ច
- និយមន័យ នៃតម្រូវការផ្នែកសារធារណៈ ក្នុងន័យ ទិន្នផលសេវា និង ស្តង់ដារការប្រព្រឹត្ត
- ការផ្ទេរ ហានិភ័យទៅ ភាគីដែលអាចគ្រប់គ្រងហានិភ័យបានល្អបំផុត (ឧទា, ការសាងសង់, ការអនុវត្តន៍ ការបពាល្កូគ្នា និង ការប្រតិបត្តិ )
- ហានិភ័យដែលបានកាតបន្ថយ សំរាប់ផ្នែកសារធារណៈ
- ការអនុញ្ញាតិអោយរដ្ឋាភិបាល ផ្តោតទៅលើ យុទ្ធសាស្រ្ត និង គោលនយោបាយ

**សំរាប់សេវាសារធារណៈ**

- ការពង្រឹងសមត្ថភាពអនុវត្តន៍
- ការចល័តធនធានហិរញ្ញវត្ថុ
- ការធ្វើអោយមាន នូវមូលនិធិសារធារណៈដែលខ្វះខាត សំរាប់ការប្រើប្រាស់ផ្សេងៗ
- រចនា, កសាង, ដំណើរការ កិច្ចសហការដើម្បីបានលទ្ធផលល្អ
- លើកទឹកចិត្តដល់ ការកែប្រែថ្មី ក្នុងការផ្តល់សេវាសារធារណៈ

**អត្ថប្រយោជន៍ ចំពោះផ្នែកឯកជន**[៤៤]

សំរាប់ផ្នែកឯកជន, PPPs ដាក់ចុះនូវ អត្ថប្រយោជន៏ខាងក្រោមៈ

- ការឈានចូលទៅក្នុង ទីផ្សារ និង ឱកាស ថ្មីៗ
- រដ្ឋាភិបាល គឺជាអតិថិជនដែលអាចពឹងផ្អែកបាន
- មានភាពប្រាកដនៃកិច្ចសន្យា ជាមួយរដ្ឋភិបាល
- កំរិតខ្ពស់នៃភាពអាចព្យាករណ៏បាន នៃលំហរូសាច់ប្រាក់

**បញ្ហា និង កង្វល់**

PPPs ខ្លះៗ គឺជាសម្បទានដែលត្រូវបានផ្តល់ទៅអោយផ្នែកជន ក្នុងការផ្លាស់បរ្ត សំរាប់ការទទួលហានិភ័យផ្សេងៗ ដែលភ្ជាប់ជាមួយនិងគម្រោង។ ក្នុងការផ្លាស់ប្តូរសំរាប់ ការប៉ាន់ស្មានហានិភ័យ, អ្នកប្រតិបត្តិផ្នែកឯកជន ជាធម្មតា ត្រូវគេធានានូវ សម្បទានផ្តាច់មុខសំរាប់សេវាសារធារណៈ ក្រោមលកខណ្ឌ៏

នៃអំណាចទីផ្សារ, អាចនិយាយថា, ភាពផ្តាច់មុខ ទាំងស្រុង រឺក៏ស្មើរតែ លើសេវាដែលកំពង់បានផ្តល់អោយ។ នៅពេលដែល បញ្ហានេះ អាចជាសំណើរ ដែលទាក់ទាញមួយសំរាប់ផ្នែកឯកជន, រដ្ឋាភិបាល នឹងត្រូវតែធានាថា ផលប្រយោជន៏របស់សារធារណះជន ត្រូវ បានគេការពារ។

បញ្ហាសំខាន់មួយ នឹងជាប្រតិកម្មរបស់ សារធារណះជនចំពោះការផ្តល់សេវាសារធារណះ សំរាប់ការបង់ថ្លៃ។ ប្រសិនបើ PPP គឺសំរាប់ ការផ្តល់សេវាដែលគ្មានពអ្នកណាអាចរកបានពីមុនមក, ប្រហែលជាគ្មាននូវការជំទាស់ រឺក៏តិចតួច ហើយនិងមានការគាំទ្រជាសារធារណះ។ សេវាសារធារណះដែលបានធ្វើអោយមានតាមរយះ PPP អាចជា សេវាដែលត្រូវបានគេពង្រឹង សំរាប់អ្នកណា ដែលបានត្រៀមខ្លួនបង់ប្រាក់សំរាប់សេវានោះ, ដូចជាការស្ថាបនា និង ដំណើរការ របស់ផ្លូវហាយវេ ជាផ្លូវមួយដែលអាចជ្រើសរើសបាន។

ក៏ប៉ុន្តែបែបផែន PPP អាចមានលកខណ្ឌ័។ នៅកង្មករណីខ្លះ, ពួកគេអាច ត្រូវបានគេរៀបចំរចនាសម្ពន្ធ័ ជុំវិញភាព្របាកដដែលបានសម្រេច នៃអ្វីដែលគេត្រូវការ និង បញ្ហានេះ តម្រូវនូវ ការកំណត់ច្បាស់លាស់មួយ នៃការផ្ទេរហានិភ័យ និង ភាពទទួលខុសត្រូវ។ បញ្ហានេះ មិនតែងតែអាចធ្វើបានទេ។ PPPs ត្រូវបានគេធ្វើអោយ សាកសម្បជាង សំរាប់ គម្រោងរយះពេលវែង ដែលមានតម្លៃខ្ពស់ ដើម្បីអោយពេលគ្រប់គ្រាន់សំរាប់ដៃគូរផ្នែក ឯកជន បានមកវិញនូវការវិនិយោគរបស់ខ្លួន។ វាប្រហែលជាពិបាកផងដែរ ដើម្បីប្តូរកិច្ចសន្យានៅពេលដែលសេវា ស្ថិតនៅក្នុង ទីតាំងនៃអានុភាពដែលទាក់ទង។

ផងដែរ PPPs ប្រហែលជាមិនអាចធ្វើអោយសាកសម្ប ចំពោះ គម្រោង អាយ ស៊ី ធី មួយចំនួនដែលបច្ចេកវិទ្យា កំពង់តែផ្លាស់ប្តូរយ៉ាងរហ័ស។ ក្រោមកាលទេៈសៈនេះ, វាប្រហែលជាមិនអាចធ្វើបានដើម្បីពព្យារណ៏ ចំណាយ និង លទ្ធផល។ ធម្មជាតិនៃការប្រឹងប្រែងដែលគេតម្រូវ ប្រហែលជាពិបាក និងប៉ាន់សន្មា ពីព្រោះ ដំណោះស្រាយ និង ដំណើរការដែលគេស្នើរ អាចពិបាកនិង វាស់វែង និង គូសព្រាង។ លើសពីនេះទៅទៀត គម្រោង អាយ ស៊ី ធី មួយចំនួន អាចតម្រូវនូវ កិច្ចការអភិវឌ្ឍន៏ដ៏សំខាន់មួយក្នុងទំរង់នៃការអភិវឌ្ឍន៏ រឺ ការសរសេរកូដ កម្មវិធី, ដែល អាចពិបាកនិង វាស់វែង នៅពេលដែល កម្មវិធី (software) និង ធនធានកម្មសិទ្ធបញ្ញា គឺជារបស់របរដែលគ្មានរូបរាង។ ជាចុងបញ្ចប់, ដូចដែលបានបង្ហាញដូចខាងក្រោម, គម្រោង អាយ ស៊ី ធី មួយចំនួន គឺពោរពេញទៅដោយ គ្រោះថ្នាក់។

## ៣.៤ គោលការណ៍នៃការអនុវត្តន៍

ដើម្បីធានាថា ការងារ PPP សំរាប់ភាពល្អវិសេសវិសាល នៃភាពជាដៃគូរផ្នែកសារធារណៈ និង ឯកជន, គោលការណ៏ផ្សេងៗមួយចំនួន ចាំបាច់ត្រូវត្រួតពិនិត្យ។ ទាំងនេះ គឺ :

- **ការផ្ទេរហានិភ័យ** – កំណត់ការបែងចែកហានិភ័យជុំវិញ សេវាដែលត្រូវបានចែកចាយ។
- **ការបញ្ជាក់លំអិតនៃលទ្ធផល** – វាយរាប់ពីលទ្ធផលសេវា ជៀសជាង ពីសណាន្ទានៃទ្រព្យទុន រឺ ធនធានទុន។
- **ការប្រព្រឹត្តនៃរបស់របរប្រើប្រាស់ពេញមួយជីវិត** – កិច្ចសន្យា គួរតែបង្ហាញ កាតព្វកិច្ចរបស់ដៃគូរ ឯកជន ដើម្បីប្រាកដថា ការប្រព្រឹត្តនៃរបស់របរប្រើប្រាស់ សំរាប់កំឡុងពេលដ៏សំខាន់នៃជីវិតដែលមាន ប្រយោជន៏របស់ពួកគេ។
- **ការប្រព្រឹត្ត-ដែលទាក់ទង រង្វាន់ បានទាក់ទង** ទៅ :
  - លទ្ធផល និង ភាពដែលអាចរកបាន
  - គ្មាន ការធានា រឺ មានកំណត់ សំរាប់ការបង់ប្រាក់
  - ការពិន័យនៃការប្រព្រឹត្តមិនល្អ
- **ការបញ្ចប់ការរៀបចំ** – កំឡុងពេលនៃភាពជាដៃគូរ គួតែបានបញ្ជាក់ ជាមួយនិង ការរៀបចំ សំរាប់ការ បោះបង់របស់របរប្រើប្រាស់ នៅចុងបញ្ចប់នៃរយះពេលដែលបានបពាក្ទា។

កិច្ចសន្យាដែលបានរៀបចំល្អ សំរាប់គម្រោង PPPs ផ្តោតទៅលើ លទ្ធផលដែលកំណត់ និង ទិន្នផលដែលទាក់ ទង-សេវា និង មិនមែនទៅលើ ការវាស់វែង ដើមទុនដែលបញ្ចូល ទេ។ នេះ មានន័យថា លទ្ធផលនៃគម្រោង PPP នឹងត្រូវបានវាស់វែង ក្នុងនយ័នៃសេវាដែលគេចែកចាយ ដូចជា ការចែកចាយ ការដឹកជញ្ជូនសារធារណៈ ដល់ ស្តង់ដារសេវាដែលកំណត់, ជៀសជាង របស់របរដែលគេផ្តល់ ដូចជា ចំនួនរថយន្តក្រុងដែលគេផ្តល់អោយ សំរាប់ ការដឹកជញ្ជូនសារធារណៈ។

មូលដ្ឋានច្បាប់សំរាប់ PPPs

មុនពេលដែល PPPមួយ អាចប្រព្រឹត្តទៅ, មនាការសេចក្តីត្រូវការមួយ ដើម្បីកំណត់មូលដ្ឋានច្បាប់របស់វា។ ជាក្បួនខ្នាតទូទៅ, PPPs គឺជាការរៀបចំដែលមានកិច្ចសន្យា ដែលអាចគេបង្កើតឡើង នៅក្រោមច្បាប់ និង បទបញ្ញាតិដែលមានស្រាប់។ របបបញ្ញាតិមានស្រាប់ ដែលអនុវត្តនច៏ពោំផ្ទែះកមួយដែលក្នុងនោះ PPP នឹងកើតឡើង នឹងអនុវត្តន៍ជាធម្មតា។ នៅក្នុងករណីនៃគម្រោង អាយ ស៊ី ធី, ទាំងនេះ នឹងជាបទបញ្ញាតិ

នៅក្នុង ផ្នែកទូរគមនាគមន៍ និង ផ្នែកថាមពល។ ច្បាប់ដែលដាក់បញ្ញាតិលើការប្រកួតប្រជែង នឹងអនុវត្តន៍ផងដែរ។
នៅពេលដែល PPPs ជាធម្មតាត្រូវបានគេស្នើរឡើង, ច្បាប់, បទបញ្ញាតិ, និង និតវិធី ផត់ផ្គង់ នឹងអនុវត្តន៍ ជាធម្មតា។

តម្រូវការផ្សេងៗទៀត គឺការរកអោយឃើញ ថាតើ PPPs ត្រូវបានអនុញ្ញាតិដោយច្បាប់ រឺទេ។ តើអងភ្នាពរដ្ឋ អាច បង្កើត, ប្រតិបត្តិ និង ថែទាំ ផលិតផល អាយ ស៊ី ធី តាមរយះអងភ្នាពក្រៅរដ្ឋាភិបាល លើមូលដ្ឋានកិច្ចសន្យា មួយ ដែររឺទេ ? តើវាអាចធ្វើបានទេ សំរាប់រដភ្នាបិលា ចាត់តាំងភារកិច្ចនៃគណៈប្រតិបតរ្ដិដ្ឋ ចំពោះ អង្គការដ៏ទៃ ទៀត រួមទាំង អ្នកប្រតិបត្តិផ្នែកឯកជន ? នៅក្នុងប្រទេសម៉ុងហ្គោលី ជាឧទាហរណ៍, វាអាចធ្វើទៅបានសំរាប់ អង្គការក្រៅរដ្ឋាភិបាល ប្រតិបត្តិ ការសំរេចចិត្តរបស់រដ្ឋាភិបាល។ ក្នុងករណីនេះ, អង្គការក្រៅរដ្ឋាភិបាល នឹងទទួល ខុសត្រូវចំពោះ ក្រសួងរដ្ឋដែលពាក់ពន្ធ័។

ក្នុងកណើនៃ អាយ ស៊ី ធី PPPs, សំនួរមួយក្នុងសំនួរជាច្រើន ដែលចាំបាច់ត្រូវសួរ គឺ ថាតើ ច្បាប់ដែលមានស្រាប់ គឺ ‘ស្របនិងច្បាប់-អេឡិចត្រូនិច’ ទេ។ ជាលំអិត, តើច្បាប់ដែលមានស្រាប់ ស្របជាមួយនិងតម្រូវការសំរាប់ ពាណិជ្ជកម្ម-អេឡិចត្រូនិចទេ? តើ កិច្ចសន្យា-អេឡិចត្រូនិច, កិច្ចការជំនួញ-អេឡិចត្រូនិច និង ហត្ថលេខាអេឡិច ត្រូនិច ត្រូវបានអនុញ្ញាតិ ទេ? តើ គណៈនីតិកម្ម ដែលមានស្រាប់ ជា អព្យាក្រឹត-អេឡិចត្រូនិច – នោះគឺថា រាល់ការផ្តលនៅក្រោមច្បាប់ អនុញ្ញាតិសំរាប់ការប្រើប្រាស់ កិចក្ខារជំនួញអេឡិចត្រូនិច ជាជម្រើសមួយ។ មិនគួរ មាន តម្រូវការណាមួយដើម្បីបង្កើតឯកសារក្នុងទំរង់ដែលមានរូបរាង តែមួយនោះទេ; ទំរង់-អេឡិចត្រូនិច គឺអាច អនុញ្ញាតិអោយ ផងដែរ ក្រោមលកខណ្ឌដែលផ្តល់អោយ ដែលអាចតម្រូវថា ឯកសារគួរតែបានចុះហត្ថលេខា និង អះអាង ជាអេឡិចត្រូនិច។

ការពិចារណាផ្នែកច្បាប់ដ៏ទៃទៀត គឺថាតើ សេវាសារធារណៈ អាចត្រូវបានគេផ្តល់ផងដែរជាអេឡិចត្រូនិច ទេ។
ដោយស្រដៀងគ្នា, ច្បាប់ត្រូវតែអនុញ្ញតិ រឺ យ៉ាងហោចណាស់មិនច្រានចោល ការផ្តល់សេវាសារធារណៈ ដោយប្រើ បែបផែនពាណិជ្ជកម្ម មួយ។

សំណួរផ្នែកច្បាប់ផ្សេងៗទៀត ដែលត្រូវការអោយគេបញ្ជាក់អោយច្បាស់ និង ធ្វើអោយស្របទៅតាម PPP គឺនៅខាងក្រោមនេះ :
-តើមាន តម្រូវការដែលនៅក្រោមច្បាប់ ដែលអ្នកផ្តល់សេវា PPPមួយ ្រត្ូវបានគេផ្តល់អជ្ញាបណ្ណ ទេ? តម្រូវករាដែលបានអជ្ញាបណ្ណ អាចអនុញ្ញាតិអោយ ការអនុវត្តន៍របបបពាគ្នា ិមួយ្ឃ ី មធ្យោបាយត្រួតពិនិត្យ និង ការដាក់បញ្ញាតិដល់ប្រតិបត្តិការណ៍ដែលបានចាត់ទុកជា PPPមួយ។ ម្យ៉ាងវិញទៀត នេះ អាចផងដែរនាំទៅដល់ បទបញ្ញត្តិ-ជ្រុល នៃផ្នែកមួយ, ចំពោះការខូចខាចនៃសមត្ថភាពរបស់ដៃគូរផ្នែកឯកជនដើម្បីកែប្រែការចែកចាយ សេវាចាំបាច់, ក្នុងការអភិវឌ្ឍន៍ប្រពន្ធ័បង់ប្រាក់ដើម្បីអោយគេប្រើ – ជាសង្ខេប ចំពោះការខូចខាតនៃ PPP។
-តើមានច្បាប់អនុញ្ញាតិអោយ ការបង់ប្រាក់-អេឡិចត្រូនិច ទេ? នេះគឺជាទិដ្ឋភាពមួយ នៃ ពាណិជ្ជកម្ម-អេឡិចត្រូនិចដែលគេតម្រូវអោយនូវចំកន្លែង ប្រសិនបើ ជម្រើសការបង់ប្រាកអេឡិចត្រូនិចត្រូវបានគេពិចារណា។ ផងដែរ វាត្រូវបានគេតម្រូវដើម្បី កំណត់ថាតើ ច្បាប់ដែលគ្របដណ្តប់ ការផ្តល់សេវាសំរាប់ សេវា-អេឡិចត្រូនិច ក្រោមការរៀបចំ PPPមួយ។ ស្រដៀងគ្នានេះ, វានឹងចាំបាច់ដើម្បីពិចារណា ច្បាប់ធានាគារអ្វីអនុញ្ញាតិអោយ។ នៅពេល ឧទាហរណ៍ជាច្រើននៃ PPPs អាចត្រូវបានគេរកឃើញ នៅក្នុងប្រទេសអភិវឌ្ឍន៍ ដែលតួនាទីនៃ ផ្នែកឯកជនតូវបានបង្កើតឡើងយ៉ាងល្អ និង ដែលមានច្បាប់ដែលការពារអ្នកប្រើប្រាស់ និងធានានូវ ទីលានរាបស្មើរ មួយ ដើម្បីអោយការប្រកួតប្រជែង កើតឡើង, នេះមិនមែនជាករណីនៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ទេ ដែល ផ្នែកឯកជនមិនត្រូវបានបង្កើតយ៉ាងល្អ និង សមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍ និងគ្រប់គ្រង នៅមាន កំណត់។
ដូចចំនុចចាប់ផ្តើម ក្នុងប្រទេសជាច្រើនបែបនោះ, មានការចាំបាច់ ដើម្បីពន្យល់អោយច្បាស់ទៅដល់ ប្រជាជន និង អត្ថប្រយោជន៍នៃ PPPs រួមនិង គ្រោះថ្នាក់។ PPPs ជាច្រើន គឺជាឱកាសផ្តាច់មុខ ដែលត្រូវតែបានគេគ្រប់គ្រង ដោយយកចិត្តទុកដាក់ និងដាក់បញ្ញាតិ ដើម្បីរារាំងការរំលោភបំពាន និង ដើម្បីសុវត្ថិភាពប្រយោជន៍សារធារណះ។
ផងដែរ អាចមានការចាំបាច់ ដើម្បីលើកទឹកចិត្តដល់ អ្នកប្រតិបត្តិផ្នែកឯកជនក្នុងស្រុក អោយធ្វើជាដៃគូរ ជាមួយ អ្នកវិនិយោគបរទេស។ នេះ គឺដើម្បីទទួលបាន នូវការផ្ទេរនៃជំនាញ និង បញ្ចូលធនធានហិរញ្ញវត្ថុ ដើម្បីធានាថា PPP មួយអាចជោគជ័យ។ យ៉ោងទៅលើបញ្ហានេះ, PPP មួយ គឺ ដូចជាវិនិយោគបរទេសដ៏ទៃទៀត និង ការការពារដែលគ្រប់គ្រាន់ ត្រូវការដាក់អោយចំកន្លែង ដើម្បីប្រាកដថា ក្រុមហ៊ុនក្នុងស្រុក រួមទាំងវិនិយោគ បរទេស បានផលប្រយោជន៍ពី ការរៀបចំ PPPមួយ។ ដោយការធ្វើដូចនេះ, ប្រទេសអាចធានា មិនគ្រាន់តែថា ប្រាក់ចំណេញមួយចំនួន សល់នៅក្នុងប្រទេស

ប៉ុន្តែថែមទាំង ថាជំនាញការបច្ចេកទេស និង គ្រប់គ្រងត្រូវបានផ្ទេរដើម្បីជាប្រយោជន៍ដល់ប្រទេសជាម្ចាស់ផ្ទះ។

សនិដ្ឋាន

តារាងទី ៣ សង្ខេបពី បុរេលក្ខខណ្ឌខ្លះៗ សំរាប់ PPPដ៏ជោគជ័យ។

តារាងទី ៣ សង្ខេបពី បុរេលក្ខខណ្ឌខ្លះៗ សំរាប់ PPPដ៏ជោគជ័យ

Source: Rahzeb Chowdhury, “PPPs in e-Government: Introduction to PPPs and commercial models” (presentation made in Ulaanbaatar, Mongolia, 26 June 2007).

## ៤. គម្រោង PPP និង រដ្ឋាភិបាល-អេឡិចត្រូនិច

ផ្នែកនេះមានគោលបំណងដើម្បី :

- ពិភាក្សាអំពី ការពាក់ពន្ធ័ នៃ PPP ជាជម្រើសផ្តល់ហិរញ្ញប្បទាន សំរាប់ គំនិតផ្តួចផ្តើម រដ្ឋាភិបាល-អេឡិចត្រូនិច
- គូសគ្រោងនូវ កត្តាគន្លឹះ ដើម្បីពិចារណា ក្នុងការអនុវត្តន៍ PPP ចំពោះគម្រោងរដ្ឋាភិបាល-អេឡិចត្រូនិច, ដែលរួមបញ្ចូល លកខ័ណ្ឌ សំរាប់ការប្រើប្រាស់ ដ៏ជោគជ័យនៃ PPP ក្នុងគម្រោងរដ្ឋាភិបាលអេឡិចត្រូនិច
- ពិពណ៌នាអំពី ឧទាហរណ៏អនុវត្តន៏ដ៏ល្អ មួយចំនួន នៃ PPPs ក្នុងរដ្ឋាភិបាល-អេឡិចត្រូនិច

### ៤.១ និន្នាការ ក្នុង រដ្ឋាភិបាល-អេឡិចត្រូនិច

PPPs សំរាប់ អាយ ស៊ី ធី នៅក្នុងផ្នែកសារធារណៈ ត្រូវបានគេប្រើយ៉ាងសំខាន់ សំរាប់គម្រោង រដ្ឋាភិបាល-អេឡិចត្រូនូចិ។ វាមានសារសំខាន់ ដើម្បីនិយាយរឿងពីរបី អំពី រដ្ឋាភិបាល-អេឡិចត្រូនិច ដើម្បីកំណត់ ពីរូបភាព។

មូលហេតុសំខាន់សំរាប់ការប្រើ អាយ ស៊ី ធី និង ការគ្រប់គ្រងដែលទាក់ទង នៅក្នុងផ្នែកសារធារណៈ គឺត្រូវពង្រឹង ការចែកចាយសេវាទៅសារធារណៈជន។ នេះ តម្រូវអោយមាន ការកែប្រែប្រសិទ្ធភាពនៃរដ្ឋាភិបាល។ ជាការពិត រដ្ឋាភិបាល-អេឡិចត្រូនិច តម្រូវនូវ ការផ្លាស់ប្តូរដ៏ធំ ក្នុងរបៀបដែលផ្នែកឯកជនធ្វើជំនួញ និង ទាក់ទងទៅ អតិថិជនរបស់ពួកគេ, សារធារណៈជន។ ដ្រាបាលដែលបានអភិវឌ្ឍន៏កម្មវិធីរដ្ឋាភិបាល-អេឡិចត្រូនិចដ៏ជោគជ័យ បានចាប់ផ្តើម ដោយ ការអភិវឌ្ឍន៍ ទឹកចិត្ត នៃសេវានៅក្នុងមន្ត្រីរាជការ។ ការផ្លាស់ប្តូរការគ្រប់គ្រង និង ការរៀប ចំគ្រឿងម៉ាស៊ីនឡើងវិញ នៃដំណើរការជំនួញក្នុងរដ្ឋាភិបាល គឺចាំបាច់ សំរាប់ការផ្លាស់ប្តូរនេះ កើតឡើង។

ក្នុងបែបផែននៃ រដ្ឋភិបាល-អេឡិចត្រូនិច, រដ្ឋាភិបាល ផ្លាស់ប្តូរខ្លួនឯង ដើម្បីបំពេញតម្រូវការរបស់សារធារណះ ជន និង សំរេចបាន ប្រសិទ្ធភាពដំណើរការជំនួញ តាមរយៈការផ្តល់សេវាចែករំលែក។ នោះគឺថា សេវារដ្ឋាភិបាល គឺត្រូវបានគេធ្វើអោយមានប្រសិទ្ធភាព និង ពង្រឹង ដើម្បីផ្តល់សារធារណៈជន

ជាមួយនិង សោវាយ៉ាងឆាប់ និង មានប្រសិទ្ធភាព តាមរយះដំណោះស្រាយបើកចំហរមួយ។ យោងទៅលើ Accenture, សេវាចែករំលែក គឺ :
ការពង្រឹងរដ្ឋបាល រឺ គាំទ្រមុខងារ (ដូចជា ធនធានមនុស្ស, ហិរញ្ញវត្ថុ, ពត៌មានវិទ្យា, និងផ្នែកផ្គត់ផ្គង់) ពីនាយកដ្ឋានផ្សេងៗ រឺ ក្រសួង ទៅក្នុង អង្គភាពដែលរៀបចំអោយដាច់តែឯង និង តែមួយ ដែលបេសកកម្មតែមួយ របស់វា គឺត្រូវផ្តល់សេវា អោយមានប្រសិទ្ធភាព ដូចដែលអាចធ្វើបាន។ សេវាចែករំលែក ធ្វើអោយមាន នូវ មូលនិធិែដលខ្វះខាត ដើម្បីអោយនាយកដ្ឋាន រឺក្រសួង ផ្តោតលើជំនួញសំខាន់របស់ពួកគេ និង ទៅលើតម្រូវការ អតិថិជនរបស់ពួកគ, នៅពេលដែលផ្តល់ ភាពបត់បែននៃអង្គការ ដេម្បីមានរចនាសម្ពន្ធ័រដ្ឋបាលផ្នែកក្រោយ ដែល ពឹងផ្អែកលើ សកម្មភាព និង រចនាសម្ពន្ធ័ជួរមុខ។

ទំរង់មួយចំនួនដែលគេទទួលយកយ៉ាងទូលំទូលាយច្រើនបំផុត នៃសេវាចែករំលែក កើតឡើងលើ ការផ្តល់សេវា ពត៌មានវិទ្យា ក្នុងផ្នែកសារធារណះ, រួមទាំងក្នុង សេវាហិរញ្ញវត្ថុ, សេវាគ្រប់គ្រងធនធាន មនុស្ស,សោវាទិញបណ្តាក់ គ្រឿងផ្គត់ផ្គង់។ សេវាចែករំលែក អាចត្រូវបានអនុវត្តន៏ តាមរយះ :

- ក្នុង-ប្រភព – រដ្ឋាភិបាល និយោជិក បុគ្គលិក សេវាចែករំលែក អង្គការ
- សហ-ប្រភព – រដ្ឋាភិបាល ធ្វើការជាមួយ ដៃគូរជំនួញយុទ្ធសាស្រ្ត
- ភាពប្រថុយប្រថានរួម ឯកជន-សារធារណះ
- ការទទួលយក ដំណើរការជំនួញ
- បន្សំនៃការរៀបចំប្រភព

ជម្រើសនៃយុទ្ធសាស្រ្ត សំរាប់ការចែកចាយសេវាចែករំលែក គឺផ្ដែកទៅលើ ការពីចារណាមួយចំនួន, ដែលរួមទាំងសុវត្ថិភាពនៃទិន្នន័យ។

មានប្រភេទមួយចំនួននៃ គម្រោង អាយ ស៊ី ធី ក្នុងរដ្ឋាភិបាលៈ

- គម្រោង សម្ភារះ/ហេដ្ឋារចនាសម្ពន្ធ័ ធំ –ការកសាង Networks, ហេដ្ឋារចនាសម្ពន្ធ័ទូរគមនាគមន៏...។ល។
- សេវាពត៌មានវិទ្យា – ថៃទាំ, បណ្តុះបណ្តាល, ទ្រទ្រង់
- កម្មវិធី Software ដាច់តែឯង
    - កម្មវិធីឯកទេស, រឺ

- កម្មវិធីដែលត្រូវបានប្រើ ដោយ អង្គការ ជាមួយ តម្រូវការដែលមានកំណត់ ដើម្បីអនុវត្តប្រតិបត្តិ
- កម្មវិធី Software ដែលសាំញ៉ាំ
    - ប្រពន្ធ័បញ្ចូលគ្នា – ផែនការធនធានសហគ្រាស (ERP), ប្រពន្ធ័គ្រប់គ្រងខាងក្នុង (CMS), ការគ្រប់គ្រងទំនាក់ទំនងអតិថិជន (CRM)......។ល។
- សេវាចែករំលែក – ការធ្វើអោយសម និង ការរួបរួម កម្មវិធីផ្សេងគ្នា មួយ រឺ ច្រើន ឆ្លងកាត់ អង្គការជាច្រើន។

ការដាក់ចែកជាក្រុម នៃគម្រោង អាយ ស៊ី ធី អនុវត្តន៏ផងដែរ ចំពោះគម្រោង រដ្ឋាភិបាល-អេឡិចត្រូនិច។

ចរិកលក្ខណះនៃប្រភេទខុសគ្នាទាំងនេះ មានឥទ្ធិពលលើការសម្រេចចិត្ត ចំពោះ ការបែងចែកមូលនិធិ និង ហានិភ័យ ក្នុងចំណោមអ្នកដំទៃ។

**គម្រោងហេដ្ឋារចនាសម្ពន្ធ័ធំ.** គម្រោងទាំងនេះ ងាយស្រួលអនុវត្តន៏ និង បទពិសោធន៏ជាច្រើន ត្រូវបានគេទទួលបាន ក្នុងការអនុវត្តន៏គម្រោងប្រភេទទាំងនេះ។ នៅពេលដែល PPPs ក្លាយជា ប្រជាប្រិយ ក្នុងចក្រភពអង់គ្លេស ក្នុងឆ្នាំ ១៩៩២, គម្រោងភាគច្រើនដែលបានធ្វើឡើងក្នុងពេលនោះគឺ គម្រោងហេដ្ឋារចនាសម្ពន្ធ័ធំ ។ សំរាប់ធម្មជាតិនៃគម្រោងនេះ, សំភារះ និង សេវា ដែលអាចកំនត់ចំនួនបានងាយ គឺត្រូវតែបានគេនាំមកអោយ។ ឧទាហរណ៏នៃគម្រោងហេដ្ឋារចនាសម្ពន្ធ័ អាយ ស៊ី ធី ធំមួយ គឺ ការងតំឡើងហេដ្ឋារចនាសម្ពន្ធ័ Network។

កម្មវិធី **Software** ដាច់តែឯង គម្រោងដែលតម្រូវ ការអភិវឌ្ឍន៏នៃកម្មវិធី Software អាចមានគ្រោះថ្នាក់ជាងការទិញនូវ នូវកម្មវិធី Software ដែលបានបង្កើត និង សាកល្បង រួចស្រាប់ហើយ។ ក្នុងរដ្ឋាភិបាល ប្រភេទផ្សេង គ្នា នៃកម្មវិធី Software រួមបញ្ចូល :

- កម្មវិធី ដែលផ្តោតទៅលើដំណើរការជំនួញមួយប្រភេទ (ឧទា ការគ្រប់គ្រងហិរញ្ញវត្ថុ, ការគ្រប់គ្រងធនធានមនុស្ស, គ្រប់គ្រងឯកសារ, រៀបចំឯកសារ, ចុះបញ្ជីលិខិតឆ្លងដែន, ការបញ្ជាក់ពីគយ, ការប្រមូលពន្ធដារ)
- ប្រពន្ធ័ដែលរៀបចំ សំរាប់ ចាក់ចោល រឺ បំបាត់អ្វីដែលអស់ប្រយោជន៏
- ប្រពន្ធ័ដែលពាក់ពន្ធ័ជាមួយ អង្គភាពជំនួញ, ក្រសួង, និង នាយកដ្ឋាន ជាច្រើន

កម្មវិធីដាច់តែឯង គ្រប់គ្រងដោយអង្គភាពមួយ ប្រហែលជាងាយស្រួលបំផុត ដើម្បីអនុវត្តន៍ និង គ្រប់គ្រង។ ប៉ុន្តែ កម្មវិធីខ្លះៗ វាឯកទេសខ្ពស់ពេក ដែលពួកវាមានតម្លៃ ដើម្បីអនុវត្តន៍ និងគ្រប់គ្រង។ កម្មវិធី ដែលមានតែមួយ ចំពោះផ្នែកមួយ ប្រហែលជាមិនតម្រូវ ការអនុវត្តន៍ពេញប្រពន្ធ័ទេ។ ការទទួលរាប់រងកាន់តែ ស្មុគស្មាញ, ហានិភ័យ នៃការអនុវត្តន៍កាន់តែច្រើនឡើង។ ការទទួលរាប់រងកម្មវិធី ដែលស្មុគស្មាញ អាចត្រូវបានគេធ្វើ ជា PPPមួយ នៅ ពេលដែល មានជំនាញការដែលបានបញ្ជាក់ និង ទទួលស្គាល់ ក្នុងការអនុវត្តន៍ដំណោះស្រាយបែបនេះនៅក្នុងទីផ្សារ ហើយជំនាញការនេះ គឺអាចរកបានសំរាប់គម្រោង នៅក្នុងដៃ។ សំរាប់កម្មវិធីជាច្រើនដែលបាននិយាយពីខាងលើ, មានកម្មវិធីដំណោះស្រាយ ចាក់ចោល-អ្វីដែលអស់ប្រយោជន៍ ដែលអាចរកបាន និង បានបញ្ជាក់។ សំរាប់កម្មវិធី សាមញ្ញ ដូចជា ការទិញ ផលិតផលមួយឈុត, ហានិភ័យត្រូវបានគេដឹងច្បាស់ជាង។

ក្នុងករណី រដ្ឋាភិបាល-អេឡិចត្រូនិច នៅម៉ុងហ្គោលី បានបង្ហាញ នៅខាងក្រោម, ការជ្រើសរើស គម្រោង រដ្ឋាភិបាល-អេឡិចត្រូនិច សំរាប់ PPPs បានរងឥទ្ធិពលមួយផ្នែក ដោយ ធម្មជាតិ និង ភាពស្មុគស្មាញដែលភ្ជាប់ ជាមួយ ហើយនិង ហានិភ័យនៃប្រភេទគម្រោងដែលបានពិពណ៌នាខាងលើ។

ការរៀបចំកម្មវិធី Software បញ្ចូលគ្នា នេះ គឺជាការប្រែប្រួលនៃ កម្មវិធី Software ដាច់តែឯង។ កម្មវិធីបញ្ចូលគ្នា ដែលកំពង់ត្រូវបានគេប្រើប្រាស់យ៉ាងច្រើន ដោយរដ្ឋាភិបាល ដោយសារតែអត្ថប្រយោជន៍ ដែល ពួកគេផ្តល់អោយ។ កម្មវិធីបញ្ចូលគ្នា ជាផ្នែកផ្នែកមួយ រួមមាន :

- ប្រពន្ធ័ EPR
- CMS ដែលអនុញ្ញាតិ សំរាប់ការផ្ទុកឯកសារ និងទទួលទិន្នន័ បានរហ័ស ។

**សេវាចែកចាយ.** កម្មវិធីតែមួយ គឺសាមញ្ញចំពោះអង្គការមួយចំនួន ដែលជាបំណែកមួយនៃផ្នែកធំទាំងមូល, ដូចជា ក្រសួង និង នាយកដ្ឋាន របស់រដ្ឋាភិបាល។ កម្មវិធីទាំងអស់នេះ ត្រូវបានគេលក់ ដោយ ក្រុមហ៊ុនអភិវឌ្ឍន៍កម្មវិធីធំៗ ដូចជា IBM, Oracle, SAP និង Microsoft, ហើយពួកគេជាធម្មតា ត្រូវបានធ្វើឡើងដោយ អ្នកប្រឹក្សាយោបល់ ដែលបានបញ្ជាក់ ដោយម្ចាស់រោងចក្រ ដើម្បីតំលើង និង ថែទាំ ផលិតផលនោះ។

សមាគមន៍ជាតិនៃភ្នាក់ងារពត៌មានសំខាន់របស់រដ្ឋ (NASCIO) របស់សហរដ្ឋអាមេរិក ទទួលស្គាល់នូវ និន្នាការ ខាងក្រោម ក្នុង ការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវ អាយ ស៊ី ធី :

- ការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព គឺត្រូវបានធ្វើ ដោយយោងទៅលើ ផែនការបច្ចេកវិទ្យាសហគ្រិន ដែលបានអភិវឌ្ឍន៍ល្អ។
- ផែនការទាំងនេះ បញ្ជាក់ពី ទស្សនះដែលធំ រឺ ‘សហគ្រាស ’ នៃរបៀបដែលប្រពន្ធ័ អាយ ស៊ី ធី នឹងធ្វើការជាមួយគ្នា និង បន្តធ្វើ បែបផែនអភិបាលកិច្ច ដែលស្របជាមួយនិង ទស្សនះប្រពន្ធ័ធំ នេះ។
- អ្នកដឹកនាំរដ្ឋាភិបាល រួមនិង អ្នកដឹកនាំនយោបាយ ដាក់ការគូសបញ្ជាក់យ៉ាងច្រើន លើភាពអាចទទួលខុសត្រូវបាន និង លើការវាស់វែង សីលធម៌ និង ការប្រព្រឹត្តិ។ ភ្នាក់ងារពត៍មានសំខាន់ (CIOs) និងបុគ្គលិករបស់ពួកគេ គឺហេតុដូចច្នេះហើ ត្រូវបានគេតម្រូវអោយប្រើប្រាស់ និយ័តករ នៃការប្រព្រឹត្តិ រួមទាំងប្រពន្ធ័វាស់វែង ដែលនិងជួយពួកគេ ទទួលផលពី ការសំរេចចិត្ត និង ការចំណាយ របស់ពួកគេ។
- មានទំនោរយ៉ាងខ្លាំងមួយ ចំពោះ ការពង្រឹងសេវា ដែលនាំទៅដល់ ទស្សនះនៃ សេវាចែករំលែក។
- នាយក CIOs និង ICT ត្រូវបានគេតម្រូវអោយរៀន គោលការណ៏ជំនួញ ដែលរួមទាំងការគ្រប់គ្រងគម្រោង, CRM, និង របៀបតាមដាន គម្រោង និង ធនធានដែលបានប្រើ។

នៅពេលដែល បញ្ហា និង កង្វល់ មិនអាចត្រូវគេបែងចែកអោយស្មើរគ្នា នៅក្នុងយុត្តាធិការផ្សេងគ្នា, ពួកគេចង្អុល បង្ហាញនូវ គម្រោងនៃការសម្រេចចិត្ត ដែលអាចប៉ះពាល់ដល់ការប្រើប្រាស់ អាយ ស៊ី ធី ជាទូទៅ។

## ៤.២ មូលហេតុ សំរាប់ PPP នៅក្នុងរដ្ឋាភិបាល-អេឡិចត្រូនិច

PPPs គឺបានកំពង់គេពិចារណា សំរាប់ រដ្ឋាភិបាល-អេឡិចត្រូនិច ដែលធ្វើឡើងសំរាប់មូលហេតុ ខាងក្រោម :

- ការផ្តោតលើសេវា – PPPs ត្រូវបានគេប្រើ នៅពេលមានតម្រូវការដែលផ្តោតទៅលើសេវា និងមិនគ្រាន់តែទៅលើលទ្ធផល។ ឧទាហរណ៏, ជំនួសអោយ ការបញ្ជាក់នៃចំនួនរថយន្តដឹកសិស្ស, តម្រូវការនៃPPPមួយ អាចដើម្បី បង្កើនការឈានដល់សេវារថយន្តដឹកសិស្ស ៥0 ភាគរយ និង ធានាថាសិស្សទាំងអស់ ទៅដល់សាលាមុនម៉ោង ៨:30ព្រឹក។ សំរាបបញ្ហានេះ, វាសំខាន់ណាស់ដើម្បីបញ្ជាក់កម្រិតនៃសេវា ដែលស្វែងរក។ បន្ទាប់មក វ ឈានាទៅដល់ក្រុមហ៊ុនដែលទទួលខុសត្រូវការអនុវត្តន៏ដើម្បីចែកចាយសេវា ដែលគេតម្រូវចំពោះកម្រិតដែលបានព្រមព្រៀងគ្នាពីមុន។ ស្រដៀងគ្នានេះដែរ, ជំនួសអោយការបញ្ជាក់ ពីបណ្តាញ network មួយ ក្នុងន័យ ម៉ាស៊ីនកំព្យូទ័រ និង Server, វាអាចសំខាន់ដើម្បីបញ្ជាក់ពី សមត្ថភាពនៃបណ្តាញ network, ល្បឿន, ចន្លោះពេលនៃការខកខាន, កំរឹតនៃការប្រើប្រាស់ដោយ បុគ្គលិក (ភាគរយ កើនឡើងក្នុងចំនួន នៃប្រតិបត្តិការណ៏-អេឡិចត្រូនិចទល់នឹង ប្រតិបត្តិការណ៏លើក្រដាស ), និងការវាស់វែង នៃកំរិតរបស់សេវា។ ការយល់ព្រមកំរិតនៃសេវា

ត្រូវបានគេប្រើប្រាស់ច្រើន ជារបៀបមួយនៃការគូសបញ្ជាក់នូវ តម្រូវការក្នុងន័យ សេវា និង មិនគ្រាន់តែក្នុងន័យ លទ្ធផល។

- ការចំណាយខ្ពស់ - នៅពេលការចំណាយខ្ពស់, PPP គឺជារបៀបមួយសំរាប់ រដ្ឋាភិបាលដើម្បីកាត់បន្ថយការចំណាយភ្លាមៗ នៃការអនុវត្តន៍។

- ភាពស្មុគស្មាញ នៃគម្រោងពត៌មានវិទ្យា, ការប្រឈមបច្ចេកវិទ្យា – គម្រោងស្មុគស្មាញជាច្រើន អាចធ្វើបាន ប្រសិនបើ ត្រូវបានគេធ្វើយ៉ាងពេញលេញ ដោយអ្នកផ្តល់ផ្នែកឯកជនដែលបានបង្ហាញ។

- អត្រាទាប នៃការអនុវត្តន៍នៃគម្រោងពត៌មានវិទ្យា ដោយរដ្ឋាភិបាល – PPPមួយ ជាមួយដៃគូរដែលមានលិខិតតែងតាំងដែលបានបញ្ជាក់ ដើម្បីធ្វើការងារ គឺជាជម្រើសមួយដើម្បីសាកល្បង វានៅក្នុងផ្ទះ។

- ការរំពឹងគិតរបស់ សារធារណៈ និង អតិថិជន – ក្រុមហ៊ុនផ្នែកឯកជនដ៏ជោគជ័យ គឺដោយសារតែ ពួកគេ បំពេញ រឺ បន្ថែមលើស ការរំពឹងគិតរបស់សារធារណៈ។ នេះ អាចមានប្រយោជន៍នៅពេលអនុវត្តន៍គម្រោងរដ្ឋាភិបាល ខ្លះ តាមរយះការរៀបចំ PPPមួយ។

- ភាពអាចមើលឃើញខ្ពស់ នៃសេវាសារធារណៈ, ដូចជា ការផ្គត់ផ្គង់, អចលនទ្រព្យ, និង សេវាសង្គម។

- ការកាត់បន្ថយថវិការ – ប្រសិនបើមានតិចតួច រឺគ្មាន ប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់ គម្រោង និង សេវាដែលគេត្រូវការ, វិធីសាស្រ្ត PPPមួយ អាចមានអត្ថប្រយោជន៍កំនត់មួយ។

- តម្រូវការ នៃភាពអាចជឿជាក់បាន និង តម្លាភាព – PPPs អនុញ្ញាតិអោយ អតិថិជនបញ្ជាក់អោយច្បាស់នូវអត្ថន័យ នៃការផ្សារភ្ជាប់ និង ការចែកចាយ។ យន្តការអភិបាលកិច្ច ដើម្បីធានាភាពអាចជឿជាក់បាន និង តម្លាភាព ដែលប្រើប្រាស់ ស្តង់ដារសវនកម្មដែលទទួលស្គាល់ជាអន្តរជាតិ អាចត្រូវបានគេដាក់អនុវត្តន៍។

- កង្វល់ពីហានិភ័យសន្តិសុខ – អ្នកផ្គត់ផ្គង់ផ្នែកឯកជន អាចមានជំនាញការ ក្នុងការអនុវត្តន៍កម្មវិធីដំណោះស្រាយដែលមានកំរិតខ្ពស់ សំរាប់គម្រោង អាយ ស៊ី ធី និង ដោះស្រាយជាមួយការរួមបញ្ចូល

នៃទិន្នន័យ, ភាពឯកជន និង សុវត្ថិភាព។ផ្នែកឯកជន ទទួលខុសត្រូវ សំរាប់ការអភិវឌ្ឍន៍គម្រោង និង សោវ ទាំងនេះ និង នៅ ក្នុងតំណែងដ៏ល្អមួយ ដើម្បី ផ្តល់យោបល់លើ ការប្រើប្រាស់របស់ពួកគេ។

ប្រទេសដែលនាំមុខខាងការប្រើប្រាស់ រដ្ឋាភិបាល-អេឡិចត្រូនិច ផ្តោលទៅលើ ការចែកចាយសេវា សំរាប់ អតិថិជន និងមួយចំនួននៃប្រទេសទាំងអស់នេះ បានកំពង់ប្រើប្រាស់ និងពិចារណាប្រើប្រាស់ PPPs រួចរាល់ហើយ។គោលការគ្រឹះ គឺ ឯករាជ្យភាព នៃស្ថានភាពអភិវឌ្ឍន៍របស់ប្រទេស, ទោះបីជាសមត្ថភាព អនុវត្តន៍ PPPs ពឹងផ្អែកទៅលើ ដំណើរការ និង សមត្ថភាព។ PPPs ទាមទារនូវ ជំនាញការពិសេសមួយ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និង ផ្គត់ផ្គង់, និងពឹងផ្អែកលើ ផ្នែកសាធារណៈ និង ឯកជន ធ្វើការជាមួយគ្នា។ ពួកគេពឹងផ្អែកផងដែរ លើការទុកចិត្ត រវាង ដៃគូរ ផ្នែកសាធារណៈ និង ឯកជន។

នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ជាច្រើន, រដ្ឋាភិបាល-អេឡិចត្រូនិច គឺភាគច្រើន សំរាប់ប្រសិទ្ធភាពដំណើរការ ជំនួញ ពីព្រោះផ្នត់គំនិតរបស់សេវា នៅតែកំពង់បង្កើត ផ្លូវមួយរបស់វា នៅក្នុងចិត្តរបស់អ្នកធ្វើការសំរេចចិត្ត។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពនេះ កំពង់តែផ្លាស់ប្តូរយ៉ាងរហ័ស នៅពេលដែលប្រទេសជាច្រើន ស្វែងរកដើម្បីធ្វើ អោយប្រសើរឡើង មិនត្រឹមតែ ដោយ ការប្រើប្រាស់ អាយ ស៊ី ធី និង កម្មវិធី រដ្ឋាភិបាល-អេឡិចត្រូនិច, ប៉ុន្តែ ថែមទាំង ដោយ ការឈានទៅដល់ផ្នែកឯកជន ដោយសារតែអត្ថប្រយោជន៍ ដ៏សំខាន់នៃការធ្វើដូចច្នេះ ប្រសិនបើ លក្ខណ្ឌត្រឹមត្រូវ។ ក្នុងករណីទាំងអស់, សំរាប់ រដ្ឋាភិបាល-អេឡិចត្រូនិច ដើម្បីជោគជ័យ មានតម្រូវការមួយ ដើម្បីផ្តោតទៅលើ តម្រូវការរបស់សារធារណៈជន។

PPPs ជាច្រើន ចាប់ផ្តើមជាមួយ ការផ្លាស់ប្តូរក្រៅផ្លូវការ និង ការពិភាក្សា រវាង រដ្ឋាភិបាល និង ផ្នែកឯកជន។ លើសពីនេះទៅទៀត, សកម្មភាពសំរាប់ពិសោធន៍មើល ត្រូវបានគេប្រើ សំរាប់សាកល្បងគំនិតរបស់គម្រោង និង ដើម្បីវាយតម្លៃ សមត្ថភាពនៃផ្នែកឯកជន មុនពេល វិធីសាស្ត្រផ្អែកលើ PPPមួយ ត្រូវបានគេពិចារណា។

មានការងារសំខាន់មួយដែលបន្ត ទៅលើការប្រើប្រាស់នៃ PPPs។ មួយចំនួននៃគម្រោងទាំងនេះ គឺត្រូវបានគេធ្វើ ផ្តល់នូវឯកទេសខ្ពស់ និង យ៉ាងលំអិតណាស់ ក្នុងទម្រង់របស់វា។ គម្រោងដែលអនុវត្តន៍ សេវាពន្ធដារ នៅក្នុង រដ្ឋ Viginia ក្នុងសហរដ្ឋអាមេរិក គឺជាករណីមួយក្នុងចំនុចនេះ។ គម្រោងនេះ បានឈ្នះនូវ រង្វាន់ការទទួលស្គាល់ ពី NASCIO ២០០១ នៅក្រោមប្រភេទ PPP។ គោលបំណងរបស់គម្រោង គឺដើម្បីជំនួស ប្រពន្ធ័កុំព្យូទ័រជាកេរ្តិ៍ ដំណែល ដែលធ្លាប់ត្រូវបានគេប្រើដើម្បីគ្រប់គ្រងប្រាក់ចំណូលរបស់រដ្ឋ។

នៅក្នុងឆ្នាំ ១៩៩៨, នាយកដ្ឋានពន្ធដារ Viginia បានភ្ជាប់ជាមួយ ភាពជាដៃគូរឯកជន-សារធារណៈ ជាមួយនិង សារជីវកម្ម ប្រពន្ធ័គ្រប់គ្រងអាមេរិក (AMS) ដើម្បីរៀបចំឡើងវិញទាំងស្រុង នូវដំណើរការជំនួញ នៅក្នុងស្ថាប័ន និង ជំនួសប្រពន្ធ័ជាកេរ្តិ៍ដំណែលដែលហួសអាយុ ដែលបានគ្រប់គ្រងប្រាក់ចំណូលរដ្ឋ។ គម្រោងភាពជាដៃគូរដែល បានផ្ដល់មូលនិធិ-ផ្ទាល់ខ្លួន ១៣៥.៥ លានដុល្លារអាមេរិក នេះ គឺជា ភាពជាដៃគូរឯកជន-សារធារណៈ ដែលងាយ ទូលំទូលាយ និង ធំជាងគេបំផុត ដែលធ្លាប់ត្រូវបានគេធ្វើឡើង ដោយស្ថាប័នប្រាក់ចំណូលរដ្ឋ, ដែលផ្ដល់ជម្រើសថ្មី សំរាប់អ្នកបង់ពន្ធ, ដែលបានពង្រឹងសមត្ថភាពផ្ដល់ សេវាអតិថិជន, និង ការអភិវឌ្ឍន៏ស្ថាបន័។

នៅក្រោមកិច្ចព្រមព្រៀងជាមួយ AMS, ក្រុមហ៊ុន នឹងមិនត្រូវបានគេបង់លុយអោយទេ រហូតដល់ នាយកដ្ឋាន ពន្ធដារ ប្រើប្រាស់ កម្មវិធីថ្មី ដោយជោគជ័យ ដើម្បីបង្កើនការប្រមូលពន្ធ។ នៅពេលដែលគម្រោងធ្វើការ ដូច កិច្ចសន្យាតម្លៃថេរ ណាមួយ, ភាពខុសគ្នា គឺថា វិក្ក័យប័ត្រ ពី AMS ត្រូវបានគេបង់លុយអោយ តែមួយករណីគត់ ប្រសិនបើ គម្រោង បង្កើតនូវប្រាក់ចំណូល។ វិធីសាស្ត្រ មូលនិធីពីផលប្រយោជន៍ នេះ បានផ្ដល់ការលើកទឹកចិត្ត អោយ AMS យល់ពី តម្រូវការ, ការរំពឹងគិត និង វិធីសាស្ត្រការងារនៃនាយកដ្ឋានពន្ធដារ។ គម្រោងត្រូវបាន គេចាត់ទុកថាជា ជោគជ័យដ៏លេចធ្លោមួយ។ អ្នកបង់ពន្ធ សប្បាយរីករាយ និង ច្រកចូល Web មួយជំហាន ត្រូវបានគេអនុវត្តន៏។ PPPនេះ បានអនុញ្ញាតិអោយ នាយកដ្ឋានពន្ធដារ ទទួលធ្វើ ការកែប្រែបេសកម្ម យ៉ាងជិតដល់ នៅពេល មុននិធិ មិនអាចរកបាន។

អ្វីដែល វិធីសាស្ត្រនេះបង្ហាញ គឺ ថាជាមួយដៃគូរដែលមានសមត្ថភាព និងការប្ដេជ្ញា, វាអាចធ្វើទៅបាន ដើម្បី បំពេញ សូម្បីតែ ការងារស្មុគស្មាញ និង មានបច្ចេកទេសខ្ពស់ ដែលប្រើប្រាស់ បែបផែន PPP។

បញ្ហាគន្លឹះ: នៅក្នុងគម្រោង PPP គឺជា សម្បទាន ដែលរដ្ឋាភិបាល ផ្ដល់ការឈានទៅដល់ សេវា និង ពត៌មាន សារធារណៈ។ សំរាប់រដ្ឋាភិបាល, ការអំពាវនាវ ជាប់នូវក្នុង ការពិតថា រដ្ឋាភិបាល មិនមានធនធាន ដើម្បីផ្ដល់ ការឈានចូលទៅដល់ សេវា និង ពត៌មានសារធារណៈ ជាពិសេសនៅក្នុងតំបន់ដាច់ស្រយាល។

នៅក្នុងប្រទេសឥណ្ឌា គម្រោង PPPមួយ ដែលបំពេញតម្រូវការនេះ គឺ គម្រោង eSava, ដែលផ្ដល់ច្រើនជាង ៦៦ នូវ សេវា រដ្ឋាភិបាល-ទៅ-ពលរដ្ឋ និង ជំនួញ-ទៅ-ពលរដ្ឋ នៅក្នុង មជ្ឈមណ្ឌល eSava ៤៦ ក្នុងរដ្ឋ Andhra Pradesh។ គម្រោង ប្រតិបត្តិក្រោម គ្រោងការណ៏ BOOT មួយ, ជាមួយ អ្នកប្រតិបត្តិកិច្ចិសន្យាផ្សេងគ្នា នៅក្នុង តំបន់ផ្សេងៗ ដែលបានប្រាក់ចំណូលពិសេស។

ឧទាហរណ៍ផ្សេងទៀត គឺ បែបផែនទំនាកទំនងជនបទ n-Logue ដែលប្រើ គួប អ៊ីនធរណែត គ្មានខ្សែ នៅក្នុងភូមិ ពាសពេញប្រទេសឥណ្ឌា តាមរយៈ បែបផែនជំនួញសំរាប់ប្រាក់ចំណេញ។ n-Logue ត្រូវបានបង្កើតឡើង ដោយ ក្រុម បណ្ដាញ Network កំព្យូទ័រ និង ទូរគមនាគមន៍ របស់វិទ្យាស្ថានបច្ចេកវិទ្យាឥណ្ឌា នៅក្នុងទីក្រុង Madras (Chennai) ដើម្បី មើលទៅកាន់ឱកាសសំរាប់ ការផ្ដល់សេវា-អេឡិចត្រូនិច នៅតំបន់ដាច់ស្រយាលរបស់ប្រទេស ឥណ្ឌា។ ក្រុមហ៊ុនដែលបានធ្វើការ សាកល្បង និង អភិវឌ្ឍន៍ កម្មវិធី ដែលនឹងបង្កើត ប្រាក់ចំណូល ដែលនៅក្នុងពេល តែមួយ ផ្ដល់ការឈានទៅដល់ភាពផ្លាស់ប្ដូរនៃសេវា, ដែលរួមទាំង សេវា និង ពត៌មានរដ្ឋាភិបាល។ n-Logue ធ្វើ ការជាមួយ ជំនួញក្នុងស្រុក ដើម្បីផ្ដល់ឈានចូលទៅដល់ គ្រឿងបរិក្ខា និងដើម្បី ជួយ ជំនួញ និង អ្នកទទួលសិទ្ធលក់ ក្នុងស្រុក អោយទាក់ទាញ ចរាចរណ៍ទៅកាន់ច្រកចូលគ្រឿងបរិក្ខា ដែលផ្ដល់សេវាអ៊ីនធរណែត និង សម្លេង។ n-Logue មិនផ្ដល់នូវ មាតិកា ប៉ុន្តែ ជួយអ្នកទទួលសិទ្ធលក់នៅក្នុងភូមិ ដើម្បីឈានទៅដល់ មាតិកាអ៊ីនធរណែត ដែលពាក់ពន្ធ័ និង ជួយអ្នកប្រើប្រាស់ក្នុងស្រុក អភិវឌ្ឍន៍ មាតិកាផ្ទាល់ខ្លួនរបស់ពួកគេ, ដូចជា គេហទំព័រ, ប្រសិនបើ មានបំណង។

នៅក្នុងឧទាហរណ៍ទាំងនេះ នៃ PPP ក្នុងប្រទេសឥណ្ឌា, រដ្ឋាភិបាល បានផលប្រយោជន៍ពីការ ចែកចាយសេវាដែល បានពង្រឹង និង សហគមន៍ជនបទ បានទទួល ការចូលទៅកាន់ សេវា និង ពត៌មាន ដែលមិននឹងអាចរកបានចំពោះពួកគេ។

នៅប្រទេស Scotland, Atos Consulting បានឈ្នះ គម្រោង PPPមួយ ដើម្បីស្ថាបនា និង ប្រតិបត្តិ គ្រឿង បរិក្ខា សេវាសុខភាព។ គម្រោង ពាក់ពន្ធ័និង Atos ដែលបានរកជួល បុគ្គលិកជាអ្នកជំនាញផ្នែកវិជ្ជសាស្ត្រ ដោយ ផ្ទាល់ អោយកាន់ការ គ្រឿងបរិក្ខាទាំងមូល និង បានផ្ដល់ សេវាវេជ្ជសាស្ត្រ ទៅសារធារណៈជន សំរាប់ការផ្ដល់ ប្រាក់អោយវិញ ដោយ សេវាសុខភាពសារធារណៈ របស់រដ្ឋាភិបាលចក្រភពអង់គ្លេស។ សំរាប់រដ្ឋាភិបាល, អត្ថប្រយោជន៍ គឺ ការមិនចាំបាច់ បង្កើតប្រាក់ទុន ដើម្បីស្ថាបនាមន្ទីរពេទ្យ រួមទាំងប្រាក់ទុនផ្សេងៗទៀត ដើម្បី ជួលបុគ្គលិក និងប្រតិបត្តិ។ ផ្នែកឯកជន បន្តប្រើប្រាស់មន្ទីរពេទ្យ ដូចដែលពួកគេនឹងប្រើគ្រឿងបរិក្ខាសុខភាព សារធារណៈផ្សេងៗទៀត នៅក្នុងចក្រភពអង់គ្លេស។ មន្ទីរពេទ្យ គឺផ្អែកទៅលើ ច្បាប់ និង បញ្ញាតិ ដូចគ្នា ដែល បានប្រើចំពោះ គ្រឿងបរិក្ខាវិជ្ជសាស្ត្រផ្សេងៗទៀត នៅក្នុងចក្រភពអង់គ្លេស។ Atos ទទួលបានវិញ នូវប្រាក់ទុន នៅក្នុងទំរង់នៃ ប្រាក់ឈ្នួល ពីប្រតិបត្តិការណ៍របស់គ្រឿងបរិក្ខា ដែលផ្អែកទៅលើ កិច្ចព្រមព្រៀងដែលបានធ្វើឡើង ជាមួយ នាយកដ្ឋានសេវាសារធារណៈ ចក្រភពអង់គ្លេស និង អ្នកគាំទ្រហិរញ្ញវត្ថុរបស់ពួកគេ។

ជាចុងបញ្ចប់, ភាពជោគជ័យ នៃ PPPs ផ្អែកទៅលើភាពរួចរួលនៃដៃគូរ ដើម្បីធ្វើការជាមួយគ្នា និងស្វែងរកដំណោះស្រាយ ចំណាយមានប្រសិទ្ធភាព និង ថ្មីប្លែកៗ ចំពោះ ការលំបាកនៃការផ្តល់សេវាសារធារណះ។ គម្រោង PPP អាចកែប្រែថ្មី ដូច គម្រោងជំនួញ ដែលគាំទ្រពួកគេ។ មានអត្ថប្រយោជន៍ សំរាប់ដៃគូរទាំងពីរ សារធារណះ និង ឯកជន។

## ៤.៣ តើ គម្រោងរដ្ឋាភិបាល-អេឡិចត្រូនិច អ្វីដែលសមរម្យសំរាប់ PPPs ?

មិនមែនរាល់ គម្រោងរដ្ឋាភិបាល-អេឡិចត្រូនិចទាំងអស់ សមរម្យសំរាប់ ការអនុវត្តន៏ ក្រោមការរៀបចំ PPPs នោះទេ ប៉ន្តែភាគច្រើន សមរម្យ។ គម្រោងខ្លះ មិនត្រូវបានគេអនុវត្តន៏ដោយផ្អែកឯកជន សំរាប់បញ្ហានៃជម្លោះផលប្រយោជន៏ជាឧទាហរណ៏។ ហើយ ការធ្វើនយោបាយ គឺនៅតែជាទំហំគម្រោងតែមួយគត់របស់រដ្ឋាភិបាល ដែលបានប្រព្រឹត្តក្នុងការពិភាក្សាជាមួយនិងម្ចាស់ជំនួយ, រួមទាំងផ្អែកឯកជន។

នៅក្នុងផ្អែកនេះ, យើងនិងពិចារណា ឧទាហរណ៏របស់ គម្រោងមេ នៃរដ្ឋាភិបាល-អេឡិចត្រូនិច នៅម៉ុងហ្គោលី និង គម្រោងដែលក្នុងនោះ គម្រោងមេ ក្នុងន័យ ភាពសមរម្យរបស់គេ សំរាប់ការអនុវត្តន៏តាមរយះ PPPមួយ។

ម៉ុងហ្គោលី ផ្តល់អត្ថប្រយោជន៍មួយចំនួនចំពោះផ្នែកឯកជន។ វាមានបរិស្ថានទាក់ទាញជំនួញ និង ផ្នែកឯកជន មាន តួនាទីដែលកើនឡើងមួយ ដើម្បីធ្វើនៅក្នុងសេដ្ឋកិច្ច។ មានសហគ្រិនជាច្រើន នៅម៉ុងហ្គោលី និង មួយចំនួន បានកំពង់តែប្រតិបត្តិ នៅក្នុងប្រទេស ដែលអភិវឌ្ឍន៍ ជំនួញ ក្នុងផ្នែក អាយ ស៊ី ធី។ ផ្នែកធានាគារ គឺសកម្ម និង មានការប្រកួតប្រជែង។ ធានាគារមួយចំនួន ផ្តល់សេវាធានាលើអ៊ីនធរណែត និង ធានាគារ គឺជាសហគ្រិន ដែល ស្វែងរកឱកាស ដើម្បីពង្រីកមុខជំនួញរបស់គេ ដែល ផ្តល់នៅក្នុងតំបន់ទីក្រុង និង ជាពិសេសទីជនបទ ដែលប្រជាជនម៉ុងហ្គោលីជាច្រើន រស់នៅ។ ម៉ុងហ្គោលី គឺត្រូវផ្សារភ្ជាប់ទៅ ឆ្អឹងខ្នងខ្សែកាបសកល និង មានបណ្តាញខ្សែកាប ដែលភ្ជាប់ ប្រទេសចិន និង រុស្សី ទៅកាន់ប៉ូលខាងជើង។ មានការទាក់ទងល្អ នៅក្នុងតំបន់ទីក្រុង និង ក្នុងស្រុក។ កុំព្យូទ័រ អាចរកបានយ៉ាងទូលំទូលាយ និង មានអត្រាខ្ពស់ នៃការប្រើប្រាស់កំព្យូទ័រ។ ប្រជាជនម៉ុងហ្គោលី គឺនៅ ក្មេង និង អត្រាចចេះអក្សរមានកម្រិតខ្ពស់។

លើផ្នែកខាងក្រោម, មានការខ្វះខាតនៃការយល់ដឹងពី PPPs និង ផលប្រយោជន៍របស់ពួកគេ។ ស្ថានភាពនេះ កំពង់តែផ្លាស់ប្តូរ នៅពេលដែល ធានាគារពិភពលោក កំពង់តែផ្សព្វផ្សាយ គម្រោង PPPមួយចំនួន, ក្នុងការ សហការជាមួយ រដ្ឋាភិបាលម៉ុងហ្គោលី។ លើពេលមួយ, វាត្រូវបានគេរំពឹងគិតថា ម៉ុងហ្គោលី នឹងបើកចំហ ចំពោះ តួនាទីរបស់ ជំនួញក្នុងការអភិវឌ្ឍន៍ប្រទេស និង PPPs នឹងត្រូវបានគេពិចារណាច្រើនឡើងៗ។

គម្រោងមេ នៃរដ្ឋាភិបាល-អេឡិចត្រូនិច សំរាប់ម៉ុងហ្គោលី គ្រោងចេញនូវ គម្រោងមួយចំនួន។ ប្រភេទសំខាន់ ៤ គឺមានដូចខាងក្រោម :

១. គម្រោងមូលដ្ឋាន សំរាប់រដ្ឋាភិបាល-អេឡិចត្រូនិច ដែលផ្អែកលើ ហេដ្ឋារចនាសម្ព័ន្ធរួម,
សេវាចែករំលែក ( ERP/ECM )
២. សកម្មភាពនយោបាយ
៣. ការស្ថាបនាសមត្ថភាព ( ការបណ្តុះបណ្តាល )
៤. ការចែកចាយសេវា

គម្រោងមូលដ្ឋាន រួមបញ្ចូល បណ្តាញ ឆ្អឹងខ្នងជាតិ រឺ រដ្ឋាភិបាល, ដែលរួមបញ្ចូល ការតំលើងនៃកុំព្យូទ័រ និង បណ្តាញ Network ក្នុងតំបន់ និង គ្មានខ្សែ, កម្មវិធីផលិតភាពសំរាប់ការិយាល័យ, ហេដ្ឋារចនាសម្ព័ន្ធរួម, និង សេវាចែក រំលែក ដូចដែលបានកំណត់ពីមុន។

ដោយគ្មានគម្រោងទាំងនេះ, រដ្ឋាភិបាល-អេឡិចត្រូនិច គឺមិនអាច រឺ នឹងមិនមានផលប្រយោជន៍ធំដែលគេបាន ប៉ុនប៉ង។ គម្រោងមូលដ្ឋានជាក់លាក់ រួមមានៈ

- ច្រកចូលតំណាងអោយរដ្ឋាភិបាល
- ប្រពន្ធ័អត្តសញ្ញាណជាតិ
- ច្រកចូលរដ្ឋបាល (ការយល់ព្រម-អេឡិចត្រូនិច, ការគ្រប់គ្រងចំណេះដឹង, ឯកសារ-អេឡិចត្រូនិច)
- ការផ្គត់ផ្គង់-អេឡិចត្រូនិច
- ការពង្រីក នៃធនធាន អាយ ស៊ី ធី
- ស្ថាបត្យកម្ម សហគ្រាស
- ប្រពន្ធ័ពត៌មានទូទាំងរដ្ឋាភិបាល រួមបញ្ចូលគ្នា (ERP, ECM)
- ប្រពន្ធ័ការពារពត៌មាន (ប្រពន្ធ័/សេវា សន្តិសុខ អាយ ស៊ី ធី ជាតិ, អជ្ញាធរលិខិតបញ្ជាក់ដែលទទួលស្គាល់ជាអន្តរជាតិ )

សកម្មភាពនយោបាយ មិនត្រូវបានគេធ្វើ ជាគម្រោង PPPមួយ, ប៉ន្តែក្នុងគោលការណ៍ ការធ្វើនយោបាយពាក់ពន្ធ័ការប្រឹក្សាយោបល់ជាមួយផ្នែកឯកជន ដូចជាមួយម្ចាស់ជំនួយផ្សេងៗទៀតដែរ។ សកម្មភាពនយោបាយ រួមបញ្ចូល ការអភិវឌ្ឍន៍ប្រពន្ធ័កូដរួមរបស់ជាតិ, និង ការកែទំរង់ច្បាប់ សំរាប់គម្រោង និងការបណ្ដុះបណ្ដាល រដ្ឋាភិបាល-អេឡិចត្រូនិច ដើម្បីចែកចាយសេវាសារធារណៈ គឺសមស្របទៅនិងវិធីសាស្រ្ត PPPមួយ ដែលផ្អែកលើ តម្រូវការ និង កាលៈទេសៈ។ ការបណ្ដុះបណ្ដាល ត្រូវបានគេរៀបចំឡើងដើម្បីពង្រឹង អង្គការ អាយ ស៊ី ធី, គម្រោងចែក ចាយសេវា រួមជាមួយប្រពន្ធ័គ្រប់គ្រងលិខិតឆ្លងដែន, ប្រពន្ធ័ពត៌មាននិយោជិក និង ការជ្រើសរើស, អតិថិជន-អេឡិចត្រូនិច, ការចុះបញ្ជីជំនួញ និង ការគ្រប់គ្រងការយល់ព្រម, និងប្រពន្ធ័គ្រប់គ្រងកម្មសិទ្ធិបញ្ញា។ គម្រោង ចែកចាយសេវាផ្សេងៗទៀត ត្រូវបានគេកំពង់ពិចារណា ដូចខាងក្រោម :

- សេវាឈានចូល សហគមន៍ និង ក្នុងតំបន់
- ច្រកចូល ពាណិជ្ជកម្ម-អេឡិចត្រូនិច សំរាប់ SMEs
- ប្រពន្ធ័ពត៌មានកសិកម្ម
- ទីផ្សារកសិកម្មលើអ៊ីនធរណែត
- ច្រកចូលពត៌មានសុខភាព
- ប្រពន្ធ័ពត៌មាន និង ការគ្រប់គ្រង ការបោះឆ្នោត

- ប្រពន្ធ័គ្រប់គ្រងចរាចរណ៍ (គម្រោង PPPសកម្ម)
- ប្រពន្ធ័គ្រប់គ្រងយានយន្ត (គម្រោង PPPសកម្ម)
- ប្រពន្ធ័កក់ទុក និង ច្រកចូលទេសចរណ៍ (នៅក្នុងមួយផ្នែក)

## ៤.៤ លក្ខណ៍សំរាប់ការជោគជ័យនៃគម្រោង PPP ក្នុង រដ្ឋាភិបាល-អេឡិចត្រូនិច

ដើម្បី PPPs ជោគជ័យ, លក្ខណ៍ខាងក្រោម ត្រូវតែបានបំពេញ :

- ការប្តេជ្ញា ពីអ្នកដឹកនាំប្រតិបត្តិ
- មូលដ្ឋានច្បាប់សំរាប់ភាពជាដៃគូរ
- ការពាក់ពន្ធ័ផ្នែកឯកជនដោយផ្ទាល់
- ផែនការប៊ិនប្រសព្វដ៏ល្អមួយ
- ការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាពជាមួយអ្នកពាក់ពន្ធ័
- ឱកាសត្រឹមត្រូវ
- ដៃគូរត្រឹមត្រូវ
- ដំណើរការគ្រប់គ្រងដែលបានកំណត់យ៉ាងល្អ

សំរាប់ គម្រោងមេ រដ្ឋាភិបាល-អេឡិចត្រូនិច របស់ប្រទេសម៉ុងហ្គោលី, លកខណ្ឌ័ខាងក្រោមត្រូវបានគេអភិវឌ្ឍន៍ ដើម្បី វាយតម្លៃភាពសមរម្យនៃគម្រោង សំរាប់ការអនុវត្តន៍ PPPs :

- បរិស្ថានដែលអាចធ្វើ
- ការគាំទ្រកំរិតខ្ពស់
- កំរិតនៃការទទួលយក/ប្រឆាំងទល់និង ការផ្លាស់ប្តូរ
- ភាពងាយស្រួល នៃការអនុវត្តន៍ - ដំណោះស្រាយ ជំនួញ/បច្ចេកទេស គឺអាចរកមាន ជាស្រេច។
- ការទាមទារ
- សក្តានុពលនៃប្រាក់ចំណូល
- ភាពបត់បែន
- សក្តានុពលនៃការបង្កើតការការងារ

- សក្តានុពលនៃការសន្សំសំចៃ សំរាប់រដ្ឋាភិបាល និង សារធារណៈជន (រថយន្តបន្តកន្ទុយគ្នាខ្លីជាងមុន, ការធ្វើដំណើរត្រូវបានគេកាត់បន្ថយ....។ល។)
- ភាពអាចចម្លងបាន និង ប្រសិទ្ធភាពទ្វេរគុណ
- សមត្ថភាព នៃស្ថាប័នរដ្ឋាភិបាល និង ដៃគូរផ្នែកឯកជន
- បទពិសោធន៏ធ្វើការជាមួយផ្នែកឯកជន
- ភាពអាចមើលឃើញ

ការប្រើ កត្តាទាំអស់នេះ, គម្រោងខាងក្រោម ត្រូវបានគេរកឃើញ សំរាប់ធ្វើការសេនិដ្ឋាន ក្នុង គម្រោងមេ នៃ រដ្ឋាភិបាល-អេឡិចត្រូនិច របស់រដ្ឋាភិបាល ម៉ុងហ្គោលី :

១. ប្រពន្ធ័គ្រប់គ្រងយានយន្ត និង ចរាចរណ៍ ជាមួយកម្មវិធីចល័ត
២. គ្រឿងបរិក្ខាចូលក្នុងសហគមន៍ និង ក្នុងតំបន់ ជាមួយ ធានាគារ, ប្រៃសណីយស្ថាន, សហគ្រិន ក្នុង ស្រុក.......។ល។
៣. ការចុះបញ្ជីជំនួញ តាមរយៈ សភាពាណិជ្ជកម្ម និង ឧស្សាហកម្ម ជាតិម៉ុងហ្គោលី
៤. ប្រពន្ធធានារ៉ាប់រងសង្គម ជាមួយ ធានាគារ និង អ្នកប្រតិបត្តិដទៃទៀត
៥. វេទិកា ពាណិជ្ជកម្ម-អេឡិចត្រូនិច សំរាប់ SMEs
៦. រដ្ឋាភិបាលសំរាប់ពិសោធន៍ នៃវេទិកាផ្គត់ផ្គង់ម៉ុងហ្គោលី សំរាប់ការភ្ជាប់ឱកាស (ប្រពន្ធ័ផ្គត់ផ្គង់-អេឡិចត្រូនិច សំរាប់ពិសោធន៍)
៧. អជ្ញាធរផ្តល់លិខិតបញ្ជាក់ជាតិ ជា ភាពប្រថុយប្រថានរួមមួយ ជាមួយ Verisign រឺ ស្មើរនិងវា

គម្រោងទាំងនេះ, មួយចំនួនដែលមិនលេចឡើងនៅលើផែនការមេ រដ្ឋាភិបាល-អេឡិចត្រូនិច ចុងក្រោយ, ត្រូវបាន គេជ្រើសរើស ដោយផ្អែកទៅលើការពិភាក្សាជាមួយ មន្ត្រី និង អ្នកប្រតិបត្តិផ្នែកឯកជន នៅក្នុង ប្រទេសម៉ុងហ្គោលីប្រពន្ធ័គ្រប់គ្រងយានយន្ត និង ចរាចរណ៍ គឺជា គម្រោង PPPមួយ ដែលបានមាន ជាច្រើនឆ្នាំមកហើយ និង ដែល ត្រូវបានគេបញ្ចុះបញ្ចូល ដោយអ្នកប្រតិបត្តិផ្នែកឯកជន ក្នុងការពិភាក្សា ជាមួយ អជ្ញាធរ។ គម្រោង បានអភិវឌ្ឍន៍ ប្រពន្ធ័បង់ប្រាក់ពិន័យស្វ័យប្រវត្តិ រួមទាំងប្រពន្ធ័ចុះបញ្ជី យានយន្តដោយកុំព្យូទ័រ។ មួយចំនួននៃគម្រោងផ្សេងៗទៀត ត្រូវបានគេរកឃើញថាជាលទ្ធផលពីការពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាល រឺជាមួយ អ្នកប្រតិបត្តិផ្នែកឯកជន។

គម្រោង ដើម្បីបង្កើតគ្រឿងបរិក្ខាចូលទៅសហគមន៍ និង ក្នុងតំបន់ គឺផ្អែកទៅលើ ការបង់ជាសាច់ប្រាក់ ដែល ពលរដ្ឋ ត្រូវបានគេផ្តល់សិទ្ធិអោយ ពីរដ្ឋាភិបាលម៉ុងហ្គោលី។ ការបង់ប្រាក់ទាំងអស់នេះ គឺត្រូវបាន សម្រុះសម្រួល តាមរយៈធានាគារដែលមានសាខាទូទាំងប្រទេសម៉ុងហ្គោលី។ សំរាប់រដ្ឋាភិបាលម៉ុងហ្គោលី, អត្ថប្រយោជន៍នៃ ការងារ តាមរយៈ ធានាគារគឺថា ពួកគេមាន បណ្តាញសាខាស្រាប់ និង ភាពដែលអាចកើតមាននៃបោកបញ្ឆោត គឺ ត្រូវបានគេបំបាត់ចោល។ អ្នកផ្តល់សេវាទូរគមនាគមន៍, ជាពិសេស អ្នកផ្តល់សេវាផ្កាយរណប, អាចប្រើ អ្នកទទួល ផ្កាយរណបចុងបញ្ចប់នៃទីលំហាតូចដើម្បី ភ្ជាប់សាខាដាច់ស្រយាល តាមរយៈប្រទេស។

ការផ្គត់ផ្គង់-អេឡិចត្រូនិច គឺជាគម្រោងដែល មានសក្តានុពលអស្ចារ្យ សំរាប់ការត្រូវបានគេចែកចាយ ដូចជា PPP មួយ។ បែបផែននៃប្រពន្ធ័ ការផ្គត់ផ្គង់-អេឡិចត្រូនិច ត្រូវបានគេចែកចាយតាមរយៈ PPPs គឺអាចរកបាន និង បានត្រូវគេអនុវត្តន៍ ក្នុងប្រទេស កាណាដា និង ហ្វីលីពីន ( មើល ផ្នែក៤.៥ ) ។

គម្រោងខាងក្រោម គឺត្រូវបានគេកត់ត្រា ដោយផ្អែកទៅលើ ភាពដែលគួរអោយចង់បាននៃការអនុវត្តន៍ពួកគេ :

១. ប្រពន្ធ័ពត៌មានទូទាំងរដ្ឋាភិបាល រួមបញ្ចូលគ្នា ( ERP, ECM )
២. ស្ថាបត្យកម្ម សហគ្រាស
៣. អត្តសញ្ញាណប័ណ្ណជាតិ
៤. ប្រពន្ធ័ធានារ៉ាប់រងសង្គម ជាមួយ ធានាគារ
៥. ការចុះបញ្ជីជំនួញ

ភាពដែលគួរអោយចង់បាន ត្រូវបានគេសំរេចចិត្តលើ មូលដ្ឋាននៃ អត្ថប្រយោជន៍អភិវឌ្ឍន៍ដែលអាចធំបផុត ដែល ការអនុវត្តន៍គម្រោងទាំងនេះ នឹងអោយដល់ប្រទេស។ ឧទាហរណ៍ , ប្រពន្ធ័ពត៌មានទូទាំងរដ្ឋាភិបាល រួមបញ្ចូលគ្នា និង គម្រោង ស្ថាបត្យកម្ម សហគ្រាស នឹងផ្តល់នូវ មូលដ្ឋានសំរាប់ ការធ្វើអោយមានប្រសិទ្ធភាព និង ការពង្រឹង សេវាចែករំលែក រឺ ទូទៅ។ ការធ្វើអោយមានប្រសិទ្ធភាព និង ការពង្រឹង អាចកែប្រែជាពិសេស នូវប្រសិទ្ធិភាព និង តម្លៃប្រាក់។ គម្រោង អត្តសញ្ញាណប័ណ្ណជាតិ នឹងអនុញ្ញាតិសំរាប់ប្រពន្ធ័គ្រប់គ្រង ទិន្នន័យជាតិនៃពលរដ្ឋ អាច ត្រូវបានគេប្រើប្រាស់ម្តងហើយម្តងទៀត សំរាប់ការចុះបញ្ជីអ្នកប្រើប្រាស់ សេវាសារធារណៈ នៅគ្រប់ក្រសួង និង នាយកដ្ឋាន ទាំងអស់ ពាសពេញប្រទេស, ដែលសន្មតថាប្រពន្ធ័ ដែលចាំបាច់ និង ស្ថាបត្យកម្មសហគ្រាស ត្រូវបាន អនុវត្តន៍។

## ៤.៥ ឧទាហរណ៍អន្តរជាតិនៃ PPPs

មានវិធីសាស្ត្រជាច្រើន ដែលក្នុងនៅ PPPs បានត្រូវគេប្រើ ពាសពេញពិភពលោក។ PPPs ត្រូវបានគេប្រើយ៉ាង ខ្លាំងក្លា សំរាប់ការវិនិយោគទហំធំ ជាមួយហេដ្ឋារចនាសម្ពន្ធ័សារធារណៈ និងច្រើនជាងនេះទៀតពេលថ្មីៗនេះ, សំរាប់ការផ្តល់សេវាពត៌មានវិទ្យា ទៅដល់សគ្រាសសារធារណៈ ដូចជារដ្ឋាភិបាលគ្រប់ជាន់ថ្នាក់។ PPPs គឺត្រូវបាន គេប្រើប្រាស់ផងដែរ ដោយ ស្ថាប័នអភិវឌ្ឍន៍ ដើម្បីជួយបែងចែកសេវាខ្លះនៅក្នុងផ្នែកសុខភាព។ ជាទូទៅ, PPPs បានត្រូវគេប្រើសំរាប់គម្រោងហេដ្ឋារចនាសម្ពន្ធ័ នៅក្នុង តំបន់ច្រើនជាង ក្នុង អាយ ស៊ី ធី។ តារាងទី ៤ និង ៥ សង្ខេបពី ប្រភេទនៃគម្រោង PPP ដែលមានសកម្មភាពក្នុងប្រទេស នៅក្នុង និង ក្រៅ សហភាពអឺរ៉ុប ចាប់តាំងពី ខែតុលា ២០០៥។

តារាងទី ៤ សង្ខេបនៃគម្រោង PPPtamRbePT នៅក្នុង សហភាពអឺរ៉ុប

Source: Paul Davies and Kathryn Eustice, *Delivering the PPP promise: A review of PPP issues and activity* (PricewaterhouseCoopers, 2005),36,http://www.pwc.com/extweb/pwcpublications.nsf/docid/5D37E0E325CF5D71852570DC0009C39B.

តារាងទី៥ សង្ខេបនៃគម្រោង PPPtamRbePT នៅក្នុងប្រទេស ក្រៅ សហភាពអឺរ៉ុប

Source: Paul Davies and Kathryn Eustice, *Delivering the PPP promise: A review of PPP issues and activity*(PricewaterhouseCoopers,2005),54,http://www.pwc.com/extweb/pwcpublications.nsf/docid/5D37E0E325CF5D71852570DC0009C39B.

មានគម្រោងពត៌មានវិទ្យាពីរបី  ត្រូវបានកត់ត្រានូវទីនេះ,  ទោះបីជាយ៉ាងណាក៏ដោយ  គម្រោងពត៌មានវិទ្យាធំមួយពីប្រទេស កាណាដា ត្រូវបានគេពិភាក្សាខាងក្រោម ជា ការអនុវត្តន៍ល្អបំផុតនៃ PPP។

វាផងដែរ ផ្តល់ ការឈានចូល ទៅដល់ឯកសារដែលពាក់ពន្ធ័ទាំងអស់ ដែលគេតម្រូវអោយ វាយតម្លៃ ការ ដេញថ្លៃមួប្រពន្ធ័ រួមបញ្ចូល វេទិកាបង់ប្រាក់ ដើម្បីអនុញ្ញាតិ សំរាប់ការទិញ នៃឯកសារស្នើរសុំផ្តល់ និង សេវាផ្សេងៗទៀត ដូចជា ការចុះបញ្ជីក្រុមហ៊ុន តាមប្រពន្ធ័អ៊ីនធរណែត និង ការយកពត៌មានពី បណ្ណ័តណទាន ដើម្បីបង់ប្រាក់សំរាប់យ។ ការចុះបញ្ជី ការទិញ, ការចែកចាយឯកសារ, និង សេវាដែលទាក់ទង ផ្សេងៗទៀត។

ប្រពន្ធ័ការផ្គត់ផ្គង់-អេឡិចត្រូនិច រដ្ឋាភិបាលកាណាដា ត្រូវបានគេផ្តួចផ្តើម នៅក្នុងចុង ទស្សវត្សន៍ ឆ្នាំ១៩៨០ នៅពេល រដ្ឋាភិបាលបានកំពង់តែព្យាយាម អនុវត្តន៍ការកាត់ បន្ថយគម្រោងថវិការជាច្រើន និងការផ្តល់ហិរញ្ញប្បទាន សំរាប់ គំនិតផ្តួចផ្តើមថ្មីៗ គឺមានកំណត់។ ការសិក្សាដំបូង បានបង្ហាញថា ១០លានដុល្លារកាណាដាត្រូវបាន គេត្រូវការ ដើម្បីបង្កើត និង ប្រតិបត្តិ សេវាការផ្គត់ផ្គង់-អេឡិចត្រូនិចមួយ, ចំនួនលើស ពីតម្លៃមួយ ដែលគេបានបង្កើត ឡើង ដើម្បីគ្រប់គ្រង ដំណើរការ ការផ្គត់ផ្គង់ដែល មានស្រាប់។ ដើម្បីឆ្ពោះទៅមុខ, រដ្ឋាភិបាល បានស្នើរអោយ ឧស្សាហកម្មបង្កើត កម្មវិធី ការផ្គត់ផ្គង់-អេឡិចត្រូនិចមួយ ជាប្រតិបត្តិការដែលឧបត្ថម្ភដោយខ្លួនឯង។ រដ្ឋាភិបាល បានចូលទៅក្នុង កិច្ចព្រមព្រៀងសម្បទានមួយ ជាមួយអ្នកប្រតិបត្តិផ្នែកឯកជន ដើម្បីស្ថាបនា និង ប្រតិបត្តិ សេវា ការផ្គត់ផ្គង់-អេឡិចត្រូនិចមួយ ដែលនឹងត្រូវ បានផ្តល់មូលនិធិដោយ ការបង់ថ្លៃរបស់អ្នកប្រើប្រាស់។ ការជ្រើស រើស របស់ អ្នកប្រតិ បត្តិដ៏ជោគជ័យ គឺផ្អែកទៅលើ លកខណ្ឌ័នៃតម្លៃល្អបំផុត ចំពោះអ្នកប្រើប្រាស់ជា បុគ្គល។ សេវា គឺត្រូវបញ្ចូល ទាំងពីរ ការចែកចាយពត៌មាន ជាអេឡិចត្រូនិច និង សេវាពេញ លេញមួយ ដើម្បីគ្រប់គ្រង ការចែកចាយឯកសារដេញថ្លៃ ជារូបរាង។

នៅក្រោមការរៀបចំនេះ, រដ្ឋាភិបាលកាណាដា គឺអាចបង្កើត កម្មវិធី ការផ្គត់ផ្គង់-អេឡិច ត្រូនិចមួយ ដែលបានគេទទួលស្គាល់ ជាប្រពន្ធ័មួយក្នុងចំណោមប្រពន្ធ័តម្លាភាព និងបើកចំហរ ជាច្រើន លើ ពិភពលោក។

>>

ដែលត្រូវបានបង្កើតដោយ ស្នើរ តែគ្មានការចំណាយចំពោះរដ្ឋាភិបាល, ប្រពន្ធ័នោះផង ដែរ បានសន្សំសំចៃ រដ្ឋាភិបាលកាណាដា ប្រហែលជា ៦ លានដុល្លារកាណាដា ក្នុងមួយឆ្នាំ នៅក្នុង ការថត ចម្លង, តម្លៃ អ្នកនាំសំបុត្រ និង ម៉ាស៊ីនផ្ញើរសារ សំរាប់ចែកចាយ ឯកសារដេញថ្លៃ ទៅដល់អ្នកផ្គត់ផ្គង់ ដែលបានស្នើរសុំ។

ចាប់តាំងពី ប្រពន្ធ័ Merx បានដំណើរការ, រដ្ឋាភិបាលកាណាដា បានផ្តល់កិច្ចសន្យាសេវា ទៅអោយ អ្នកផ្គត់ផ្គង់ បី ផ្សេងៗគ្នា ដោយប្រើប្រាស់លកខណ្ឌ័ដូចគ្នា - ឧទាហរណ៍ អ្នកផ្គត់ផ្គង់ដែលអាចចែកចាយ សេវាដែលគេត្រូវការ នូវតម្លៃដ៏ល្អ សំរាប់អ្នកប្រើប្រាស់។ ដើម្បីធានាថា ភាគច្រើនបំផុតនៃពត៌មាន រដ្ឋាភិបាលសហពន្ធ័ គឺ បានគេធ្វើអោយអាចរកបាន ចំពោះអ្នកប្រើប្រាស់ ដោយមិនអស់តម្លៃ, រដ្ឋាភិបាល បច្ចុប្បន្ន កំពង់តែអោយប្រាក់បម្រុង លើ ការប្រតិបត្តិសេវា។

វិធីសាស្រ្ត PPP អនុញ្ញាតិអោយ រដ្ឋាភិបាល បន្ទូរហានិភ័យដែលភ្ជាប់ជាមួយ ការរៀបចំដែលផ្តល់ មូលនិធិផ្ទាល់ខ្លួន ដែលគេស្នើរសុំ, នៅពេលដែល គ្មានការធានាថា ទំហំនៃជំនួញណាមួយ នឹងបានសំរេច។ វាត្រូវការរយះពេលពីរ បី ឆ្នាំ សំរាប់មូលដ្ឋានទីផ្សារ រីកធំធាត់ ដល់កម្រិតដែលអាចទ្រទ្រង់រួច។ នៅក្នុងឆ្នាំដំបូង នៃប្រតិបត្តិការ, មូលដ្ឋាន អ្នកប្រើប្រាស់ បានកើនឡើង ពី ២០០០ ទៅ ៦០០០នាក់។ បន្ទាប់ពី ៥ ឆ្នាំ, សេវា បានកំពង់តែទ្រទ្រង់ អ្នកប្រើ ប្រាស់ ប្រហែល ១២,០០០ នាក់។ ឥឡូវនេះ សេវា MERX រក្សាបាន អ្នកប្រើប្រាស់ច្រើនជាង ២៥,០០០ នាក់។ ទីផ្សារធំផ្តល់ រដ្ឋាភិបាលនូវ ការប្រកួតប្រជែងជាបន្តបន្ទាប់សំរាប់ឱកាសផ្គត់ផ្គង់ ដែលអនុញ្ញាតិអោយមាន ការ សន្សំសំចៃ ១០ ភាគរយ លើការផ្តល់អោយដែលស្នើរសុំពីមុន ដែលត្រូវបានគេអនុវត្តន៍ ដោយគ្មានការប្រកួតប្រជែង។

ដោយចាប់ផ្តើមជាមួយជំនួយការ នៃភ្នាក់ងារអភិវឌ្ឍន៍ អន្តរជាតិ កាណាដា, រដ្ឋាភិបាល ហ្វីលីពីនផងដែរ បាន អនុវត្តន៍ វិធីសាស្រ្ត PPPមួយ ជាមួយអ្នកផ្គត់ផ្គង់ ក្នុងស្រុក ដើម្បីអភិវឌ្ឍន៍ កម្មវិធី ការផ្គត់ផ្គង់-អេឡិចត្រូនិច របស់ វា ដែលត្រូវបានគេហៅថា PhilGEPS ( htpp://www.philgeps.net /GEPS/default.aspx )។

>>

មួយក្នុងចំណោមបញ្ហា ដែល PPPរបស់កាណាដា មួយនេះ បានទទួលជោគជ័យ គឺថា ក្រុមហ៊ុនដែលបានឈ្នះ ការដេញថ្លៃ, Merx Cebra, ចំនែកមួយនៃធានាគារ Montreal, មួយក្នុងចំណោមធានាគារដែលធំបំផុត នៅក្នុង កាណាដា, បានអភិវឌ្ឍន៍រួចរាល់ហើយនូវកម្មវិធីស្រដៀងគ្នាមួយ។ Merx Cebra មានជំនាញការទាំងអស់ ដែល គេតម្រូវ និង ការយល់ដឹងពិតប្រាកដ នៃតម្លៃ និង ហានិភ័យ និងនៃករណីជំនួញ ជាទូទៅ។

PPPs នៅ សាំងហ្គាពួរ[៥៦]

រដ្ឋាភិបាលសាំងហ្គាពួរ បានអនុវត្តន៍ គម្រោង PPPs ខាងក្រោម:

- រោងចក្រ បន្សាប (គណៈកម្មការអគ្គប្រយោជន៍សារធារណៈ)- ២០០៣
- រោងចក្រ NEWater Ulu Pandan (ក្រុមប្រឹក្សាអគ្គប្រយោជន៍សារធារណៈ)- ២០០៤
- ឡ (ស្ថាប័នបរិស្ថានជាតិ)- ២០០៥
- TradeXchange (ពន្ធគយ សាំងហ្គាពួរ)- ២០០៥

គម្រោងដែលផ្អែកលើ PPP ខាងក្រោម គឺត្រូវបានគេពិចារណាផងដែរ:

- មជ្ឈមណ្ឌល កីឡា (ក្រសួងអភិវឌ្ឍន៍សហគមន៍ យុវជន និង កីឡា/ក្រុមប្រឹក្សា កីឡា សាំងហ្គាពួរ)
- ការអភិវឌ្ឍន៍ មហាវិទ្យាល័យ ITE College West (វិទ្យាស្ថាន អប់រំ បច្ចេកវិទ្យា)
- ការកែប្រែ សាលាមធ្យមសិក្សា ៥ ក្រោម កម្មវិធី សំរាប់ ការកសាងឡើងវិញ និង ការធ្វើអោយប្រសើរឡើង ចំពោះសាលាដែលមានស្រាប់ (ក្រសួងអប់រំ)

The Singapor Customs TradXChange គឺជា គម្រោង រដ្ឋាភិបាល-អេឡិចត្រូនិច មួយ។

សំរាប់រដ្ឋាភិបាលសាំងហ្គាពួរ, ការផ្តោតអារម្មណ៍ គឺ នៅលើការស្វែងរក វិធីសាស្រ្តដែលមានប្រសិទ្ធភាពបំផុត នៃ ការចែកចាយសេវាសារធារណៈ សំរាប់វិនិយោគសារធារណៈដែលបានលើកឡើងមួយ។ ក្រសួងហិរញ្ញវត្ថុ នៃ រដ្ឋាភិបាលសាំងហ្គាពួរ ទទួលខុសត្រូវ ការផ្គត់ផ្គង់សារធារណៈសំរាប់រដ្ឋបាល និង គេហទំព័ររបស់គេ រួមបញ្ចូល ផងដែរ បញ្ជីសំណួរដែលត្រូវបានគេសួរជាញឹកញាប់ ចំពោះ PPP។

PPPs គឺជាជម្រើសមួយ សំរាប់ការចែកចាយសេវាសារធារណៈ ដែលមានតម្លៃលើស ៥០លានដុល្លារសាំងហ្គាពួរ។ពួកគេនឹងត្រូវបានគេពិចារណាផងដែរ សំរាប់គម្រោងជាមួយនិងតម្លៃក្រោមការកំណត់នេះ ប្រសិនបើវិធីសាស្រ្ត អាចត្រូវបានគេចង្អុលបង្ហាញ ដើម្បីចែកចាយ តម្លៃសំរាប់សាច់ប្រាក់។ នេះ ស្រដៀងគ្នាទៅនិងទស្សនៈនៃ ក្រុម PPP របស់ចក្រភពអង់គ្លេស ដែលមានអង្គភាពនៅក្នុងក្រសួងហិរញ្ញវត្ថុ ដែលបង្កើតការយល់ដឹងនៃ PPP, កាន់កាប់គោលនយោបាយ PPP និង ផ្តល់ការណែនាំ លើបញ្ហា PPP។

PPPs នៅ ហុងកុង

នៅហុងកុង ផ្នែកឯកជន បានដើរតួនាទីសំខាន់ជាយូរមកហើយ ក្នុងការផ្តល់ហេដ្ឋារចនាសម្ពន្ធ័ សេដ្ឋកិច្ច និង សេវា សារធារណះ, ដែលរួមទាំង សេវាអេឡិចត្រូនិច និង ឧស្ម័ន, ហេដ្ឋារចនាសម្ពន្ធ័ ទូរគមនាគមន៍, និង សេវាដឹកជញ្ជូន សារធារណះ។ នៅដើមទសវត្សរ៍ ឆ្នាំ ២០០០ ឧនភាពនៃថវិកា និង បំណង ដើម្បីកាត់បន្ថយ ការចំណាយ សារធារណះ ដែលធ្វើអោយ PPPs ក្លាយជាវិធីសាស្រ្តដែលពេញនិយម ដើម្បីអភិវឌ្ឍន៍ នៅក្នុងប្រទេស។ នៅក្រោម ការរៀបចំបែបនេះ, រដ្ឋាភិបាល កំណត់គុណភាព និង បរិមាណ របស់សេវា និង កំណត់គ្រោងពេល នៅ ពេលដែល ផ្នែកឯកជន ផ្តល់ ហិរញ្ញប្បទានគម្រោង និង ចែកចាយ សោវា។ គោលដៅនៃផលប្រយោជន៍ គឺ ការ កែប្រែ ផលិតភាព និង ប្រសិទ្ធភាពតម្លៃ, គុណភាពដែលបានកែប្រែ នៃការចែកចាយសេវា, ការចែករំលែក ហានិភ័យ, ការកែលម្អឡើងវិញ, ឱកាសជំនួញ និង ការងារ ច្រើនជាងមុន, ការឈានចូលទៅហរិញ្ញវត្ថុឯកជន, និង លំហូរសាច់ប្រាក់ដែលបានធ្វើអោយប្រសើរឡើង។

ទោះបីជ យ៉ាងាណាក៏ដោយ, PPPs នៅក្នុង ហុងកុង បានមាន ជោគជ័យលាយគ្នា នៃ គម្រោង ៤ ដូចជា the Cyberport, the Asia-World Expo, the West Kowloon Cultural District និង the Center for Youth Development, ប៉ន្តែគម្រោង the Asia-World Expo, the West Kowloon Cultural District និង the Center for Youth Development, បានជួបជាមួយនិងការលំបាក។ បញ្ហា ដូចជា ការប្រឹក្សាយោប់មិន គ្រប់គ្រាន់, អនុគ្រោះនិយម និង បញ្ហាផ្គត់ផ្គង់ បានធ្វើអោយបាក់ស្រុត ទំនុកចិត្តរបស់សារធារណះជន ក្នុង PPPs។

ជាការពិត សំរាប់ PPP ដើម្បីជោគជ័យ មាននូវ តម្រូវការជាច្រើន ដើម្បីមាន តម្លាភាពពេញលេញ នៅគ្រប់ ដំណាក់កាលនៃគម្រោង, ការធានានៃការទទួលខុសត្រូវសង្គម របស់ដៃគូរឯកជន, និង ភាពអាចជឿជាក់បាននៃ រដ្ឋាភិបាល ក្នុង ការរៀបចំ, ការដាក់បញ្ញាត្តិ និង ការត្រួតពិនិត្យ នៃគម្រោង PPP ។

នៅក្នុងរយះពេលខ្លី ទំនុកចិត្តរបស់សារធារណះជនហុងកុង នៅក្នុងការរៀបចំ PPP នឹងចាំបាច់ត្រូវបានគេស្តារ ឡើងវិញ។ ក្នុងរយះពេលវែង, យន្តការភាពអាចជឿជាក់បាន ចាំបាច់ត្រូវបានគេពង្រឹង ដើម្បីទ្រទ្រង់ ការគាំទ្រ សារធារណះលើ PPP។ ការផ្សព្វផ្សាយយ៉ាងខ្លាំងក្លា នៃការអនុវត្តន៍ល្អ, វិធីសាស្រ្តដែលរាប់បញ្ចូល,ការប្រឹក្សាជា បន្តបន្ទាប់ និង យុទ្ធនាការពត៌មានសារធារណះ គឺ គេត្រូវការទាំងអស់ ដើម្បីអោយវាកើតឡើង។

## ៥. ហានិភ័យ ក្នុងគម្រោង PPP សំរាប់ រដ្ឋាភិបាល-អេឡិចត្រូនិច

ហានិភ័យ សំដៅលើកត្តាណាមួយដែលបន្ថយភាពពិតប្រាកដនៃលទ្ធផលដែលប៉ុនប៉ង។ ហានិភ័យ ប្រែប្រួលជាមួយនិង តម្រូវការ និង កាលៈទេស។ ហើយ ហានិភ័យ គឺផ្អែកលើ ការពិត រួមទាំង ការយល់ឃើញ។

មានហានិភ័យដែលភ្ជាប់ជាមួយ រដ្ឋាភិបាល-អេឡិចត្រូនិច/គម្រោង អាយ ស៊ី ធី ហើយនិង មានហានិភ័យដែលភ្ជាប់ជាមួយ PPPs។ ផ្នែកឯកជន និង សារធារណៈ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត ដែលរួមទាំងសង្គមស៊ីវិល និងសារធារណៈជនទូទៅ ត្រូវតែដឹងពីបញ្ហាទាំងនេះ ដើម្បីអាចវាយតម្លៃ ជម្រើសយ៉ាងប្រុងប្រយ័ត្ន និងឈានទៅ ដល់ការសំរេចចិត្តល្អមួយ ដែលផ្អែកទៅលើ ការវិភាគមិនលំអៀង នៃការពិត។ ការគ្រប់គ្រង និង ការសម្រាល ហានិភ័យ ក្នុងដំណើរការ PPP គឺ សំខាន់ណាស់ ដើម្បីជៀសវាងបរាជ័យរួមនិង ការប្រឆាំង ទៅនិង ឱកាស PPP ផ្សេងៗទៀត។

### ៥.១ ហានិភ័យដែលភ្ជាប់ជាមួយ គម្រោង អាយ ស៊ី ធី[៦១]

គម្រោង អាយ ស៊ី ធី ផ្ទុក នូវហានិភ័យនៃការបរាជ័យ យ៉ាងទូលំទូលាយ ដោយសារតែ ចរឹកលក្ខណៈមួយចំនួន នៃ ធាតុផ្សំព័ត៌មានវិទ្យា របស់គម្រោងនោះ។ ក្នុងឆ្នាំ ១៩៩៥, The Standish Group, របាយការណ៍ CHAOS, បានបង្ហាញថា ត្រឹមតែ១៨ ភាគរយ នៃគម្រោងពត៌មានវិទ្យារដ្ឋាភិបាល ចំនួន ១៣,000 ដែលគេស្ទង់មើល បានទទួលជោគជ័យ។ ដែលបន្តពីក្រោយ ដោយ ស៊េរី នៃការបរាជ័យគម្រោងពត៌មានវិទ្យា ចំនួនខ្ពស់មួយ ដែលបានកំណត់ ដោយ អគ្គសាវនកររបស់ប្រទេសកាណាដា (GoC), the GoC បានសំរេចប្តូរ វិធីសាស្រ្តសាមញ្ញមួយ សំរាប់ការគ្រប់គ្រង គម្រោងពត៌មានវិទ្យា ដើម្បីជំនះនូវរាល់បញ្ហាដែលបានកំណត់ និង ដើម្បី បង្កើនភាពដែលអាចកើតមានឡើង នៃជោគជ័យគម្រោង។

វិធីសាស្រ្តសាមញ្ញោនះ គឺត្រូវបានគេហៅថា គម្រោងគ្រប់គ្រងបន្ថែម (EMF)។ វាគឺជាវិធីសាស្រ្តមួយ ដែលទូលំ ទូលាយ សំរាប់ការគ្រប់គ្រង គម្រោងពត៌មានវិទ្យា ក្នុងរដ្ឋាភិបាល។ ដើម្បីធានា ការអនុវត្តន៏នៃ EMF ក្រសួង និមួយៗ, ក្រុមប្រឹក្សារតនាគាកាណាដា (ភ្នាក់ងារកណ្តាល ទទួលខុសត្រូវការធានាតម្លៃនៃប្រាក់) បានផ្សព្វផ្សាយ វិធីសាស្រ្តរៀបចំនិងចូលរួមមួយ ចំពោះការអនុវត្តន៏ EMF។ ការស្រាវជ្រាវ លើការទទួល យកដំណើរការ ដែលមានរចនាសម្ពន្ធ័ខ្ពស់ (ដូចជា វិទ្យាស្ថានវិស្វកម្មកម្មវិធី សមត្ថភាព ភាពចាស់ទុំ បែបផែនការរួមបញ្ចូល) សំរាប់គម្រោងពត៌មានវិទ្យា (ដែលជាផ្នែកមួយនៃ EMF) ពិតជាចង្អុលបង្ហាញ ការទទួល

ប្រសិទ្ធិភាព និង គុណភាព (មេរៀនទី៧ ផ្តោតទៅលើ ការគ្រប់គ្រងគម្រោង, ដែលសំខាន់ដើម្បីពង្រឹង ឱកាសជោគជ័យនៃគម្រោង អាយ ស៊ី ធី)។ ការប្រើប្រាស់ នៃ ដំណើរការផែនការ និង ការអនុវត្តន៍ ដែលបានគិតនិងរៀបចំ បណ្តាលអោយ មានអត្ថប្រយោជន៏ខាងក្រោមនេះ :

- ការកើនឡើង ផលិតភាព ចាប់ពី ១០ ទៅ ១០០ ភាគរយ
- ការកាត់បន្ថយអត្រា ខុសឆ្គង និង ខ្វះចន្លោះ ពី ៤០ ទៅ ៧០ ភាគរយ
- ការសន្សំ ៤-៦ ដុល្លារអាមេរិក សំរាប់ រាល់ដុល្លារ ដែលបានវិនិយោគជាមួយការកែប្រែដំណើរការ
- ការកែប្រែ គម្រោងពេល ដែលក្នុងករណីខ្លះ នាំទៅដល់ អត្រាកែប្រែ ពី ៥០ ទៅ ១ ភាគរយ ទៅលើ កាលវិភាគនៃគម្រោង និង
- ការកាត់បន្ថយលើតម្រូវការ ដើម្បីធ្វើឡើងវិញ រឺធ្វើម្តងទៀត នូវការប្រឹងប្រែដែលបានធ្វើរួចហើយ

ពី ៤០ ទៅ ២៥ ភាគរយ នៃការប្រឹងប្រែងនៃគម្រោងសរុប។

## ហានិភ័យនៃគម្រោង អាយ ស៊ី ធី ផ្សេងៗ

ការផ្លាស់ប្តូរបច្ចេកទេសយ៉ាងឆាប់រហ័ស អាចបង្កើន ចំណាយ និង អាចបន្ថែម ទិដ្ឋភាពមួយ នៃភាពមិនច្បាស់លាស់ និង ហានិភ័យ ដែលពិបាកគ្រប់គ្រង។ គម្រោង ដែលប្រើបច្ចេកវិទ្យាដែលគេបានបង្កើត, ដូចជា បច្ចេកវិទ្យា ដែលទំនង ជាត្រូវបានប៉ះទង្គិច ក្នុងគម្រោងអភិវឌ្ឍន៏ និងជាពិសេសក្នុងគម្រោង នៅក្នុងប្រទេស ដែលមាន ប្រាក់ ចំណូលទាប, មិនគួរជាកង្វល់ទេនៅក្នុងចំនុចខាងលើនេះ។ បច្ចេកវិទ្យាខ្លះ ត្រូវបានគេចាត់ទុក ថាជា ភស្តុតាង អានាគត ដែលប្រែប្រួល។

ការស្ថាបនា ភាពរឹងមាំនៃ ខ្សែអុបទិក ដែលត្រូវគ្នាជាមួយ បច្ចេកវិទ្យាពហុគុណាការបែងចែកប្រវែងរលក (WDM) និងរ៉ាប់រង ការប្រើប្រាស់របស់វា។ WDM អនុញ្ញាតិអោយ មានការបញ្ជូនច្រើនដងដ៏អស្ចារ្យ និង ជាបច្ចេកវិទ្យា ដែលអាចប្រើបានរយះពេលជាច្រើនឆ្នាំទៀត។ យ៉ាងណាក៏ដោយ, ការប្រើ បច្ចេកវិទ្យា broadband គ្មានខ្សែជាកម្មសិទ្ធ ប្រហែលមិនអាចផ្តល់ការរ៉ាប់រងដូចគ្នានោះទេ។ ក្នុងគម្រោង អាយ ស៊ី ធី ស្មុគស្មាញ ដែលពាក់ពន្ធ័ ការរចនាប្រពន្ធ័ និង ការរៀបចំ ដំណើរការជំនួញ ដើម្បី អោយមានការប្រើឧបករណ៏ស្វ័យប្រវត្តិ, ទំហំនៃគម្រោង និង កំរិតនៃការប្រឹងប្រែងដែលត្រូវការ អាចជា ពិបាកវាយតម្លៃ។

កត្តាមនុស្ស ដូចជា ការប្រឆាំងទៅនិងការផ្លាស់ប្តូរ គឺពិបាកផងដែរ ដើម្បីវាស់វែង និង ប៉ាន់ស្មាន។ គម្រោង ដែល ពាក់ពន្ធ័ អង្គភាពជាច្រើន ដូចជា គម្រោង រដ្ឋាភិបាល-អេឡិចត្រូនិច ខ្នាតធំ បង្ហាញនូវ ការលំបាកស្រដៀងគ្នា។

គម្រោងខ្លះ ពាក់ពន្ធ័ និងរបស់ទ្រព្យគ្មានរូបរាង ដូចជា វេបសាយ និង កម្មសិទ្ធបញ្ញា, ផ្លាកសញ្ញា, សិទ្ធជួញដូរ, កេរ្តិ៍ឈ្មោះ, ម៉ាកយីហោ, បណ្ណ័ប៉ាតង់ និង ការរក្សាសិទ្ធ។ ដោយសារតែ ភាពងាយស្រួល ដែលជាមួយរបស់ទ្រព្យទាំងនេះ អាច និង ត្រូវបានក្លែងបន្លំ និង លួច, ពួកគេ ពាក់ពន្ធ័មនិង ហានិភ័យចំពោះ អ្នកនិពន្ធ និង ម្ចាស់កម្មសិទ្ធិ។

## ៥.២ ការគ្រប់គ្រង គម្រោង អាយ ស៊ី ធី ដើម្បីកាត់បន្ថយហានិភ័យ

ជាសង្ខេប, ជាតុផ្សំព័ត៌មានវិទ្យា របស់គម្រោង អាយ ស៊ី ធី តម្រូវនូវ ការយកចិត្តទុកដាក់ពិសេសមួយ។ បញ្ហាដែលអាចកើតឡើង គួរតែបានគេរំពឹងទុក និង បានបរិយាយ។ ភាពដែលអាចប្រតិបត្តិជាមួយគ្នា គឺ សំខាន់សំរាប់ការពង្រឹង និង ធ្វើអោយមានប្រសិទ្ធភាព សេវា។ ការប្រើប្រាស់នូវស្តង់ដារបើកចំហ លើកទឹក ចិត្តដល់ភាពដែលអាចប្រតិបត្តិជាមួយគ្នា និង ទំរង់ទូទៅ សំរាប់ការរក្សាទុក, ការទទួលមកវិញ និង ការ ផ្លាស់ប្តូរព័ត៌មាន។ កម្មវិធីដែលប្រើស្តង់ដារទូទៅ ជំនួសអោយ ស្តង់ដារជាកម្មសិទ្ធ សំរាប់ការបញ្ចេញទិន្នន័យធ្វើអោយ វាងាយស្រួលជាង ដើម្បីដំណើរការលើទិន្នន័យដែលបញ្ចេញដោយ កម្មវិធី Software ផ្សេងៗដោយគ្មាន តម្រូវការ សំរាប់ លំដាប់លំដោយនៃការបញ្ជូនទិន្នន័យ និង ការបាត់បង់ដែលអាច នូវទ្រង់ទ្រាយ រឺក៏ ភាពពេញ លេញនៃទិន្នន័យ ដែលពេលខ្លះអាចកើតឡើង នៅពេលទិន្នន័យត្រូវបាននាំចូល រឺ នាំចេញរវាង កម្មវិធី ដែលប្រើ ប្រាស់នូវ ទម្រង់ និង ស្តង់ដារទិន្នន័យ ផ្សេងគ្នា។

ការអភិវឌ្ឍន៍ គម្រោងដំណោះស្រាយទូទៅមួយ គឺជារបៀបមួយទៀត ដើម្បីកាតបន្ថយហានិភ័យ ដែលភ្ជាប់ជាមួយ គម្រោង អាយ ស៊ី ធី។ ការគូសបញ្ជាក់ នៅទីនេះ គឺទៅលើ ការអភិវឌ្ឍន៍ វិធាន និង និតិវិធីគ្រប់គ្រងលំអិត។ នេះ ពាក់ពន្ធ័និង ចំនុចមួយចំនួន ដូចជា :

- ផែនការ និង ការត្រួតពិនិត្យ
- ការត្រួតពិនិត្យគុណភាព
- ការផ្គត់ផ្គង់
- ការគ្រប់គ្រង ហានិភ័យ
- ការគ្រប់គ្រង ការផ្លាស់ប្តូរ – ដែលគ្រប់គ្រង ការផ្លាស់ប្តូរ នៅក្នុងកម្រិតនៃគម្រោង, ឧទា. នៅក្នុងវដ្តគម្រោង សំរាប់ការអនុវត្តន៏គម្រោងផ្ទាល់ខ្លួន

ក្នុងករណីខ្លះ, ការរៀបចំស្ថាប័ន ត្រូវតែធ្វើ ដើម្បីធានា គុណភាព និង ការត្រួតត្រា។

PPPs គឺជា របៀប ផ្សេង មួយ នៃគម្រោងហិរញ្ញប្បទាន, ប៉ុន្តែ នៅតែមានតម្រូវការមួយ ដើម្បីអោយ ការងារ ត្រូវបានគេធ្វើ។ ឯកសារ ស្នើសុំផ្តល់ និងត្រូវតែបានគេអភិវឌ្ឍន៍។ ដោយសារតែ គម្រោង PPP ខុសប្លែកពី កិច្ចសន្យាធម្មតា សំរាប់ ការងារ រឺសេវា, វាមាននូវតម្រូវការមួយ ដើម្បីធានាថា និតិវិធីផ្គត់ផ្គង់ ច្បាស់លាស់ ហើយនិង ការស្នើរ សុំផ្តល់ គឺងាយយល់ និង មានន័យច្បាស់លាស់ ជាពិសេស ប្រសិនបើ គម្រោង PPP កំពង់ត្រូវបានគេធ្វើ សំរាប់ លើក ទីមួយ។

វាមិនមែនធម្មតាទេ នៅដំណាក់កាលនេះ ដើម្បីជួល ក្រុមហ៊ុនឯកទេស ក្នុងការសរសេរ សំណើរគម្រោង PPP និងឯកសារស្នើរសុំផ្តល់ ដើម្បីជួយ ក្នុង ការពង្រាងឯកសារស្នើរសុំផ្តល់ និង ការផ្តល់ប្រឹក្សាដល់ រដ្ឋាភិបាល លើ វិធីសាស្រ្តដែលត្រូវយក។ នៅពេល ដែលគម្រោង PPPមួយ ត្រូវបានគេស្នើរសំផ្តល់, អ្នកប្រឹក្សា PPP អាចបន្តផ្តល់យោបល់ ទោដល់រដ្ឋាភិបាល ក្នុងការៀបចំ សំរាប់ និង កំឡុងពេល ការចរចារ ដែល ចាំបាច់ ត្រូវកើត ឡើង មុនពេលកិច្ចព្រមព្រៀងសំរាប់ PPPមួយ អាចត្រូវបានគេបញ្ចប់។ នៅក្នុងករណីខ្លះ, ក្រុមហ៊ុន ផ្នែកឯកជន នឹងរក្សាផងដែរ នូវជំនាញការ ដើម្បីជួយពួកគេ ក្នុង ការចរចារ និង ការរៀបចំ កិច្ចព្រមព្រៀង។

ការគ្រប់គ្រងការផ្លាស់ប្តូរ គឺសំខាន់ ចំពោះគម្រោងរដ្ឋាភិបាល។ ការប្រើប្រាស់ឧបករណ៍ស្វ័យប្រវត្តិ និង ការប្តូរ ទៅជាប្រពន្ធ័កំព្យូទ័រ បញ្ជាក់ពី ការផ្លាស់ប្តូរទាំងស្រុងក្នុងរបៀបធ្វើការងារ។ ដើម្បីធានា ការគាំទ្រដ៏ ខ្លាំងក្លា ដែលអាចបាន ពី និយោជិក និង បុគ្គលិកផ្នែកឯកជន, កម្មវិធីគ្រប់គ្រងការផ្លាស់ប្តូរ អាចចាំបាច់ត្រូវគេ បង្កើត។

ការយកចិត្តទុកដាក់ពិសេស ចំពោះការគ្រប់គ្រងគម្រោង គឺជារបៀបមួយនៃការគ្រប់គ្រង និង ការសម្រាល ហានិភ័យ។ ក្រុម រចនានិង គ្រប់គ្រងគម្រោង មួយ ត្រូវបានគេភ្ជាប់ជាមួយ ការរៀបចំនៃគម្រោង។ ក្រុម បច្ចេកទេស មួយ ផ្តល់ជំនាញការបច្ចេកទេស ដែលអាចត្រូវបានគេតម្រូវ។ បទពិសោធន៍, ប៉ុន្តែពិសេស ភាពជោគ ជ័យ, ដែលស្ថាប័ន រឺ អង្គការ បានសំរេចក្នុងការគ្រប់គ្រងគម្រោង គឺត្រូវបានគេដាក់ជាឯកសារ ដើម្បីបង្កើត ការអនុវត្តន៍ ដ៏ល្អបំផុត ដើម្បីអោយ មេរៀន អាចត្រូវបានគេសិក្សា និងចែកចាយ។

### ៥.៣ ហានិភ័យ ក្នុង គម្រោង PPP

ហានិភ័យមួយចំនួនដែលភ្ជាប់មកជាមួយគម្រោង PPP គឺទាក់ទងទៅនិង ភាពថ្មីប្លែកនៃវិធីសាស្រ្ត និងការប្រឆាំង ទៅនិង គំនិងនៃការធ្វើការជាមួយផ្នែកឯកជន ជា ដៃគូរ និង មិនមែនជា អ្នកម៉ៅការបន្ទាប់

ជាឧទាហរណ៍ ។ ដើម្បីជំនះ ហានិភ័យនេះ អាចតម្រូវអោយមាន ការផ្លាស់ប្តូរសំខាន់មួយ ក្នុងរបៀបធ្វើការងារ រួមទាំង ការផ្លាស់ប្តូរ ទស្សនះ និង ផ្លូវចិត្ត។

នៅក្នុងប្រទេសជាច្រើន, ផ្នែកសារធារណៈ គឺជាតួអង្គចំបងមួយ និង ផ្នែកឯកជនមានសារៈសំខាន់មួយ ប៉ុន្តែជា តួអង្គទីពីរ។ ដូចគ្នានេះដែរ, នៅក្នុងយុត្តធិការមួយចំនួន, ផ្នែកឯកជន គឺជាតួអង្គថ្មីមួយ និង ដើម្បី អោយមានការប្រព្រឹត្តស្មើរគ្នា ចំពោះអ្នកប្រតិបត្តិផ្នែកឯកជន នៅពេលដែល ត្រូវបានផ្តល់ រឺ ទទួលយក ដោយដៃគូរផ្នែក ឯកជន តម្រូវអោយមាន ការផ្លាស់ប្តូរទស្សនះ។

សំរាប់បញ្ហាដូចគ្នាទាំងនេះ នៅក្នុងប្រទេសជាច្រើន,ផ្នែកឯកជន គឺទន់ខ្សោយ និង មិនអាចទទួលយកតួនាទីជា ដៃគូរ ចំពោះផ្នែកសារធារណះ។ ហើយ ការនាំយកដៃគូរបរទេសក្នុងការរៀបចំជំនួញដែលបថុយប្រថានរួមគ្នា មួយ គឺតែងតែមិនអាចធ្វើបាន រឺ មិនបានដូចបំណង។ ប្រសិនបើមានការប្រឆាំងទៅនិងផ្នែកឯកជន, វាទំនងជា នៅមាន នៅពេលដែល ដៃគូរឯកជនត្រូវបានគេនាំយកមកចូលរួម។ ម៉្យាងវិញទៀត, នៅក្នុងករណីខ្លះ ដៃគូរ ឯកជន ជាក់ស្តែង អាចធ្វើអោយ ការស្នើរសុំ PPP ក្លាយជាការពិត។

កត្តាដែលបង្កើនហានិភ័យ ក្នុង PPPs ត្រូវបានគេពិភាក្សា ខាងក្រោម។

១. ទំហំគម្រោង: គម្រោង អាយ ស៊ី ធី ធំ និង ស្មុគស្មាញ ផ្ទុកនូវ ហានិភ័យជាច្រើន។ ការយល់ដឹងពី គម្រោងជំនួញ របស់ភ្នាក់ងារផ្សេងៗ និង ការធានាថា ដំណោះស្រាយ អាយ ស៊ី ធី មួយ អាចដោះស្រាយ បញ្ហារបស់អ្នករាល់គ្នា តម្រូវអោយមាន ការប្រឹងប្រែង និង ការសាមគ្គី ជាច្រើន ដែលចំណាយពេលច្រើន។ ការរៀបចំគម្រោងជំនួញឡើងវិញ និង ការគ្រប់គ្រងការផ្លាស់ប្តូរ ជារឿយ គឺចាំបាច់, ហើយនិង លទ្ធផល តែងតែមិនច្បាស់ រឺ មិនអាចព្យាករណ៍បាន។

២. បទពិសោធន៍ជាមួយ PPPs : កង្វះខាតបទពិសោធន៍ជាមួយ PPPs លើ ផ្នែកនៃភាគីណាមួយ អាចនាំអោយមាន កង្វះខាតទំនុកចិត្ត, ការយល់ខុស, កង្វះនៃការសម្របសម្រួល និង កំហុសឆ្គង ចំពោះគ្នាទៅវិញទៅមក។

៣. តម្លៃគម្រោង និង តម្រូវការហរិញ្ញប្បទានៈ វាប្រហែជាពិបាកដើម្បីកំណត់ទំហំអោយត្រឹមត្រូវ នូវការចំណាយ និង តម្រូវការហរិញ្ញប្បទាន របស់ PPP មួយ, ជាពិសេស ប្រសិនបើ គម្រោង ស្មុគស្មាញ និងពាក់ពន្ធ័ជាមួយ តួអង្គផ្សេងៗច្រើន។ លើសពីនេះទៅទៀត ការចំណាយនៃការទទួលបានហរិញ្ញប្បទាន អាច

ខ្ពស់ជាង ផែនការ ផ្តល់អោយ ដោយផ្អែកទៅលើ កម្រិតដែលបានប៉ាន់ស្មាននៃហានិភ័យ របស់ជំនួញដែលនៅ ក្រោមការគ្រប់គ្រង របស់អ្នកប្រតិបត្តិផ្នែកឯកជនដែលមិនបានបង្ហាញមួយ។

៤. ទស្សនៈសារធារណៈ : អ្វីដែលសារធារណៈជន គិតអំពី PPPs មានឥទ្ធិពលទៅលើ ការទទួលយក PPPs ។ នៅក្នុងប្រទេសខ្លះ, អន្តរអំពើ រវាង ផ្នែកឯកជន និង ផ្នែកសារធារណៈ អាចត្រូវបានគេបង្ហាញ ដោយប្រុងប្រយត្ន័ ពីព្រោះនៅក្នុងករណីខ្លះ វាអាចនាំទៅដល់ អនុគ្រោះនិយម និងអត្តចរឹករកកន្លែងរហែក។ អាចនិងមានផងដែរ នូវការថប់អារម្មណ៏ ទៅលើឥទ្ធិពលរបស់ PPPs លើ ការងារសារធារណៈ។ PPPs អាចត្រូវបានគេដឹង ដោយ និយោជិកសារធារណៈ, សហជីព និង ផ្សេៗទៀត ថាជា របៀបមួយ នៃការធ្វើអោយផ្នែក សារធារណៈតូចជាងមុន ដែលអាចបង្កអោយមាន ការប្រឆាំងចំពោះ PPPs។

៥. ចំនួននៃគូអង្គដែលពាក់ពន្ធ័ : ការពាក់ពន្ធ័នៃគូអង្គច្រើន បង្កើននូវហានិភ័យ ពីព្រោះ មាន ភាពស្មុគស្មាញ ដែល កើនឡើង ( មើល លេខ១ ) និង មាន មនុស្ស និង កត្តា ជាច្រើន ដើម្បីដោះស្រាយ។

៦. ការរៀបចំគម្រោង: ការរៀបចំមិនបានល្អ អាចបណ្តាលអោយមាន ការចំណាយខ្ពស់ និងហានិភ័យច្រើន។

៧. សមត្ថភាពនៃបញ្ញាតិ: បរិស្ថាននៃបញ្ញតិដែលមិនគ្រប់គ្រាន់ មានន័យថា កង្វះនូវការការពារ ទល់នឹងការរំលោភបំពាន ដោយ ភាគីណាមួយ, ជាចុងបញ្ចប់ ចំពោះការចំណាយរបស់សារធារណៈជន។

៨. ដំណើរការផ្តត់ផ្គង់: ដំណើរការផ្តត់ផ្គង សំរាប់ PPPមួយ អាចមានរយៈពេលយូរជាងធម្មតា ប្រសិនបើ វាកំពង់ត្រូវបានធ្វើ សំរាប់លើកទីមួយ។

៩. អន្តរអំពើរវាងគូអង្គ និង ដៃគូរ: ហានិភ័យនៃការបរាជ័យ ក្នុង PPPមួយ គឺ ខ្ពស់ នៅពេលដែល មានការសម្របសម្រួលមិនបានល្អ ក្នុងចំណោមដៃគូរ, ការផ្លាស់ប្តូរពត៍មានមិនគ្រប់គ្រាន់, កង្វះកិច្ចសហការណ៏, ភាពដឹកនាំ មិនច្បាស់, ភាពជាម្ចាស់មិនច្បាស់ និង កង្វះភាពទទួលខុសត្រូវ។ ទាំងនេះ គឺ តិច រឺ ច្រើន បាន ទាក់ទងដោយផ្ទាល់ ទៅសមត្ថភាព នៃស្ថាប័ន រឺ ដៃគូរដែលទទួលខុសត្រូវ។ ពួកគេ បានទាក់ទងផងដែរ ទៅ បទពិសោធន៏ ក្នុងការ គ្រប់គ្រង គម្រោង ជាទូទៅ និង គម្រោង PPPs យ៉ាងជាក់លាក់ (មើល លេខ២ ខាងលើ )។

ការដែលបានលើកឡើងខាងលើ គឺជាកត្តាធ្វើអោយ PPPs មានគ្រោះថ្នាក់, រឺក៏ ងាយនិងបរាជ័យ។ យើងអាចក្រឡេកមើល ហានិភ័យក្នុង PPPs ក្នុងន័យ ផលវិបាកអវិជ្ជមាន (នៃការចូលទៅក្នុងភាពជាដៃគូរ) សំរាប់ដៃគូរនិមួយៗ។

## ហានិភ័យសំរាប់រដ្ឋាភិបាល

សំរាប់រដ្ឋាភិបាល, មួយក្នុងចំណោមហានិភ័យទាំងអស់ ដែលបានភ្ជាប់មកជាមួយ PPPs គឺ កង្វះនៃការយល់ដឹង និង ការគាំទ្រ ពីមន្ត្រីសារធារណះ សំរាប់ការផ្លាស់ប្តូរ ដែលរដ្ឋាភិបាល-អេឡិចត្រូនិច ពាក់ពន្ធ័ ។ កង្វះនៃការយល់ដឹង នេះ អាចចញ្ជឹម ភាពភ័យខ្លាចសំរាប់សន្តិសុខការងារ និង ដូចច្នេះ បង្កើនការប្រឆាំង ចំពោះការផ្លាស់ប្តូរ។ កម្មវិធីគ្រប់គ្រងការផ្លាស់ប្តូរ គឺជារបៀបមួយ នៃការបង្ហាញ បញ្ហានេះ។

ហានិភ័យមួយទៀត សំរាប់រដ្ឋាភិបាល គឺ ការបាក់ស្រុត នៃការគាំទ្រប្រជាប្រិយភាពរបស់រដ្ឋាភិបាល ប្រសិនបើ លទ្ធផលនៃគម្រោង PPP មិនអាចមានជីវិតរហូតដល់ ការរំពឹងទុករបស់ប្រជាជន។ លំដាប់នេះ អាចនាំទៅដល់ ការបាត់បង់នៃការគាំទ្រ ពីក្រុមមានឥទ្ធិពលនយោបាយ, ដូចជា មន្ត្រីរាជការ, សហជីព និង ពលរដ្ឋ។ ហានិភ័យទីបី សំរាប់រដ្ឋាភិបាល ក្នុងគម្រោង PPPs គឺ ការបាត់បង់នៃការគ្រប់គ្រងផ្នែកសារធារណះ។ ដោយការអនុញ្ញាតិអោយ ផ្នែកឯកជន ប្រតិបត្តិ និង ធ្វើជាម្ចាស់នៃសេវាសារធារណះ, ផ្នែកសារធារណះ បាត់បង់ការគ្រប់គ្រងទៅលើ សេវានោះ រឺ នឹងត្រូវបានដឹងថាបានបាត់បង់ការគ្រប់គ្រង។ នៅក្នុង សម្បទាន BOO, ហានិភ័យនៃការបាត់បង់ការគ្រប់គ្រង គឺ ខ្ពស់ជាងមុន។ ដើម្បីបង្ហាញពីបញ្ហានេះ, និតិវិធីត្រួតត្រា ដែលកំពង់កើតមានឡើង ចាំបាច់ត្រូវបានដាក់ចុះ សំរាប់សម្បទានប្រតិបត្តិ។

## ហានិភ័យសំរាប់សារធារណះជន

នៅក្នុងករណីនេះ, សារធារណះជន អាចមើលឃើញ PPPs ថា រដ្ឋាភិបាលផ្តល់ ទំនិញសារធារណះ អោយផ្នែកឯកជនធ្វើអាជីវកម្ម ចំពោះការចំណាយរបស់សារធារណះជន។ កង្វល់ជាក់លាក់មួយចំនួន ដែលសារធារណះជនអាចមាន ពី ការដាក់សេវា និង ពត៌មានសារធារណះ អោយនៅក្នុងដៃរបស់អ្នកប្រតិបត្តិផ្នែកឯកជន គឺនៅ ខាងក្រោមនេះ :

- អ្នកប្រតិបត្តិ ផ្នែកឯកជន លទ្ធផលចុងក្រោយធ្វើជាម្ចាស់ សេវាសារធារណះ
- អ្នកប្រតិបត្តិ ផ្នែកឯកជន បង្កើតភាពផ្តាច់មុខ លើសេវាសារធារណះ

- អ្នកប្រតិបត្តិ ផ្នែកឯកជន គឺផ្តោះទៅរក ប្រាក់ចំណេញ, មិនមែន ប្រយោជន៍សារធារណះ
- អាចមាន ការធ្លាយសុវត្ថិភាពទិន្នន័យ ជាមួយ ពត៌មានផ្ទាល់ខ្លួន ដែលត្រូវបានគេដាក់ខុសកន្លែង ដោយធ្វេសប្រហែស, ចែកចាយ, រឺក៏ ដាក់ជាសារធារណះ។

ហានិភ័យសុវត្ថិភាព នឹងមាន ទោះជានៅពេលដែល រដ្ឋាភិបាល ទទួលខុសត្រូវតែមួយគត់ លើការគ្រប់គ្រង ពត៌មានផ្ទាល់ខ្លួនរបស់ពលរដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ, វាគឺជា កង្វល់ដែលមានសុពលភាព និង ហានិភ័យ មួយ ដែលដូចជាហានិភ័យផ្សេងៗទៀត ខាងលើ។ ប្រសិនបើហានិភ័យទាំងនេះ មិនត្រូវបានគេធ្វើ អោយធូរស្រាលទេ, ពួកគេ អាចបណ្តាលអោយមាន ការបាក់ស្រុតនៃទំនុកចិត្តសារធារណះ លើរដ្ឋាភិបាល។

រដ្ឋាភិបាល ត្រូវតែព្រួយបារម្មណ៍ ពីអ្វីដែលសារធារណះជនគិត ប្រសិនបើ ដើម្បីជោគជ័យក្នុងការលើកទឹកចិត្ត សារធារណះជន អោយប្រើសេវាដែលកំពង់ត្រូវបានអភិវឌ្ឍន៏ដោយមានការជួយពី ដៃគូរផ្នែកឯកជន។

### ហានិភ័យ សំរាប់ផ្នែកឯកជន

សំរាប់ផ្នែកឯកជន, ហានិភ័យនៃការរៀបចំគម្រោង PPPមួយ រួមមានដូចខាងក្រោមៈ

- មិនមានការធានាថា ទីផ្សារនឹងទទួលសំណើរពាណិជ្ជកម្ម ពីដៃគូរផ្នែកឯកជន។ ប្រសិនបើ លទ្ធផល អវិជ្ជមាន, គម្រោង នឹង បរាជ័យ។
- ហានិភ័យ (ដែលបានពិភាក្សាខាងលើ) អាចជាច្រើនជាង គម្រោង រឺ ជំនួញ អាចផ្តល់អោយ។

### ការបែងចែក ហានិភ័យ ក្នុង PPPs

នៅក្នុងប្រភេទផ្សេងគ្នានៃ PPP, ហានិភ័យ ត្រូវគេបែងចែក រវាង ផ្នែកឯកជន និង សារធារណះ ផ្សេងៗគ្នា (មើល រូបភាពទី ៧)។ ពេលដែល ហានិភ័យចំពោះពួកគេ គឺមានច្រើន, ផ្នែកសារធារណះជន ជាធម្មតា តម្រូវ អោយមាន អត្រានៃការទទួលបានមកវិញ ខ្ពស់។

**រូបភាពទី ៧ ការបែងចែក នៃហានិភ័យក្នុងគម្រោង PPP**

( Source: World Bank, *Toolkit for Public Private Partnerships in Highways* (2002),http://rru.worldbank.org/Documents/Toolkits/Highways/1_overdiag/12 /12_.htm and http://rru.worldbank.org /Documents/Toolkits/Highways/start.HTM)

## ៥.៤ ការគ្រប់គ្រង និង បន្ទូរ ហានិភ័យ ក្នុងគម្រោង PPPs សំរាប់ រដ្ឋាភិបាល-អេឡិចត្រូនិច

ការគ្រប់គ្រងហានិភ័យ គឺជា សមាសធាតុស្នូល នៃដំណើរការ PPP។ ការគ្រប់គ្រងហានិភ័យ អនុវត្តន៏ចំពោះ ផ្នែកខាងក្រៅគម្រោង ដូចជា ទស្សនះសារធារណះ និង បញ្ហាច្បាប់ ដែលទាក់ទងទៅ ការគ្រប់គ្រងនៃ គម្រោង PPP។

ដើម្បីគ្រប់គ្រងហានិភ័យ, ដៃគូរ គួរតែ ធ្វើការស្រាវជ្រាវអោយបានច្រើនតាមតែអាចធ្វើបាន ទៅលើគម្រោង ខ្លួនវា និង និតិវិធីដែលបានភ្ជាប់ជាមួយ PPPs, ទទួលជំនួយពីអ្នកជំនាកខាងក្រៅ, ធ្វើផែនការគម្រោង អោយលម្អិត, និង ភ្ជាប់ការប្រឹក្សាបន្តរហូត ពេញមួយអាយុកាលនៃគម្រោង។ ហើយ ដៃគូរទាំងពីរ គួរតែ ធានាថា កិច្ចសន្យាដែលដោះស្រាយរាល់បញ្ហា បំពេញបំណងពួកគេទៅវិញទៅមក។

រាល់ដំណាក់កាល នៅក្នុងគម្រោង, ខាងក្រោម ត្រូវតែបានគេធ្វើ :

១. ហានិភ័យ ត្រូវតែបានគេស្គាល់
២. ហានិភ័យទាំងនេះ ត្រូវតែបានគេកំណត់

៣. ហានិភ័យទាំងនេះ ត្រូវតែបានគេវាយតម្លៃ
៤. ហានិភ័យទាំងនេះ ត្រូវតែបានគេបែងចែក រវាង ដៃគូរផ្នែកឯកជន និង សារធារណះ
៥. វិធានការបន្ធូរ ត្រូវតែបានគេស្គាល់
៦. ភាពដែលអាចកើតមានឡើង និង តម្លៃ គួរត្រវបានគេគណនា

ការចុះបញ្ជីហានិភ័យ គួរតែបានគេរក្សាទុក ដើម្បីត្រួតពិនិត្យហានិភ័យ។

នៅពេល ហានិភ័យត្រូវបានគេស្គាល់, វាជាប្រពៃណី ដើម្បីអភិវឌ្ឍន៍វិធានការបន្ធូរហានិភ័យ។ ហានិភ័យ អាចត្រូវបានគេចាត់ជាក្រុម ជា ណាមួយ នៃយោបាយ (P) រឺក៏ នៃពាណិជ្ជកម្ម (C) ក្នុងធម្មជាតិ។ តារាងទី ៦-៨ ពិពណ៌នាហានិភ័យផ្សេងគ្នា នៅក្នុងដំណាក់ផ្សេងៗ ក្នុងការអនុវត្តន៏ គម្រោង PPPមួយ, ជាមួយនិង យន្តការបន្ធូរហានិភ័យ ដែលគេបានអោយយោបល់ ដើម្បីដោះស្រាយជាមួយហានិភ័យជាក់លាក់មួយចំនួន។

តារាងទី៦ ហានិភ័យ នៃការរៀបចំគម្រោង និង យន្តការបន្ធូរបន្ថយ

| ការពិពណ៌នា នៃ ហានិភ័យ | ប្រភេទនៃ ហានិភ័យ | យន្តការបន្ធូរបន្ថយ ហានិភ័យ |
|---|---|---|
| អជ្ញាធរដែលមានជម្លោះ | P | គម្រោងអនុវត្តន៏វិទ្យាស្ថានដ៏ខ្លាំង |
| បរាជ័យ ដើម្បីទទួលរាល់ លិខិតអនុញ្ញាត, ការយល់ព្រម, និង អជ្ញាបណ្ណ័ | CP | គម្រោងអនុវត្តន៏វិទ្យាស្ថានដ៏ខ្លាំង |
| ការពន្យាពេល ក្នុង ការយល់ព្រម | P | គម្រោងអនុវត្តន៏វិទ្យាស្ថានដ៏ខ្លាំង |
| ភាពផ្តាច់មុខ ក្នុងផ្នែកឯកជន | P | សេរីកម្មផ្នែក |
| រចនាសម្ពន្ធច្បាប់មិនសមរម្យ សំរាប់ គម្រោង | P | ការកែទម្រង់ច្បាប់ |
| ជំទាស់ ប្រឆាំង ដោយ ក្រុមដែលមានប្រយោជន៏ (សហជីព, NGOs ។ល។) | CP | កិច្ចសហប្រតិបត្តិការណ៏ និង ការរួមបញ្ចូល នៃអ្នកដែលពាក់ពន្ធ័ទាំងអស់ |
| ហានិភ័យការដេញថ្លៃ | C | ផលប្រយោជន៏គួរតែត្រូវបានគេធ្វើអោយធំបំផុត, មិនមែនបន្ថយទេ |
| ផលលំបាកនៃច្បាប់ ចំពោះ ការអោយរង្វាន់ដល់គម្រោង | P | និតិវិធីរង្វាន់ដែលមានតម្លាភាព |

| | | |
|---|---|---|
| ការពន្យាពេល ការបិទហិរញ្ញវត្ថុ | CP | ពេលកំណត់នៃការបិទ ចាំបាច់ត្រូវពិតប្រាកដ |

**តារាងទី៧ ហានិភ័យ នៃការសាងសង់គម្រោង និង យន្តការបន្ធូរបន្ថយ**

| ការពិពណ៌នា នៃ ហានិភ័យ | ប្រភេទ នៃ ហានិភ័យ | យន្តការបន្ធូរបន្ថយ ហានិភ័យ |
|---|---|---|
| ប្រាក់លើស ការប្រមាណចំណាយ | C | |
| ការពន្យាលពេល ការបញ្ចប់ | C | |
| បរាជ័យ ដើម្បីបំពេញភាពលម្អិតនៃ ការប្រព្រឹត្ត | C | |
| ការផ្លាស់ប្តូរ ចំពោះកិច្ចសន្យា និង ការយល់ព្រម | P | ការចរចារ,អាជ្ញាកណ្តាល |
| បរាជ័យ ដើម្បីធ្វើជាថ្មី ចំពោះ: ការយល់ព្រម, កិច្ចសន្យា និង ការអនុញ្ញាតិ | CP | គម្រោងអនុវត្តន៍វិទ្យាស្ថានដ៏ខ្លាំង |
| ការពន្យាលដែលមិនអាចដឹងមុន | CP | កិច្ចព្រមព្រៀងគម្រោង |

| | | |
|---|---|---|
| ព្រឹត្តិការណ៍ដែលមិនរំពឹងទុក | CP | កិច្ចព្រមព្រៀងគម្រោង |
| ការមិនគោរពកិច្ចសន្យា ដោយ អ្នកម៉ៅការ រឺ អ្នកកាន់កាប់ | C | កិច្ចព្រមព្រៀងរបស់ម្ចាស់ភាគហ៊ុន,សិទ្ធិត្រួតពិនិត្យ |
| ហានិភ័យ ភាពទទួលខុសត្រូវ | C | ការធានារ៉ាប់រង ឯកជន |
| ការផ្លាស់ប្តូរ ច្បាប់ | P | ការធានារបស់រដ្ឋាភិបាល |
| អត្រាប្តូរប្រាក់, អត្រាការប្រាក់ និង ចលនាអតិផរណា | CP | |
| កូដកម្ម និង បាតុកម្ម | CP | ការធានារ៉ាប់រង ឯកជនពហុភាគី |

តារាងទី៨ ហានិភ័យ នៃការប្រតិបត្តិគម្រោង និង យន្តការបន្ធូរបន្ថយ

| ការពិពណ៌នា នៃ ហានិភ័យ | ប្រភេទ នៃ ហានិភ័យ | យន្តការបន្ធូរបន្ថយ ហានិភ័យ |
|---|---|---|
| ប្រាក់លើស ការប្រមាណចំណាយ | C | កិច្ចព្រមព្រៀងគម្រោង |
| បរាជ័យ ដើម្បីបំពេញភាពលម្អិតនៃការប្រព្រឹត្ត | C | កិច្ចព្រមព្រៀងគម្រោង |
| ហានិភ័យ នៃការទាមទារ | C | កិច្ចសន្យារវាងអ្នកផលិត និង អ្នកទិញ ក្នុង អវត្តមាននៃទីផ្សារប្រកួតប្រជែង |
| ហានិភ័យ នៃការផ្គត់ផ្គង់ | C | កិច្ចសន្យាផ្គត់ផ្គង់ ក្នុង អវត្តមាននៃទីផ្សារប្រកួតប្រជែង |
| ហានិភ័យ នៃការបង់ប្រាក់ | CP | សមត្ថភាពការពង្រឹងផ្នែកឯកជន ដោយ ច្បាប់ |
| ចន្លោះប្រហោង នៃកិច្ចសន្យា ដោយដៃគូរផ្នែកឯកជន | P | ការធានារបស់រដ្ឋាភិបាល, អជ្ញាកណ្តាលអន្តរជាតិ |
| ការដក ការធានារបស់ រដ្ឋាភិបាល | P | អជ្ញាកណ្តាលអន្តរជាតិ |
| តម្លៃកើនឡើង,យន្តការកែប្រែតម្លៃ | P | បទបញ្ញត្តិឯករាជ្យ |
| ការផ្លាស់ប្តូរ ចំពោះកិច្ចសន្យា | P | បទបញ្ញត្តិឯករាជ្យ, |

| | | |
|---|---|---|
| | | អង្គការកណ្តាលអន្តរជាតិ |
| ការដកហូតទ្រព្យសម្បត្តិ | P | បទបញ្ញាតិឯករាជ្យ,<br>អង្គការកណ្តាលអន្តរជាតិ |
| ហានិភ័យ ភាពទទួលខុសត្រូវ | C | ការធានារ៉ាប់រង ឯកជន |

**ការគ្រប់គ្រងហានិភ័យខាងក្រៅ**

មានហានិភ័យដ៏ទូលំទូលាយជាច្រើន បន្ថែមទៅលើហានិភ័យដោយផ្ទាល់ ដែលភ្ជាប់ជាមួយគម្រោង PPP ដ៏ជាក់លាក់មួយចំនួន។ ទាំងនេះ គឺទាក់ទងទៅនិង បរិស្ថាន អភិបាលកិច្ច និង ជំនួញ នៅក្នុងប្រទេស រឺ យុត្តាធិការ ដែលបានបញ្ជាក់មួយ, រួមទាំង សមត្ថភាពក្នុងតំបន់ ដើម្បីគាំទ្រគម្រោង PPP។ វាមានសារៈសំខាន់ ដើម្បីរ៉ាយរ៉ាប់ទាំងអស់នេះ ពីព្រោះពួកគេ មានឥទ្ធិពលលើ ការចូលរួមផ្នែកឯកជន, និង ចំនួន និង គុណភាព នៃអ្នកផ្គត់ផ្គង់គម្រោង PPP ដែលរដ្ឋាបាលសារធារណៈអាចជ្រើសរើស។ ខាងក្រោមនេះគឺជា វិធានដើម្បីបន្ធូរ ហានិភ័យខាងក្រៅទាំងនេះ :

១. ផ្តល់នូវ បរិយាកាស នៃភាពប្រាកដនៃជំនួញ មួយ ដោយការអភិវឌ្ឍន៍ បរិស្ថាន ច្បាប់ និង ជំនួញដែលប្រកួតប្រជែង និង បើកចំហរ ដែលប្រព្រឹត្តទៅតាម ច្បាប់ និង កិច្ចព្រមព្រៀង WTO, ដូចជាGATS និង ABT ក្នុងករណីនៃទូរគមនាគមន៍ និង អាយ ស៊ី ធី។ ការប្រព្រឹត្តទៅតាម WTO នឹងធានារ៉ាប់រង អ្នកវិនិយោគបរទេស និង ស្ថាបនា បរិយាកាសទុកចិត្តមួយ ដែលនឹងលើកទឹកចិត្ត អ្នកវិនិយោគក្រៅស្រុក អោយពិចារណាគម្រោង PPP និង ឱកាសជំនួញដ៏ទៃទៀត។

២. ទទួលយក គោលនយោបាយ PPP ច្បាស់លាស់មួយ និង គ្រោងច្បាប់ -

- ទទួលស្គាល់ថា អង្គភាពផ្នែកសារធារណៈ អាចផ្ទេរទៅអោយ ផ្នែកឯកជន, តាមរយៈ សម្បទាន, សិទ្ធិផ្តល់សេវាសារធារណៈ។ ច្បាប់ ចំពោះប្រសិទ្ធភាពនេះ គួរតែទទួលស្គាល់ PPP រឺ នៅចុងបញ្ចប់, មិនត្រូវបានគេឃើញថាជា ឧបសគ្គ ចំពោះការបង្កើត នៃកិច្ចព្រមព្រៀង PPPមួយ
- អនុវត្តន៏ច្បាប់ ក្នុងលក្ខណៈសមធម៌ និង យុត្តិធម៌, ដោយស្របជាមួយ ស្តង់ដារ និង សន្ធិស្សន៍ អន្តរជាតិ, និង ធានា ការប្រកាន់ភ្ជាប់ រឺ ប្រព្រឹត្តទៅតាម ច្បាប់តុលាការ, និយ័តករ, និង អជ្ញាកណ្តាល។ នេះ កាត់បន្ថយ ហានិភ័យសំរាប់ផ្នែកឯកជន និង ផ្គត់ផ្គង់ ភាពអាចព្យាករណ៏បានក្នុងទំនាក់ទំនងជំនួញ។

៣. ដាក់អោយអនុវត្តន៏ គោលការណ៏ប្រតិបត្តិ និង យន្តការស្ថាប័ន សំរាប់ការចរចារ, ត្រួតត្រា និង អនុវត្តន៏ PPPs។ ឧទាហរណ៏ ក្រសួងហិរញ្ញវត្ថុ គួរតែមាន អង្គភាព PPPមួយ នៅក្នុង អង្គភាពនិតិវិធីក្រសួង រឺ ក៏ ជំនាញការដែលមានតម្លៃស្មើរ។ អង្គភាពនេះ គួរតែទទួលខុសត្រូវ ធ្វើការជាមួយ គណៈរដ្ឋាភិបាលណាមួយ ដែលមានបំណង អនុវត្តន៏កិច្ចព្រមព្រៀង PPPមួយ ដោយផ្តល់ការគាំទ្រ និង យោបល់ ទៅដល់ គណៈរដ្ឋា ភិបាល និង ជួយរៀបរចនាសម្ពន្ធ័ របស់ គម្រោង PPP ដើម្បីធានាថា សិទ្ធិ របស់រដ្ឋាភិបាល និង សារធារណៈជន ត្រូវបានគេគោរព។

៤. ផ្តល់ ដំណើរការ ការផ្គតផ្គង់សាធារណៈដែលមាន ស្ថិរភាព, សមធម៌, តម្លាភាព និង ជឿជាក់ បាន។ ដំណើរការស្នើរសុំ ដែលមានប្រសិទ្ធិភាព និង តម្លាភាព ធ្វើកើនឡើង ការប្រកួតប្រជែង និង ទាក់ទាញ ជំនាញការ, បច្ចេកវិទ្យា, និង ទុន។ ប្រសិនបើ ដំណើរការ មិនមានតម្លាភាព រឺ មិនត្រូវ បានគេជឿថាយុត្តិធម៌, នឹងមាន ដៃគូរផ្នែកឯកជន ពីរ បី ដែលធ្វើការដេញថ្លៃ និងប្រហែលជា គ្មានTNCs និង ក្រុមហ៊ុនបរទេសផ្សេងៗទៀត។ ក្រុមហ៊ុនបរទេស នាំយក ជំនាញការ, ហរិញ្ញប្បទាន និង ជំនាញគ្រប់គ្រង ដែលអាចផ្តល់ប្រយោជន៏ ដល់អ្នកពាក់ពន្ធ័ទាំងអស់, ដែលរួមបញ្ចូលទាំង ដៃគូរប្រថុយប្រថានរួមក្នុងស្រុក មិនរាប់បញ្ចូល រដ្ឋាភិបាល និង សារធារណៈជន។

៥. បំពេញចិត្ត ការទាមទារជាអាទិភាព ដែលអាចបង្កើត ការគាំទ្រ និង សុឆន្ទះ របស់ PPP។ ក្រឡេកមើលទៅ សេវាសារធារណៈ ដែលបិតក្នុងការទាមទារយ៉ាងច្រើន និង ព្យាយាមអនុវត្តន៏ គម្រោងទាំងអស់នេះ មុនគេ ពីព្រោះ ប្រសិនបើពួកគេជោគជ័យ, ពួកគេ នឹងប្រមូល ការគាំទ្រ សារធារណៈ និង ធ្វើអោយវាងាយស្រួលជាងមុន ដើម្បីបន្តទៅ ឱកាសគម្រោង PPP ផ្សេងៗទៀត។

៦. រកមើល គម្រោងដែលផលប្រយោជន៏ គឺងាយយល់ ដោយសារធារណៈជន។ គម្រោងដែល ពង្រឹងការឈានចូលទៅកាន់សេវា នៅក្នុង កម្រិត សហគមន៏ រឺក្នុងតំបន់ តាមរយៈធានាគារ,

អ្នកប្រតិបត្តិទូរគមនាគមន៍,.......។ល។ ពេលខ្លះ អាចមានប្រជាប្រិយជាង គម្រោងដែលផ្តោត ទៅលើ ការប្រែ ដំណើរការរដ្ឋាភិបាលផ្ទៃក្នុង។ ឧទាហរណ៍, សារធារណៈជន អាចចូលចិត្តជាង នូវសេវា សារធារណៈដែលផ្តល់ ប្រាក់លើកទឹកចិត្ត ទៅដល់ ពលរដ្ឋ ក្នុងទំរង់ជា ប្រាក់ចូល និវត្តន៍,ការគាំពារកុមារ, និង ប្រាក់លើកទឹកចិត្ត អាពាហ៍ពិពាហ៍ និង ការសំរាលកូល និង ប្រាក់លើកទឹកចិត្ត ផ្សេងៗទៀត ដែលរដ្ឋាភិបាលអាចបានអនុវត្តន៍។

៧. កាត់បន្ថយ ភាពស្មុគស្មាញ – ជៀសវាងការអនុវត្តន៍ស្មុគស្មាញ ជាលើកដំបូង ដើម្បី កាត់បន្ថយហានិភ័យ និង គ្រប់គ្រងបានល្អ ក្នុងការអនុវត្តន៍លើកទី។

៨. កាត់បន្ថយ ភាពមិនប្រាកដ – ធ្វើការជាមួយគម្រោង ដែលងាយយល់ និង ដែលដៃគូរមាន បទពិសោធន៍ខ្លះ អំពីពួកគេ។ គម្រោងទាំងនេះ នឹងងាយស្រួលជាង ដើម្បីអនុវត្តន៍។

៩. រកមើល ជ័យជំនះងាយស្រួល –

- ធ្វើការ លើ គម្រោងសាមញ្ញ ជាមួយហានិភ័យដែលគេបានដឹង និង កំណត់
- ធ្វើការ ជាមួយ ស្ថាប័ន ដែលងាយស្រួលធ្វើការជាមួយ ពីព្រោះពួកគេមានបទពិសោធន៍ច្រើនជាង, សមត្ថភាពខ្ពស់ជាង, ឆន្ទះធំជាង ដើម្បីសន្មតហានិភ័យ (ស៊ាំ និងហានិភ័យ)។
- ស្វែងរក ឱកាសដែលអាចផ្តល់ លទ្ធផលវិជ្ជមាន និង រហ័ស ដែលនឹងទាក់ទាញ ចំណាប់អារម្មណ៍ របស់សារធារណៈជន ជាមួយការកែប្រែការចែកចាយសេវាសារធារណៈ។

១០. អនុវត្តន៍ ការត្រួតពិនិត្យ និង សមតុល្យ – PPPs ជាច្រើន គឺជា ឱកាសផ្តាច់មុខ ដែលត្រូវតែបានគេគ្រប់គ្រង និង ដាក់បញ្ញាត្តិ ដើម្បីការពារ ការរំលោភបំពាន និង ដើម្បីការពារ អត្ថប្រយោជន៍សារធារណៈ។ ការត្រួតពិនិត្យ និង សមតុល្យ គួរតែត្រូវបានគេផ្តល់អោយ នៅក្នុងកិច្ចសន្យា។ នេះរួមទាំង ការផ្តល់សំរាប់ការពិនិត្យឡើងវិញយ៉ាងទៀងទាត់។ នៅក្នុងករណីខ្លះ, របៀបនៃការកំណត់ ហានិភ័យប្រភេទនេះ គឺ ដោយការតម្រូវនូវ ការកែជាថ្មីទៀងទាត់ នៃពាក្យក្នុង កិច្ចសន្យា ជាមួយការផ្តល់មួយ ដែលរដ្ឋាភិបាល មិនមានកាតព្វកិច្ច ដើម្បីកែជាថ្មី គម្រោង PPPមួយ នៅពេលដែលពាក្យ ដំបូង នៃគម្រោង PPP ត្រូវបានគេធ្វើអោយសម ហើយ។ នៅក្នុង ព្រឹត្តការណ៍ នៃគម្រោង BOO, បណ្តឹងសើរើតាមច្បាប់ គឺ បើកចំហ តាមរយៈតុលាការ, ប៉ុន្តែ នេះ អាចជា សុំណើរដ៏គ្រោះថ្នាក់មួយ។

ការគ្រប់គ្រង ហានិភ័យ ខាងក្នុង

១. រៀបចំ ករណីជំនួញ និង អនុវត្តន៍ ការពិសោធន៍មួយ។ នោះគឺ អនុវត្តន៍ ការសិក្សាភាពអាចធ្វើបាន និង រៀបចំ ករណីជំនួញ។ ប្រសិនបើ ករណីជំនួញ មិនល្អ, គម្រោងគួរតែមិនត្រូវបានបន្ត។ នៅក្នុងការរៀបចំ ករណីជំនួញ, ជួល អ្នកជំនាញខាងក្រៅ ប្រសិនបើចាំបាច់ និង ពាក់ពន្ធ័ ផ្នែកឯកជន ប្រសិនបើអាច។ ដើម្បី សាកល្បង អំណះអំណាង ដែលមាននៅក្រោម គំនិតរបស់គម្រោង, វាអាចចំបាច់ ដើម្បីអនុវត្តន៍ គម្រោង សំរាប់ធ្វើពិសោធន៍ ក្នុងទំហំតូចមួយ ដើម្បីសាកល្បង អំណះអំណាង និង សម្មតិកម្ម។

២. អនុវត្តន៍ ផែនការលម្អិត និង ការត្រួតពិនិត្យជាបន្តបន្ទាប់។ ក្រាភិច ខាងក្រោម ដែលពិពណ៌នាអំពី ប្រពន្ធ័ គាំទ្រការសំរេចចិត្ត ដែលប្រើការអនុវត្តន៍ការគ្រប់គ្រងគម្រោងពត៌មាវិទ្យាដែលគេទទួលស្គាល់ បង្ហាញថា កម្រិត នៃភាពលម្អិត ដែលពេលខ្លះត្រូវគេតម្រូវ ដើម្បីធ្វើ ផែនការ អោយត្រឹមត្រូវ និង អនុវត្តន៍គម្រោង អាយ ស៊ី ធី។

**រូបភាពទី៨ ក្រាភិចដែលបង្ហាញពី ប្រពន្ធ័គាំទ្រការធ្វើការសម្រេចចិត្តមួយ សំរាប់**

៣. អនុវត្តន៍ និតិវិធិគ្រប់គ្រង ហានិភ័យ ដែលរួមទាំង ការចុះបញ្ជីហានិភ័យ (មើលខាងលើ)ការគ្រប់គ្រង

**ហានិភ័យគម្រោង រដ្ឋាភិបាល-អេឡិចត្រូនិច/អាយ ស៊ី ធី**

១. វិធីសាស្ត្រទូទៅ ចំពោះ ការគ្រប់គ្រងគម្រោងពត៌មានវិទ្យា

ការទទួលយក វិធីសាស្ត្រទូទៅ ចំពោះ ការគ្រប់គ្រងគម្រោងពត៌មានវិទ្យា ធ្វើអោយ គម្រោង ងាយស្រួល អនុវត្តន៍, កត់ត្រា, គ្រប់គ្រង និង កំណត់ពេល។ ការទទួលយក វិធីសាស្ត្រទូទៅ រួមបញ្ចូល ដូចខាងក្រោម :

- អនុវត្តន៍ គោលនយោបាយពត៌មានវិទ្យា ទូទៅ និង មិនអនុញ្ញាតិអោយ អង្គភាពពត៌មានវិទ្យា ឯករាជ្យ ប្រតិបត្តិ។ អនុវត្តន៍ ច្បាប់ការផ្គត់ផ្គង់ ទូទៅ ដូចដែល ប្រឆាំងចំពោះ ការអនុញ្ញាតិអោយ មណ្ឌល រឺ ក្រសួង កំណត់ ច្បាប់ និង អជ្ញាធរផ្គត់ផ្គង់ ផ្ទាល់ខ្លួន។ រាល់ការផ្គត់ផ្គង់ទាំងអស់ គួរតែត្រូវបានអនុវត្តន៍ ដោយ គណៈផ្គត់ផ្គង់មជ្ឈឹម សំរាប់រដ្ឋាភិបាល ដូចជា 'គណៈកម្មការផ្គត់ផ្គង់ និង បោះចោល សម្បត្តិទ្រព្យ' រឺក៏ គណៈកម្មការស្រដៀងនេះ។
- យល់ព្រម លើ ស្តង់ដារ និង គោលការណ៍។
  - ធានា ភាពដែលអាចប្រត្តិបិត្តិរវាងគ្នា តាមរយៈ ស្តង់ដារបើកចំហរ។
  - ប្រើ ស្តង់ដារបើកចំហរ ដើម្បីកាត់បន្ថយ ចំណាយ និង ធានា ភាពយូរអង្វែង
  - ជៀសវាង កម្មវិធី ប្រភពតែមួយ រឺ កម្មវិធីដែលភ្ជាប់អ្នកទៅនិង អ្នកលក់តែម្នាក់។
- អនុវត្តន៍ សេវាចែករំលែក និងគោលនយោបាយទូទៅមួយ លើការអនុវត្តន៍គម្រោងពត៌មានវិទ្យា។ សេវាចែករំលែក និង មជ្ឈមណ្ឌលទិន្នន័យ អនុញ្ញាតិអោយ អង្គភាពរដ្ឋាភិបាលផ្សេងៗ ចែករំលែកពត៌មាន, និតិវិធី និង ប្រពន្ធ័ ដូចច្នេះហើយ កាត់បន្ថយចំណាយ និង ភាពមិនប្រាកដ។

២. ការធានា សុវត្ថិភាពទិន្នន័យ និង ភាពឯកជន

ដូចដែលបាននិយាយពីមុន, ហានិភ័យមួយចំនួន ដែលគម្រោង រដ្ឋាភិបាល-អេឡិចត្រូនិច ដាក់ចុះសំរាប់ ពលរដ្ឋ ត្រូវតែធ្វើជាមួយ សុវតិភាពទិន្នន័យ និង ភាពឯកជន។ ហានិភ័យជាក់លាក់ ចំពោះបញ្ហានេះ រួមមាន:

- ការគ្រប់គ្រងខុស នៃពត៌មានឯកជនរបស់បុគ្គល, ដែលនាំអោយមានការធ្លាយភាពឯកជន
- សុវត្ថិភាពទិន្នន័យ
- ភាពទទួលខុសត្រូវច្បាប់
- ភាពជឿជាក់រដ្ឋាភិបាលថយចុះ សំរាប់ការធានា សុវត្ថិភាពទិន្នន័យ និង ភាពឯកជន

- បរាជ័យ រដ្ឋាភិបាល-អេឡិចត្រូនិច – ប្រហែល ៦០ ភាគរយ នៃគំនិតផ្តួចផ្តើម រដ្ឋាភិបាល-អេឡិចត្រូនិច ត្រូវបានគេរំពឹងគិតថាបរាជ័យ រឺ មិនអាចសំរេចគោលដៅ។
- ការគំរាមកំហែង នៃការបិទទីផ្សារ, រឺ ការផ្ទេរទាំងស្រុង នៃសេវា និង ទំនិញសារធារណៈទៅអោយផ្នែកឯកជនគ្រប់គ្រង

មានវិធីសាស្រ្តជាច្រើន ដើម្បីដោះស្រាយ ជាមួយហានិភ័យទាំងនេះ។ វិធីសាស្រ្តទូទាំងរដ្ឋាភិបាល ទូទៅមួយ ដើម្បីធានា សុវត្ថិភាពពត៌មាន និង ការបញ្ចូលទិន្នន័យ គឺសំខាន់។ សេវាចែករំលែក និង មជ្ឈមណ្ឌលទិន្នន័យរួមមួយ អាចជាវិធីសាស្រ្តដ៏ល្អ សំរាប់ដោះស្រាយជាមួយនិង បញ្ហាទាំងនេះ ដែលជាទូទៅ ចំពោះអង្គភាពរដ្ឋាភិបាលទាំងអស់ ទោះបីជា ពួកគេ ជាកង្វល់ដ៏ខ្លាំង សំរាប់ក្រសួងមួយចំនួន ដូចជា ការពារជាតិ, សន្តិសុខជាតិ, សុខាភិបាល, ហិរញ្ញវត្ថុ និង ធនធានមនុស្ស។

លើសពីនេះទៅទៀត, គួរតែមាន ការិយាល័យប្រកួតប្រជែង ដែលមានសមត្ថភាព និង ឯករាជ្យ និង និយ័តករ, ដែលរួមមាន និយ័តករ អាយ ស៊ី ធី និង ទូរគមនាគមន៍, ដើម្បីបន្លឺសំលេងជូង នៅពេល ការគ្រប ដណ្តប់ រឺ ការបិទទីផ្សារ ត្រូវបានគេគំរាមកំហែង។ ការិយាល័យ ផ្គត់ផង់ និង PPP ខ្លាំងមួយ នៅក្នុង ក្រសួង ហិរញ្ញវត្ថុ រឺស្ថាប័នដែលមានតម្លៃស្មើរ គឺត្រូវបានគេតម្រូវផងដែរ ដើម្បីបន្ធូរ ហានិភ័យនេះ។

ផងដែរ វាអាចជួយអោយមាន ក្រុមឆ្លើយតបភាពបន្ទាន់កុំព្យូទ័រជាតិ ដើម្បីឆ្លើយតបទៅ ការគំរាមកំហែង បច្ចេកវិទ្យា និង អជ្ញធ្វារវិញ្ញាបនប័ត្រជាតិ សំរាប់ប្រតិបត្តិការអេឡិចត្រូនិចរបស់រដ្ឋាភិបាល។ ការអនុវត្ត៏ វិធីសាស្រ្ត សេវាចែករំលែក មានន័យថា បញ្ហាសន្តិសុខ អាចត្រូវបានគេថ្លែង ក្នុងលក្ខណៈ ជាក់លាក់ និង ងាយយល់ កាត់តាម រដ្ឋាភិបាល ជំនួសអោយ មូលដ្ឋានមួយចំណែកម្នាក់ៗ និង មួយក្រសួងម្តង-មួយក្រសួងម្តង ដែលងាយនឹងអាចឈានដល់ ការយល់ច្រឡំ និង មិនស្រុះស្រួលគ្នា រួមនិង ការអស់សុពលភាព និង អសន្តិសុខ។

## ៦. ជំរើសមូលនិធិផ្សេងទៀត

គោលបំណងផ្នែកនេះដើម្បីពិពណ៌នាជម្រើសមូលនិធិគម្រោង ICTD ផ្សេងទៀតជាង PPPs ។

### ៦. ១ វិនិយោគផ្ទាល់បរទេស

មួយក្នុងចំណោមប្រភេទមូលនិធិសំខាន់ៗ ជាច្រើន ដែលរដ្ឋាភិបាល អាចពិចារណាបាន គឺ FDI។ UNCTAD និង មូលនិធិរូបិយវត្ថុអន្តរជាតិ កំណត់ FDI ថា :

> ការវិនិយោគមួយ ដែលបង្កើតឡើង ដើម្បីទទួល ចំណាប់អារម្មណ៍ ចុងក្រោយ ជាមួយ សហគ្រាស ដែល ប្រតិបត្តិ នៅផ្នែកខាងក្រៅ នៃសេដ្ឋកិច្ចរបស់អ្នកវិនិយោគ។ លើសពីនេះទៅទៀត ក្នុងករណី FDI គោលបំណងរបស់អ្នកប្រើប្រាស់ គឺដើម្បីទទួល សម្លេងដែលមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រង របស់ សហគ្រាស។ អង្គភាពបរទេស រឺ ក្រុមនៃអង្គភាពដែលរួមបញ្ចូល ដែលធ្វើការវិនិយោគ គឺត្រូវបានគេ កំណត់ ន័យថា ‘អ្នកវិនិយោគ ផ្ទាល់’ ។ សហគ្រាស មិនមែនសារជីវកម្ម រឺ សារជីវកម្ម – សាខាមួយ រឺ ក្រុមហ៊ុនតំណាង ជារៀងគ្នា ដែលក្នុងនោះ វិនិយោគផ្ទាល់ ត្រូវបានគេបង្កើត – គឺគេសំដៅទៅលើ ជា ‘សហគ្រាស វិនិយោគផ្ទាល់ ’។ កំរិតខ្លះ នៃភាពជាម្ចាស់ស្មើរភាពគ្នា គឺតែងតែ ត្រូវបានគេចាត់ទុកថា ត្រូវ បានភ្ជាប់ ជាមួយ សម្លេងដែលមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រង នៃសហគ្រាស។ the BPM5 ផ្តល់ យោបល់ថា កម្រិតចាប់ផ្តើម ១០ភាគរយ នៃភាពជាម្ចាស់ស្មើរភាពគ្នា ដើម្បីកែប្រែ អ្នកវិនិយោគមួយ ទៅជា អ្នកវិនិយោគផ្ទាល់បរទេស។

មានការធ្លាក់ចុះយ៉ាងខ្លាំងក្លា ក្នុងទំហំ នៃការហូរចូល FDI ទៅកាន់ សេដ្ឋកិច្ចដែលអភិវឌ្ឍន៍ បន្ទាប់ពី ការប៉ះទង្គិច DOT Com ក្នុងឆ្នាំ ២០០០។ ប៉ុន្តែចាប់តាំងពីឆ្នាំនោះមក, ស្ថានភាព ត្រូវបានបញ្ច្រាស ជាមួយ ចំនួនដែលកើនឡើង នៃ FDI ដែលឆ្ពោះទៅកាន់ ប្រទេសកំពង់អភិវឌ្ឍន៍។ ប្រទេសកំពង់អភិវឌ្ឍន៍ របស់អាស៊ី ផ្តល់ ពីរភាគបីនៃការហូរចូរសរុប ទៅកាន់ប្រទេសកំពង់អភិវឌ្ឍន៍។ ចិន, ហុងកុង និង សាំងហ្គាពួរ បានរក្សា ការនាំមុខរបស់ពួកគេ ជាអ្នកទទួលធំបំផុតបី នៃFDI ក្នុងតំបន់។

**រូបភាពទី៩ ការហូរចូល** FDI/ skl nig tamEpñkénesdækic©/ 1980-2006

(រាប់សិបកោដដុល្លា)

(Source: UNCTAD, *World Investment Report 2007: Transnational Corporations, Extractive Industries and Development* (New York and Geneva: United Nations, 2007), 3, http://www.unctad.org/en/docs/wir2007_en.pdf)

នៅក្នុងឆ្នាំ ២០០៦, FDI នៅអាស៊ីប៉ាស៊ីហ្វិក បានឈានដល់ ប្រហែល ២០០ កោដិដុល្លារអាមេរិក, នៅពេល នៅ អូសេអានី បានឈានដល់ ៤០០ កោដិដុល្លារអាមេរិក។ ដោយយោងទៅលើ របាយការណ៍វិនិយោគពិភព លោក ២០០៧, ចំនួនគម្រោងវិនិយោគ បានកើនឡើង ១៣ភាគរយ ចំពោះ ១១,៨០០ គម្រោង, ដែលគួរ អោយកត់សំគាល់ នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ និង ក្នុងផ្នែកសេវា។

FDI ភាគច្រើន គឺបានមកពី ការផលិតប្រេង និង រ៉ែ និង សេដ្ឋកិច្ចថាមពល ដែល បានឃើញប្រាក់ចំណូល និង ប្រាក់ចំណេញ កើនឡើងយ៉ាងលឿន ក្នុងប៉ុន្មានឆ្នាំចុងក្រោយ។ សហរដ្ឋអាមេរិក មានចំនួនហ៊ុនធំជាងគេ បំផុត នៃ FDI ខាងក្រៅ ។ ទោះបីជាយ៉ាងណាក៏ដោយ, នេះអាចផ្លាស់ប្តូរ នៅពេល SWFs ចាប់ផ្តើម ក្រឡេកមើលទៅកាន់ ឱកាសមកពីបរទេសសំរាប់ការវិនិយោគ។ មាន អង្គការជាច្រើនដែលផ្តល់មូលនិធិដល់ ការអភិវឌ្ឍន៍ SMEs តាមរយះ FDI។ បែបផែននេះ គឺមួយផ្អែកផ្អែកទៅលើ របៀបមួយ ដែលប្រើដោយ នាយទុនដែលប្រថុយប្រថាន នៅក្នុងពិភពឧស្សាហាកម្ម និង គឺផ្អែកទៅលើ ការបង្កើតជំនួញ (មើលលើ ផ្នែក ទុនដែលប្រថុយប្រថាន)។

ប្រហ៊ុនបរទេស គឺចាប់អារម្មណ៍ជាមួយ ឱកាសពាណិជ្ជកម្ម។ អ្វីក៏ដោយ ដែលអាចទាកទាញ វិនិយោគ និង លើកទឹកចិត្ត ការអភិវឌ្ឍន៍ សំរាប់ផ្នែកឯកជន នឹងជាចំណាប់អារម្មណ៍ចំពោះអ្នកវិនិយោគបរទេស។ ស្ថាប័ន ពាណិជ្ជកម្ម នឹងអភិវឌ្ឍន៍ផែនការជំនួញមួយ បន្ទាប់ពី ការកំណត់ដំបូងថា ការវិនិយោគមួយ មានឱកាសសម

ហេតុផលច្រើនជាង នៃការបង្កើតប្រាកចំណេញសំរាប់អ្នកវិនិយោគ។ ផែនការវិនិយោគ រួមមាន គម្រោងថវិកា និង អត្រាំពឹងគិតនៃការទទួលបានវិញ ផ្អែកលើ ការលក់, ការប្រតិបត្តិ, ការជួល, រឺ ការបញ្ចូលគ្នានៃប្រភព ប្រាក់ចំណូលទាំងអស់នេះ។ នេះ នឹងតម្រូវអោយមាន ការវិភាគលំហូរសាច់ប្រាក់ ក្នុងចំណោមឧបករណ៍ផ្សេងៗ ទៀត។

កង្វល់មួយ របស់អ្នកវិនិយោគបរទេស គឺ ស្ថេរភាព និង ភាពអាចព្យាករណ៍បាន។ ការផ្លាស់ប្តូរ សង្គម និងនយោ បាយ ធ្វើអោយកើនឡើង ភាពមិនប្រាកដ និង ហានិភ័យ។ អ្នកវិនិយោគ មានទំនោរ ជៀសវាងការវិនិយោគ នៅក្នុង យុត្តាធិការ ដែលដំណើរការផ្លាស់ប្តូរអំណាច មិនត្រូវបានគេកំណត់ ច្បាស់ និងបរិយាកាសនៃភាពមិន ប្រាកដ មានឥទ្ធិពលជាង។

ច្បាប់ជាតិសំរាប់ FDI គឺត្រូវបានគេបោះផ្សាយតាមអ៊ីនធរណែត ជាច្រើន និង គឺជា ការបញ្ជាក់មួយ នៃការបើក ចំហរ ចំពោះជំនួញ ដែលនឹងលើកទឹកចិត្តដល់ផ្នែកឯកជន។ ប្រទេសជាច្រើន ផងដែរ នឹងថែរក្សាផ្នែកអភិវឌ្ឍន៍ ជំនួញ និង ពាណិជ្ជកម្ម នៅក្នុង មួយចំនួន បើមិនបានច្រើន នៃគណៈប្រតិភូកុងស៊ុល និងស្ថានទូត របស់ពួកគេ នៅក្រៅប្រទេស ដើម្បី ផ្សាយបន្ថែម និង ពន្យល់ គោលដៅវិនិយោគរបស់ពួកគេ និងបែបផែន ចំពោះអ្នកវិនិយោគបរទេស។

ការប្រកាន់ភ្ជាប់ ទៅនិង WTO បង្កើន ការអំពាវនាវនៃប្រទេសមួយ ចំពោះ FDI នៅពេលវា ផ្តល់អោយអ្នកវិនិយោគទុន ជាមួយ អ្នកធានារ៉ាប់រងប្រាកដ ជា អ្នកវិនិយោគខាងក្រៅ ជាមួយសិទ្ធិនៃការអំពាវនាវ និងថ្លែង ក្រោមច្បាប់អន្តរជាតិ។

ប្រទេសជាច្រើន គឺមានចំណាប់អារម្មណ៍ណាស់ ជាមួ ការទាក់ទាញ ក្រុមហ៊ុន អាយ ស៊ី ធី ធំៗ ដូចជា Microsoft, Cisco, Intel, IBM, SAP និង ផ្សេងៗទៀត ដើម្បីបង្កើត ហាងនៅក្នុងប្រទេស រឺ
យុត្តាធិការ របសពួកគេ។ ប្រទេសជាច្រើន មានមហិច្ឆតា ដើម្បីប្រើប្រាស់ អាយ ស៊ី ធី អោយក្លាយជា សេវា, ការដឹកជញ្ជូន, មជ្ឈមណ្ឌលហិរញ្ញវត្ថុ សំរាប់តំបន់ រឺ លើសពីនេះទៀត។ យុត្តាធិការ ដូចជា ចិន, អេហ្ស៊ីប, ហុងកុង, ម៉ាឡេស៊ី, សាំងហ្គាពួរ និង តៃវ៉ាន់ បានមានជោគជ័យ ក្នុងការទាក់ទាញ ក្រុមហ៊ុន អាយ ស៊ី ធី អោយ វិនិយោគ នៅក្នុងសេដ្ឋកិច្ចរបស់ពួកគេ។ ប៉ុន្តែ មិនមែនប្រទេសទាំងអស់ទេ អាចរពឹងថា ក្លាយជា មជ្ឈមណ្ឌល សេវាក្នុងតំបន់ របស់ Microsoft មួយ រឺ មជ្ឈមណ្ឌលផលិត Intel។ មួយផ្នែកពី បរិស្ថាន ប្រតិបត្តិ ដែលអាច ព្យាករណ៍ ដែលច្បាប់នៃការប្រតិបត្តិ មិនផ្លាស់ប្តូរញឹកញាប់, ចំនុចខាងក្រោម ត្រូវតែគេបានពិចារណា ដើម្បី ទាក់ទាញ FDI :

- បរិស្ថានបញ្ញាតិ, ច្បាប់, និង គោលនយោបាយដែលបានកំណត់ដ៏ល្អ
- វិធាននៃច្បាប់ - ច្បាប់ ត្រូវបានគេប្រកាន់ភ្ជាប់ និង តុលាការ គឺមានមុខងារ; ក្រុមហ៊ុនបរទេសអាចរំពឹងថាត្រូវបានគេប្រព្រឹត្តចំពោះ ដោយសុក្រឹត និង ស្មើរភាព ជាមួយនិង ក្រុមហ៊ុនជាតិ
- អ្នកធានារ៉ាប់រងអន្តរជាតិ ដូចជា អ្នកដែលបានស្របជាមួយនិង ប្រទេសដែលបានអនុគ្រោះដល់ស្ថានភាពពាណិជ្ជកម្មជាមួយប្រទេស រឺ យុត្តាធិការ ដ៏ទៃទៀត រឺ ប្រទេសដែលប្រកាន់ភ្ជាប់ ទៅនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាតិ, ក្នុងតំបន់ រឺ ក្នុងប្រទេស។
- ការប្រកាន់ភ្ជាប់ទៅនិង វិធាន នៃច្បាប់អន្តរជាតិ និង ពាណិជ្ជកម្ម ជាមួយ ការផ្សារភ្ជាប់ទៅនិង WTO ជាទម្រង់បន្ថែមនៃការធានារ៉ាបរង
- គោរព កម្មសិទ្ធិបញ្ញា (IPR) – នេះ គឺជាបញ្ហាមួយ នៅក្នុងប្រទេសមួយចំនួន ដែលជាការពិត ក្រុមហ៊ុនត្រូវបានគេលើកទឹកចិត្ត ដើម្បីទម្លាក់ កម្មសិទ្ធិបញ្ញា (IPR) ក្នុងការផ្លាស់ប្តូរសំរាប់ការឈានចូលទៅកាន់ទីផ្សារជាតិ
- ជំនាញការ បច្ចេកទេស និង គ្រប់គ្រង ក្នុងស្រុក – ភាពដែលអាចរកបាន នៃកម្លាំងការងារដែលមានការអប់រំ
- សមត្ថភាព និយាយភាសាចំបង ជាមួយភាសាអង់គ្លេស
- ប្រវត្តិ នៃទំនាក់ទំនង ចំពោះអ្នកវិនិយោគបរទេស និង អ្នកប្រតិបត្តិផ្នែកឯកជន យ៉ាងជាក់លាក់
- អាកប្បកិរិយាវិជ្ជមាន ចំពោះ ផ្នែកឯកជន

ឧបសគ្គ ចំពោះ FDI គឺជា ឧបសគ្គផងដែរ ចំពោះ ការអភិវឌ្ឍន៏ជំនួញ, ដូចជា :

- ពន្ធដារ ខ្ពស់
- អំពើពុករលួយ
- ការិយាល័យធិបតេយ្យ
- ឧបសគ្គចំពោះការចាប់ផ្តើម និង ការប្រតិបត្តិ ជំនួញ
- ការដាក់កម្រិត លើ មាតុភូមិនិវត្តន៍នៃប្រាក់ចំណូល

របាយការណ៏ ‘ការធ្វើជំនួញ’ប្រចាំឆ្នាំ ដែលចេញផ្សាយដោយ ស្ថាប័នធានាគារពិភពលោក គឺជា ប្រភពដែលមានប្រយោជន៏មួយនៃពត៌មាន ដែលពឹងទៅលើវា គោលនយោបាយ លើកទឹកចិត្តដល់ ការអភិវឌ្ឍន៏ផ្នែកឯកជន និង ដែលពឹងទៅលើវា ប្រទេស កំពង់តែកែប្រែ និង ប្រទេស កំពង់តែតាមពីក្រោយ ក្នុងន័យការអភិវឌ្ឍន៏ ផ្នែកឯកជន។ ការស្ទាបស្ទង់មិតិក្នុងប្រទេសដែលអាចរកបាន ពី អ្នកបោះពុម្ពផ្សាយ ដូចជា

អង្គភាព ចារកម្ម អ្នកសេដ្ឋសាស្ត្រ ផងដែរ ផ្តល់ដល់ អ្នកវិនិយោគបរទេស ជាមួយពត៌មានអំពី ឱកាស និង ហានិភ័យ ដែលពួកគេ នឹងបង្ហាញខ្លួនរបស់គេ នៅក្នុងទីកន្លែងក្រៅស្រុក។

ភាពជោគជ័យ នៃ FDIs គឺត្រូវបានគេវាស់វែង តាមរយៈ និយ័តករ ដូចដែល ត្រូវបានបោះផ្សាយ ដោយ វិទ្យាស្ថានហិរញ្ញវត្ថុ (FDIs), OECD, UNCTAD និង ដ៏ទៃទៀត។ នៅក្នុង អាស៊ី, បទពិសោធន៏ ជាមួយ និង FDI នៃប្រទេស ចិន, ហុងកុង, សាំងហ្គាពួរ, តៃវ៉ាន់ និង សារធារណះរដ្ឋកូរ៉េ ចងល្អទៅ សារសំខាន់ នៃកត្តាខាងក្រោម ក្នុងការប្រើប្រាស់ដ៏ជោគជ័យរបស់ FDI :

- ទស្សនះ
- ភាពជាអ្នកដឹកនាំនយោបាយ ខ្លាំង និង មានការបូជា
- ការផ្តោតទៅលើ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ក្នុងការអប់រំ
- ការយល់ដឹងច្រើន នៃទីផ្សារអន្តរជាតិ, តម្រូវការរបស់ផ្នែកឯកជន, និន្នាការក្នុងពាណិជ្ជកម្ម ។ល។
- ការបើកចំហរ ចំពោះផ្នែកឯកជន, ដែលរួមទាំង គ្រឿងលើកទឹកចិត្ត សំរាប់អ្នកវិនិយោគឯកជន

ខាងក្រោម គឺជាករណីសិក្សាមួយ នៃការភ្ជាប់ FDI ដ៏ជោគជ័យ មួយ ក្នុងប្រទេស កូស្តារីកា។ ករណីនេះ បង្ហាញថា គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដែលគ្រប់គ្រងស្ថានភាព, បរិស្ថានគាំទ្រជំនួញ និង ការប្តេជ្ញា ខ្លាំងក្លា និង ជាប់លាប់ ពី ភាពជាអ្នកដឹកនាំ របស់ប្រទេសមួយ និង យុទ្ធសាស្ត្រ វិនិយោគ និង អភិវឌ្ឍន៏ ច្បាស់លាស់ មួយ គឺជា ធាតុផ្សំសំខាន់ នៃ យុទ្ធសាស្ត្រ FDI ដ៏ជោគជ័យ។

ក្រុមហ៊ុន Intel នៅប្រទេស កូស្តារីកា : ការទាក់ទាញ ការវិនិយោគ បច្ចេកទេសខ្ពស់ Intel ក្រុមហ៊ុន ផលិត និង រចនា បន្ទះដំណើរការ (microprocessor) ដែលមាន ជោគជ័យ បំផុត នៅលើ ពិភពលោក, វិនិយោគ នៅក្រៅប្រទេស ដើម្បីបង្កើត ចំនួនដ៏ធំនៃសមត្ថភាពថ្មី យ៉ាងឆាប់រហ័ស និងសាកសម ទៅនិងតម្លៃ ដូចដែលអាចធ្វើបាន និង ដើម្បីកាត់បន្ថយ ហានិភ័យ ដោយការផលិតនៅក្នុង រោងចក្រផ្សេងៗ គ្នា។ រោងចក្របង្កើតបន្ទះ Intel តាមបែបផែន មួយ ជាធម្មតា ត្រូវការ រយៈពេលពីរឆ្នាំដើម្បីសាងសង់ និង ការចំណាយរហូត ដល់ ១ កោដិដុល្លារ អាមេរិក។ ប៉ុន្តែ ដោយសារតែ ល្បឿន ដែលជាមួយ បន្ទះ ត្រូវបានគេ ចម្លង ដោយអ្នកប្រកួត ប្រជែង, Intel ត្រូវការ ធ្វើអោយប្រសើរឡើងនូវ រោងចក្រដែលមានស្រាប់ រឺ កន្លែង ដែល ការពង្រីក គឺមិនអាចធ្វើបានតទៅ ទៀត, អភិវឌ្ឍន៍តំបន់ថ្មី។ ការបង្កើន សមត្ថភាពផលិតផលថ្មី ត្រូវតែ ឆាប់រហ័ស និង ភ្ជាប់បញ្ចូលគ្នា ដោយរលូន ជាមួយ សមត្ថភាពដែលមានស្រាប់ ប្រសិនបើ Intel ចង់ រក្សា ភាពនាំមុខខាងបច្ចេកវិទ្យា របស់វា និង រកប្រាក់បានមកវិញ ដែលក្រុមហ៊ុនបាន ធ្លាប់មាន។ Intel មិនអាច លៃលក ដើម្បីខ្ជះខ្ជាយ ពេលវេលាណាមួយ ក្នុងការធ្វើផែនការ រឺ ការសាងសង់ នៃគ្រឿងបរិក្ខារបស់វា។ ដូចដែល អ្នកគ្រប់គ្រង Intel ម្នាក់ បានពន្យល់ថា “ការពន្យាលពេល ត្រឹមតែមួយសប្តាហ៍ អាចមានតម្លៃ ១០ លានដុល្លារ ក្នុងការលក់ដែលបាត់បង់- និង ភាពនាំមុខសំខាន់ លើគូរប្រកួតប្រជែង ” ។

ក្រៅពី ល្បឿន, Intel (ដូច ក្រុមហ៊ុនបច្ចេកវិទ្យាផ្សេងៗទៀត) ពឹងផ្អែកលើ កម្លាំងការងារ ដែល មានការអប់រំខ្ពស់ និង អាចពឹងផ្អែកបាន។ រោងចក្រ ទាមទារ ជំនាញផលិតស្មុគស្មាញ ដែលជាក់ លាក់ និង សុក្រិត។ ជាផលលំបាក, Intel នឹងកសាងសង់រោងចក្រ នៅកន្លែងដែល វាត្រូវបានគេ ធានា នៃការឈានចូលទៅកាន់ ការផ្គត់ផ្គង់ពលករ ដែលមានបច្ចេកទេសខ្ពស់ និង អាចបណ្តុះ បណ្តាលបានខ្ពស់, នៅពេល វាបានវិនិយោគ ជាមួយ កម្លាំងការងារនេះ, Intel គឺទំនងជាមិន ចាកចេញទេ ទោះបីជា នៅពេលដែល បច្ចេកវិទ្យាក្នុង រោងចក្ររបស់វា យ៉ាងរហ័សប្រែក្លាយជា លែងប្រើ ។

ផ្ទុយទៅវិញ ជាប្រពៃណី ក្រុមហ៊ុន បានពេញចិត្តជាង ក្នុងការវិនិយោគម្តងទៀត ជាមួយកន្លែងដែលមានស្រាប់ ដែលប្រើប្រាស់កម្លាំងការងារដែលបានបណ្តុះបណ្តាល របស់វា ដើម្បីចាប់ផ្តើម ការផលិត ចំពោះ គ្រឿង បរិក្ខាដែលកែប្រែថ្មី យ៉ាងឆាប់រហ័សដូចដែលអាច ធ្វើបាន។ លោក Craig Barett, មន្ត្រីប្រតិបត្តិរបស់ Intel ពីឆ្នាំ ១៩៩៨ ដល ឆ្នាំ ២០០៥, បានកត់ សំគាល់ថា វា គឺ "ងាយស្រួលយ៉ាងច្រើន ដើម្បី រៀបចំដំណាក់កាល ក្នុងជំនាន់អនាគត នៃបន្ទះចំពោះគ្រឿង បរិក្ខាដែលមានស្រាប់ ជាមួយបុគ្គលិក ដែលមានបទពិសោធន៍ជៀសជាង ការចាប់ផ្តើមពី ដំបូងជាមួយ មនុស្ស ថ្មី និង គ្មានការសាកល្បង" ។

ក្នុងការជ្រើសរើសទីកន្លែង សំរាប់រោចក្រក្រៅប្រទេស របស់វា, Intel ផងដែរគឺមិនសុំទៅនិង ការទាក់ចិត្ត នៃទុនលើកទឹកចិត្ត, យ៉ាងជាក់លាក់ នៅក្នុងករណីនៃរោងចក្រផលិត ដែលប្រើទុន ច្រើនសន្ធឹកសន្ធាប់ជាង រោងចក្រ ផ្គុំ និង សាកល្បង ។ ពីព្រោះ Intel កំពង់ស្វែងរកភ្លាម ដើម្បី ពង្រីកសមត្ថភាព, វា តែងតែ សំខាន់ ក្នុង ចំណោមនៃការរំលឹកឡើងវិញនូវ ទីកន្លែងដែលអាច និង ការវាយតម្លៃ ជម្រើស វិនិយោគ។ រោងចក្រ នៃប្រទេស កូស្តារីកា បានដើបឡើងពីមួយ ក្នុង ចំណោមការរំលឹកឡើងវិញជាបន្តបន្ទាប់ ទាំងនេះ។

ដើមឆ្នាំ ១៩៩៦, នាយកប្រតិបត្តិរបស់ Intel បានសំរេចចិត្ត ស្រាវជ្រាវរក ទីកន្លែង សំរាប់រោងចក្រ ផ្គុំ និង សាកល្បង (ATP) ដូចជា រោងចក្រ នឹងមានតម្លៃប្រហែល ១០០ ទៅ ៣០០ លានដុល្លារ អាមេរិក ដើម្បី សាងសង់ ហើយនិង នឹងជួលបុគ្គលិក ពី ១៥០០ ទៅ ៤០០០ នាក់ ដែលប្រាក់ឈ្នួល របស់គេ ជាធម្មតានឹងរាប់ ពី ២៥-៣៥ ភាគរយ នៃចំណាយប្រតិបត្តិសរុប ។
ដើម្បី ដំណើរការ ATP ថ្មីមួយ ដែលសាកសមនិងតម្លៃដូចដែលអាចធ្វើបាន, Intel ត្រូវតែ ស្វែងរក កម្លាំងពលកម្ម ដែលមានតម្លៃទាប ប៉ន្តែអាចបណ្តុះបណ្តាលបាន។

ផងដែរ វា នឹងត្រូវតែ ស្វែងរក ទីតាំង ដែល វិស្វករមានជំនាញខ្ពស់ អាចរកបាន, និង ដែលអត្រាផ្លាស់ប្តូរនិយោជិក អាចត្រូវបាន គេរក្សាទុក ដោយសម ហេតុផល ក្នុងកម្រិតអប្បរិមា។មុនពេល ការចាប់ផ្តើម ដំណើរ ការជ្រើសរើស ទីកន្លែងជា ផ្លូវការ, ផងដែរ នាយកប្រតិបត្តិរបស់ Intel បានសំរេចចិត្ត ដើម្បី ធ្វើ ATP នេះ ជា រោងចក្រថ្មីមួយ ក្នុងប្រទេសថ្មីមួយ, ជៀសជាងការពង្រីកនៃសមត្ថភាព ដែលមានស្រាប់។ ការសំរេចចិត្តនេះ មានប្រភព មកពី ការប្តេជ្ញារបស់ ការគ្រប់គ្រង ដើម្បី ធ្វើអោយ ប្លែកពីគ្នាច្រើននូវ មូលដ្ឋានទ្រព្យសម្បត្តិ តាម ភូមិសាស្រ្ត និង ដើម្បី ជៀសវាង ការ ផ្តោតទៅលើ ច្រើនជាង ៣០ ភាគរយ នៃប្រាក់ចំណូលរបស់វា ពី ប្រភេទផលិផលណាមួយ ចំពោះ រោងចក្រ ណាមួយ រឺ ក្នុងតំបន់ភូមិសាស្រ្តតែមួយណាមួយនោះ។

ខណះពេលដែល, CINDE, ស្ថាប័នផ្សព្វផ្សាយការវិនិយោគជាតិ របស់ប្រទេស កូស្តារីកា, បាន ចាប់តាំង ពី ចុងទសវត្សឆ្នាំ ១៩៨០ ទទួលយក យុទ្ធសាស្រ្តផ្តោតទៅលើ នៃការទាក់ទាញវិនិយោគ ទុន បរទេស។ សំរាប់ ជាេច្រើនឆ្នាំ ការផ្តោតនេះ បានក្លាយជា វាយនភណ្ឌ, ប៉ុន្តែ នៅពេល កម្រិត ប្រាក់ឈ្នួល របស់ប្រជាជន កូស្តារីកា បានកើនឡើង ហើយនិង ការប្រកួតប្រជែង ពីប្រាក់ឈ្នួល ទាប ជាង ដែលងើប ឡើងពី ទីផ្សារ ដែលគេបានបង្កើត, CINDE, បានប្តូរការផ្តោតទៅលើ អេឡិច ត្រូនិច។ ជាមួយនិង កម្រិតខ្ពស់ នៃចំណេះដឹងបច្ចេកទេស ក្នុងប្រទេស, ដែលទាក់ទង តម្លៃ ពលករទាប (សំរាប់ ឧស្សាហកម្មនេះ) និង ភាពសម្បូណ៌ នៃ ពលករដែលនិយាយពីរភាសា, កូស្តារីកា ហាក់បីដូចជា ចុះសម្រុងល្អ ជាមួយ តម្រូវការ នៃការកើនឡើង ឧស្សាហកម្មអេឡិច ត្រូនិចសកល។ ចាប់តាំងពី ១៩៩៣, CINDE បានកំពង់តែលួងលោម Intel និង ក្រុមហ៊ុនធំៗ ផ្សេងទៀត ក្នុងឧស្សាហកម្ម អេឡិចត្រូនិច យ៉ាងយកចិត្តទុកដាក់ ។ នៅខែ វិច្ឆិកា ១៩៩៥, ជា ចុងក្រោយ Intel បានឆ្លើយតប ជាមួយ ការចាប់អារម្មណ៍ និង បានអញ្ជើញ នាយក នៃការិយាល័យ New York របស់ CINDE, លោក Armando Heilbron, ទៅកាន់ ទីបញ្ជាការរបសវា ក្នុងទីក្រុង Sata Clara រដ្ឋ California ។

បន្ទាប់ពី បុគ្គលិក CINDE បានបញ្ជូន កញ្ចប់ពត៌មានដែលទូលំទូលាយ និង លម្អិត ទៅអោយ Intel, កូស្តារីកា បានចូលទៅក្នុង បញ្ជីដ៏វែងរបស់ Intel នៃទីកន្លែងវិនិយោគ ដែលអាចធ្វើបាន ។ ដើម្បី អោយគេ ចាត់ទុកជាអ្នកតស៊ូ, ប្រទេសមួយត្រូវតែមាន លកខណ្ឌ័សេដ្ឋកិច្ចវិជ្ជមាន, ប្រពន្ធ័នយោបាយ ដែលបានបង្កើត និង អាចពឹងផ្អែកបាន និង ប្រតិបត្តិការណ៍ដែលមានតម្លាភាពមួយ និង បរិស្ថានច្បាប់។ ផងដែរ វាត្រូវតែបាន បំពេញតម្រូវការខាងក្រោមៈ

- ធនធានមនុស្ស – ការផ្គត់ផ្គង់គ្រប់គ្រាន់ នៃអ្នកប្រតិបត្តិបច្ចេកទេស និង អាជីព ហើយនិង បរិស្ថានការងារក្រៅសហជីព។
- រចនាសម្ពន្ធ័តម្លៃសមហេតុផល – ស្ថានភាពហិរញ្ញវត្ថុដែលអាចធ្វើការបាន សំរាប់ Intel, ដែលត្រូវបានដឹកនាំក្នុងផ្នែកដ៏ទូលំទូលាយ ដោយតម្លៃពលករ និង ការចំណាយ ផ្សេងៗ, អត្រាពន្ធដារ, ជាស៊ី, ពន្ធគយ, ប្រាក់ឈ្នួល និង ភាពងាយស្រួល នៃមាតុភូមិនិត្តន៏របស់ទុន។ ពីព្រោះ ផលិតផលរបស់ រោងចក្រទាំងអស់ ដែលត្រូវបានគេប៉ុនប៉ង សំរាប់ការ នាំចេញ, ជាស៊ី, ពន្ធគយ, និង ប្រាក់ឈ្នួល គឺសំខាន់ណាស់។
- បរិស្ថាន ‘គាំទ្រ-ជំនួញ’ – រដ្ឋាភិបាល បានចាប់អារម្មណ៏ ជាមួយ ការជួយ ការអភិវឌ្ឍន៏សេដ្ឋកិច្ច និង ការវិនិយោគបរទេស, និង សញ្ញានៃសេរីកម្ម សេដ្ឋកិច្ច។
- ពេលវេលា ផលិត និង ភស្តុភារ – ដែលផ្តល់ សំពាធពេលវេលា ដែល Intel ជាទូទៅ ប្រតិបត្តិ ផលិតផលដែលចេញពី រោងចក្ររបស់វា ត្រូវតែអាចជញ្ជូន ដោយប្រសិទ្ធភាព ពីរោងចក្រ ទៅ ចំនុចច្រកទ្វារអន្តរជាតិ ហើយនិងឆ្លងកាត់ យ៉ាងរហ័ស តាមពន្ធគយ និងនិតិវិធីនាំចេញផ្សេងៗទៀត។
- ដំណើរការលិខិតអនុញ្ញាតិរហ័ស – ការធានាថា លិខិតអនុញ្ញាតិដែលចាំបាច់ទាំង អស់នឹងត្រូវបានគេទទួល ក្នុងរយះពេល ៤-៦ ខែ ព្រោះថាការពន្យាលពេល ណាមួយ អាចធ្វើ អោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ដល់កាលកំណត់ពេលយ៉ាងតឹងរឹង របស់គម្រោង ។

ក្នុងកំឡុងពេល ទស្សនៈកិច្ចដំបូង ដោយ Intel, CINDE ផងដែរបានរៀបចំអោយ គណៈកម្មការ ជ្រើសរើទីកន្លែង ជួបជាមួយ ឯកឧត្តម Jose Rossi, រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បរទេស របស់ កូស្តារីកា និង ជាមួយ ឯកឧត្តម Jose Maria Figueres, ប្រធានាធិបតេយ្យ របស់ប្រទេស។ ប្រធានាធិបតេយ្យ វ័យក្មេង និង បានទទួលការអប់រំ ពី សកលវិទ្យាល័យ Harvard បានយល់ដឹងយ៉ាងច្បាស់ អំពី ឥទ្ធិពល ដែលមាន សក្តានុពល ដែល Intel អាចមានក្នុងការជួយនាំអោយ មានការរីកចំរើនរបស់ប្រទេស។ គាត់ បានមាន ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន យ៉ាងខ្លាំង ក្នុងការទាក់ទង ជាមួយ Intel និង គឺជាធាតុផ្សំសំខាន់នៃ ជោគជ័យ ចុងក្រោយរបស់ កូស្តារីកា។ កំឡុងពេលទស្សកិច្ចដំបូង, គាត់បានចំណាយពេល ពីរម៉ោងកន្លះ ជាមួយអ្នក តំណាង របស់ Intel ដែលកំឡុងពេលនោះ គាត់បានសន្យា “ធ្វើអ្វីក៏ដោយដែលចាំបាច់” ដើម្បីធ្វើអោយ កូស្តារីកា អាចប្រកួតប្រជែងក្នុងការ ប្រកួត។ គាត់ បានសន្យា, ដោយរំភើប និង ស្វាហាប់ ក្នុង សម្លេងរបស់ គាត់, និង បានឆ្លើយតប ដោយផ្ទាល់ទៅនិង កង្វល់របស់ Intel ។ នៅពេលដែល គណៈកម្មការ បានបង្ហាញពី ភាពមន្ទិល អំពី គុណភាពនៃកម្លាំងការងារ និង ភាពគ្រប់គ្រាន់ នៃអ្នកបញ្ចប់ការ សិក្សាដែលបាន បណ្តុះបណ្តាលផ្នែកបច្ចេកទេស នៅក្នុងប្រទេស, Figueres បានផ្តល់យោបល់ នូវគំនិតនៃ កម្មវិធី បណ្តុះបណ្តាលពង្រឹងមួយ ដែលរដ្ឋាភិបាលអាចបង្កើត ដើម្បីបំពេញតម្រូវការ របស់ Intel។នៅក្នុង អ្វីដែល នឹងក្លាយជា ចលនាចំបងមួយ, Figueres ផងដែរ បានចាត់តាំង Rossi ដើម្បីគ្រប់គ្រង គម្រោង Intel សំរាប់រដ្ឋាភិបាល កូស្តារីកា ។ CINDE នឹងបានរក្សា កិចសន្យាសំខាន់ របស់ Intel និង អ្នក សម្របសម្រួល សំរាប់ការប្រជុំ និង ការចរចារជាបន្តបន្ទាប់ ប៉ុន្តែ Rossi,មន្ត្រីរដ្ឋាភិបាលដែល មាន ឋានៈខ្ពស់ និង មានការគោរព នឹងបានធ្វើជា ចំណុចកណ្តាល នៃការសម្របសម្រួល ជាមួយ រដ្ឋាភិបាល កូស្តារីកា។

អ្នកជំនួញម្នាក់ មុនពេលគាត់បានចូលរួមជាមួយរដ្ឋបាលលោក Figueres, Rossi បានទទួលស្គាល់ សារៈសំខាន់ នៃល្បឿន និង តម្លៃ ដែល Intel នឹងបានមកពី ដំណើរការយ៉ាងរហ័ស និង ការប្រាស្រ័យ ទាក់ទង យ៉ាងច្បាស់លាស់ និង បិតថេរ ពី រដ្ឋាភិបាល។ ទោះបីជា មានកេរ្តិ៍ឈ្មោះ សំរាប់ការប្តេជ្ញារបស់វា ចំពោះ ការអប់រំមូលដ្ឋាន និង កម្រិតខ្ពស់ នៃភាពចេះអក្សរ របស់វា, កូស្តារីកា មិនបានបង្កើត ចំនួនគ្រប់គ្រាន់ នៃអ្នកបញ្ចប់ការសិក្សាដែលបានបណ្តុះបណ្តាល ផ្នែកបច្ចេកទេស ដែល Intel បានទាមទារ។ ជាទូទៅ ក្រុមហ៊ុន បានបារម្ភណ៍ថា មិនមាន សមត្ថភាព នៃការអប់រំគ្រប់គ្រាន់ នៅក្នុងប្រទេស កូស្តារីកា ដើម្បី បណ្តុះ បណ្តាល អ្នកបច្ចេកទេស ៨០០ នាក់ ដែល ATP នឹងត្រូវការ។ មានផងដែរ ចន្លោះក្នុង ជំនាញភាសា អង់គ្លេស ក្នុងចំណោម និស្សិតបច្ចេកទេស និង សមត្ថភាពទូទៅ ក្នុង រូបវិទ្យា និង គមីវិទ្យា គឺទាបជាង កម្រិត ដែល Intel ចង់បាន។ ប្រទេស បានខ្វះខាតផងដែរ នូវកម្មវិធីសិក្សាកម្រិតខ្ពស់ ក្នុងផលិតកម្ម វត្ថុចំលងពាក់កណ្តាល។

ជាធម្មតា Intel ប្រកាសថា គម្រោងមួយ នឹងត្រូវគេបោះទីតាំង នៅក្នុងប្រទេស ដែលបានជ្រើសរើស ប្រសិនបើ រដ្ឋាភិបាល បានចែកចាយ ទៅលើ ការផ្តល់ នៃកិច្ចសន្យាដែលបានព្រមព្រៀង។ នៅក្នុងករណី នៅក្នុងប្រទេសកូស្តារីកា, ការផ្តល់ ទាំងនេះ បានរួមបញ្ចូល ការបំពេញនៃការចុះបញ្ជីរបស់ Intel ក្នុងតំបន់ពាណិជ្ជកម្ម សេរី ដែលបានផ្តល់អជ្ញាបណ្ណ៍, ការផ្តល់រង្វាន់ នៃប្រភេទ នៃ លិខិតអនុញ្ញាតិសាងសង់ និង បរិស្ថាន និង ការប្តេជ្ញារបស់រដ្ឋាភិបាល ដើម្បីពង្រឹងកម្មវិធីសិក្សា បច្ចេកទេស និងគ្រឿងបរិក្ខា បណ្តុះ បណ្តាល ចំពោះ វិទ្យាស្ថានមួយចំនួន សំរាប់ និស្សិតដែលសិក្សា អេឡិចត្រូនិច។ សំរាប់បីបួនខែបន្ទាប់ ក្រសួងផ្សេងៗ, CINDE, និង Intel បានធ្វើការដើម្បី រៀបចំឯកសារដែលពាក់ពន្ធ័ និង បញ្ចប់ការ រៀបចំ នៃការព្រម ព្រៀងគ្នារបស់ពួកគេ។ នៅក្នុងខែ មេសា ១៩៩៧ ការសាងសង់ នៃ ATP

## ៦.២ ទុនប្រថុយប្រថាន

អង្គការ អភិវឌ្ឍន៍ ឧស្សាហកម្ម សហប្រជាជាតិ (UNIDO) ពិពណ៌នា ទុនប្រថុយប្រថាន ដូចនេះ :

> គោលដៅនៃអ្នកវិនិយោគ ទុនប្រថុយប្រថាន គឺត្រូវអនុវត្តន៍ជាមួយក្រុមហ៊ុនដែលមានការរីកចំរើនរហ័ស ដើម្បីលក់ចេញអោយអស់ ទៅអោយសហគ្រិន, ភាគីផ្សេងៗទៀតរឺ ផ្សារភាគហ៊ុន, ជាបែបផែន បន្ទាប់ពី ៥ ទៅ ៨ ឆ្នាំ។ ហានិភ័យខ្ពស់នៃប្រភេទវិនិយោគទុននេះ គឺត្រូវបានគេទូទាត់សង ដោយការទទួលបានមកវិញខ្ពស់លើការប្រថុយប្រថាយដែលជោគជ័យ។ ភាគហ៊ុនរបស់មនុស្ស ម្នាក់ដែលគេបានធ្វើអោយមានឡើងច្រើនមុខអាចកាត់បន្ថយ អត្រាបរាជ័យ ២០-៣០ ភាគរយ, ដែលត្រូវបានទូទាត់សង ដោយការរីកចំរើនរហ័ស នៅក្នុងផ្នែកដែលនៅសល់នៃភាគហ៊ុននោះ។

បន្ថែមទៅលើ ទុន, ម្ចាស់ទុនប្រថុយប្រថាន គាំទ្រ សហគ្រាសក្មេងខ្ចី តាមរយះ ការត្រួតពិនិត្យយ៉ាងជិតដល់ និង ការគាំទ្រផ្នែកគ្រប់គ្រង។ "ផ្នែកដែលមានសារសំខាន់បំផុត នៃការគាំទ្រ គឺ ការធ្វើការសំរេចចិត្តនៃយុទ្ធសាស្រ្ត និង ការស្ថាបនា អង្គការរដ្ឋបាល និង គ្រប់គ្រង, ផ្នែកដែលក្រុមហ៊ុនថ្មី ជារឿយៗ បរាជ័យ។" ការផ្តល់ការគាំទ្រប្រភេទនេះ បង្កើន អត្រារស់រាន របស់ ក្រុមហ៊ុនដែលទើបចាប់ផ្តើម, ដែលបណ្តាលអោយមានការទទួលបានខ្ពស់មួយ លើការវិនិយោគ សំរាប់ ម្ចាស់ទុនប្រថុយប្រថាន។

ម្ចាស់ទុនប្រថុយប្រថាន គឺជា ទម្រង់ដែលគេបង្កើតឡើងយ៉ាងល្អមួយ នៃការផ្តល់ហិរញ្ញប្បទាន ក្នុងប្រទេសអភិវឌ្ឍន៍។ វាចាប់ដំណើរការ នៅពេលដែល មាន ឥណទានមិនគ្រប់គ្រាន់ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ជំនួញ។ ម្ចាស់ទុនប្រថុយប្រថាន ភាគច្រើន ចាប់អារម្មណ៍ជាមួយ ការផ្តល់ហិរញ្ញប្បទានដល់ គម្រោងធំៗ។ នៅក្នុងប្រទេសដែលកំពង់អភិវឌ្ឍន៍, ទុនប្រថុយប្រថាន បានត្រូវគេប្រើ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ ការវិនិយោគធំៗ ជាមួយ ឧស្សាហកម្មទាញយក ដូចជា ការជីករ៉ែ ។

សំរាប់ការប្រថុយប្រថានតូចតាច, រឺ សំរាប់ SMEs និង ឧស្សាហកម្មខ្នាតតូច និង មធ្យម, បែបផែន ដែលប្រើនៅក្នុងប្រទេសអភិវឌ្ឍន៍ អនុវត្តន៍ផងដែរចំពោះផ្នែកខ្លះ នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍។ នោះគឺថា ម្ចាស់ទុនប្រថុយប្រថាន លើកទឹកចិត្តដល់ ការបង្កើត ប្រដាប់ភ្ជាស់ ដែលក្នុងនោះ សហគ្រិន អាចអភិវឌ្ឍន៍ ជំនួញដែលផ្តល់កម្រៃច្រើន ដែលគួរអោយចាប់អារម្មណ៍ និង ជាសក្តានុពល ជាមួយការជួយ នៃជំនាញការ ដែល

ម្ចាស់ទុនប្រថុយប្រថាន ធ្វើអោយមាន ក្នុងការផ្លាស់ប្តូរសំរាប់ផលប្រយោជន៍ក្នុង ភាពជាម្ចាស់នៃជំនួញ និង ក្នុងប្រាក់ចំណូលពេលអនាគត។ ម្ចាស់ទុនប្រថុយប្រថាន របស់ SMEs នៅក្នុងប្រទេសដែលកំពង់អភិវឌ្ឍន៍ មកពី មូលនិធិ និង សហគ្រាសជំនួញ។ UNIDO លើកទឹកចិត្តដល់ បែបផែននេះ នៃការវិនិយោគ ជាមួយ ការគាំទ្រការអភិវឌ្ឍន៍ជំនួញ។

ដែលគួរអោយចាប់អារម្មណ៏ ប្រទេសចិន គ្មាន ទុនប្រថុយប្រថាន សំរាប់ការគាំទ្រ ជំនួញដែលមានសង្ឃឹម។ ជំនួញដែលចាប់អារម្មណ៏ជាមួយ ការទាក់ទាញទុនប្រថុយប្រថាន ត្រូវការអភិវឌ្ឍន៍ គំនិតជំនួញមួយ និង បញ្ជូនគំនិតនោះ ទៅក្រុមហ៊ុនទុនប្រថុយប្រថាន។ ជាមួយ ភាពដែលអាចរកបានដែលកើនឡើង នៃទុន ឯកជន និង SWFs រួមនិង ក្រុមហ៊ុនគ្រប់គ្រងដោយរដ្ឋដែលផ្តល់ទាយជ្ជទានហិរញ្ញវត្ថុ, មាន សមធម៌ ដែល អាចរក បាន។ ការលំបាក គឺ ការទាក់ទាញ ទុនប្រថុយប្រថាន ទៅកាន់ប្រទេសដែលកំពង់អភិវឌ្ឍន៍ ជាទូទៅ និង ទៅកាន់ សហគ្រិន នៅក្នុងប្រទេសទាំងអស់នោះ យ៉ាងជាក់លាក់។

ទុនប្រថុយប្រថាន មានទំនោរទៅតាម FDI និង ស្វែងរក ប្រទេស និង យុត្តាធិការ នៃសហគ្រាស និងដែល រាក់ទាក់ជំនួញ។ ម្ចាស់ទុនប្រថុយប្រថាន មិនវិនិយោគទេ លុះត្រាតែ ពួកគេ មានការយល់ដឹង និង ចំណេះដឹង ក្នុងស្រុកច្រើន, ដែលមិនទំនងជាមូលហេតុ, ទោះបីជាមានការលើកលែង។ ម្ចាស់ទុនប្រថុយ ប្រថានជាច្រើន គឺមានមូលដ្ឋាននៅប្រទេសលោកខាងលិច ដែលចាត់ទុក ការវិនិយោគជាមួយ ប្រទេសកំពង់ អភិវឌ្ឍន៍ ថាគ្រោះ ថ្នាក់ណាស់។ ឱកាសនៃការទាក់ទាញ ទុនប្រថុយប្រថាន គឺខ្ពស់ កន្លែងណាដែល មាន ជំនួញដែលជោគជ័យច្រើន និង ការវិនិយោគធំៗ ត្រូវបានគេធ្វើឡើង។

ជាចុងបញ្ចប់ ទុនប្រថុយប្រថាន គឺ ជាហានិភ័យដែលគេមិនពេញចិត្តយ៉ាងខ្លាំក្លា។ ម្ចាស់ទុនប្រថុយប្រថាន អាចយល់ឃើញថា វាងាយស្រួលជាង ដើម្បី វិនិយោគជាមួយ ក្រុមហ៊ុនបរទេស ដែលមានកំណត់ត្រាល្អមួយ ជាអន្តរជាតិ មុនពេល ការប្រថុយប្រថាន ទៅក្នុង គម្រោង ICTD ក្នុងប្រទេសកំពង់អភិវឌ្ឍន៍។ ទោះបីជា យ៉ាងណាក៏ដោយ មានការកើនឡើងការយល់ដឹងថា មួយចំនួននៃវិស្វករកម្មវិធីល្អបំផុត គឺមិនជាចាំបាច់ ‘កើត នៅក្នុង សហរដ្ឋអាមេរិកទេ’ និង ការវិនិយោគទុនជាមួយ ឱកាស ដើម្បីបញ្ចេញ ទៅក្នុងថាមពលច្នៃប្រឌិត និង ទុនបញ្ញា នេះ នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ គឺប្រហែលជា កំពង់តែកើតឡើងហើយ។

## ៦.៣ សារជីវកម្មឆ្លងប្រទេស

ដោយយោងទៅលើ UNCTAD, TNC គឺ សហគ្រាសដែលរួមគ្នា រឺ មិនរួមគ្នា ដែលមាន សហគ្រាសមេ និង សាខាក្រៅប្រទេសរបស់ពួកគេ។ សហគ្រាសមេ គឺត្រូវបានគេកំណត់ ជា សហគ្រាសមួយ ដែលត្រួត ពិនិត្យ ទ្រព្យសម្បត្តិ នៃស្ថាប័នដ៏ទៃទៀត ក្នុងប្រទេសជាច្រើន ជាង ប្រទេសម្ចាស់ផ្ទះរបស់វា, ជាធម្មតា ដោយ ការធ្វើជាម្ចាស់ ហ៊ុនទុនស្មើរភាពគ្នា ប្រាកដមួយ។ TNCs គឺជា ប្រភពនៃ FDI រួមទាំងសក្តានុពល ដៃគូរ ក្នុង PPPs ។ នេះ អនុវត្តន៏ជាពិសេសទៅលើ ក្រុមហ៊ុនពត៌មានវិទ្យាធំៗ, ធានាគារហិរញ្ញវត្ថុធំៗ និង TNCs ដែលប្រតិបត្តិក្នុងផ្នែកដ៏ទៃទៀត។

កម្មករប្រហែលជា ៧៣ លាននាក់ ត្រូវបានគេជួលអោយធ្វើការ ក្នុងសាខាក្រៅប្រទេស របស់ TNCs ក្នុង ឆ្នាំ ២០០៦, ក្បែរ បីដងច្រើនជាង ក្នុងឆ្នាំ ១៩៩០, និង ការផ្តល់ការងារសរុបរបស់ពួកគេ មានចំនួនប្រហែល ជា ៣ ភាគរយនៃកម្លាំងការងារសកល។ ប្រទេសចិន មានចំនួនច្រើនជាងគេបំផុត នៃនិយោគជិក ក្នុងសាខា ក្រៅប្រទេស។ ក្នុងឆ្នាំ ២០០៤ កម្មករ ប្រហែល ២៤ លាននាក់ (៣ ភាគរយនៃការងារសរុប ក្នុងប្រទេស ចិន) ត្រូវបានគេជួល ក្នុងសាខាក្រៅប្រទេស ក្នុងប្រទេសនោះ ដែលប្រៀបធៀប តិចជាង ៥ លាន ក្នុងឆ្នាំ ១៩៩១។

TNCs មានសិទ្ធឈានចូលទៅកាន់ ខ្សែច្រវាក់ផ្គត់ផ្គង់សកល។ ធ្វើការជាមួយ TNC អាចបើកចំហរ ការឈានចូលទៅកាន់ ធនធានទាំងនេះ និង ឱកាសទីផ្សារ។ អត្ថប្រយោជន៏ជាក់លាក់ រួមមាន ការផ្តល់ហិរញ្ញប្បទាន, រួមនិង ជំនាញការគ្រប់គ្រង និង បច្ចេកទេស និង ឱកាសសំរាប់ ការផ្ទេរជំនាញទាំងនេះ ទៅអោយដៃគូរជាតិ។

តើអ្វី ធ្វើសំរាប់ បរិយាកាសលើកទឹកចិត្ត សំរាប់ការផ្តល់ហិរញ្ញប្បទាន TNC ? កត្តាដូចគ្នា ដែលទាក់ទាញ FDI លើកទឹកចិត្តដល់ TNCs ដើម្បីបង្កើត ហាងនៅក្នុងប្រទេស រឺ យុត្តាធិការមួយ។ ភាពដែលអាចរកបាន នៃ ជំនាញការ និងអ្នកបញ្ចប់ការសិក្សាដែលមានសមត្ថភាព គឺសំខាន់ រួមទាំង ផ្នែកបច្ចេកទេស និង វិទ្យាសាស្ត្រ។ នេះ បញ្ជាក់នូវ វត្តមាននៃវិទ្យាស្ថានបច្ចេកវិទ្យា ដ៏ខ្លាំង និង ការសិក្សាថ្នាក់ខ្ពស់ (មហាវិទ្យាល័យ) និង មជ្ឈមណ្ឌលស្រាវជ្រាវ និង អភិវឌ្ឍន៏។ ជំនាញគ្រប់គ្រង និង ផ្ទេរ បច្ចេកវិទ្យា និង ចំណេះដឹង គឺ សំខាន់។

## ៦.៤ វិទ្យាស្ថានហិរញ្ញវត្ថុ (វិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ)

ដោយយោងទៅលើ Wikipedia :

> វិទ្យាស្ថានហិរញ្ញវត្ថុ រឺ IFIs សំដៅទៅលើ វិទ្យាស្ថានហិរញ្ញវត្ថុ ដែលត្រូវបានគេបង្កើត (រឺ អនុញ្ញាតិ) ដោយ ប្រទេស ច្រើនជាងមួយ និងដូចច្នេះហើយ គឺឋិតនៅក្រោមច្បាប់ អន្តរជាតិ។ ម្ចាស់ រឺ ម្ចាស់ភាគហ៊ុនរបស់វា ជាទូទៅ គឺជារដ្ឋាភិបាលជាតិ ទោះបីជា វិទ្យាស្ថានអន្តរជាតិ និង អង្គការ ដ៏ទៃទៀត យូរៗម្តង ចាត់ទុកជា ម្ចាស់ភាគហ៊ុន។ IFI ដែល លេចធ្លោច្រើនបំផុត គឺ ការបង្កើតនៃពហុជាតិ ទោះបីជា វិទ្យាស្ថានហិរញ្ញវត្ថុ ទ្វេភាគី ខ្លះៗ (បានបង្កើតដោយពីរប្រទេស) កើតមាន និង ជាបច្ចេកទេស IFIs ។ ភាគច្រើននៃទាំងនេះ គឺ ធានាគារអភិវឌ្ឍន៏ពហុភាគីជាច្រើន។

ខាងក្រោម គឺជា ក្រុមសំខាន់ៗនៃ IFIs :

- វិទ្យាស្ថាន Bretton Woods – ធានាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ, សារជីវកម្ម ហិរញ្ញវត្ថុ និង សមាជិកផ្សេងៗទៀត នៃក្រុមធានាគារពិភពលោក
- ធានាគារអភិវឌ្ឍន៏តំបន់ -
- ធានាគារអភិវឌ្ឍន៏ អន្តរ-អាមេរិក
- ធានាគារអភិវឌ្ឍន៏អាស៊ី
- ធានាគារអភិវឌ្ឍន៏អាហ្វ្រិក
- ធានាគារអ៊ឺរ៉ុប សំរាប់ ការស្ថាបនា និង អភិវឌ្ឍន៏
- ធានាគារអភិវឌ្ឍន៏ទ្វេភាគី
- វិទ្យាស្ថានហិរញ្ញវត្ថុនៃតំបន់ ដ៏ទៃទៀត -
- ធានាគារវិនិយោគអ៊ឺរ៉ុប
- ធានាគារអភិវឌ្ឍន៏អ៊ីស្លាម
- ធានាគារវិនិយោគ Nordic

ការផ្តល់ ហិរញ្ញប្បទាន ពី IFIs និង ស្ថាប័នទ្វេភាគី គឺត្រូវបានគេចងភ្ជាប់យ៉ាងណែន ជាមួយនិង អាទិភាព ផែនការ អភិវឌ្ឍន៏ជាតិ និង បែបផែនអភិវឌ្ឍន៏។ ដើម្បីទទួលបាន ការគាំទ្រ, អង្គការផ្នែកសារធារណៈ ត្រូវការ

គម្រៀប សំណើររបស់ពួកគេ យ៉ាងជិតស្និតដូចដែលអាចធ្វើបាន ជាមួយអាទិភាពនៃរដ្ឋាភិបាល។ ហេតុនេះហើយ មានតម្រូវការមួយ ដើម្បីធានថា គម្រោង ដែលសម្រាប់វា ការផ្តល់ហិរញ្ញប្បទាន ត្រូវបាន គេស្វែងរក, ត្រូវបាន គេគាំទ្រក្នុងស្រុក និង ត្រូវបានគេបង្ហាញជាអាទិភាពមួយ ដោយ រដ្ឋាភិបាល។

សេចក្តីប្រកាសទីក្រុងប៉ារីស លើប្រសិទ្ធភាពនៃជំនួយ ដែលបានយល់ព្រមដោយ DAC នៃ OECD លើកទឹកចិត្តម្ចាស់ជំនួយអោយ ផ្តល់ហរិញ្ញប្បទានដោយផ្ទាល់ ទៅដល់ឃ្លាំងប្រាក់របស់ប្រទេសអ្នកទទួល។ ប្រទេស អ្នកទទួល សំរេចចិត្ត ដោយផ្អែកទៅលើ អាទិភាពផែនការអភិវឌ្ឍន៏របស់វា និង បែបផែន ពីរបៀបដែលមូលនិធិ ត្រូវតែបានគេចាយវាយ។ ដោយមានការកើនឡើង, ម្ចាស់ជំនួយនៃប្រទេស OECD ធ្វើការជាមួយគ្នា យ៉ាង ជិតស្និត ជាមួយនិង IFIs ដើម្បីធានា ការសម្របសម្រួល ក្នុងការធ្វើផែនការ និង ការចែកចាយ នៃជំនួយ អភិវឌ្ឍន៏។ ប្រទេសដែលមាន កំណត់ត្រានៃអភិបាលកិច្ចដែលបានបញ្ជាក់ និង ខ្លាំងក្លាមួយ គឺ អ្នកទីមួយដែល ទទួលផលប្រយោជន៏ពី ទម្រង់នៃជំនួយនេះ។ ប្រទេសដែលគ្មានកំណត់ត្រាបែបនេះ គឺមិនទំនងជា ទទួលបាន ជំនួយឥតចំណង នៃប្រភេទដែលបានស្នើរសុំ ដោយសេចក្តីប្រកាសទីក្រុងប៉ារីសទេ លុះត្រា តែ ពួកគេធ្វើអោយមាន ការរីកចំរើនខ្លាំងក្លា ក្នុង ការគាំទ្រ អភិបាលកិច្ចល្អ, កាត់បន្ថយអំពើពុករលួយ, និង ការបង្កើត របបបញ្ញតិដែល មានតម្លាភាព និងបើកចំហរ, រួមនិងបរិយាសកាសវិនិយោគសំរាប់ផ្នែកឯកជន។

ទោះបីជាយ៉ាងណាក៏ដោយ ឥឡូវនេះ មាន ម្ចាស់ជំនួយ មិនមែនជា OECD លេចឡើង ដែលមិនត្រូវបានរាំងដោយបញ្ហាអភិបាលកិច្ច និង ការអភិវឌ្ឍន៏ប្រជាធិបតេយ្យ ដែលត្រូវបានគេចាប់ អារម្មណ៏យ៉ាងច្រើន ជាមួយការគាំទ្រ ជំនួយអភិវឌ្ឍន៏ និងជាមួយការធ្វើការក្នុងភាព ជាដៃគូរជាមួយ ប្រទេសកំពង់អភិវឌ្ឍន៏ លើ ទិសដៅអភិវឌ្ឍន៏រួម។

គុណសម្បត្តិ និង គុណវិប្បត្តិ មួយចំនួនដែលបានភ្ជាប់ជាមួយនិង FDI អនុវត្តន៏ផងដែរ ជាមួយ ការផ្តល់ហិរញ្ញប្បទាន ពី IFIs។

## ៦.៥ ការផ្តល់ហិរញ្ញប្បទាន រដ្ឋាភិបាល-ទៅ-រដ្ឋាភិបាល

ការផ្តល់ហិរញ្ញប្បទាន រដ្ឋាភិបាល-ទៅ-រដ្ឋាភិបាល ត្រូវបានគេចាត់ជាក្រុម ក្រោម ‘ជំនួយ’ ដែល Wikipedia កំណត់ន័យ ដូចខាងក្រោម :

> ជំនួយ គឺ ការជួយ, ភាគច្រើន សេដ្ឋកិច្ច, ដែលអាចត្រូវបានគេផ្តល់ទៅដល់សហគមន៍ រឺ ប្រទេសនៅក្នុង ព្រឹត្តិការណ៍ នៃវិបត្តិមនុស្សធម៌មួយ រឺ ដើម្បីសំរេច គោលដៅ សេដ្ឋកិច្ចសង្គម។ ដោយហេតុនេះហើយ ជំនួយមនុស្សធម៌ គឺជាចំបង ដែលប្រើសំរាប់ បន្ធូរន្ធូរភាពបន្ទាន់, នៅពេលដែល ជំនួយអភិវឌ្ឍន៍ មាន គោលបំណង ដើម្បីបង្កើត ការរីកចំរើនសេដ្ឋកិច្ចដែលអាចទ្រទ្រង់បានរយះពេលវែង។ ជាបែបផែន ថាតើ ប្រទេស ជាច្រើន ផ្តល់ជំនួយ ទៅដល់ ប្រទេសដែលកំពង់អភិវឌ្ឍន៍សេដ្ឋកិច្ចទេ។

នៅក្នុងឆ្នាំ ២០០៦, ម្ចាស់ជំនួយ OECD បានបង្កើនការផ្តល់អោយរបស់គេ ទៅដល់ ប្រហែលជា ៧៥ កោដិ ដុល្លារអាមេរិក ឡើងពី ៥៣ កោដិដុល្លារអាមេរិក ក្នុងឆ្នាំ ២០០២។ ទូរលេខជាក់ស្តែង បានរាយការណ៏ថា OECD សំរាប់ឆ្នាំ ២០០៦ គឺ ៧៧.៨ កោដិដុល្លារអាមេរិក ដែលរួមបញ្ចូលទាំង ការផ្តល់ទៅ ប្រទេសអ៊ីរ៉ាក់ ( ៧ កោដិដុល្លារអាមេរិក ) ។ ភាគច្រើននៃជំនួយដែលកើនឡើងនេះ គឺសំរាប់ធ្វើអោយធូរស្រាលបំណុល។

ប្រទេសមានប្រាក់ចំណូលកណ្តាល ដូចជា ប្រេស៊ីល, ចិន, ឥណ្ឌូនេស៊ី និង ថៃ ហើយនិង ប្រទេសដែលសំបូរ ធនធាន ដូចជា អង់ហ្គោឡា កំពង់តែទទួល ជំនួយអភិវឌ្ឍន៍ (ODA) តិចតួច នៅពេលដែល ម្ចាស់ជំនួយ ចូលចិត្តជួយជាងដល់ប្រទេសដែលមានលទ្ធភាពតិចតួច ដើម្បីផ្តល់ហិរញ្ញប្បទាន ដល់ការអភិវឌ្ឍន៍របស់ខ្លួន ។ សមាមាត្រ នៃ ODA ដែលទៅកាន់ ប្រទេសអភិវឌ្ឍន៏តិចតួច និង ប្រទេសមានប្រាក់ចំណូលទាប បានកើន ឡើង យ៉ាងខ្លាំង – ពី ៤០ ភាគរយ ក្នុងឆ្នាំ ២០០២ ទៅ ៤៦ ភាគរយ ក្នុងឆ្នាំ ២០០៦។ លើសពីនេះទៅ ទៀត សមាមាត្រខ្ពស់ជាង នៃជំនួយ គឺ គ្មានចំណង – នោះអាចនិយាយបានថា មិនត្រូវបានគេចង ទៅនិង ការទិញ ពីប្រទេសដែល ផ្គត់ផ្គង់ ជំនួយ។

អាទិភាពដំបូងនៃ IFIs គឺ ការកាត់បន្ថយភាពក្រីក្រ, ការពង្រឹងអភិបាលកិច្ច, ការផ្តល់អំណាចដល់ ស្ត្រី, ការ ការពារ សិទ្ធិជនជាតិភាគតិច និង ការការពារ បរិស្ថាន។ គម្រោង ដែលអាចគេភ្ជាប់យ៉ាងច្បាស់ ទៅ ការកាត់ បន្ថយភាពក្រីក្រ និង ទិសដៅ ដ៏ទៃៗទៀត គឺទំនងជាត្រូវបានគេយល់ព្រម ច្រើនជាង។ ម្ចាស់ជំនួយ បានកាត់បន្ថយ ការគាំទ្ររបស់គេ សំរាប់គម្រោង អាយ ស៊ី ធី, ដែលចូលចិត្តជាង ជំនួសអោយ ការដោះ ស្រាយ អាយ ស៊ី ធី ជាឧបករណ៏ ក្នុងការប្រឆាំង ភាពក្រីក្រ និង ក្នុងការគាំទ្រ អភិបាលកិច្ច។ ការផ្លាស់ប្តូរ បរិយាកាស ថ្មីៗនេះ ត្រូវបានគេទទួលស្គាល់ ថាជា និន្នាការចំបង និង ការអភិវឌ្ឍន៍ ប្រទេស អាចរំពឹងទុក ការគាំទ្រយ៉ាងច្រើន ពី ប្រទេសអភិវឌ្ឍន៍ ក្នុងការកសាងសមត្ថភាព សំរាប់ការបន្ធូរ និងផងដែរ ការទទួល យក ការផ្លាស់ប្តូរបរិយាកាស និង ផលប៉ះពាល់របស់វា។

ការផ្តល់ហិរញ្ញប្បទាន គឺផ្អែកទៅលើ កិច្ចព្រមព្រៀងដែលដូចជា សន្ធិសញ្ញា រវាងប្រទេសម្ចាស់ជំនួយ និង ប្រទេសអ្នកទទួល។ កិច្ចព្រមព្រៀងនេះ ត្រួតពិនិត្យ បែបបទនៃកិច្ចសហការ។ ស្ថាប័នទ្វេភាគី ផ្សេងៗគ្នា មាន តម្រូវការ ផ្សេងៗគ្នា សំរាប់ការទទួល ជំនួយអភិវឌ្ឍន៍ និង សំរាប់ ការរាយការណ៍ លើការប្រើប្រាស់ នៃ មូលនិធិអភិវឌ្ឍន៍។ ដោយយោងទៅលើ សេចក្តីប្រកាសទីក្រុង ប៉ារីស នៃ OECD, ជំនួយអភិវឌ្ឍន៍ នឹងត្រូវ បានគេបញ្ជូន ទៅអោយ រតនាគាររបស់ប្រទេសដែលកំពង់អភិវឌ្ឍន៍ដោយផ្ទាល់។ ប្រទេសកំពង់អភិវឌ្ឍន៍ ជា ចុងបញ្ចប់ នឹងនៅក្នុងទីតាំងមួយ ដើម្បីសំរេច សំរាប់ខ្លួនរបស់គេ លើ របៀបដែលប្រាក់ជំនួយទាំងនេះ ត្រូវ បានគេចំណាយ។ អ្វីដែលត្រូវការជាមុន គឺ ការធានាថា ប្រទេស មាន ការគ្រប់គ្រងហិរញ្ញវត្ថុ, អភិបាលកិច្ច, ការផ្គត់ផ្គង់, និង សមត្ថភាពត្រួតត្រា ដើម្បីប្រើប្រាស់អោយបានត្រឹមត្រូវ នូវមូលនិធិទាំងនេះ នៅពេល បំពេញ តម្រូវការសំរាប់ ការបើកចំហរ, តម្លាភាព, ភាពសុក្រិត និង សមធម៌ ដែលប្រទេស OECDគាំទ្រ។
ដូចនេះ ភាគច្រើននៃបញ្ហាដែលបានពិភាក្សាក្រោម FDI អនុវត្តន៍ផងដែរ។

ភាពជោគជ័យ នៃជំនួយអភិវឌ្ឍន៍ ត្រូវបានគេវាស់វែង ក្នុងន័យ :

- ការរួមចំណែក ចំពោះការកាត់បន្ថយភាពក្រីក្រ
- ការរួមចំណែក ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច និង កំនើនគាំទ្រអ្នកក្រ
- ការរួមចំណែក ចំពោះការសំរេច MDGs និង
- ផលប៉ះពាល់រយះពេលវែង នៃជំនួយដែលបានផ្តល់។

## ៧. ការរៀបចំ យុទ្ធសាស្រ្តចល័តធនធាន

ផ្នែកនេះមានគោលបំណងដើម្បី :

- ពិភាក្សាអំពី ដំណាក់កាល ដេម្បីអោយគេអនុវត្តន៏ក្នុង ការអភិវឌ្ឍន៏សំណើមួយ សំរាប់ការផ្តល់ហិរញ្ញប្បទានដល់ គម្រោង អាយ ស៊ី ធី និង
- ផ្តល់លក្ខណះសង្ខេបនៃបញ្ហាចំបង់ក្នុងការបង្កើតសំណើរ

### ៧.១ ទិដ្ឋភាពនៃការចល័តធនធាន

មានជំហានជាច្រើន បានពាក់ពន្ធ័ ក្នុងការរៀបចំ យុទ្ធសាស្រ្តចល័តធនធាន។ យើងសូម ចាប់ផ្តើមជាមួយនិយមន័យ នៃ យុទ្ធសាស្រ្តចល័តធនធាន និង ទស្សនះដែលទាក់ទង។

ធនធាន អាចជា ហិរញ្ញវត្ថុ, មនុស្ស, រឺ ក្នុងប្រភេទ ទំនិញ និង សេវា ដែលអាចរកបាន ដើម្បីអនុវត្តន៏យុទ្ធសាស្រ្ត, ផែនការ, កម្មវិធី, គម្រោង និង សកម្មភ្នាព។

យុទ្ធសាស្រ្តចល័តធនធាន គឺជាផែនការមួយ ដែលពន្យល់ពី របៀបដែលអង្គការមួយ នឹងធ្វើអោយមានសុវត្ថិភាព ធនធាន ដើម្បីអនុវត្តន៏ គម្រោង និង សំរេចគោលដៅ ដែលបានកំណត់ក្នុងពេលមួយ។

ការអភិឌ្ឍន៏ យុទ្ធសាស្រ្តចល័តធនធាន ជាធម្មតា គឺជា ជំហានទី១ ក្នុងការអភិវឌ្ឍន៏ សំណើរហិរញ្ញប្បទាន។ វាគឺជា ផែនការ ដែលរកឃើញ សក្តានុពល ដៃគូរ និង ម្ចាស់ជំនួយ និង ពន្យល់ពី របៀប និង ធនធានអ្វីដែលពួកគេអាច ផ្តល់អោយ។ វាគឺជា សមាសធាតុនៃសំណើរគម្រោង ផងដែរ, ប្រសិនបើប្រភពនៃមូលនិធិ និង ធនធានផ្សេងទៀត មិនអាចត្រូវបានរកឃើញ, ហើយបន្ទាប់ប្រហែលជា គម្រោង រឺសកម្មភាពដែលគេស្នើរសុំ មិនអាចសំរេចបានទេ។

យុទ្ធសាស្រ្តចល័តធនធាន អាចឋិតនៅ កម្រិត នៃយុទ្ធសាស្រ្ត, ផែនការ, និង សកម្មភាព ជាតិ; យុទ្ធសាស្រ្ត និង ផែនការ ផ្នែក; អង្គការ រឺ គម្រោងបុគ្គល។ នៅក្នុងផ្នែកឯកជន, យុទ្ធសាស្រ្តចល័តធនធាន គឺជាផ្នែកមួយនៃ ផែនការជំនួញ និង វាផ្តោតទៅលើប្រាក់ចំណេញ។ នៅក្នុងផ្នែកសារធារណះ, យុទ្ធសាស្រ្តចល័តធនធាន គឺត្រូវបាន គេនាំឆ្ពោះទៅ ការធានា និរន្តរ៏ភាពគម្រោង។ យុទ្ធសាស្រ្តចល័តធនធាន តែងតែ មិនគួរបានគេ

រួមបញ្ចូល នៅក្នុង ផែនការគម្រោង។ ពេលខ្លះ ពួកគេត្រូវបានគេដាក់បញ្ចូល ក្រោមចំណងជើង ដូចជា ផែនការហិរញ្ញវត្ថុ រឺ ពួកគេ មិនអាចលេចឡើង នៅក្នុងផែនការគម្រោង សូម្បីតែបន្តិច។ ការចល័តធនធាន គឺជា ការពិចារណាដំបូងមួយ ដែល អ្នកបង្កើតគម្រោង គិតអំពី។

ដំណាក់កាល ដែលពាក់ពន្ធ័ ក្នុងការដាក់ជាមួយគ្នា នូវយុទ្ធសាស្រ្តចល័តធនធាន គឺ:

១. កំណត់អត្តសញ្ញាណ និង កម្រិតចំនួន ធនធានដែលគេតម្រូវ និង ពន្យល់មូលហេតុដែលពួកគេតម្រូវ។ គម្រោងថវិការ អាចគ្រប់គ្រាន់ សំរាប់គោលបំណងនេះ, ជាមួយ ការពិពណ៌នាអំពី ចំនុចក្នុងគម្រោងថវិកា និងសារសំខាន់របស់ពួកគេ ចំពោះការអនុវត្តន៍។
២. ពន្យល់ របៀបដែលធនធាន នឹងត្រូវបានគេតម្រូវ, កំណត់អត្តសញ្ញាណដៃគូរ រឺ អ្នកសហការ ដែលអាច ផ្តល់ធនធាន។
៣. ពន្យល់របៀបដែល ដៃគូរ រឺ អ្នកសហការ នឹងចូលរួមចំណែក ដល់គម្រោង។ ធ្វើអោយសុក្រិតការជ្រើស រើស ដៃគូរ រឺ អ្នកសហការ និង តួនាទី និង ការចូលរួមចំណែក របស់ពួកគេ។
៤. កំណត់អត្តសញ្ញាណ របៀបដែលដៃគូរ នឹងត្រូវបានគេចូលទៅដល់ និង របៀបដែលការប្រាស្រ័យទាក់ទង ជាមួយពួកគេ នឹងត្រូវបានបង្កើតឡើង។
៥. ពិភាក្សា និង រំលឹក ជម្រើស, វាយតម្លៃ និង ធ្វើអោយសុក្រិត ជម្រើស។
៦. ផ្តល់ អនុសាស្រ្តន៍
៧. ចូលទៅដល់ សក្តានុពលដៃគូរ, ធ្វើសំណើរ និង វាយតម្លៃផលប្រយោជន៍របស់ពួកគេ
៨. ចរចារ កិច្ចព្រមព្រៀង និង កែប្រែ សំណើរគំរោង។
៩. យល់ព្រម និង ចុះហត្ថលេខា លើកិច្ចព្រមព្រៀង ដើម្បីអនុវត្តន៍គម្រោង

វាច្បាស់ណាស់ ពី ការពិពណ៌នានៃដំណាក់កាល ដែលពាក់ពន្ធ័ មូលហេតុដែល ពត៌មានដែល បានលើក ឡើងខ្លះៗ អាចមិនត្រូវបានគេតម្រូវ នៅក្នុងឯកសារគម្រោង រឺ ឯកសារសំណើរ ជាក់ស្តែង។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាទាំងអស់នេះ ត្រូវតែបានគេពិចារណា នៅពេលដែលស្វែងរកមូលនិធិ និង វិធីសាស្រ្តដែលមូលនិធិ នឹងត្រូវបាន គេទទួល។

## ៧.២ ការរៀបចំ សំណើរមូលនិធិ

អ្នកទទួលដែលប៉ុនប៉ង នូវសំណើរមូលនិធិ គឺ ស្ថាប័នអភិវឌ្ឍន៍អន្តរជាតិប្រពៃណី ដូចជា ស្ថាប័នទ្វេភាគី របស់ក្រុម OECD របស់ប្រទេស, the IFIs និង អង្គការសហប្រជាជាតិ។ ប្រភពផ្សេងទៀត នៃមូលនិធិ ដែលគេអាចពិចារណាបាន គឺ SWFs និង ជំនួយទ្វេភាគី រវាងប្រទេសនិងប្រទេស ដូចជា ចិន និង ឥណ្ឌា ដែលកំពង់ ក្លាយជា តួអង្គសំខាន់របស់ពិភពលោក។

លកខណ្ឌ័ជាច្រើន ត្រូវបានគេប្រើ ដើម្បីពិពណ៌នា សំណើរមូលនិធ និង ម្ចាស់ជំនួយផ្សេងៗ មានតម្រូវការ និង ដំណើរការ ផ្សេងៗគ្នា សំរាប់សំណើរមូលនិធិអភិវឌ្ឍន៍។ ទោះបីជាយ៉ាងណាក៏ដោយ, ដំណាក់កាលក្នុងការរៀបចំសំណើរមូលនិធិ ជាមូលដ្ឋាន គឺដូចគ្នា។

### ដំណាក់កាលវាយតម្លៃ

ដំណាក់កាលដំបូង គឺ វិភាគរក តម្រូវការ សំរាប់គម្រោង តាមរយៈ ការវាយតម្លៃ និង វិភាគ ។ នេះគឺ ដំណាក់កាល សំខាន់មួយ ពីព្រោះ ប្រសិនបើ ការវិភាគរក មិនកំពង់តែបង្ហំ, គម្រោង អាចមិនទាក់ទាញមូលនិធិ។
បន្ទាប់ការកំណត់តម្រូវការច្បាស់លាស់, វាសំខាន់ផងដែរ ដើម្បីវាយតម្លៃ កាលៈទេសៈ និងកត្តាទាក់ទងដែលមាន ឥទ្ធិពល លើតម្រូវការ សំរាប់គម្រោង និង មូលនិធិដែលគេត្រូវការ។ យ៉ាងល្អវិសេសទិន្នន័យដែលអាចវាស់វែង បាន ដែលបង្ហាញតម្រូវការ, ការទាមទារសំរាប់ និងភាពរួចរាល់ដើម្បិប្រើប្រាស់អាយ ស៊ី ធី គួរតែត្រូវបានគេ ប្រមូល, រួមនិងពត៌មានអំពីអាទិភាពដែលភ្ជាប់ទៅគម្រោង ដែលបាន ស្នើរដោយរដ្ឋាភិបាល, អ្នកទទួលផល និង ម្ចាស់ជំនួយ។ ពត៌មានទាំងនេះ នឹងជួយធ្វើអោយសុក្រឹត ញ្ញាតិដែលបានស្នើរ និង ថវិកាដែលបានភ្ជាប់ជាមួយវា។

## ការរៀបជាជួរ អាទិភាពអភិវឌ្ឍន៍ជាតិ និង អន្តរជាតិ

ផ្នែកនៃការបង្ហាញភាពត្រឹមត្រូវ សំរាប់គម្រោង គឺ របៀបដែលវាទាក់ទងទៅ អាទិភាព និង តម្រូវការ នៃប្រទេស និង យុត្តាធិការ ដែលស្វែងរកការគាំទ្រ។ សំណើរគម្រោង ត្រូវតែដាក់នៅ ក្នុង ផែនការ និង យុទ្ធសាស្រ្តអភិវឌ្ឍន៍ ជាតិ ទូទៅ។

សំរាប់ម្ចាស់ជំនួយជាច្រើន, គោលបំណងសំខាន់ នៃជំនួយអភិវឌ្ឍន៍ គឺ ការកាត់បន្ថយភាពក្រីក្រ នៅក្រោម កាលៈទេសៈធម្មតាមួយ។ 'កាលៈទេសៈធម្មតា ' មានន័យថា អវត្តមាន នៃជម្លោះ, គ្រោះមហន្តរាយ និង ប្រតិបត្តិ ការជំនួយមនុស្សធម៌ធំទូលាយ ដែលចាំបាច់ដើម្បីនាំយកប្រទេសមួយ ត្រឡប់ទៅកាន់ស្ថានភាព ដែលរដ្ឋាភិបាល មិនកំពង់ប្រតិបត្តិ នៅក្នុងទម្រង់វិបត្តិ។ គោលដៅនៃការកាត់បន្ថយភាពក្រីក្រ គឺលើកដំបូង នៃកិច្ចព្រមព្រៀង ជា សកល ផ្អែកលើ MDGs។

ជាមួយនិង ជំនួយនៃម្ចាស់ជំនួយអន្តរជាតិ, ប្រទេសកំពង់អភិវឌ្ឍន៍ជាច្រើន បានអភិវឌ្ឍន៍ វិធីសាស្រ្តដែល មានផែនការ ដើម្បីប្រឆាំង និងភាពក្រីក្រ ដែលត្រូវបានគេកំណត់ នៅក្នុងដំណើការ ឯកសារយុទ្ធសាស្រ្ត កាត់បន្ថយភាពក្រី ក្រ (PSRP)។ ធានាគារពិភពលោក ត្រូវបានគេផ្សារភ្ជាប់យ៉ាងជិតស្និទ ជាមួយ ដំណើរការ PRSP និង មូលនិធិ ធានាគារពិភពលោក គឺត្រូវបានគេផ្តោតទៅលើ ការសំរេចគោលបំណង និង គោលដៅ នៃការកាត់បន្ថយ ភាពក្រីក្រ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលគ្រោងក្នុង PRSPs នៅថ្នាក់ជាតិ។ ដំណើរការ PRSP បានវិវត្តន៍បន្តិច បន្តួច និង ឥឡូវ រួមបញ្ចូល សមាសធាតុ ដើម្បីផ្សព្វផ្សាយកំណើនសេដ្ឋកិច្ច។ នេះ អាចត្រូវបានគេសង្ខេប នៅពេល ដំណើរការ យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍សេដ្ឋកិច្ច ដែលត្រូវបានគេប្រើ ក្នុងប្រទេសមួយចំនួន។

ម្ចាស់ជំនួយអន្តរជាតិ ផងដែរបានយល់ព្រម ដែលអាទិភាពអភិវឌ្ឍន៍ផ្សេងៗ ត្រូវតែបានគេបរិយាយ ផងដែរ, នៅពេលដែលពួកគេចាំបាច់ សំរាប់ការកាត់បន្ថយភាពក្រីក្រ និង កំណើនសេដ្ឋកិច្ច។ អាទិភាពផ្សេងៗ ទាំងនេះ រួមមាន

- ការផ្សព្វផ្សាយ អភិបាលកិច្ចល្អ
- ការផ្សព្វផ្សាយ ការផ្តល់អំណាចដល់ស្រ្តី
- ការផ្សព្វផ្សាយ ការគ្រប់គ្រងបរិស្ថានល្អ ដែលពេលខ្លះ ត្រូវបានគេទាក់ ដោយទស្សនៈការអភិវឌ្ឍន៍ និរន្តរ៍ភាព

- ប្រយុទ្ធប្រឆាំង និង ការផ្លាស់ប្តូរបរិយាកាស ដោយការផ្សព្វផ្សាយ វិធីសាស្រ្ត ដើម្បីជួយប្រទេស បន្ទូរ និង ទទួលយក ការផ្លាស់ប្តូរបរិយាកាស។
- ធានាថា តម្រូវការមនុស្សជាមូលដ្ឋាន ត្រូវបានគេបំពេញនៅក្នុងវិស័យ អាហារបំប៉ន និង សុខភាព, ការអប់រំ, និង ជំរក ជាមួយការផ្តោតយ៉ាងខ្លាំង ទៅលើការដោះស្រាយ ជាមួយវិបត្តិ ជំងឺ អេដស៍ និង
- ការការពារ វិបត្តិ និង ការធូរស្បើយឡើងវិញ

## ការផ្តល់ហិរញ្ញប្បទាន ICTD

ប្រសិនបើទាំងនេះ គឺជា អាទិភាព នៃប្រទេសម្ចាស់ជំនួយ, តើកន្លែណាអាយ ស៊ី ធី តម្រូវចិត្ត? រហូតដល់បច្ចុប្បន្ន, ហិរញ្ញប្បទាន សំរាប់ គម្រោង អាយ ស៊ី ធី បានមកពី ស្ថាប័នជំនួយផ្សេងៗទៀត, ជាពិសេស ស្ថាប័នប្រតិបត្តិជំនួយធំ ដូចជា UNDP និង ស្ថាប័នទ្វេភាគីមួយចំនួន ដូចជា នាយកដ្ឋានចក្រភពអង់គ្លេស សំរាប់ ការអភិវឌ្ឍន៍អន្តរជាតិ (DFID)។ ទោះបីជាយ៉ាងណាក៏ដោយ, ការភ្ជាប់គ្រឿងឧបករណ៍ឌីជីថល មិនត្រូវបានគេ ចាត់ទុកទៀតទេ ជាគោលដៅសំខាន់ក្នុង និង នៃខ្លួនរបស់វា, និង ការប្រើប្រាស់ អាយ ស៊ី ធី នៅពេលដែល ឧបករណ៍ សំរាប់ការអភិវឌ្ឍន៍ គឺជា វិធីសាស្រ្តដែលត្រូវតែបានគេអនុវត្តន៍។

ធានាគារពិភពលោក ផ្តល់មូលនិធិ ដល់គម្រោងរដ្ឋាភិបាល-អេឡិចត្រូនិច យ៉ាងទៀងទាត់ និង បានគាំទ្រប្រទេស ដែលអភិវឌ្ឍន៍ យុទ្ធសាស្រ្ត និង ផែនការសកម្មភាព អាយ ស៊ី ធី ជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ, ផែនការ និងយុទ្ធសាស្រ្តទាំងអស់នេះ បានចង្អុលបង្ហាញថា ពួកគេដោះស្រាយ ជាមួយ MDGs និង យ៉ាងជាក់លាក់ ជាមួយ ការប្រយុទ្ធប្រឆាំង ភាពក្រីក្រ និង ការផ្សព្វផ្សាយ ការអភិវឌ្ឍន៍ និង កំណើនសេដ្ឋកិច្ច។ ទស្សនៈ នៃ កំណើនអ្នកក្រ-និយម បានងើបឡើង និង គម្រោងដែលអាចគេចង្អុល បង្ហាញ ដើម្បីផ្សព្វផ្សាយ កំណើន អ្នកក្រ-និយម ត្រូវបានគេលើកទឹកចិត្ត និង មានឱកាសល្អ នៃការត្រូវបានគេផ្តល់ហរិញ្ញប្បទាន។

ស្ថាប័នខ្លះៗ នៅតែបរិយាយ គម្រោង អាយ ស៊ី ធី ដោយផ្ទាល់, ITU មានការទទួលខុសត្រូវ ការអនុវត្តន៍ អនុសាស្រ្តមួយចំនួន ដែលគេធ្វើឡើងក្រោម ផែនការសកម្មភាព សំរាប់ WSIS។ ប៉ុន្តែ ITU មិនមែនជា ស្ថាប័ន ប្រតិបត្តិធំ មួយ និង វាបានកំណត់ មធ្យោបាយ សំរាប់ការអនុវត្តន៍ WSIS។ ផងដែរ ស្ថាប័នដ៏ទៃទៀត ដោះ ស្រាយដោយផ្ទាល់ ជាមួយ អាយ ស៊ី ធី ដែលរួមបញ្ចូលទាំង មជ្ឈមណ្ឌល ស្រាវជ្រាវ ការអភិវឌ្ឍន៍ អន្តរជាតិ (IDRC) នៃកាណាដា ប៉ុន្តែ នៅក្រោម មុំ នៃវិទ្យាសាស្រ្ត និង បច្ចេកវិទ្យា សំរាប់ការអភិវឌ្ឍន៍។ IDRC

គឺជា ស្ថាប័នតូចមួយ និង មានអត្ថន័យកំណត់ ដែលផ្តោតជាពិសេសទៅលើ ការស្រាវជ្រាវ អាយ ស៊ី ធី និង សកម្មភាព អភិវឌ្ឍន៍ ដែលអាចជួយប្រទេស អភិវឌ្ឍន៍សមត្ថភាព ដើម្បីបំពេញ ទិសដៅ និង គោលដៅអភិវឌ្ឍន៍ របស់គេ ដែលនៅពេលតែមួយ សំរេចបាន MDGs។

គម្រោង អាយ ស៊ី ធី, ជាពិសេស គម្រោងរដ្ឋាភិបាល-អេឡិចត្រូនិច, អាចត្រូវបានភ្ជាប់ជាមួយ ការកាត់បន្ថយ ភាពក្រីក្រ និង អភិបាលកិច្ច និង ការផ្សព្វផ្សាយ MDGs ជាច្រើន នៅក្នុងផ្នែកដែលពាក់ពន្ធ័។ ឧទាហរណ៍, គម្រោង សុខាភិបាល-អេឡិចត្រូនិច អាចត្រូវបានគេចង្អុលបង្ហាញ ដើម្បីផ្តល់ ប្រសិទ្ធិភាពខ្ពស់ ក្នុងការត្រៀម ធនធាន និង ការចូលទៅដល់ និង ការព្យាបាលអ្នកជំងឺ ដែលឈឺចាប់ដោយជំងឺ។ កង្វល់ចំបង ដែលស្ថាប័នជាច្រើន មានលើ អាយ ស៊ី ធី គឺការជៀសវាង ការត្រូវបានគេមើលឃើញថាត្រូវបានគេផ្តល់មូលនិធិ ដល់គម្រោង អាយ ស៊ី ធី សំរាប់ ប្រយោជន៍នៃការទិញ កំព្យូទ័រ និង គ្រឿង តែឯង។ ហេតុដូចច្នេះហើយ, ក្នុងការអភិវឌ្ឍន៍ សំណើរមួយ សំរាប់ គម្រោង អាយ ស៊ី ធី រឺ រដ្ឋាភិបាល-អេឡិចត្រូនិច, ខាងក្រោមនេះ គួរតែត្រូវបានគេបរិយាយ :

- តើ គម្រោង បានត្រូវគេអនុវត្តន៍ ពីមុនទេ ?
- តើ មានសកម្មភាព រឺ គម្រោងផ្សេងទៀត ដែល កំពង់តែបរិយាយអំពី តម្រូវការដែលគេបង្ហាញ ?
- តើ ការផ្តល់មូលនិធិ ដល់គម្រោងនេះ បរិយាយ តម្រូវការអភិវឌ្ឍន៍អាទិភាព ដែលបានគេរកឃើញសំរាប់ ប្រទេស រឺ យុត្តាធិការ មួយ យ៉ាងដូចម្តេច?
- តើ គម្រោងនេះ អាចធ្វើទៅបានទេ ? តើស្ថាប័នដែលគេស្នើរឡើង ដើម្បីអនុវត្តន៍គម្រោង មាន សមត្ថភាព គ្រប់គ្រងគម្រោង និងតើ ស្ថាប័ន នឹងអាចមានផលប្រយោជន៍ពី គម្រោងនេះលើ រយះពេលវែងមួយ រឺ តើ គម្រោងនេះ នឹងតម្រូវអោយមាន ការគាំទ្រខាងក្រៅជាបន្តបន្ទាប់ ដើម្បីជោគជ័យ ទេ ?សរុបសេចក្តីមក, តើ គម្រោង មាននិរន្តរ៍ភាព ទេ ?

តម្លៃ មិនមែនជាបញ្ហាដំបូង ដែលម្ចាស់ជំនួយ នឹងមិនបារម្មណ៍ អំពី។ ប្រសិនបើគម្រោងត្រូវបានគេ បង្កើតយ៉ាងល្អ និង លេចឡើង ដើម្បីបរិយាយបញ្ហា និង អាទិភាពគន្លឹះជាច្រើន ដែលធ្វើអោយម្ចាស់ជំនួយ បារម្មណ៍, ហើយ បន្ទាប់មក វាទំនងជាទទួលបានការគាំទ្រពីម្ចាស់ជំនួយ។ សំណើរមូលនិធិល្អមួយគួរតែធ្វើ ដូចខាងក្រោម :

- បញ្ជាក់ពី របៀបដែលគម្រោង នឹងផ្តល់ដល់ ទិសដៅ និង គោលដៅ ជាតិ, រដ្ឋាភិបាល, ក្រសួង រឺ អង្គការ

- បញ្ជាក់ពី គោលដៅគម្រោង និង ដាក់ពួកគេ ទៅក្នុង បរិបទធំមួយ នៃទិសដៅ និង គោលដៅ អភិវឌ្ឍន៍ជាតិ រួមនិង ការសំរេចបាន MDGs
- ពិពណ៌នាពី របៀបដែលគម្រោង នឹងត្រូវបានគេអនុវត្តន៍, អភិបាលកិច្ចគម្រោង និង ការរៀបចំស្ថាប័ន, និង វិធីសាស្ត្រ ចំពោះគម្រោង ដែលស្ថាប័ន រឺ ក្រសួង មានបំណងយក ដែលរួមបញ្ចូល ការធ្វើការជាមួយ អ្នកពាក់ពន្ធ័ទាំងអស់ និង មិនគ្រាន់តែអ្នកនៅក្នុងជួររដ្ឋាភិបាល។
- រៀបរាប់ តម្រូវការ អាយ ស៊ី ធី, ការបញ្ជាក់លំអិត, លទ្ធផល។
- ទទួលយក គ្រោងការណ៏ RBM មួយ ដែលពិពណ៌នាពី អ្វីដែលនឹង ត្រូវបានសំរេច ក្នុងន័យ លទ្ធផល, បន្ថែមទៅលើ ទិន្នផល។ ទិន្នផល ពិពណ៌នាពី អ្វីដែលនឹងត្រូវគេតម្រូវ រឺ បង្កើត ដោយ គម្រោង។ លទ្ធផល រួមបញ្ចូល ដំណើរការ និង ប្រពន្ធ័ និង ជា រង្វាស់ដ៏សំខាន់នៃការជោគជ័យ ក្នុងន័យ អភិវឌ្ឍន៍ ដែលអាចនិយាយបានថា ក្នុងន័យ កាត់បន្ថយភាពក្រីក្រ ដែលពាក់ពន្ធ័ទៅនិងការសំរេច MDGs។ គ្រោងការណ៏ RBM គឺផ្អែកទៅលើ ការប្រើប្រាស់ នៃនិយ័តករ និង មធ្យោបាយនៃការពិនិត្យបញ្ជាក់ ស្របជាមួយ ការពិពណ៌នា នៃអំណះអំណាង ដែលនឹងណែនាំការប្រើប្រាស់ និង ការវាស់វែងនៃនិយ័តករទាំងនេះ។
- ផ្តល់ ការវាយតម្លៃមួយ នៃតម្រូវការធនធាន, ដែលរួមទាំង ធនធានមនុស្សនិង សមត្ថភាពដែលតម្រូវសំរាប់គម្រោង។
- គូសឡើង តារាងពេល និង កាលវិភាគ គម្រោងមួយ។ ក្រាភិច អាចមានប្រយោជន៏ណាស់ចំពោះរឿងនេះ។
- ផ្តល់ គម្រោងថវិកា ដែលរៀបរាប់ សមាសធាតុតម្លៃសំខាន់ៗ និង របៀបដែលតម្លៃនឹងត្រូវបានគេគ្រប់គ្រង។
- ពិពណ៌នា ធាតុផ្សំការវាយតម្លៃ និង ត្រួតពិនិត្យ ដែល និងឹប្រើ និយ័តករ IBM ដើម្បីកត់ត្រា និង រាយការណ៏ ការប្រព្រឹត្ត និង លទ្ធផល ក្នុងកំឡុងពេលមួយ។ប្រអប់ទី១ សាមាសធាតុ នៃសំណើរផ្តល់ហិរញ្ញប្បទាន

សំរាប់ពត៌មានបន្ថែម លើ ផែនការ, ការអនុវត្តន៍, ការត្រួតពិនិត្យ និង ការវាយតម្លៃ គម្រោង ICTD, សូម យោង ទៅលើ មេរៀនទី ៧ ។

ការរៀបចំមេរៀន

ដោយអាស្រ័យលើសិក្ខាកាម ពេលវេលាដែលមាន ព្រមទាំងការកំណត់ និងលក្ខណ្ឌក្នុងមូលដ្ឋាន ខ្លឹមសារម៉ូឌុលអាចត្រូវបាន បង្ហាញជាសេចក្តីសង្ខេបដែលយោងតាមពេលវេលាខុសៗគ្នា ។ អ្វីដែលអាចលើកឡើងនៅវគ្គបណ្តុះបណ្តាលដែលមានរយៈពេល ខុសៗគ្នាត្រូវបានលើកឡើងខាងក្រោម ។ គ្រូបង្គោលត្រូវបានអញ្ជើញដើម្បីធ្វើការកែសម្រួលរចនាសម្ព័ន្ធមេរៀនដោយផ្អែក លើការយល់ដឹងផ្ទាល់ខ្លួនអំពី ប្រទេស និងសិក្ខាកាម ។

*សម្រាប់ការបណ្តុះបណ្តាលរយៈពេល ៩០នាទី*

មានគោលដៅអភិវឌ្ឍការយល់ដឹងមូលដ្ឋានអំពីរដ្ឋាភិបាលអេឡិចត្រូនិក រួមទាំងមូលហេតុនៃ អត្ថប្រយោជន៍ និងកត្តាសំខាន់ៗ សម្រាប់ជោគជ័យនៃគម្រោងរដ្ឋាភិបាលអេឡិចត្រូនិកក្នុងផ្នែកទី ១ ។

*សម្រាប់ការបណ្តុះបណ្តាលរយៈពេល ៣ ម៉ោង*

បន្ទាប់ពីការពិភាក្សាជាទូទៅអំពីសនិទានភាពសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក និងកត្តាជោគជ័យ សំខាន់ៗ ផ្តល់នូវទិដ្ឋភាពទូទៅ អំពីគំរូរដ្ឋាភិបាលអេឡិចត្រូនិក និងការរៀបចំផែនការយុទ្ធសាស្ត្ររដ្ឋាភិបាលអេឡិចត្រូនិកដែលនាំទៅរកការបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តរដ្ឋាភិបាល អេឡិចត្រូនិក ។ ការពិភាក្សា និងលំហាត់ពាក់ព័ន្ធមាននៅក្នុងផ្នែកទី ២ ។

*សម្រាប់ការបណ្តុះបណ្តាលរយៈពេល ១ថ្ងៃ (រយៈពេលប្រាំមួយម៉ោង)*

ពេលវេលានេះនឹងអនុញ្ញាតអោយមានការស្វែងរកមួយ ឬពីរនៃកម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកដែលបានបង្ហាញក្នុងផ្នែកទី ៣ ជាការបន្ថែមទៅលើទិដ្ឋភាពទូទៅអំពីគោលការណ៍រដ្ឋាភិបាលអេឡិចត្រូនិក គំរូ និងការរៀបចំផែនការយុទ្ធសាស្ត្រដែល បានផ្តល់នៅក្នុងផ្នែកទី ១ និង ទី ២ ។ ផ្តោតលើកម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិក ដែលមានការពាក់ព័ន្ធច្រើនបំផុតចំពោះ សិក្ខាកាម និងប្រើប្រាស់សំណួរ

ពិភាក្សាពាក់ព័ន្ធ (“សំណួរដែលត្រូវត្រិះរិះ”) ព្រមទាំងសកម្មភាពសិក្សា (“កិច្ចការដែលត្រូវធ្វើ”) ដើម្បីធ្វើអោយមេរៀនមានអន្តរកម្ម ។

*សម្រាប់ការបណ្តុះបណ្តាលរយៈពេល ៣ថ្ងៃ*

ពេលវេលានេះគួរតែសមល្មមក្នុងជួយអោយអ្នកអាចទទួលការបណ្តុះបណ្តាលអំពីម៉ូឌុលទាំងមូលបានដោយ រួមមានការពិភាក្សា លម្អិតលើករណីសិក្សាពាក់ព័ន្ធរបស់កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកជាក់លាក់ ។ រួមមានករណីសិក្សាអំពី “រស់នៅ” តាមរយៈ ការធ្វើដំណើរដល់ទីកន្លែងទៅកាន់ទីតាំងគម្រោងអនុវត្ត រដ្ឋាភិបាលអេឡិចត្រូនិកក្នុងមូលដ្ឋាន ។ រៀបចំពេលវេលាសម្រាប់ការ រៀបចំផែនការយុទ្ធសាស្ត្រ រដ្ឋាភិបាលអេឡិចត្រូនិកដោយសិក្ខាកាម លទ្ធផលដែលនឹងត្រូវបង្ហាញដល់ក្រុមផ្សេងទៀត ។

## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់អ្នកមានដូចខាងក្រោមសំរាប់ការប្រើពត៌មាននិងឯកសារដែលពួកគេផ្តល់ឲ្យនៅពេលការធ្វើការលើ PPP នេះក្នុងគម្រោងរាជរដ្ឋាភិបាលអេឡិចត្រូនិចក្នុង Mongolia ធ្វើក្នុងឆ្នាំ ២០០៧ សំរាប់រាជរដ្ឋាភិបាលនៃ Mongolia ក្រោមជំនួយមួយពីធនាគារពិភពលោក ។

- Rahzeb Chowdhury, Atos Consulting, London សំរាប់រក្សាសិទ្ធប្រើប្រាស់ឯកសារលើ PPPsនិងកិច្ចសន្យា និងបញ្ហាដ៏ទៃទៀតដែលទាក់ទង ។
- Ken Chia, ប្រធាននៃក្រុមអនុវត្តន៏គមនាគមន៏រឺ IT, Baker & McKenzie.
  Wong & Leow, Singapore

សូមថ្លែងអំណរគុណផងដែរទៅ Joe Faganសំរាប់ការផ្តល់ពត៌មានដែលមានតំលៃអំពីបទពិសោធន៏ របស់គាត់ក្នុងការបង្កើតប្រព័ន្ធ Merx e-procurement ដែលគឺបច្ចុប្បន្នក្នុងការប្រើដោយរដ្ឋាភិបាលនៃប្រទេស Canadaនិងសំរាប់ជូនដំណឹងពួកយើងនៃការងារលើ Merx e-procurement ក្នុងប្រទេស Philippine ក្នុងការបង្កើត PhilGEPS e-procurement system.

## UN-APCICT

មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ការអភិវឌ្ឍតំបន់អាស៊ី និង ប៉ាស៊ីហ្វិករបស់អង្គការ សហប្រជាជាតិ (UN-APCICT) គឺជាអង្គភាពបុត្រសម្ព័ន្ធរបស់គណៈកម្មការ សេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និង ប៉ាស៊ីហ្វិក (ESCAP) ។ UN-APCICT មានគោលដៅពង្រឹង កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសជាសមាជិក ESCAP ដើម្បីប្រើប្រាស់ ICT ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច របស់ខ្លួនតាមរយៈការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័ន ។ ការងារ របស់ UN-APCICT គឺផ្តោតលើ សសរស្តម្ភសំខាន់បី ៖

១. ការបណ្តុះបណ្តាល ៖ ដើម្បីកែលម្អចំណេះដឹង និងជំនាញផ្នែក ICT របស់អ្នកបង្កើតគោលនយោបាយ និងអ្នកវិជ្ជាជីវៈ ICT ព្រមទាំងពង្រឹងសមត្ថភាពរបស់គ្រូបង្គោល ICT និងស្ថាប័នបណ្តុះបណ្តាល ICT ។

២. ការស្រាវជ្រាវ ៖ ដើម្បីចាប់ផ្តើមអនុវត្តការសិក្សាវិភាគទាក់ទងនឹងការអភិវឌ្ឍន៍ធនធានមនុស្សផ្នែក ICT និង

៣. ការណែនាំ ៖ ដើម្បីផ្តល់សេវាណែនាំអំពីកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សដល់សមាជិក EKSCAP និងសមាជិកពាក់ព័ន្ធ ។

UN-APCICT មានទីតាំងនៅ Incheon សាធារណរដ្ឋកូរ៉េ ។

http://www.unapcict.org

# ESCAP

ESCAP គឺជាអង្គភាពអភិវឌ្ឍន៍ក្នុងតំបន់របស់អង្គការសហប្រជាជាតិ និងដើរតួនាទីជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ចម្បងសម្រាប់អង្គការសហប្រជាជាតិក្នុងទ្វីបអាស៊ី និងប៉ាស៊ីហ្វិក ។ អាណត្តិរបស់ ESCAP គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ រវាងសមាជិកចំនួន ៥៣ និងសមាជិកពាក់ព័ន្ធចំនួន ៩ របស់ខ្លួន ។ ESCAP ផ្តល់នូវការភ្ជាប់យុទ្ធសាស្ត្ររវាងកម្មវិធី និងបញ្ហា កម្រិតសកល និងកម្រិតប្រទេស ។ ESCAP គាំទ្រដល់រដ្ឋាភិបាលរបស់ប្រទេសនៅក្នុងតំបន់ក្នុងការពង្រឹងមុខងារតំបន់ និង គាំទ្រដល់វិធីសាស្ត្រក្នុងតំបន់ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចសង្គមពិសេសរបស់តំបន់ក្នុងពិភពសកលភាវូបនីយកម្ម ។ ការិយាល័យ ESCAP មានទីតាំងនៅទីក្រុងបាងកក ប្រទេសថៃ ។

http://www.unescap.org